## លទ្ធផលការសិក្សាស្រាវជ្រាវ

# បរិយាកាសគោលនយោបាយ ទាក់ទងការទទួលបានជាសកល និងសិទ្ធិទទួលបានការងារធ្វើ របស់អ្នកបំរើសេវាកំសាន្ត នៅកម្ពុជា

Project implemented by: NAA in collaboration with CACHA, WNU, CPU, CNMWD, CCW and BC
Supported by: UNFPA, UNAIDS, WAC, ICASO/APNSW and ActionAid

## រៀបចំ និងសហការដោយៈ

## ឧបត្ថម្ភដោយៈ

CPU

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះគឺជាលទ្ធផលនៃការសិក្សាស្រាវជ្រាវដែលមានឈ្មោះថា " **បរិយាកាសគោលនយោបាយទាក់ទងនឹងការទទួលបានជាសកល និងសិទ្ធិទទួលបានការងារធ្វើរបស់អ្នកបម្រើសេវាកំសាន្ត**"។ ការសិក្សានេះត្រូវបានប្រព្រឹត្តឡើងក្រោមការដឹកនាំនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ក្នុងកិច្ចសហការជាមួយសម្ព័ន្ធប្រជាជនកម្ពុជាប្រយុទ្ធមេរោគ-អេដស៍និងជំងឺអេដស៍(CACHA) សហជីពស្ត្រីរកស៊ីផ្លូវភេទ(CPU) បណ្តាញបុរសស្ត្រីអភិវឌ្ឍកម្ពុជា(CNMWD) បណ្តាញ-ថ្នាក់ជាតិនៃបុរសស្រឡាញ់បុរស(BC) សហគមន៍ស្ត្រីផ្ទុកមេរោគអេដស៍និងជំងឺអេដស៍ (CCW) និងបណ្តាញស្ត្រីរួបរួមគ្នា (WNU) និងរួមជាមួយការគាំទ្រខាងថវិកានិងបច្ចេកទេសពី ActionAid, ICASO/APNSW, UNAIDS, UNFPA និង WAC ។

ជាដំបូងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកនាង ផេង ផារ៉ូហ៊្សីន [អ្នកសម្របសម្រួលថ្នាក់ជាតិនៃCACHA] និងអ្នកនាង ហេង ចាន់សុភា [អ្នកសម្របសម្រួលផ្នែកសិក្សាស្រាវជ្រាវ] ជាអ្នកដែលសម្របសម្រួលរាល់ដំណើរការប្រព្រឹត្តទៅរបស់ការសិក្សានេះ។ ជាពិសេសសូមថ្លែងអំណរគុណយ៉ាងខ្លាំងដល់វេជ្ជបណ្ឌិត លី ចេងហ៊ុយ [ប្រធានគណៈកម្មាធិការដឹកនាំនៃCACHA] វេជ្ជបណ្ឌិត សេង ស៊ុតវណ្ណថា [ហិរញ្ញិកនៃCACHA] សមាជិកដទៃទៀតនៃCACHA និង អ្នកស្រី ឌី ម៉ានី [មន្ត្រីកម្មវិធីនៃ ActionAid Cambodia និងជាទីប្រឹក្សាបច្ចេកទេសនៃCACHA] ចំពោះការប្រឹងប្រែង និងការខិតខំយ៉ាងមុតមាំរបស់ពួកគាត់ក្នុងការផ្តួចផ្តើមអោយមានការសិក្សានេះឡើង។

សូមថ្លែងអំណរគុណអស់ពីដួងចិត្តនិងការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះក្រុមវិភាគការសិក្សាស្រាវជ្រាវដែលមានដូចជា វេជ្ជបណ្ឌិត ទា ផលា [ទីប្រឹក្សាឯករាជ្យនៃគំរោងការសិក្សាស្រាវជ្រាវ] លោកសុខ សិរី [ទីប្រឹក្សាឯករាជ្យនៃការវិភាគទៅលើបរិមាណវិស័យ] លោកសេង សារី [ទីប្រឹក្សាឯករាជ្យនៃការវិភាគទៅលើបរិមាណវិស័យ] Ms. Sally Francess Low [ទីប្រឹក្សាឯករាជ្យអន្តរជាតិនៃច្បាប់ និងសិទ្ធមនុស្ស] និងលោក កែវ ចិន្តា [ទីប្រឹក្សាឯករាជ្យនៃច្បាប់និងសិទ្ធមនុស្ស] ជាពិសេសសូមថ្លែងអំណរគុណទៅដល់លោកវេជ្ជបណ្ឌិត ទា ផលា ដែលជាអ្នកចូលរួមយ៉ាងសកម្មក្នុងការធ្វើរបាយការណ៍ទាំងមូលនេះឡើង។ ប្រសិនបើគ្មានការណែនាំនិងជំនួយផ្នែកបច្ចេកទេសយ៉ាងហ្មត់ចត់ពីលោកទេរបាយការណ៍នេះនឹងពុំអាចមានទូលំទូលាយនិងត្រឹមត្រូវតាមក្បួនវិទ្យាសាស្ត្រទេ។

សូមថ្លែងអំណរគុណយ៉ាងកក់ក្តៅដល់វេជ្ជបណ្ឌិត ខាន់ ចាន់មុនី លោកវេជ្ជបណ្ឌិតអ៊ឹង សុវណ្ណៈ [ប្រធានក្រុមនិងជាអ្នកតំណាងដែលមកពីអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍] អ្នកនាង ច័ន្ទ វត្តី និងលោកសំទីន ណូរិន [ប្រធានក្រុមនិងជាអ្នកតំណាងដែលមកពីសង្គមស៊ីវិល] ក្នុងការដឹកនាំជំនួយសំរាប់ប្រមូលទិន្នន័យ និងជំនួយការស្រាវជ្រាវនៅសហគមន៍។

ទិន្នន័យនេះពោរពេញដោយព័ត៌មានដែលត្រឹមត្រូវ និងច្បាស់លាស់អាស្រ័យទៅលើការខិតខំប្រឹងប្រែងរបស់ពួកគាត់ និងអ្នកជំនួយការផ្នែកស្រាវជ្រាវ ។

ជាចុងក្រោយនេះ សូមគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ (NAA) ដែលគាំទ្រយ៉ាងពេញទំហឹងនៃការផ្តួចផ្តើមដ៏សំខាន់នេះ ។ ជាចុងបញ្ចប់នេះ សូមអរគុណ និងដឹងគុណចំពោះអាជ្ញាធរមូលដ្ឋាននិងមន្ត្រីទទួលបន្ទុកការងារមេរោគអេដស៍ និងអង្គការសង្គមស៊ីវិលក្នុងការជ្រើសរើសក្រុង-ខេត្ត៤ យកមកសិក្សាដែលមានដូចជា ទីក្រុងភ្នំពេញ បន្ទាយមានជ័យ សៀមរៀប និងព្រះសីហនុ នឹងជាជំនួយដល់ការសម្របសម្រួលក្នុងការជ្រើសរើសអ្នកផ្តល់បទសម្ភាសដើម្បីឱ្យសមស្របទៅនឹងភាពចំបាច់នៃការស្រាវជ្រាវនៅកន្លែងដែលកើតមានឡើង ។
ជាពិសេសជាចុងក្រោយនេះសូមអរគុណជូនចំពោះអ្នកផ្តល់បទសម្ភាស រួមមានបុរសស្រលាញ់បុរស ខាវ៉ាអូខេ អ្នកម៉ាស្សា ស្ត្រីផ្សព្វផ្សាយស្រាបៀរ អ្នកបម្រើផ្លូវភេទឯករាជ្យ អ្នកបម្រើផ្លូវភេទដោយផ្ទាល់ និងក្រុមស្រីស្រស់ដែលអនុញ្ញាតអោយធ្វើបទសម្ភាសនិងពិភាក្សា ។



វេជ្ជបណ្ឌិត លី ចេងហ៊ុយ
ប្រធានគណៈកម្មាធិការដឹកនាំនៃកាចា

# មាតិកា

**១. សារតារ**

**២. គោលបំណង**

**៣. វិធីសាស្ត្រ**

១. ក្របខ័ណ្ឌទស្សនាទាន

២. គម្រោងស្រាវជ្រាវ

**៤. លទ្ធផលរកឃើញ**

- **គោលបំណង១: សិទ្ធិទទួលបានការងាររបស់អ្នកបម្រើសេវាកំសាន្ត/អ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់បុរស,ស្រីស្រស់**

១. សង្គមសេដ្ឋកិច្ច

២. ការងារ

៣. ការយល់ឃើញ

៤. កត្តាសំខាន់ៗពាក់ព័ន្ធសិទ្ធិទទួលបានការងារ

៥. ការអនុវត្តច្បាប់ និងគោលនយោបាយ

៦. ការចូលរួម

- **គោលបំណង២: បរិយាកាសអំណោយផលស្តីពីការបង្កើត និងជំរុញ ការអនុវត្តគោលនយោបាយមាន ស្រាប់ និងបទដ្ឋានសង្គមទាក់ទងនឹងសិទ្ធិទទួលបានសេវាជាសកលសម្រាប់អ្នកបម្រើសេវាកំសាន្ត/ អ្នករកស៊ីផ្លូវភេទ**

១. ការចូលរួមក្នុងយន្តការតស៊ូមតិដើម្បីលទ្ធភាពទទួលបានជាសកល

២. ការយល់ឃើញ

ក. សិទ្ធិប្រកបមុខរបរផ្លូវភេទ

ខ. សេចក្តីបង្គាប់ជាសាធារណៈ (បក់ដៃហៅភ្ញៀវ)

គ. កត្តាសំខាន់ៗពាក់ព័ន្ធនឹង UA

៣. ការអនុវត្តជាក់ស្តែងលើ LSHSE

ក. តើអតិថិជនរបស់អ្នកបម្រើសេវាកំសាន្ត/អ្នករកស៊ីផ្លូវភេទ និងបុរសស្រលាញ់បុរស, ស្រីស្រស់ គួរដាក់ពិន័យដែរឬទេ?

ខ. ការបំបែកអ្នកដែលត្រូវបានជួញដូរ និងអ្នកមិនត្រូវបានជួញដូរ

- **គោលបំណង៣: ការវាយតម្លៃភាពគ្របដណ្តប់ និងសេវាប្រកបដោយគុណភាពពាក់ព័ន្ធនឹង លទ្ធភាពទទួលបានជាសកលសម្រាប់ អ្នកបម្រើសេវាកំសាន្ត/អ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់ បុរស,ស្រីស្រស់**

១. ភាពគ្របដណ្តប់

ក. ការប្រើស្រោមអនាម័យ

ខ. មិត្តអប់រំមិត្ត

គ. ការប្រើសេវា

២. គុណភាព

ក. ភាពរួសរាយរាក់ទាក់នៃអ្នកផ្តល់សេវា

ខ. ការបង់ថ្លៃសេវា

- **គោលបំណង៤: កំណត់បញ្ហា (និងបញ្ហាដែលអាចកើតមាន) ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ថ្មីស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើ អ្នកបម្រើសេវាកំសាន្ត/អ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់បុរស, ស្រីស្រស់**

១. បញ្ហាអាចកើតមាន

២. ការគាំទ្រ

៣. ការផ្លាស់ប្តូរអថេរមួយចំនួនរវាងឆ្នាំ ២០០៧ និងឆ្នាំ២០០៨

- **គោលបំណង៥: តំបន់គោលដៅ (សម្រាប់ការបណ្តុះបណ្តាល) និងអភិវឌ្ឍជំនាញបណ្តាញ ពាក់ព័ន្ធនិងផែនទូសំខាន់ៗ រាប់បញ្ចូលទាំង អ្នកបម្រើសេវាកំសាន្ត/អ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់បុរស, ស្រីស្រស់**

១. ការកសាងសមត្ថភាពលើភាពជាអ្នកដឹកនាំដើម្បីទទួលបានលទ្ធផល

២. ការកសាងសមត្ថភាពក្នុងការរៀបចំ និងផ្សព្វផ្សាយកម្មវិធីBCC ជាយុទ្ធសាស្ត្រដែលមាន លក្ខណៈច្នៃប្រឌិត និងសមស្របសម្រាប់ អ្នកបម្រើសេវាកំសាន្ត/អ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់បុរស,ស្រីស្រស់ និងអតិថិជនរបស់អ្នកទាំងនោះ

៣. បង្កើតជំនាញសម្រាប់កងកម្លាំងប៉ូលីស និងអាជ្ញាធរមូលដ្ឋានដើម្បីដើរតួជាចលករសហគមន៍

៤. ការពង្រឹងសមត្ថភាពតាមស្ថាប័ន និងសមត្ថភាពតស៊ូមតិរបស់បណ្តាញ អ្នកបម្រើសេវាកំសាន្ត/ អ្នករកស៊ីផ្លូវភេទ និងបុរសស្រលាញ់បុរស/ស្រីស្រស់

៥. ការពង្រឹងសមត្ថភាពតាមស្ថាប័ន និងការតស៊ូមតិសម្រាប់បណ្តាញធ្វើការជាមួយ អ្នកបម្រើសេវាកំសាន្ត/ អ្នករកស៊ីផ្លូវភេទ និងបុរសស្រលាញ់បុរស/ស្រីស្រស់

## ៥. ការវិភាគ

១. ផ្លាស់ប្តូរលក្ខណៈទូទៅនៃឧស្សាហកម្មផ្លូវភេទ

២. សិទ្ធិទទួលបានការងារ

៣. ភាពមិនស្របគ្នារវាងការយល់ឃើញ និងភាពពិតជាក់ស្តែង

៤. សិទ្ធិទទួលបានសេវាជាសកល

៥. គុណភាពទទួលបានសេវាជាសកល

៦. បញ្ហាដែលអាចកើតមានពាក់ព័ន្ធនឹងការអនុវត្តច្បាប់ថ្មីស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការ កេងប្រវ័ញ្ចផ្លូវភេទ

## ៦. អនុសាសន៍

១. សសរស្តម្ភទី ១: ធានាឱ្យបាននូវលទ្ធភាពទទួលបានជាសកល ដើម្បីការបង្ការ ការព្យាបាល ការថែទាំ និងគាំទ្រ មេរោគអេដស៍ឱ្យបានទូលំទូលាយ

២. សសរស្តម្ភទី ២: បង្កើតបរិយាកាសគាំទ្រ ពង្រឹងភាពជាដៃគូ និងបង្កើនជម្រើស

៣. សសរស្តម្ភទី ៣: កាត់បន្ថយភាពងាយរងគ្រោះ និងដោះស្រាយបញ្ហារចនាសម្ព័ន្ធ

## ៧. សេចក្តីសន្និដ្ឋាន

១. ការយល់ដឹងអំពីភាពងាយរងគ្រោះរបស់ អ្នកបម្រើសេវាកំសាន្ត/អ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់បុរស,ស្រីស្រស់ និងសិទ្ធិទទួលបានការងារធ្វើរបស់អ្នកទាំងនោះ

២. ភាពគ្របដណ្តប់នៃលទ្ធភាពទទួលបានសេវាជាសកល

៣. គុណភាពសេវា

៤. ផលប៉ះពាល់នៃការអនុវត្តច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ

៥. ការកសាងសមត្ថភាព

៦. ភាពជាអ្នកដឹកនាំ និងការសម្របសម្រួល

# ពាក្យបំព្រួញ

| | | |
|---|---|---|
| AAC | អង្គការអាក់សិនអេត កម្ពុជា | ActionAid Cambodia |
| AIDS | ជំងឺអេដស៍ | Acquired Immunodeficiency Syndrome |
| AFESIP | អង្គការអាហ្វេស៊ីព | Agir Pour les Femmes En Situation Precaire |
| APNSW | បណ្តាញការងាររកស៊ីផ្លូវភេទនៅអាស៊ីប៉ាស៊ីហ្វិក | Asia Pacific Network of Sex Work |
| ART | សេវាព្យាបាលដោយប្រើថ្នាំពន្យារជីវិត | Antiretroviral Therapy |
| BC | បណ្តាញចតុមុខ | Bandanh Chaktomuk |
| BCC | ការប្រាស្រ័យទាក់ទងឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត | Behavior Change Communication |
| BPG | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | Beer Promotion Girls |
| CACHA | សម្ព័ន្ធប្រជាជនកម្ពុជាប្រយុទ្ធនឹងមេរោគអេដស៍និងជំងឺអេដស៍ | Cambodian Alliance for Combating HIVand AIDS |
| CBOs | អង្គការសហគមន៍ | Community Base Organisations |
| CCW | សហគមន៍ស្ត្រីផ្ទុកមេរោគអេដស៍និងជម្ងឺអេដស៍នៅកម្ពុជា | Cambodian Community of Women Living with HIV/AIDS |
| CDHS | ការអង្កេតសុខភាពប្រជាសាស្ត្រកម្ពុជា | Cambodian Demographic Health Servey |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី | Convention on the Elimination of all forms of Discrimination Against Women |
| CNMWD | បណ្តាញបុរសស្ត្រីអភិវឌ្ឍន៍កម្ពុជា | Cambodian Network for Men and Women Development |
| CPU | សហជីពស្ត្រីរកស៊ីផ្លូវភេទ | Cambodian Prostitute Union |
| CUCC | គណៈកម្មាធិការសម្របសម្រួលការប្រើស្រោមអនាម័យ | Condom Use Coordinating Committee |
| CUP | កម្មវិធីប្រើស្រោមអនាម័យ | Condom Use Programme |
| DHATWG | ក្រុមការងារបច្ចេកទេសស្តីពីគ្រឿងញៀននិងមេរោគអេដស៍ | Drug and HIV Technical Working Group |
| DSW | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | Direct Sex Worker |
| DU/IDU | អ្នកប្រើគ្រឿងញៀន/ អ្នកប្រើគ្រឿងញៀនដោយការចាក់ | Drug User/Inject Drug User |
| EW | ស្ត្រីបម្រើសេវាកំសាន្ត | Entertainment Worker |
| FHI | អង្គការសុខភាពគ្រួសារអន្តរជាតិ | Family Health International |
| FSW | អ្នករកស៊ីផ្លូវភេទឯករាជ្យ | Freelance Sex Worker |
| GFATM | មូលនិធិសកលដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ របេង និងគ្រុនចាញ់ | Global Fund for the fight against AIDS , Tuberculosis and Malaria |
| HACC | គណៈកម្មាធិការសម្របសម្រួលជំងឺអេដស៍ | HIV/AIDS Coordinating Committee |
| HBC | ការថែទាំតាមផ្ទះ | Home Base Care |

| | | |
|---|---|---|
| HCW | បុគ្គលិកសុខាភិបាល | Health Care Worker |
| HIV | មេរោគអេដស៍ | Human Immunodeficiency Virus |
| ICASO | ក្រុមប្រឹក្សាអន្តរជាតិស្តីពីអង្គការប្រយុទ្ធនឹងជំងឺអេដស៍ | International Council on AIDS Organisations |
| IDSW | អ្នករកស៊ីផ្លូវភេទដោយប្រយោល | Indirect Sex Workers |
| IDU | អ្នកប្រើគ្រឿងញៀនចាក់តាមសរសៃ | Intravenous Drug Users |
| KHANA | អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជម្ងឺអេដស៍ | Khmer HIV/AIDS NGO Alliance |
| LICADHO | អង្គការជំរឿន និងការពារសិទ្ធិមនុស្ស | Cambodian League for the Promotion and Defense of Human Rights |
| LSHSE | ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ច ផ្លូវភេទ | Law on Suppression of Human Trafficking and Sexual Exploitation |
| MARPS | ប្រជាជនងាយរងគ្រោះបំផុត | Most At Risk Populations |
| MHC | គ្លីនិកសុខភាពបុរស | Men Health Clinic |
| MHSS | សេវាសង្គមសម្រាប់សុខភាពបុរស | Men's Health Social Service |
| MOI | ក្រសួងមហាផ្ទៃ | Ministry of Interior |
| MOLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | Ministry of Labor and Vocational Training |
| MSM | បុរសស្រឡាញ់បុរស | Men who have Sex with Men |
| NAA | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | National AIDS Authority |
| NACD | អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | National Authority Combating Drug |
| NCHADS | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និង កាមរោគ | National Center for HIV/AIDS, Dermatology and STD |
| NCDD | គណៈកម្មាការជាតិទទួលបន្ទុកការងារវិមជ្ឈការ និងវិសហមជ្ឈការ | National Commission for Decentralization and Deconcentration |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល | Non Government Organisations |
| NMSMTWG | ក្រុមការងារបច្ចេកទេស MSM ថ្នាក់ជាតិ | National MSM Technical Working Group |
| OPC | ការផ្សព្វផ្សាយកម្មវិធីមិត្តអប់រំមិត្ត និងការប្រើស្រោមអនាម័យ ១០០ភាគរយ | Outreach Peer Education and 100% Condom Use |
| PMTCT | ការបង្ការការចម្លងមេរោគពីម្តាយទៅកូន | Prevent of Mother to Child Transmission |
| SOP | នីតិវិធីប្រតិបត្តិជាស្តង់ដារ | Standard Operational Procedure |
| STI | ជំងឺកាមរោគ | Sexually Transmitted Infection |
| SW | អ្នករកស៊ីផ្លូវភេទ | Sex Worker |
| TWG | ក្រុមការងារបច្ចេកទេស | Technical Working Group |
| UA | ការទទួលបានសេវាជាសកល | Universal Access |
| UNAIDS | កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍របស់អង្គការសហប្រជាជាតិ | Joint United Nations Programme on HIV/AIDS |
| UNDP | អង្គការសហប្រជាជាតិសម្រាប់កម្មវិធីអភិវឌ្ឍ | United Nations Development Program |

| | | |
|---|---|---|
| VCCT | សេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយមានផ្តល់ការប្រឹក្សា ស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ | Voluntary Confidential Counseling and Testing |
| WHN | បណ្តាញសុខភាពស្ត្រី | Women Health Network |
| WAC | កម្មវិធីស្ត្រីសម្រាប់ការផ្លាស់ប្តូរ | Womyns Agenda for Change |
| WNU | បណ្តាញការងារស្ត្រីរួបរួមគ្នា | Women Network for Unity |

# សង្ខេបប្រតិបត្តិ

ជាមួយនឹងការការលេចឡើងនូវរលកទីពីរនៃការឆ្លងមេរោគអេដស៍ ការដឹកនាំដ៏រឹងមាំមានសារៈសំខាន់ណាស់ក្នុងការរៀបចំ បន្សី និងធ្វើសុខដុមមណីកម្មរាល់គំនិតផ្តួចផ្តើមនៃវិស័យផ្សេងៗគ្នា ដែលធ្វើការពាក់ព័ន្ធទៅនឹង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់បុរស និងស្រីស្រស់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងការទទួលបានសេវាជាសកលរបស់អ្នកទាំងនោះ។ ការស្រាវជ្រាវនេះមានគោលបំណងធ្វើការវិភាគស្ថានភាពស្តីពីសិទ្ធិទទួលបានការងាររបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទ និងពិនិត្យមើលដែនកំណត់ដ៏ទូលំទូលាយនៃបរិយាកាសអំណោយផល ដែលអាចជះឥទ្ធិពលទៅលើការគ្របដណ្តប់នៃគុណភាពក្នុងការទទួលបានសេវាជាសកល។ ការស្រាវជ្រាវនេះក៏ព្យាយាមកំណត់នូវបញ្ហាចុងក្រោយបំផុតដែលបណ្តាលមកពីការអនុវត្តន៍ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ។

ដោយមានការគាំទ្រពីបណ្តាញ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ការស្រាវជ្រាវនេះបានធ្វើឡើង ចំពោះ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយចំនួន ១១១៦នាក់ (ស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ ស្ត្រីម៉ាស្សា ស្ត្រីរកស៊ីផ្លូវភេទឯករាជ្យ ស្ត្រីខារ៉ាអូខេ ស្ត្រីបំរើស្រាបៀរ) និងបុរសស្រលាញ់បុរស និងស្រីស្រស់ចំនួន ៥៩១នាក់ (សក់ខ្លីចំនួន ៣៦២ នាក់ និងសក់វែងចំនួន ២២៩នាក់) ដែលបានជ្រើសរើសចេញពីខេត្តចំនួន៤ គឺខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ កាលពីខែវិច្ឆិកា ឆ្នាំ២០០៨។

## លទ្ធផលរកឃើញ

### ១. <u>សិទ្ធិទទួលបានការងារ</u>

**ក.** ជាមធ្យម បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទមានអាយុ ២៥ឆ្នាំ ចំណែកឯបុរសស្រឡាញ់បុរស និងស្រីស្រស់មានអាយុតិចជាង១ឆ្នាំ។ ទោះបីជាយ៉ាងនេះក្តីជាមធ្យមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ទទួលបានការអប់រំច្រើនជាង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ពោលគឺបានរៀន ៩ឆ្នាំ ចំណែកឯក្រុមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទរៀនបានត្រឹមតែ៣,៩ឆ្នាំ។ ការស្រាវជ្រាវបានបង្ហាញថាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទមានអនក្ខរជនប្រមាណ២៧ភាគរយ។ ចំណែកឯ១ភាគ៣នៃក្រុម បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនៅលីវហើយ ច្រើនជាង២ភាគ៣ នៃក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់បង្ហាញថាពួកគេមិនដែលរៀបការទាល់តែសោះ។ រយៈពេលនៃការ

ធ្វើការងារក្នុងមុខរបរផ្លូវភេទសម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទគឺចាប់ពី២០ទៅ ៣៦ ខែ ចំណែកឯបុរសស្រលាញ់បុរស និងស្រីស្រស់ គឺចាប់ពី ១៥ ទៅ ៤០ខែ ហើយ ១៨ ភាគរយនៃបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទធ្លាប់បានធ្វើការងាររោងចក្រកាត់ដេរ។ ជាមធ្យមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទជាស្ត្រីមានអ្នកនៅក្នុងបន្ទុកចំនួន៣.១២នាក់ ចំណែកបុរសស្រលាញ់បុរស និងស្រីស្រស់មានចំនួន២នាក់។

ខ. ទោះបីជាចំនួនពាក់កណ្តាលនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទបង្ហាញថា ពួកគេសម្រេចចិត្តធ្វើជាអ្នករកស៊ីផ្លូវភេទដោយស្ម័គ្រចិត្តប៉ុន្តែការវិភាគស៊ីជម្រៅបានបង្ហាញថាអ្នកទាំងនោះរងការបង្ខិតបង្ខំពីគ្រួសារ។ របររកស៊ីផ្លូវភេទជាជម្រើសចុងក្រោយដែលពួកគេជ្រើសរើស ដើម្បីការរស់រាននៃជីវិត។ តិចជាង ១ភាគរយក្នុងចំណោមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទ បង្ហាញថាពួកគេត្រូវបានគេលក់ឱ្យធ្វើជាពេស្យាចារ។ ៨៦ភាគរយនៃបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទសុទ្ធតែបានរួមភេទជាមួយអតិថិជនរបស់ខ្លួនកាលពីសប្តាហ៍មុនចំណែកឯបុរសស្រឡាញ់បុរស និងស្រីស្រស់មាន៤០ភាគរយក៏បានរួមភេទជាមួយអតិថិជនរបស់ខ្លួនដែរ។ ប្រាក់ចំណូលសរុបរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ គឺទទួលបានចាប់ពី ៩១ដុល្លាសហរដ្ឋអាមេរិក (សម្រាប់ក្រុមបុរសស្រឡាញ់បុរស) ដល់១៥៧ដុល្លា (សម្រាប់ស្ត្រីខារ៉ាអូខេ)។ ស្ត្រីខារ៉ាអូខេបានផ្ញើប្រាក់ទៅផ្ទះជាមធ្យម ២០ដុល្លាសហរដ្ឋអាមេរិកក្នុងមួយខែចំណែកឯបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទបានផ្ញើប្រាក់ ចំនួន៣៨ដុល្លាសហរដ្ឋអាមេរិកសម្រាប់អ្នកនៅក្នុងបន្ទុក។ បំណុលរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទមានចំនួនស្ទើរតែ២ដងខ្ពស់ជាងក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ពោលគឺ៤៤ដុល្លា ធៀបនឹង ២៤ដុល្លា។ ការស្រាវជ្រាវបានបង្ហាញថាជាញឹកញាប់អ្នករកស៊ីផ្លូវភេទដោយប្រយោលងាយស្រវឹងជាងអ្នករកស៊ីផ្លូវភេទដោយផ្ទាល់។ មានស្ត្រីខារ៉ាអូខេ ៤១ភាគរយ និងស្ត្រីបំរើស្រាបៀ ចំនួន២៨ភាគរយបានអះអាងថាពួកគេ បានស្រវឹងស្រាកាលពីសប្តាហ៍មុន។ អត្រាប្រើប្រាស់គ្រឿងញៀនតាមរយៈការជក់ហាក់បីដូចជាមានការកើនឡើង ខ្ពស់ជាងការអង្កេតការប្រព្រឹត្តផ្លូវភេទក្នុងឆ្នាំ (BSS) ឆ្នាំ២០០៧។ ជាង៩០ភាគរយនៃបុគ្គលិកគ្រឹះស្ថានកំសាន្ត សប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់បានលើកឡើងថារដ្ឋាភិបាលមានតួនាទីក្នុងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋទាំងអស់រាប់បញ្ចូលទាំងក្រុមដែលងាយរងគ្រោះបំផុតផងដែរហើយក្រុមនេះគួរមានសិទ្ធិស្មើគ្នាដូចជាពលរដ្ឋដទៃទៀតដែរ។ អ្នកទាំងនោះបានលើកឡើងអំពីកត្តាមួយចំនួនដែលពាក់ព័ន្ធនឹងការងាររបស់ខ្លួន ឧទាហរណ៍កង្វះឱកាសការងារកង្វះតំណាង មានគោលនយោបាយមិនច្បាស់លាស់រួមជាមួយនឹងការយល់ដឹង និង

ការអនុវត្តនីមានភាពច្របូលច្របល់។ ប៉ុន្តែអ្នកទាំងនោះក៏បានទទួលស្គាល់ថាភាពអាម៉ាស់ ការរើសអើង ការបៀតបៀន និងអំពើហិង្សា ដែលខ្លួនទទួលរងពីក្រុមប្រជាជនផ្សេងៗគ្នាមានការថយចុះ។

## ២. បរិយាកាសអំណោយផលសម្រាប់ការទទួលបានសេវាជាសកល

### *ក. ការចូលរួមក្នុងយុទ្ធការគាំទ្រឱ្យមានលទ្ធភាពទទួលបានជាសកល*

ការចូលរួមរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់កើតមានភាគច្រើននៅថ្នាក់មូលដ្ឋានតាមរយៈការចូលរួមក្នុងសិក្ខាសាលា។ ភាគច្រើនពួកគេជាអ្នកស្តាប់។ ដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល និងក្រុមអន្តរាគមន៍ថ្នាក់កណ្តាលរបស់ពួកគេ អន្តរាគមន៍ស្វែងរកការគាំទ្រមួយចំនួន (ដូចជាការធ្វើយុទ្ធនាការ សិក្ខាសាលា ក្បួនព្យុះហយាត្រា និងសន្និសីទសារព័ត៌មាន) បានរៀបចំឡើងក្នុងបរិយាកាសមួយដ៏ល្អប្រសើរ។ មានស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់៣៨ភាគរយ ស្ត្រីម៉ាស្សា៣៨ភាគរយ និងអ្នករកស៊ីផ្លូវភេទឯករាជ្យ ៤៣ ភាគរយបានចូលរួមក្នុងយុទ្ធនាស្វែងរកការគាំទ្រ។ មានស្ត្រីខារ៉ាអូខេ២៧ភាគរយ និងស្ត្រីបំរើស្រាបៀរ ៣០ភាគ រយមិនសូវបានចូលរួមក្នុងការគាំទ្រ ប៉ុន្តែមានបុរសស្រឡាញ់បុរសនិង ស្រីស្រស់ ៤៦ភាគរយបានចូលរួម។

ការចូលរួមក្នុងយុទ្ធនាការរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទ បង្ហាញឱ្យឃើញថាមានកម្រិតទាបជាងការចូលរួមក្នុងសកម្មភាពស្តីពីសិទ្ធិទទួលបានការងារធ្វើ។ ការចូលរួមរបស់ស្ត្រីម៉ាស្សាមាន ៣២ភាគរយ ស្ត្រីរកស៊ីផ្លូវភេទឯករាជ្យមាន១៩ភាគរយ និង ៣៣ភាគរយ។ ផ្ទុយទៅវិញស្ត្រីខារ៉ាអូខេ៣១ភាគរយ និងស្ត្រីបំរើស្រាបៀរ៣៣ភាគរយ បានចូលរួមក្នុងកម្មវិធីសិទ្ធិទទួលបានការងារ ច្រើនជាងការចូលរួមក្នុងកម្មវិធីសិទ្ធិទទួលបានសេវាជាសកល។ មានបុរសស្រឡាញ់បុរស៥៨ភាគរយ និងស្រីស្រស់៤៣ភាគរយបានចូលរួមច្រើនជាងក្រុមស្ត្រី។

### *ខ. ការយល់ឃើញ*

*សិទ្ធិទទួលបានការលក់ខ្លួនដោយស្ម័គ្រចិត្តៈ* ភាគច្រើននៃបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយមកពីគ្រប់បណ្តាប្រភេទការងារយល់ស្របថាខ្លួនមានសិទ្ធិក្នុងការលក់ខ្លួនដោយស្ម័គ្រចិត្ត (៨៤ភាគរយ)។ ចំណែកឯបុរសស្រឡាញ់បុរស និងស្រីស្រស់ ក៏បានផ្តល់ចម្លើយស្រដៀងគ្នាដែរពោលគឺពួកគេមានសិទ្ធិក្នុងការលក់ខ្លួនដោយស្ម័គ្រចិត្ត (៨៦ភាគរយ)។

*ការបញ្ចោទិញជាសាធារណៈ: ដោយដៃហៅអតិថិជនៈ* ការយល់ស្រប និងមិនយល់ស្របរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ទៅនឹងមាត្រា២៤ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទមានចំនួនស្មើគ្នា។ ការវិភាគលើប្រភេទការងារបង្ហាញថាអ្នកលក់ខ្លួនដោយផ្ទាល់ (ស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់តាមផ្ទះបន ស្ត្រីម៉ាស្សា និងស្ត្រីរកស៊ីផ្លូវភេទឯករាជ្យ) មានភាគរយស្មើរតែដូចគ្នាទៅលើការយល់ស្រប និងការមិនយល់ស្របទៅនឹងការលើកឡើងនេះ។ អ្នកដែលលក់ខ្លួនដោយប្រយោល (ស្ត្រីខារ៉ាអូខេ និងស្ត្រីបំរើស្រាបៀរ) មានកម្រិតនៃការយល់ស្រប ទៅនឹងការលើកឡើងនេះតិចជាងក្រុមស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ ស្ត្រីម៉ាស្សា និងអ្នករកស៊ីផ្លូវភេទឯករាជ្យ។ ចំណែកឯបុរសស្រលាញ់បុរស៦៧ភាគរយ និងស្រីស្រស់៧៤ភាគរយមិនយល់ស្របទាំងស្រុងទៅលើការលើកឡើងនៃមាត្រា២៤នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទទេ។ គួរកត់សម្គាល់ថាតាមរយៈការវិភាគតាមតំបន់របស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ចម្លើយដែលផ្តល់ដោយអ្នកផ្តល់សម្ភាសន៍មានវិសមភាពយ៉ាងខ្លាំង។

*កត្តាចម្បង៧ដែលពាក់ព័ន្ធនឹងការទទួលបានសេវាជាសកលៈ* ការវិភាគដោយប្រើប្រាស់ WAI បង្ហាញឱ្យឃើញថា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ពិតជាយល់ឃើញថា ភាពអាម៉ាស់ និងការរើសអើងដែលជាឧបសគ្គសម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទ កង្វះតំណាងសម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទក្នុងដំណើរការរៀបចំគោលនយោបាយ និងកម្មវិធី កង្វះការសម្របសម្រួលរវាងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន និងកង្វះការចូលរួមរបស់បណ្តាញប្រឆាំងការជួញដូរមនុស្ស ការត្រួតពិនិត្យគ្រឿងញៀន និងសិទ្ធិមនុស្សក្នុងកម្មវិធីប្រើប្រាស់ស្រោមអនាម័យឱ្យបាន ១០០ ភាគរយជាកត្តាចម្បង៧ដែលជះឥទ្ធិពលដល់ការទទួលបានសេវាជាសកល។

### ឥ. ការអនុវត្តជាក់ស្តែងលើគោលនយោបាយ

*ការលក់ខ្លួនដោយខុសច្បាប់ និងការទទួលបានសេវាផ្លូវភេទដោយស្របច្បាប់ៈ* តាមរយៈប្រភេទការងារ ៨០ភាគរយនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ បង្ហាញថាអាជ្ញាធរមិនបានដាក់ពិន័យទៅលើអតិថិជនរបស់ខ្លួនឡើយ។

*សកម្មភាពរបស់កងឯកសណ្ឋាន និងអាជ្ញាធរមូលដ្ឋានចំពោះអ្នកដែលត្រូវបានជួញដូរ និងអ្នក លក់ខ្លួនដោយស្ម័គ្រចិត្តៈ* លំនាំនៃការឆ្លើយតបទៅនឹងសំណួរដែលបានចោទសួរថាតើកងឯកសណ្ឋាន និងអាជ្ញាធរមូលដ្ឋានបានរំដោះអ្នកដែលត្រូវបានជួញដូរឬមិនបាន? ការលក់ខ្លួន ដោយស្ម័គ្រចិត្ត មិនមែនសុទ្ធតែដូចគ្នានៅគ្រប់បណ្តាខេត្ត

ទាំងអស់នោះទេ។ ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ជា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទ ភាគច្រើនមិនបានផ្តល់ចម្លើយចំណែកឯអ្នកផ្តល់សម្ភាសន៍ជា បុរសស្រលាញ់បុរសនិងស្រីស្រស់ ៧៨ភាគរយនៅទីក្រុងភ្នំពេញបង្ហាញថាមិនមានការរំដោះ ចំណែកឯអ្នកផ្តល់សម្ភាសន៍នៅខេត្តបន្ទាយមានជ័យ និងខេត្តព្រះសីហនុ ៤៦ភាគរយ បង្ហាញថាមានការរំដោះ។

## ៣. *__លទ្ធភាពទទួលបានជាសកល__*

### ក. កំរិតគ្របដណ្តប់

**ក.១. ការប្រើស្រោមអនាម័យៈ** តាមការសង្កេតជារួមអត្រានៃការប្រើប្រាស់ស្រោមអនាម័យរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទជាមួយគ្រប់ក្រុមអតិថិជនគឺមានពី ៨៨ ទៅ ៩៩ភាគរយជាមួយ គូសង្សារពី ៧០ ទៅ៩១ភាគរយ ជាមួយប្តីប្រពន្ធផ្លូវការ និងមិនផ្លូវការដោយមិនបានរៀបការពី ៤១ ទៅ ៧៨ភាគរយ។ អត្រានៃការប្រើប្រាស់ស្រោមអនាម័យ របស់ស្ត្រីខារ៉ាអូខេ ជាមួយគូសង្សាររបស់ខ្លួនមាន៧០ភាគរយ និងស្ត្រីបំរើស្រាបៀរជាមួយគូសង្សារ៧៨ភាគរយ។ អត្រានៃការប្រើប្រាស់ស្រោមអនាម័យរបស់បុរសស្រឡាញ់បុរស (សក់ខ្លី) ជាមួយដៃគូប្រភេទផ្សេងៗគ្នាមានអត្រាលើសពី៨០ភាគរយ។ អត្រានៃការប្រើប្រាស់ស្រោមអនាម័យរបស់ស្រីស្រស់ (សក់វែង) ជាមួយដៃគូរបស់ខ្លួនក៏មានអត្រាលើសពី ៨០ភាគរយដែរលើកលែងតែការប្រើប្រាស់ស្រោមអនាម័យជាមួយបុរសជាដៃគូដោយមិនមានបង់ប្រាក់មានអត្រាត្រឹមតែ ៦៥ភាគរយប៉ុណ្ណោះ។

**ក.២. មិត្តអប់រំមិត្ត ៖** ការរីកចម្រើនក្នុងចំណោម បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទដែលសម្រេចបានដោយក្រុមមិត្តអប់រំមិត្តនៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យទទួលបានក្នុងកម្រិតមួយតិចតួចបំផុត។ ប៉ុន្តែការរីកចម្រើននេះមានការកើនឡើងខ្លាំងនៅខេត្តព្រះសីហនុប៉ុន្តែនៅរាជធានីភ្នំពេញមានការថយចុះបន្តិចវិញ។ កំរិតគ្របដណ្តប់ជារួមក្នុងខេត្តទាំង៤ កើនឡើងពី ៦៣ភាគរយនៅឆ្នាំ២០០៧ ទៅដល់ ៦៥ភាគរយនៅឆ្នាំ២០០៨។ គួរកត់សម្គាល់ផងដែរថាការគ្របដណ្តប់នៅខេត្តសៀមរាបនៅ ឆ្នាំ២០០៧ និងឆ្នាំ២០០៨ មានកម្រិតទាបពោលគឺពី៣១ភាគរយធៀបនឹងតំបន់ផ្សេងទៀត។ ក្នុងចំណោមបុរសស្រឡាញ់បុរសនិងស្រីស្រស់ កំរិតគ្របដណ្តប់លើមិត្តអប់រំមិត្តនៅខេត្តសៀមរាបក្នុងឆ្នាំ២០០៧ និងឆ្នាំ២០០៨ ក៏មានកម្រិតទាបដែរ ពោលគឺ ៥៣ភាគរយសម្រាប់បុរសស្រឡាញ់បុរស និង៤៩ភាគរយសម្រាប់ស្រីស្រស់។ សម្រាប់តំបន់ផ្សេងៗទៀតការគ្របដណ្តប់មានកម្រិតខុសគ្នា ចាប់ពី៧៩ ទៅ ៩៤ភាគរយ។

**ក.៣. ចំណាប់អារម្មណ៍ក្នុងកម្មវិធីមិត្តអប់រំមិត្ត:** ការវិភាគតាមរយៈ WAI បែងចែកតាមតំបន់ បង្ហាញថាគ្រប់ក្រុមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទមានចំណាប់យ៉ាងខ្លាំងទៅលើមិត្តអប់រំមិត្តលើកលែងតែខេត្តសៀមរាប ដែលមានការចាប់អារម្មណ៍បន្តិចបន្តួច។ តាមរយៈការវិភាគលើប្រភេទការងារ មានតែអ្នករកស៊ីផ្លូវភេទឯករាជ្យប៉ុណ្ណោះដែលបង្ហាញពីការចាប់អារម្មណ៍តិចតួច ចំណែកឯអ្នកដទៃទៀត មានការចាប់អារម្មណ៍ខ្លាំង។បុរសស្រឡាញ់បុរសនិងស្រីស្រស់នៅទីក្រុងភ្នំពេញទទួលបានពិន្ទុតិចតួចណាស់ (ចាប់អារម្មណ៍តិចតួច) ចំណែកឯអ្នកផ្តល់សម្ភាសន៍នៅតំបន់ដទៃទៀតមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ ការស្រាវជ្រាវបង្ហាញថាទាំងក្រុមបុរសស្រឡាញ់បុរស ទាំងក្រុមស្រីស្រស់ មានការចំណាប់អារម្មណ៍លើកម្មវិធីមិត្តអប់រំមិត្តយ៉ាងខ្លាំង។

**ក.៤. ការប្រើប្រាស់សេវា :**

- **ជំងឺកាមរោគ និងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់**
  - ក្នុងចំណោម បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទការប្រើសេវាជំងឺកាមរោគសម្រាប់ក្រុមអ្នករកស៊ីផ្លូវភេទដោយផ្ទាល់ ស្ត្រីម៉ាស្សា និងអ្នករកស៊ីផ្លូវភេទឯករាជ្យ (មានអត្រាចាប់ពី ៧២ ទៅ៨៣ភាគរយ) មានកម្រិតខ្ពស់ជាងក្រុមអ្នករកស៊ីផ្លូវភេទដោយប្រយោល (ស្ត្រីខារ៉ាអូខេ ៥៨ភាគរយ និងស្ត្រីបំរើស្រាបៀរ ៦១ភាគរយ)។ ការប្រើសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ក៏មានកម្រិតដូចគ្នាដែរ ប៉ុន្តែក្រុមទាំងអស់មានភាគរយខ្ពស់ៗដូចគ្នា (ចាប់ពី ៧០ ទៅ៩០ភាគរយ)។ ការប្រើសេវារំលូតកូនមានកម្រិតខ្ពស់ក្នុងក្រុមអ្នករកស៊ីផ្លូវភេទឯករាជ្យ ពោលគឺ ១៧ភាគរយ និងស្ត្រីបំរើស្រាបៀរ ១១ភាគរយ។ សម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទដែលមកទទួលសេវាជំងឺកាមរោគ និងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់នៅក្នុងខេត្តទាំង ៤ ជាមធ្យមមាន ការថយចុះលើកលែងសេវាជំងឺកាមរោគនៅរាជធានីភ្នំពេញ។ តាមរយៈការសង្កេតជារួម បុរសស្រឡាញ់បុរសនិងស្រីស្រស់ប្រើសេវាសុខភាពតិចជាងមិត្តភ័ក្តិស្ត្រីរបស់ខ្លួន។ ការប្រើសេវាជំងឺកាមរោគមានចំនួនតិចជាង ៥០ភាគរយ ចំណែកឯការប្រើសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់សម្រាប់បុរសស្រឡាញ់បុរសមានអត្រា៧១ភាគរយ និងស្រីស្រស់ មានអត្រា៧៦ភាគរយ។ ការវិភាគតាមតំបន់បានបង្ហាញថា ការគ្របដណ្តប់នៃសេវាសម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទនៅខេត្តសៀមរាបមានកម្រិតទាប ចំណែកឯការគ្របដណ្តប់នៃសេវាសម្រាប់បុរសស្រឡាញ់បុរសនិងក្រុមស្រីស្រស់នៅខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប មានកម្រិតទាបធៀបនឹងខេត្តពីរដទៃទៀត។

○ ក្នុងចំណោម បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទ ការីតគ្របដណ្តប់នៃសេវាជំងឺកាមរោគ និង សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ កើនឡើងនៅគ្រប់ខេត្តទាំងអស់លើកលែងនៅរាជធានីភ្នំពេញ។ ការគ្របដណ្តប់នៃសេវាទាំងនេះនៅខេត្តបន្ទាយមានជ័យ និងខេត្តព្រះសីហនុមានលក្ខណៈស្រដៀងគ្នា។ ការប្រើសេវាជំងឺកាមរោគ និងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ដោយក្រុមបុរសស្រឡាញ់បុរសនិងក្រុមស្រីស្រស់បង្ហាញថា មានការថយចុះនៅគ្រប់ខេត្តលើកលែងខេត្តបន្ទាយមានជ័យ។ ការប្រើសេវា ជំងឺកាមរោគ នៅរាជធានីភ្នំពេញនៅមិនទាន់មានការផ្លាស់ប្តូរ ចំណែកឯការប្រើសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់មានការថយចុះបន្តិច។ ការប្រើសេវាជំងឺកាមរោគ ផ្តល់ដោយរដ្ឋាភិបាលសម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទមានអត្រា៤៣ភាគរយ និងបុរសស្រឡាញ់បុរសនិងស្រីស្រស់មានអត្រា ៤២ភាគរយ។ ចំនួនដែលនៅសល់ភាគច្រើនផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល។

- ***ការទទួលបានកម្មវិធីអប់រំស្តីពីគ្រឿងញៀន និងការថែទាំតាមផ្ទះ***

○ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទចាប់ពី៥៥ភាគរយ ទៅ៦១ភាគរយនៅខេត្តបន្ទាយមានជ័យ ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញទទួលបានការផ្សព្វផ្សាយអំពីបុគ្គលិកផ្សព្វផ្សាយស្តីពីការបំពានគ្រឿងញៀន។ ទោះបីជាយ៉ាងនេះក្តី បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ នៅខេត្តសៀមរាបប្រមាណ ៣២ភាគរយប៉ុណ្ណោះដែលទទួលបានការផ្សព្វផ្សាយ។ ការផ្សព្វផ្សាយរបស់ក្រុមថែទាំតាមផ្ទះនៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យមានកម្រិតតិចតួចពោលគឺ១៦ភាគរយនៅខេត្តព្រះសីហនុ និងនៅរាជធានីភ្នំពេញមានកម្រិតខ្ពស់ ៤៦ភាគរយ។

○ ការផ្សព្វផ្សាយអំពីកម្មវិធីអប់រំគ្រឿងញៀនសម្រាប់បុរសស្រឡាញ់បុរស និងស្រីស្រស់មានកម្រិតខុសគ្នាពោលគឺ ៤២ភាគរយនៅខេត្តព្រះសីហនុ និង៦៦ភាគរយ នៅរាជធានីភ្នំពេញ។ កម្រិតនៃការផ្សព្វផ្សាយរបស់ក្រុមថែទាំតាមផ្ទះមានភាពខុសគ្នាខ្លាំង ពោលគឺ៥៥ភាគរយសម្រាប់បុរសស្រឡាញ់បុរស ស្រីស្រស់និងប្រមាណ ៧ភាគរយនៅខេត្តបន្ទាយមានជ័យ។

- ***ការទៅរកដៃគូ***

ចំនួននៃការទៅរកដៃគូសរុបមានចំនួនត្រឹមតែ ២៦ភាគរយសម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទ និង២២ភាគរយសម្រាប់ស្រីស្រស់។ នៅខេត្តព្រះសីហនុការទៅរកដៃគូជាបុរសស្រលាញ់បុរស និងស្រីស្រស់ស្ថិតក្នុងកម្រិតមួយខ្ពស់ (៥៧ភាគរយ)។

**ក.៥. គុណភាពសេវា**

- ***សេវាប្រកបដោយភាពរួសរាយ***

ទិន្នន័យដែលប្រមូលបាននិងវិភាគតាមតំបន់បង្ហាញថាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទបាននិយាយថាបុគ្គលិកថែទាំសុខភាពនៅគ្លីនិកជំងឺកាមរោគនិងមណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់មានភាពរួសរាយណាស់សម្រាប់ពួកគេ។ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយមកពីខេត្តសៀមរាបបង្ហាញថាបុគ្គលិកថែទាំសុខភាពនៃសេវាទាំងពីរពិតជារួសរាយណាស់។ ពិន្ទុសម្រាប់បុរសស្រឡាញ់បុរសនិងស្រីស្រស់តិចជាងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនៅគ្រប់ខេត្តទាំងអស់ដោយសារអ្នកទាំងនោះបាននិយាយថាបុគ្គលិកថែទាំសុខភាពនៃគ្លីនិកជំងឺកាមរោគ និងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ពិតជារួសរាយណាស់សម្រាប់ពួកគេ។

- ***ការបង់ថ្លៃសេវា***

យោងតាមចម្លើយរបស់អ្នកផ្តល់សម្ភាសជា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករក ស៊ីផ្លូវភេទការបង់ថ្លៃសេវាលើការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍និងសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមិនមានភាពខុសគ្នាឡើយ។ ទោះបីជាយ៉ាងនេះក្តីសមាមាត្រនៃការចំណាយរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនៅខេត្តសៀមរាបលើសេវាជំងឺកាមរោគ និងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ហាក់បីដូចជាមានកម្រិតខ្ពស់ (បុគ្គលិកគ្រឹះស្ថានកំសាន្ត សប្បាយ២៦.៦ភាគរយ និងអ្នករកស៊ីផ្លូវភេទ ៣៧.២ភាគរយ)។ ទោះបីជាយ៉ាងនេះក្តីការចំណាយប្រាក់នេះ មានកម្រិតតិចតួចបើធៀបទៅនឹងកន្លែងដទៃទៀត។ ការបង់ប្រាក់សម្រាប់ការព្យាបាលដោយឱសថប្រឆាំងមេ រោគអេដស៍ក៏មិនខុសគ្នាដែរ។

## ៤. <u>បញ្ហាដែលអាចកើតមានពាក់ព័ន្ធនឹងការអនុវត្តន៍</u>ច្បាប់ថ្មីស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ

### ***ក. បញ្ហាដែលអាចកើតមានពាក់ព័ន្ធនឹងការអនុវត្តន៍***ច្បាប់ថ្មីស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ

### ក.១. ការផ្លាស់ប្តូរកន្លែង

ការវិភាគផ្អែកលើប្រភេទការងារបង្ហាញថា អ្នករកស៊ីដោយផ្ទាល់ បានផ្លាស់ប្តូរកន្លែងយ៉ាងច្រើននៅឆ្នាំ២០០៨ ធៀបទៅនឹងឆ្នាំ២០០៧។ ចំណែកឯការផ្លាស់ប្តូរកន្លែងរបស់ស្ត្រីខារ៉ាអូខេ ក្នុងឆ្នាំ២០០៨ មានកម្រិតតិចតួចធៀបនឹងឆ្នាំ២០០៧។ ការផ្លាស់ប្តូររបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយដទៃទៀតពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៨មានការថយចុះ។ ក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់ការផ្លាស់ប្តូររបស់ស្រីស្រស់មានការកើនឡើងបន្តិចបន្តួច នៅឆ្នាំ២០០៨ ធៀបនឹងឆ្នាំ២០០៧។ ការផ្លាស់ប្តូរកន្លែង របស់ក្រុមបុគ្គលិកគ្រឹះស្ថានកំសាន្ត

សប្បាយដទៃទៀតថយចុះពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៨។ ក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់ ការផ្លាស់ប្តូរកន្លែងរបស់អ្នកប្តូរភេទក្នុងឆ្នាំ២០០៨ កើនឡើងបន្តិចបន្តួចធៀបនឹងឆ្នាំ២០០៧។ ក្នុងឆ្នាំ២០០៨បុរសស្រឡាញ់បុរសមិនសូវផ្លាស់ប្តូរកន្លែងទេធៀបនឹងឆ្នាំ ២០០៧។

### ក.២. ការចាប់ខ្លួន

ការវិភាគតាមតំបន់បង្ហាញថា ក្នុងខេត្តទាំង ៣ ដូចជាខេត្តសៀមរាប បន្ទាយមានជ័យ និងខេត្តព្រះសីហនុមិនសូវមានការចាប់ខ្លួនបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទច្រើននាក់ប៉ុន្មានទេឡើយ នៅឆ្នាំ២០០៧ និងឆ្នាំ២០០៨ពោលត្រឹមតែពី២ទៅ៤ភាគរយប៉ុណ្ណោះ។ សម្រាប់ការចាប់ខ្លួន បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនៅរាជធានីភ្នំពេញមានចំនួន ១០៣ នាក់ (ឬ ១៩ភាគរយនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនៅរាជធានីភ្នំពេញដែលបានសម្ភាសន៍) នៅឆ្នាំ២០០៧ និងចំនួន៨0នាក់ (ឬ ១៤ភាគរយនៃបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនៅរាជធានីភ្នំពេញដែលបានសម្ភាសន៍) ក្នុងឆ្នាំ២០០៨។ និន្នាការនៃការចាប់ខ្លួន នៅគ្រប់ខេត្តទាំងអស់ មានការថយចុះ ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៨ លើកលែងតែនៅខេត្តព្រះសីហនុ។ នៅខេត្តទាំង៤ ការចាប់ខ្លួនបុរសស្រឡាញ់បុរសនិងស្រីស្រស់មានការកើនឡើង លើកលែងនៅខេត្តបន្ទាយមានជ័យ។ ការចាប់ខ្លួននៅរាជធានីភ្នំពេញ មានលក្ខណៈធ្ងន់ធ្ងរ ដោយសារ បុរសស្រលាញ់បុរស និងស្រីស្រស់បានស្វែងរកអតិថិជន របស់ខ្លួននៅតាមសួន និងទីកន្លែងសាធារណៈ។

### ក.៣. ការដោះលែង

ទិន្នន័យដែលប្រមូលបានពីខេត្តទាំង៤បង្ហាញថាចំនួនពាក់កណ្តាលនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទត្រូវបានដោះលែងដោយមាន និងគ្មានការអន្តរាគមន៍ពីអង្គការមិនមែនរដ្ឋាភិបាល។ ថវិកា (៧ភាគរយ) ឬរបស់មានតម្លៃ (២៧ភាគរយ) ត្រូវបានប្រើប្រាស់ក្នុងអំឡុងពេល ឬក្រោយពេលចាប់ខ្លួន។ ៦ ភាគរយនៃអ្នកដែលបានចាប់ខ្លួននិយាយថា ខ្លួនសុខចិត្តរួមភេទជាមួយដើម្បីជាថ្នូរនឹងការដោះលែង។ ក្រុមបុរសស្រឡាញ់បុរសនិងស្រីស្រស់ប្រើវិធីស្រដៀងគ្នានេះ ប៉ុន្តែខុសត្រង់ថា ពួកគេអាចប្រគល់របស់មានតម្លៃ ឬប្រគល់ប្រាក់តែម្តង ដើម្បីជាថ្នូរនឹងការដោះលែង។

### *ក.៤. ការគាំទ្រ*

- ***ការគាំទ្រក្នុងករណីមានអំពើហិង្សា***

តាមរយៈការឆ្លើយតបរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទបានបង្ហាញថា ឱកាសក្នុងការទទួលបានការគាំទ្រពីប្រជាពលរដ្ឋ ឬកងឯកសណ្ឋាន/អាជ្ញាធរមូលដ្ឋាន ដើម្បីជួយជ្រោមជ្រែងនៅពេលខ្លួនទទួលរងនូវអំពើហិង្សាមានកម្រិតមធ្យមក្នុងខេត្តសៀមរាប និងខេត្តព្រះសីហនុ និងនៅខេត្តបន្ទាយ

មានជ័យ និងរាជធានីភ្នំពេញមានកម្រិតតិចតួច។ ឱកាសក្នុងការគាំទ្របុរសស្រឡាញ់បុរសនិងស្រីស្រស់នៅក្នុងខេត្តទាំង៤មានកម្រិតតិចតួចលើកលែងតែនៅក្រុងព្រះសីហនុ ដែលពួកគេអាចបានប្រជាពលរដ្ឋ ជាអ្នកជួយ។

- ***ការគាំទ្រភ្លាមៗបន្ទាប់ពីមានការប្រើអំពើហិង្សា***

ក្នុងចំណោមប្រភពនៃការគាំទ្រក្រោយពេលមានអំពើហិង្សាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ មកពីខេត្តទាំង៤ អះអាងថាការគាំទ្ររួមគ្នាពីសំណាក់ប៉ូលីស និងអាជ្ញាធរមូលដ្ឋានមានកម្រិតតិចជាង ៤០ភាគរយ។ ភាគច្រើនពួកគេចូលចិត្តពឹងពាក់អង្គការមិនមែនរដ្ឋាភិបាល និងប្រជាជននៅតាមមូលដ្ឋានឱ្យជួយ។ ចម្លើយរបស់បុរសស្រឡាញ់បុរសនិងស្រីស្រស់ក៏ស្រដៀងគ្នាទៅនឹងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយដែរ។

- ***បម្រែបម្រួលអថេរសំខាន់ៗមួយចំនួននៅរវាងឆ្នាំ២០០៧ និង២០០៨***

***ក្នុងចំណោម***បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ/អ្នករកស៊ីផ្លូវភេទ

- មធ្យោបាយក្នុងការផ្លាស់ប្តូរកន្លែង មានការថយចុះគួរឱ្យកត់សម្គាល់ ពោលគឺពី ០,៥៩ នៅ ឆ្នាំ២០០៧ មក ០,៤៩ នៅឆ្នាំ២០០៨
- មធ្យោបាយក្នុងការប្រើប្រាស់សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់គឺមានការថយចុះ គួរឱ្យកត់សម្គាល់ ពោលគឺពី ១,៤៦ នៅឆ្នាំ២០០៧ ដល់ ១,៣៣ នៅឆ្នាំ២០០៨
- មិនមានការផ្លាស់ប្តូរលើមធ្យោបាយនៃការចាប់ខ្លួននិងការទទួលបានសេវាជំងឺកាមរោគសម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនៅរវាងឆ្នាំ២០០៧ និងឆ្នាំ២០០៨។

**ក្នុងចំណោម**បុរសស្រឡាញ់បុរស និងស្រីស្រស់

- មធ្យោបាយក្នុងការផ្លាស់ប្តូរកន្លែងមានការថយចុះគួរឱ្យកត់សម្គាល់ពោលគឺពី ១,១៧ នៅឆ្នាំ ២០០៧ ដល់ ១,០៣ នៅឆ្នាំ២០០៨
- មធ្យោបាយក្នុងការចាប់ខ្លួន មានការកើនឡើងគួរឱ្យកត់សម្គាល់ ពោលគឺពី ០,០៧១ នៅ ឆ្នាំ២០០៧ ដល់ ០,១២១ នៅឆ្នាំ២០០៨
- មិនមានការផ្លាស់ប្តូរលើមធ្យោបាយនៃការប្រើសេវាជំងឺកាមរោគ និងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់សម្រាប់បុរសស្រឡាញ់បុរសនិងស្រីស្រស់ នៅរវាងឆ្នាំ២០០៧ និងឆ្នាំ២០០៨។

## ៥. <u>ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍បំណិនបណ្តាញពាក់ព័ន្ធ និងដៃគូសំខាន់ៗរាប់បញ្ចូលទាំងបុគ្គលិកគ្រឹះស្ថានកំសាន្តនិងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់</u>

## ៥. ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍បំណិនបណ្តាញពាក់ព័ន្ធ និងដៃគូសំខាន់ៗរាប់បញ្ចូលទាំងបុគ្គលិកគ្រឹះស្ថានកំសាន្តនិងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់

***ក. ការកសាងសមត្ថភាពសម្រាប់លទ្ធផលនៃភាពជាអ្នកដឹកនាំ ត្រូវបានស្នើឡើងដើម្បី*** បង្កើតបណ្តាញមួយដ៏មានឥទ្ធិពល និងដំណើរការក្នុងរយៈពេលមួយយូរអង្វែង ពីបណ្តាមន្ត្រីគោលនយោបាយ មន្ត្រីប្រតិបត្តិកម្មវិធី និងអ្នកទទួលផលប្រយោជន៍ដែលអាចសម្របសម្រួលដល់ការបង្កើតគោលនយោបាយជាពិសេសនៅថ្នាក់មូលដ្ឋាន។ មន្ត្រីគោលនយោបាយ មន្ត្រីប្រតិបត្តិកម្មវិធីត្រូវទទួលបានការតាមដាន ដើម្បីគាំទ្រលើការផ្លាស់ប្តូរគំរូនេះ។ មន្ត្រីសំខាន់ៗមកពីស្ថាប័នពាក់ព័ន្ធដែលមានការងារជាប់ទាក់ទងដោយផ្ទាល់ទៅនឹងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរសនិងស្រីស្រស់ និងលទ្ធភាពទទួលបានសេវា មូលដ្ឋានរបស់អ្នកទាំងនោះ (ឧទាហរណ៍ៈលទ្ធភាពទទួលបានសេវាជាសកលលើ សេវាស្របច្បាប់ សេវាសង្គម...)

***ខ. ការកសាងសមត្ថភាពក្នុងការរៀបចំ និងផ្សព្វផ្សាយគំនិតផ្តួចផ្តើម និងកម្មវិធី ប្រាស្រ័យទក់ទងឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត ជាយុទ្ធសាស្ត្រ សមស្របសម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្ត សប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរសនិងស្រីស្រស់និងអតិថិជនរបស់អ្នកទាំងនោះ។***

ការកសាងសមត្ថភាពសម្រាប់ការប្រាស្រ័យទក់ទងឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត ត្រូវផ្សារភ្ជាប់ទៅនឹងសិទ្ធិមនុស្សជាមូលដ្ឋាន ការបង្ការ ការឆ្លងមេរោគអេដស៍ ការថែទាំបន្ត និងបរិយាកាសអំណោយផល។ កម្មវិធីគូសង្សារ ត្រូវពិនិត្យ និងវាយតម្លៃសារឡើងវិញ រៀបចំសារឡើងវិញ និងពង្រីកបន្ថែម ដោយឱ្យមានការចូលរួមយ៉ាងសកម្មពីបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ។

***គ. ការកសាងជំនាញរបស់កងកម្លាំងប៉ូលីស និងអាជ្ញាធរមូលដ្ឋានឱ្យដើរតួជាចលករសហគមន៍***

គាំទ្រដល់សិទ្ធិរបស់បុគ្គលិកគ្រឹះស្ថានកំសាន្ត សប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរសនិងស្រីស្រស់ និងបង្កើនលទ្ធភាពចូលរួមរបស់អ្នកទាំងនោះដើម្បីទទួលបានសេវាជាសកល។ កងកម្លាំងប៉ូលីសដែលមានសមត្ថភាពជំនាញ និងអាជ្ញាធរមូលដ្ឋាននៅចំនុចក្តៅ ត្រូវអភិវឌ្ឍបន្ថែមដើម្បីបង្កើត បរិយាកាសអំណោយផលសម្រាប់កម្មវិធីបង្ការរបស់ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។

***ឃ. ការពង្រឹងសមត្ថភាពតាមស្ថាប័ន និងការគាំទ្រដល់ ទៅនឹងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបណ្តាញបុរសស្រឡាញ់បុរស និងស្រីស្រស់***

សម្រាប់លទ្ធផលរំពឹងទុកគឺធ្វើយ៉ាងណាបង្កើតបណ្តាញរឹងមាំសម្រាប់ទៅនឹងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ដែលអាចធ្វើការរួមគ្នាជាមួយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល និងអាចគាំទ្របានយ៉ាងមានប្រសិទ្ធភាព មិនមែនត្រឹមតែទៅលើ សុវត្ថិភាពផ្លូវភេទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទៅលើទិដ្ឋភាពសិទ្ធិមនុស្សដ៏ទូលំទូលាយរាប់បញ្ចូលទាំងការគាំទ្រផ្នែកច្បាប់ និងសង្គម។

***ង. ការពង្រឹងសមត្ថភាពតាមស្ថាប័ន និងការគាំទ្រដល់បណ្តាញនានាដែលធ្វើការងារជាមួយ ទៅនឹងបុគ្គលិកគ្រឹះស្ថានកំសាន្ត សប្បាយ និងអ្នករកស៊ីផ្លូវភេទនិងបុរសស្រឡាញ់បុរសនិងស្រីស្រស់***

សមាសធាតុផ្សេងៗគ្មានសម្រាប់សមត្ថភាពបច្ចេកទេស និងតាមស្ថាប័ននៃយន្តការដែលមាន ស្រាប់ត្រូវពង្រឹងបន្ថែម។ ការគាំទ្រលេខាធិការដ្ឋាន គួរតែបន្តដើម្បីធ្វើឱ្យសមាសធាតុ នីមួយៗ នៃប្រព័ន្ធអាចអនុវត្តកិច្ចការដែលមានកំណត់ពេលវេលាបាន។ សមាសធាតុសំខាន់ៗមួយចំនួននៃប្រព័ន្ធត្រូវធ្វើការតាមដានដោយយកចិត្តទុកដាក់ដោយក្រុមពិគ្រោះយោបល់រយៈពេលខ្លីសម្រាប់មុខងារ ដ៏គួរឱ្យទុកចិត្ត និងប្រកបដោយប្រសិទ្ធភាពជាមួយនឹងការពង្រឹងភាពជាម្ចាស់នៅតាមមូលដ្ឋាន។

**ការវិភាគ**

១. *ផ្លាស់ប្តូរលក្ខណៈទូទៅនៃមុខរបរផ្លូវភេទដោយបង្កើនចំនួន* បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ *ការផ្លាស់ប្តូរទៅកាន់កន្លែងដែលមិនមែនជាផ្ទះបន ការរួមបញ្ចូលនូវគ្រោះថ្នាក់របស់* បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ *ការផ្លាស់ប្តូរទំនាក់ទំនងរវាង* បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ *និងដៃគូ និងអតិថិជនរបស់ពួកគេ និងការផ្លាស់ប្តូរបរិយាកាសអំណោយផល។*

២. *ការសិក្សាអំពី* សង្គម សេដ្ឋកិច្ច និងប្រជាសាស្ត្រ *នៃការស្រាវជ្រាវនេះ បង្ហាញអំពីល័ក្ខខ័ណ្ឌដែលស្ត្រី និងបុរសវ័យក្មេងអាចចូលរួមក្នុងមុខរបរផ្លូវភេទ និងអាចចិញ្ចឹមជីវិតតាមរយៈការលក់ខ្លួន។ ភាគច្រើននៃអ្នកទាំងនោះមកពីគ្រួសារក្រីក្រ និង/ឬគ្រួសារបែកបាក់។ តិចជាង១ភាគរយនៃអ្នកទាំងនោះត្រូវបានលក់ទៅឱ្យផ្ទះបន។ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទ ត្រូវផ្ញើលុយមកផ្ទះប្រមាណ ៣០ ទៅ៥០ដុល្លា ជារៀងរាល់ខែ ដើម្បីផ្គត់ផ្គង់អ្នកនៅក្នុងបន្ទុកដែលមានចំនួនជាមធ្យម៣,១២នាក់។ ប្រការសំខាន់ដែលគួរឱ្យកត់សម្គាល់គឺថាក្នុងចំណោម បុរសស្រលាញ់បុរស និងស្រីស្រស់ ៦៦,៦ភាគរយ និងស្រីស្រស់ ៨៤,៥ ភាគរយ ទទួលស្គាល់ថា ខ្លួនទទួលបានប្រាក់ពីការលក់ខ្លួន។*

៣. ភាពមិនស្របគ្នារវាងការយល់ឃើញ និងភាពពិតជាក់ស្តែង

ក. ៨៤ភាគរយនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង៩០ភាគរយនៃបុរសស្រឡាញ់បុរស និងស្រីស្រស់មានសិទ្ធិចូលរួមក្នុងការបង្កើតច្បាប់ និងគោលនយោបាយពាក់ព័ន្ធនឹងការងាររកស៊ីផ្លូវភេទ។

*ការសម្ភាសស៊ីជម្រៅជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះបានបង្ហាញថាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ខ្វះតំណាងក្នុងដំណើរការពិគ្រោះយោបល់សម្រាប់ការបង្កើត*

*គោលនយោបាយទាំងនេះ។ ការចាត់តាំងអ្នកទាំងនោះឱ្យធ្វើការនៅក្នុងអតីតការផ្សព្វផ្សាយកម្មវិធីមិត្តអប់រំមិត្ត និងការប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយគ្រាន់តែជាគោលបំណងមួយក្នុងការបង្កើតឱ្យមានតំណាងសម្រាប់អ្នកទទួលផលពីសេវាមិនមែនឱ្យដើរតួយ៉ាងសំខាន់ក្នុងការការពារសិទ្ធិឱ្យបានកាន់តែទូលំទូលាយរាប់បញ្ចូលទាំងសិទ្ធិទទួលបានការងារធ្វើ និងសិទ្ធិរស់រានមានជីវិត (មិនមានតំណាងបណ្ដាញការងារស្ត្រីរួមគ្នានៅក្នុងក្រុម ការងារបច្ចេកទេសការផ្សព្វផ្សាយកម្មវិធីមិត្តអប់រំមិត្ត និងការប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយនៅថ្នាក់មូលដ្ឋាន និងក្នុងគណកម្មាធិការសម្របសម្រួលការប្រើប្រាស់ស្រោមអនាម័យនៅថ្នាក់ ខេត្ត)នោះទេ។ ទោះបីជាបណ្ដាញការងារស្ត្រីរួមគ្នា និងបណ្ដាញសុខភាពស្ត្រី មានសកម្មភាពយ៉ាងសកម្មនៅក្នុងខេត្តទាំង ៩ ទំនាក់ទំនងរវាងថ្នាក់មូលដ្ឋាន និងថ្នាក់កណ្ដាល នៅមានចំណុចខ្វះចន្លោះ។ ភាពពិតជាក់ស្ដែង នៅថ្នាក់មូលដ្ឋាន មិនអាចរាយការណ៍ទៅថ្នាក់ខេត្ត និង/ឬថ្នាក់កណ្ដាលបានដោយងាយស្រួលឡើយ ប្រសិនបើមិនមានការរួមចំណែក ក្នុងការបង្កើតគោលនយោបាយ និងការពិនិត្យវាយតម្លៃ។*

ខ. តើ៨៩ភាគរយនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង៩៦ភាគរយនៃ បុរសស្រឡាញ់បុរស និងស្រីស្រស់មានសិទ្ធិដូចជាពលរដ្ឋដទៃទៀតដែរឬទេ?

*ទោះបីជាការរកស៊ីផ្លូវភេទដោយខុសច្បាប់មិនទាន់បានលើកឡើងឱ្យបានច្រើនក្នុងច្បាប់ស្ដីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទក៏ដោយ ប៉ុន្តែមាត្រាជាច្រើននៃច្បាប់នេះ បានកាត់បន្ថយឱកាសរបស់ស្ត្រីបម្រើសេវានៅតាមគ្រឹះស្ថានកំសាន្តសប្បាយក្នុងការរកចំណូលពីការលក់ខ្លួន។*

៤. សិទ្ធិទទួលបានសេវាជាសកល

*ទោះបីជាបណ្ដាញការងារស្ត្រីរួមគ្នា និងបណ្ដាញសុខភាពស្ត្រី មានសកម្មភាពយ៉ាងសកម្មក្នុងខេត្តទាំង៩ ប៉ុន្តែទំនាក់ទំនងរវាងថ្នាក់ មូលដ្ឋាន និងថ្នាក់កណ្ដាល នៅមានចំណុចខ្វះចន្លោះ។ ក្រៅពីទីភ្នាក់ងារផ្ដល់មូលនិធិ អង្គការសហគមន៍បុរសស្រឡាញ់បុរសធ្វើការនៅថ្នាក់មូលដ្ឋានដូចជាអង្គការគ្លីនិកសុខភាពបុរស សេវាសង្គមសម្រាប់សុខភាពបុរស និងកញ្ញា មិនបានផ្សារភ្ជាប់ជាប្រព័ន្ធទៅនឹងក្រុមការងារបច្ចេក ទេសបុរសស្រឡាញ់បុរសថ្នាក់ជាតិដើម្បីរាយការណ៍អំពីបញ្ហាពាក់ព័ន្ធទៅនឹងកំរិតគ្របដណ្ដប់នៃការធ្វើអន្តរាគមន៍នៅតំបន់របស់ខ្លួន។*

*អង្គការមិនមែនរដ្ឋាភិបាលប្រើវិធីសាស្ត្រផ្សេងគ្នាក្នុងការធ្វើអន្តរាគមន៍និងច្រកផ្សេងគ្នាក្នុងការរាយការណ៍។ ក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរសថ្នាក់ជាតិ និងក្រុមការងារបច្ចេកទេសគ្រឿងញៀន និងជំងឺអេដស៍*

*កំពុងព្យាយាមពុះពារកំណត់សូចនាករ ដើម្បីប្រមូល និង ចងក្រង ទិន្នន័យនៃការគ្របដណ្តប់នៃសេវាសម្រាប់បុរសស្រឡាញ់បុរស និងស្រីស្រស់ និងអ្នកប្រើ និងចាក់គ្រឿងញៀន ។*

៥. គុណភាពនៃការទទួលបានសេវាជាសកល

*ទោះបីជា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ត្រូវបានចាត់ទុកថាជាអ្នកទទួលផលប្រយោជន៍បំផុតពីការផ្តល់សេវា ប៉ុន្តែបញ្ហាពាក់ព័ន្ធនឹងការទទួលបានសេវាជាសកលប្រកបដោយគុណភាព (ឧទាហរណ៏សេវាមេត្រី ការបង់ថ្លៃសេវានៅតំបន់មួយចំនួន) មិនទាន់បានពិភាក្សាគ្នាដោយបើកចំហនៅឡើយ ។*

៦. បញ្ហាដែលអាចកើតមានពាក់ព័ន្ធនឹងការអនុវត្តន៏ច្បាប់ថ្មីស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ

*ការសម្ភាសស៊ីជម្រៅជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ បង្ហាញថាការបណ្តុះបណ្តាលសមស្របដល់ប៉ូលីសមូលដ្ឋានតាមរយៈការប្រើគោលការណ៏ណែនាំរួមសម្រាប់ការអនុវត្តន៏ច្បាប់នៅមានចំណុចខ្វះខាត ។ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរមូលដ្ឋានអាចប្រើហេតុផលជាច្រើនដើម្បីឃាត់ខ្លួន បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់មិនឱ្យឈានទៅដល់ការជួញដូរ ។ ទាំងនេះមានដូចជា អំពើអូសទាញ បន្ទប់ជួល សណ្តាប់ធ្នាប់សាធារណៈ ការជួញដូរកុមារឱ្យធ្វើជាពេស្យាចារ ។ល។ អ្នកផ្តល់សម្ភាសចំនួន ៣៤ ភាគរយបានអះអាងថាខ្លួនបានប្រើសំណូកដើម្បីជាថ្នូរនឹងការដោះលែង ។*

*ជារួម ការរំពឹងនិងការជឿជាក់ថា ប៉ូលីស និងអាជ្ញាធរមូលដ្ឋានអាចជួយ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នក រកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់បានក្នុងករណីមានអំពើហិង្សា គឺមានកម្រិតតិចតួច ។*

## អនុសាសន៍

អនុសាសន៏របស់កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៏អង្គការសហប្រជាជាតិបានបង្កើតឡើងក្នុងទម្រង់ជា គោលការណ៏ណែនាំស្តីពីមេរោគអេដស៏ និងការរកស៊ីផ្លូវភេទ ដែលបានផ្សព្វផ្សាយជាសាធារណៈនៅខែកុម្ភៈ ឆ្នាំ២០០៩ ។

- *គោលដៅទី ១ : ធានាឱ្យបាននូវលទ្ធភាពទទួលបានសេវាជាសកល ដើម្បីការបង្ការ ការថែទាំ ការព្យាបាល និងគាំទ្រអ្នកផ្ទុកមេរោគអេដស៏ និងជំងឺអេដស៏ឱ្យបានទូលំទូលាយ*
- *គោលដៅទី ២ : បង្កើតបរិយាកាសគាំទ្រ ពង្រឹងភាពជាដៃគូ និងបង្កើនជម្រើស*
- *គោលដៅទី ៣ : កាត់បន្ថយភាពងាយរងគ្រោះ និងដោះស្រាយបញ្ហារចនាសម្ព័ន្ធ*

# សេចក្តីសន្និដ្ឋាន

ដើម្បីជាការឆ្លើយតបទៅនឹងលទ្ធផលនៃការរកឃើញ ស្តីពីគោលបំណងទាំង៥ និងការវិភាគ អាចឱ្យធ្វើការសន្និដ្ឋានបានថាការដឹកនាំដ៏រឹងមាំ មានសារៈសំខាន់ណាស់ក្នុងការសម្របសម្រួលការឆ្លើយតប ដើម្បីធានាឱ្យបាននូវសិទ្ធិទទួលបានការងារ និងសិទ្ធិទទួលបានសេវាជាសកលសម្រាប់ *បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ*។

វិស័យ និងយន្តការនីមួយៗ ត្រូវមានការគាំទ្រលើសកម្មភាពដែលបានផ្តល់អនុសាសន៍ ដូចមានបង្ហាញក្នុងគោលដៅទាំង ៣។ គំនិតផ្តួចផ្តើមដែលមានស្រាប់ ដូចជាយុទ្ធសាស្ត្រជាតិសម្រាប់បង្ការ និងត្រួតពិនិត្យការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ អ្នកបម្រើសេវាកំសាន្ត អតិថិជន និងសង្សាររបស់ពួកគេ ផែនការយុទ្ធសាស្ត្ររបស់ក្រសួងមហាផ្ទៃដើម្បីឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ ២០០៩-២០១៣ ប្រកាស ០៨៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និតិវិធីអនុវត្តស្តង់ដាថ្មីសម្រាប់ការបង្ការ ការថែទាំ និងការព្យាបាលបន្ត វិធីសាស្ត្រសម្រាប់ស្ត្រីបម្រើសេវាកំសាន្តនៅប្រទេសកម្ពុជា (NCHADS) បណ្តាញ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការជាមួយក្រុមដែលងាយរងគ្រោះបំផុត គួរទទួលបានការគាំទ្រ។

# I.សារចតារ

សម្ព័ន្ធប្រជាជនកម្ពុជាប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ (CACHA) កំពុងធ្វើកិច្ចការយ៉ាងជិតស្និទ្ធជាមួយអ្នករកស៊ីផ្លូវភេទ និងបណ្តាញអ្នករកស៊ីផ្លូវភេទ ដែលរួមមានដូចជាបណ្តាញការងារស្ត្រីរួបរួមគ្នា (WNU) បណ្តាញបុរសស្ត្រីអភិវឌ្ឍកម្ពុជា (CNMWD) សហជីពស្ត្រីរកស៊ីផ្លូវភេទ (CPU) បណ្តាញថ្នាក់ជាតិនៃបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ និងសហគមន៍ស្ត្រីផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍នៅកម្ពុជា (CCW) ចាប់តាំងពីខែមេសា ឆ្នាំ១៩៩៦មក។ សម្រាប់គម្រោងស្រាវជ្រាវនេះគឺបានការផ្តល់មូលនិធិពី កម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ (WAC) បណ្តាញការងារស្ត្រីរួបរួមគ្នា (WNU) ក្រុមប្រឹក្សាអន្តរជាតិស្តីពីការប្រយុទ្ធនឹងជំងឺអេដស៍ (ICASO) តាមរយៈបណ្តាញការងាររកស៊ីផ្លូវភេទនៅអាស៊ីប៉ាស៊ីហ្វិក (APNSW) អង្គការអាក់សិនអេត (ActionAid) កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍អង្គការសហប្រជាជាតិ (UNAIDS)។

តាមរយៈបទពិសោធដ៏ច្រើនក្រាស់ក្រែល ក្នុងការធ្វើការងារជាមួយ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ អស់រយៈពេលជិត ៣ឆ្នាំមកនេះ សម្ព័ន្ធប្រជាជនកម្ពុជាប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស យល់ជ្រួតជ្រាបយ៉ាងច្បាស់អំពីមូលហេតុដែលបង្កឱ្យមានការរីករាលដាលមេរោគអេដស៍។ ទោះបីជាការពិតបានបង្ហាញថាអត្រាប្រេវ៉ាឡង់មេរោគអេដស៍បានធ្លាក់ចុះពី ៣,២ ភាគរយនៅឆ្នាំ ១៩៩៧ មកនៅត្រឹម ០,៩ភាគរយនៅឆ្នាំ២០០៦ ក្តី ប៉ុន្តែអត្រាប្រេវ៉ាឡង់របស់ក្រុមគោលដៅ មួយចំនួនដូចជាក្រុមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនៅមានកម្រិតខ្ពស់នៅឡើយ ពោលគឺប្រមាណ ១២,៦៩ភាគរយ នៅឆ្នាំ ២០០៦។ បច្ចុប្បន្នបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទកំពុងជួបប្រទះនូវបញ្ហាប្រឈមដែលមិនធ្លាប់ជួបកាលពី ទស្សវត្សរ៍កន្លងមកពោលគឺផ្ទះបនចំនួនច្រើនជាងពាក់កណ្តាលត្រូវបានបិទទ្វារហេតុនេះអ្នករកស៊ីផ្លូវភេទមិនអាចដាក់ស្រោមអនាម័យតាមខ្លួនបានទៀតឡើយ។ អ្នករកស៊ីផ្លូវភេទភាគច្រើន ត្រូវបានចាប់ខ្លួន ឃុំឃាំង វាយដំ ហើយក្នុងករណីខ្លះទៀតអ្នកទាំងនោះត្រូវបានគេចាប់រំលោភ។ អ្នករកស៊ីផ្លូវភេទមួយចំនួនក្នុងចំណោមអ្នករកស៊ីផ្លូវភេទទាំងអស់មិនអាច មានលទ្ធភាពទទួលបានឱសថប្រឆាំងមេរោគអេដស៍ដូចកាលពីមុនឡើយ។ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទដែលបានផ្លាស់ប្តូរពីការរស់នៅផ្ទះបន មកធ្វើជា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទឯករាជ្យ (ដោយប្រយោល) បានបង្ហាញឱ្យឃើញយ៉ាងច្បាស់ និងបានរីករាលដាលនៅពាសពេញប្រទេស។ បន្ថែមពីលើនេះបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងម្ចាស់បនត្រូវបានចាប់ខ្លួនជាពិសេសបន្ទាប់ពីមានការអនុវត្តន៍ច្បាប់ថ្មីស្តីពីការបង្រ្កាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលផ្លូវភេទ។ បញ្ហានេះត្រូវបានមើលឃើញថាប្រសិនបើមិនមានការចាត់ វិធានការឱ្យបានសមស្រប និងទាន់ ពេលវេលាទេនោះ អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវ ភេទ នឹងកើនឡើងវិញមានន័យថារលកទី២នៃការរាលដាលមេរោគអេដស៍នឹងកើតមានឡើងដោយជៀសមិនផុត។

ដើម្បីឆ្លើយតបនឹងបញ្ហាទាំងនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** នាឱកាសបិទសន្និសីទជាតិលើកទី ៣ស្តីពីជំងឺអេដស៍កាលពីថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០០៨ នៅសាលសន្និសីទចតុមុខបានទទួលស្គាល់ថាមុខរបរផ្លូវភេទនៅប្រទេសកម្ពុជា (និងនៅប្រទេសដទៃ) មិនអាចលុបបំបាត់បានឡើយ។ ដោយសារមានការគាំទ្រចាំបាច់លើគោលនយោបាយប្រើប្រាស់ស្រោមអនាម័យ ១០០ភាគរយ និងការធានាឱ្យបាននូវការអនុវត្តន៍ច្បាប់ថ្មីស្តីពីការបង្ក្រាប ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទឱ្យបានរលូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានជំរុញឱ្យស្ថាប័នចំនួន ២ ពោលគឺ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងនាយកដ្ឋានប្រឆាំងការជួញដូរនៃក្រសួងមហាផ្ទៃ ឱ្យធ្វើការ ជាមួយគ្នាឱ្យបានជិតស្និទ្ធដោយបង្ហាញនូវសកម្មភាពយោគយល់ និងអាចអនុវត្តបានជារួម ដើម្បីដោះស្រាយបញ្ហារសើបទាំងនេះ។ សំខាន់ជាងនេះទៅទៀត ឯកឧត្តមក៏បានបញ្ជាក់សារជាថ្មីម្តងទៀតថាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គួរសហការឱ្យបានជិតស្និទ្ធជាមួយស្ថាប័នសង្គមស៊ីវិល ដែលជាអ្នកដំណើរការ និងជាអ្នកអនុវត្តដ៏សកម្មលើមេរោគអេដស៍ និងជំងឺអេដស៍នៅតំបន់ជនបទ។

គួររំពឹងផងដែរថាលទ្ធផលការស្រាវជ្រាវស្តីពីបរិយាកាសគោលនយោបាយទាក់ទងការទទួលបានសេវាជាសកល និងសិទ្ធិទទួលបានការងារធ្វើរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ នឹងផ្តល់នូវគំនិតដ៏មានតម្លៃសម្រាប់ការបង្កើតគោលនយោបាយនិងកម្មវិធីសម្រាប់បណ្តាភាគីពាក់ព័ន្ធជាពិសេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃដើម្បីពិចារណា។ ជាងនេះទៅទៀត លទ្ធផលនៃការស្រាវជ្រាវនេះនឹងត្រូវពិភាក្សាជាមួយគ្រប់បណ្តាភាគីពាក់ព័ន្ធរាប់បញ្ចូលទាំងមន្ត្រីគោលនយោបាយ មន្ត្រីបច្ចេកទេស (មន្ត្រីកម្មវិធី និងមន្ត្រីប្រតិបត្តិច្បាប់) តំណាងវិស័យឯកជន (ក្រុមហ៊ុនស្រាបៀរ ម្ចាស់ហាងខារ៉ាអូខេ ម្ចាស់សណ្ឋាគារ ។ល។) តំណាងក្រុមដែលងាយរងគ្រោះបំផុត និងប្រជាជនងាយរងគ្រោះដើម្បីទទួលបានគំនិតយោបល់ពីអ្នកទាំងនោះ និងឆ្លុះបញ្ចាំងតាមរយៈការផ្តល់ជាអនុសាសន៍ចុងក្រោយដល់ការស្រាវជ្រាវ។

មេរៀនជាបទពិសោធដ៏សំខាន់មួយដែលសម្ព័ន្ធប្រជាជនកម្ពុជាប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ទទួលបានតាមរយៈបទពិសោធធ្វើការជាមួយក្រុមគោលដៅគឺថា ដំណើរការក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរប្រកប ដោយនិរន្តរភាព ទាមទារនូវការចំណាយពេលវេលា ជាពិសេសបើគិតទៅលើស្ថានភាពស្មុគស្មាញដែលប្រឈមមុខដោយបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ក្នុងបរិបទសង្គមកម្ពុជា។ បញ្ហានេះក៏បានទទួលស្គាល់ផងដែរថាប្រតិបត្តិករភាគច្រើនជាក្រុមគោលដៅដោយខ្លួនឯង។ ផលប៉ះពាល់លើចេរភាពក្នុងរយៈពេលយូរអង្វែង អាស្រ័យលើការពង្រឹងសម្លេង និងជម្រើសនៃការចិញ្ចឹមជីវិតរបស់ អ្នកទាំងនោះ។ ការផ្តល់សិទ្ធិអំណាច និងការជួយប្រជាជនឱ្យប្រើសិទ្ធិរបស់ខ្លួនព្រមជាមួយគោលដៅ កាន់តែទូលំទូលាយក្នុងការកាត់បន្ថយការរើសអើង ការជួបការលំបាកក្នុងសង្គម ការកេងប្រវ័ញ្ច និងការកសាងសង្គមមួយឱ្យកាន់ តែមានការចូលរួមក៏មានសារៈសំខាន់ផងដែរ។ ការអនុវត្តន៍នេះជាដំណើរការមួយដែលចំណាយរយៈពេលយូរ និងមិន អាចឈាន ទៅសម្រេចបានក្នុងរយៈពេលមួយដ៏ខ្លីឡើយ។

ការទទួលស្គាល់សិទ្ធិជាបណ្តើរៗ អាចកើតមានតាមរយៈការបង្កើតដំណើរការព្រមៗគ្នាមួយចំនួន ដែលជាប់ពាក់ព័ន្ធនឹងក្រុមគោលដៅ សង្គមស៊ីវិល អាជ្ញាធរផ្នែកច្បាប់ និងនយោបាយ អ្នកផ្តល់សេវា និងបណ្តាភាគីពាក់ព័ន្ធដទៃទៀត។ ដំណើរការនេះទាមទារឱ្យមានការអនុវត្តនីតិវិធីសាស្ត្រជាបន្តបន្ទាប់ និងជាជំហានៗ។ ហេតុដូច្នេះគម្រោងបានជ្រើសរើសវិធីសាស្ត្ររួម ហើយសមាសភាពថ្នាក់កណ្តាលតម្រូវឱ្យមានការផ្តល់សិទ្ធិអំណាចដល់ក្រុមគោលដៅ ដែលជាភ្នាក់ងារធ្វើការផ្លាស់ប្តូរដ៏មានសក្តានុពល មានសិទ្ធិ និងការទទួលខុសត្រូវ តាមរយៈការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិ ការផ្សារភ្ជាប់ក្រុមសង្គមស៊ីវិលទៅនឹងអ្នកផ្តល់សេវា។ លក្ខណៈរួមនៃសកម្មភាពភាគច្រើនរួមមាន ការសម្របសម្រួលការផ្សារភ្ជាប់រវាងក្រុមគោលដៅ និងអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវា ការចូលរួមរបស់សង្គមស៊ីវិលដែលជាភ្នាក់ងារធ្វើឱ្យមានការផ្លាស់ប្តូរសំខាន់ៗ ការប្រើប្រាស់សមត្ថភាពរបស់ក្រុមចលករប្រកបដោយសក្តានុពល ការផ្តល់សិទ្ធិអំណាចដល់ក្រុមនេះតាមរយៈការបណ្តុះបណ្តាលដើម្បីលើកកម្ពស់ការយល់ដឹង ដើម្បីឱ្យអ្នកទាំងនោះកាន់តែមានទំនុកចិត្តក្នុងការផ្សព្វផ្សាយសកម្មភាពជាសាធារណៈដើម្បីប្រឆាំងនឹងការរើសអើង។

ក្នុងអំឡុងដំណាក់កាលរៀបចំគម្រោង អង្គភាពជាច្រើនដែលបានធ្វើការជាមួយក្រុមគោលដៅ ត្រូវបានកត់សម្គាល់ឃើញថា ភាគច្រើនខ្លួនបានអនុវត្តគម្រោងតាមវិស័យដាច់ដោយឡែក ដោយផ្តោតសំខាន់លើការចែកចាយសេវា ជាពិសេសសិទ្ធិចំពោះបញ្ហាសុខភាព។ ផ្អែកលើបទពិសោធន៍នេះ គម្រោងបានផ្តោតលើការកសាងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នរដ្ឋាភិបាល និងអងការមិនមែនរដ្ឋាភិបាលដើម្បីឱ្យការផ្លាស់ប្តូរជាយុទ្ធសាស្ត្រក្នុងរយៈពេលយូរអង្វែង អាចប្រព្រឹត្តទៅបាន។

# II. គោលបំណង

## គោលបំណងជាក់លាក់

១. វិភាគស្ថានភាពស្ដីពីសិទ្ធិទទួលបានការងាររបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនិងអ្នករកស៊ីផ្លូវភេទ ដោយពិចារណាទៅលើស្ថានភាពនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន (នៅពេលច្បាប់ស្ដីពីការជួញដូរមនុស្សបានយកមកអនុវត្ត)។

២. ពិនិត្យមើលបរិយាកាសអំណោយផលលើការបង្កើត និងការដាក់ឱ្យប្រតិបត្តិគោលនយោបាយ និងបទដ្ឋានសង្គមដែលមានស្រាប់ពាក់ព័ន្ធនឹងលទ្ធភាពទទួលបានសេវាជាសកលសម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ។

៣. វាយតម្លៃលើលទ្ធភាពគ្របដណ្ដប់ និងសេវាប្រកបដោយគុណភាពទាក់ទងនឹងលទ្ធភាពទទួលបានសេវាជាសកលសម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ។

៤. កំណត់បញ្ហា (និងបញ្ហាដែលអាចកើតមាន) ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ថ្មីស្ដីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ក្នុងចំណោមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ។

៥. ពង្រីកចំណេះដឹង សមត្ថភាព និងជំនាញរបស់បណ្ដាញ និងដៃគូពាក់ព័ន្ធ។

# II. វិធីសាស្ត្រ

## ១. ក្របខ័ណ្ឌសម្រួលការ

ការស្រាវជ្រាវដើម្បីធ្វើសកម្មភាពនេះរៀបចំឡើងដើម្បីដោះស្រាយបញ្ហាសិទ្ធិជាមូលដ្ឋានចំនួន ២ នៃសិទ្ធិរស់រានមានជីវិតសម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្ត សប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ ពោលគឺសិទ្ធិទទួលបានការងារធ្វើ និងសិទ្ធិទទួលបានសេវាមូលដ្ឋាន។



បន្ទាប់ពីការសិក្សាអំពីប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ច និងការស្វែងយល់អំពីឥរិយាបថ និងភាពងាយរងគ្រោះរបស់បុគ្គលិកគ្រឹះស្ថានកំសាន្ត សប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ការស្រាវជ្រាវដើម្បីធ្វើសកម្មភាពនេះមានបំណងស្វែងយល់លើទិដ្ឋភាពសំខាន់ៗចំនួន ២ :

## គ. សិទ្ធិទទួលបានការងារធ្វើ

- ការប្រកបមុខរបររកស៊ីផ្លូវភេទ
- បរិយាកាសអំណោយផល (ការចូលរួមបង្កើតច្បាប់ និងគោលនយោបាយ និងសកម្មភាពស្វែងរកការគាំទ្រ លទ្ធផលនៃសកម្មភាពស្វែងរកការគាំទ្រ)
- បទដ្ឋានសង្គម (លើសិទ្ធិពលរដ្ឋ សណ្តាប់ធ្នាប់សង្គម ភារកិច្ចរបស់អាជ្ញាធរមូលដ្ឋាន ការមាក់ងាយ និងការរើសអើង)
- បញ្ហាពាក់ព័ន្ធនឹងបរិយាកាសអំណោយផល (ការបៀតបៀន និងអំពើហិង្សា ការប្រកាន់ខ្ជាប់ការអនុវត្តន៍គោលនយោបាយ និងច្បាប់ការចាប់ខ្លួន និងដោះលែងពីការឃុំឃាំង)
- ការគាំទ្រពីសង្គម (ពីពលរដ្ឋទូទៅ ពីអាជ្ញាធរមូលដ្ឋាន និងប៉ូលីស ពីសហគមន៍)
- ការយល់ឃើញលើកត្តាសំខាន់ៗពាក់ព័ន្ធនឹងសិទ្ធិទទួលបានការងារ

## ខ. សិទ្ធិទទួលបានសេវាជាសកល

- កំរិតគ្របដណ្តប់នៃកម្មវិធីមិត្តអប់រំមិត្ត
- ការប្រើសេវាមូលដ្ឋាន (ឧទាហរណ៍សេវាជំងឺកាមរោគ សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ មណ្ឌលសំចត...)
- ការបញ្ជូនទៅរកសេវាដទៃទៀត (ឧទាហរណ៍សេវាថែទាំតាមផ្ទះ ការអប់រំផ្សព្វផ្សាយអំពីគ្រឿងញៀន)
- គុណភាពសេវា (ឧទាហរណ៍ ការចាប់អារម្មណ៍លើកម្មវិធីមិត្តអប់រំមិត្ត ភាពរួសរាយនៃបុគ្គលិកថែទាំសុខភាព ការបង់ថ្លៃសេវា)
- ការយល់ឃើញចំពោះកត្តាសំខាន់ៗពាក់ព័ន្ធនឹងសិទ្ធិទទួលបានសេវាជាសកល

ការផ្តោតការចាប់អារម្មណ៍ជាពិសេសមួយនៃការស្រាវជ្រាវសកម្មភាព មានគោលបំណងស្វែងរកឱ្យឃើញថា តើការអនុវត្តច្បាប់ស្តីពីការបង្រ្កាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ដែលបានអនុម័តកាលពីខែកុម្ភៈ ឆ្នាំ២០០៨ កន្លងទៅនេះ អាចជះឥទ្ធិពលអាក្រក់ដល់សិទ្ធិក្នុងការរស់នៅរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ និងសិទ្ធិទទួលបានសេវាជាមូលដ្ឋានរបស់អ្នកទាំងនោះដែរឬយ៉ាងណា?

## ២. គម្រោងស្រាវជ្រាវ

### ក. ប្រភេទការសិក្សាស្រាវជ្រាវ

- **គោលបំណង: គោលបំណងរួម**នៃការស្រាវជ្រាវសកម្មភាពនេះគឺដើម្បីស្វែងរកការគាំទ្រឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានក្នុងវិធីសាស្រ្ត ការអនុវត្តន៍គោលនយោបាយ យន្តការរបស់អាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍ អ្នកផ្តល់សេវា និងសង្គមស៊ីវិល តាមរយៈភាពជាដៃគូជាយុទ្ធសាស្រ្តចំពោះលទ្ធភាពទទួលបានសេវាជាសកល និងសិទ្ធិទទួលបានការងារក្នុងចំណោមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនៅប្រទេសកម្ពុជា។
- **ប្រភេទ:** ការស្រាវជ្រាវដើម្បីធ្វើសកម្មភាពនេះ ជាការរួមបញ្ចូលនូវវិធីសាស្រ្តបែបគុណភាព និង បរិមាណដែលមានគោលបំណងប្រមូលទិន្នន័យស្តីពី "បរិយាកាសគោលនយោបាយទាក់ទងការទទួលបានសេវាជាសកល និងសិទ្ធិទទួលបានការងារធ្វើរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ "។ ការវិភាគនាពេលបន្ទាប់នេះត្រូវធ្វើឡើងដើម្បីផ្តល់យោបល់លើលទ្ធផលដែលបានរកឃើញ និងដើម្បីលើកឡើងនូវបុព្វហេតុដែលអាចជះឥទ្ធិពលដល់សិទ្ធិ ទទួលបានការងារ និងលទ្ធភាពទទួលបានសេវាជាសកលរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ក្នុងបរិបទមួយកាន់តែទូលំទូលាយ។ ជាចុងក្រោយការស្រាវជ្រាវនេះ មានបំណងផ្តល់អនុសាសន៍ដល់ការអនុវត្តន៍សម្រាប់ពេលអនាគត និងការធ្វើផែនការសម្រាប់បរិយាកាសការងារប្រកបដោយសុវត្ថិភាព និងលទ្ធភាពទទួលបានសេវាជាសកលប្រកបដោយគុណភាពកាន់តែប្រសើរ។



## រូប ២ : គម្រោងស្រាវជ្រាវដើម្បីធ្វើសកម្មភាព

- **សំណាកដែលជ្រើសរើសមកសិក្សា :** ការស្រាវជ្រាវដើម្បីធ្វើសកម្មភាពនេះ មានបំណងដោះស្រាយបញ្ហារបស់អ្នកទាំងឡាយណាដែលប្រកបរបររកស៊ីផ្លូវភេទដោយផ្ទាល់ឬដោយប្រយោល ។ អ្នកផ្តល់សម្ភាសទាំងអស់ជាអ្នករកស៊ីផ្លូវភេទដោយផ្ទាល់ ស្ត្រីម៉ាស្សា អ្នករកស៊ីផ្លូវភេទឯករាជ្យ ស្ត្រីខារ៉ាអូខេ ស្ត្រីបំរើស្រាបៀរ បុរសស្រឡាញ់បុរស (MSM) និងក្រុមស្រីស្រស់ ។
- **ទីតាំងសម្រាប់ការសិក្សា :** ការសិក្សានេះបានធ្វើឡើងនៅខេត្តក្រុងចំនួន ៤ ដែលសម្បូរទៅដោយមុខរបរផ្លូវភេទដូចជានៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តបន្ទាយមានជ័យ ។



**រូប ៣ : ទីតាំងផែនទីខេត្ត និងរាជធានីភ្នំពេញដែលបានប្រមូលទិន្នន័យ**

តារាងខាងក្រោមបង្ហាញអំពីចំនួនប្រជាជនដែលជាអ្នករកស៊ីផ្លូវភេទដោយផ្ទាល់ ដោយប្រយោល និងបុរសស្រឡាញ់បុរសដែលរាយការណ៍ដោយមន្ទីរសុខាភិបាលអេដស៍ខេត្តទាំង៤ ដែលបានជ្រើសរើសៈ

**តារាង ១ : ចំនួនបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ដែលរាយការណ៍ដោយមន្ទីរសុខាភិបាលអេដស៍**

| **ប្រភេទ** អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ ដោយប្រយោល បុរសស្រឡាញ់បុរស និង**ស្រីស្រស់** | **ខេត្តសៀមរាប** | **ខេត្តបន្ទាយមានជ័យ** | **ខេត្តព្រះសីហនុ** | **រាជធានីភ្នំពេញ** | **សរុប** |
|---|---|---|---|---|---|
| **អ្នករកស៊ីផ្លូវភេទដោយផ្ទាល់** | 131 | 124 | 96 | 743 | 1098 |
| **អ្នករកស៊ីផ្លូវភេទដោយប្រយោល** | 3400 | 1345 | 955 | 11109 | 16854 |
| បុរស ស្រឡាញ់បុរស និង**ស្រីស្រស់** (**ដែលបាន ទំនាក់ទំនងជាមួយ**) | 1312 | 1257 | 105 | 1014 | 3683 |

## ខ. ការប្រមូលទិន្នន័យ

*ប្រភព និងវិធីសាស្ត្រប្រមូលទិន្នន័យ*

- **ប្រភពទិន្នន័យបន្ទាប់បន្សំ**

ទិន្នន័យបន្ទាប់បន្សំពាក់ព័ន្ធនឹងទិន្នន័យដែលត្រូវប្រមូលពីឯកសារមានស្រាប់ដូចជា NCHADS, NAA, MoI, MoH, MOLVT, CARE, UNAIDS, WHO, HACC, PAO ក្នុងខេត្តដែលជ្រើសរើសយកមកសិក្សា (ស្ថិតិខេត្ត និងអង្គភាព និងស្ថាប័នពាក់ព័ន្ធដទៃ ទៀត)។

- **ប្រភពទិន្នន័យចាំបាច់**

*សម្រាប់ចំណែកការស្រាវជ្រាវបែបគុណវិស័យ:*

មន្ត្រីមកពីស្ថាប័ន និងអង្គភាពពាក់ព័ន្ធសំខាន់ៗ (រដ្ឋាភិបាល សង្គមស៊ីវិល អង្គភាពសហគមន៍ អង្គការអន្តរជាតិ និងអង្គការសហប្រជាជាតិ) និងតំណាងអ្នករកស៊ីផ្លូវភេទដោយផ្ទាល់ អ្នករកស៊ីផ្លូវភេទឯករាជ្យ ស្ត្រីខារ៉ាអូខេ ស្ត្រីបំរើស្រាបៀរ បុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ ត្រូវបានជ្រើសរើសយកមកសិក្សា ដើម្បីបញ្ចេញទស្សនៈលើសិទ្ធិរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ និងលទ្ធភាពរបស់ពួកគេក្នុងការទទួលបានសេវាជាសកល។ បច្ចេកទេសក្នុងការប្រមូលទិន្នន័យមាន ដូចជាការអង្កេតយកការ កម្រងសំណួរជាប្រព័ន្ធ ការសម្ភាស ការពិភាក្សាជាក្រុម និងការសង្កេត។

- **ការអង្កេតយកការណ៍:** ការអង្កេតនេះនឹងអនុវត្តនៅដំណាក់កាលដំបូងក្នុងខេត្ត សិក្សាចំនួន៤ដើម្បីកំណត់ទំហំគំរូ ធ្វើតេស្តកម្រងសំណួរជាប្រព័ន្ធ និងរៀបចំផែនការដើម្បីចុះអនុវត្តផ្ទាល់។ ទន្ទឹមនឹងនេះ ការអង្កេតនឹងផ្តល់នូវការយល់ដឹងជាមូលដ្ឋានសម្រាប់ស្ថានភាពនៅតំបន់ដែលកំពុងកើតមាន និងខេត្តដែលបានជ្រើសរើស ដែលផ្តល់អត្ថប្រយោជន៍ដល់ការធ្វើផែនការនៅដំណាក់កាលដទៃទៀត។
- **ការសង្កេតនៅកន្លែងអនុវត្តផ្ទាល់:** ការសង្កេតនឹងយកមកអនុវត្តដើម្បីសង្កេតនៅតំបន់ ជុំវិញ មជ្ឈដ្ឋាន និងទីតាំងផ្ទះបន ហាងខារ៉ាអូខេ ភោជនីយដ្ឋាន ផ្ទះសំណាក់ បន្ទប់ជួល សួនច្បារសាធារណៈ និងកន្លែងកម្សាន្តដទៃទៀត ដែលសកម្មភាពរូបភាពអាចប្រព្រឹត្តទៅបាន។
- **កម្រងសំណួរជាប្រព័ន្ធ:** កម្រងសំណួរបានរៀបចំឡើងដើម្បីសម្ភាសអ្នករកស៊ីផ្លូវភេទ ស្ត្រីខារ៉ាអូខេ ស្ត្រីបំរើស្រាបៀរ បុរសស្រឡាញ់បុរស និង ក្រុមស្រីស្រស់។ កម្រងសំណួរនេះ នឹងមានរួមបញ្ចូលទាំងសំណួរបិទ និងសំណួរបើក។
- **អ្នកផ្តល់ព័ត៌មានគន្លឹះៗ:** អ្នកផ្តល់ព័ត៌មានគន្លឹះៗក្នុងខេត្តដែលបានជ្រើសរើសមកសិក្សា មានដូចជាមន្ត្រីរដ្ឋាភិបាល សង្គមស៊ីវិល អង្គការសហគមន៍ អង្គការអន្តរជាតិ និងអង្គការសហប្រជាជាតិ។
- **ការពិភាក្សាជាក្រុម:** ការពិភាក្សានឹងធ្វើឡើងដើម្បីស្វែងរកព័ត៌មានបន្ថែម ជាពិសេស បញ្ហាដែលកំពុងកើតមាននាពេលបច្ចុប្បន្ន។ ការពិភាក្សានឹងធ្វើឡើងក្នុងចំណោមអ្នករកស៊ីផ្លូវភេទ ស្ត្រីខារ៉ាអូខេ បុរសស្រឡាញ់

បុរស និងក្រុមស្រីស្រស់ ប្រជាជនមូលដ្ឋាន (ទាំងប្រជាជនវ័យក្មេង និងវ័យចំណាស់) អាជ្ញាធរមូលដ្ឋាន ប៉ូលីស និងបណ្តាភាគីពាក់ព័ន្ធដទៃទៀត។

*សម្រាប់ចំណែកការស្រាវជ្រាវបែបបរិមាណវិស័យ :*

**ក. ទំហំគំរូ :**

រូបមន្តសម្រាប់ការគណនាទំហំគំរូគឺប្រើជាលក្ខណៈស្ថិតិ (Yamane, 1960) និងក្នុងកម្រិតជឿជាក់៩០ភាគរយ។

$$n = N / ( 1 + N^* e2 )$$

n: ទំហំគំរូ (អ្នកផ្តល់សម្ភាស)

N: ចំនួនប្រជាជនសរុប (អ្នកផ្តល់សម្ភាស)

e: កម្រិតជាក់លាក់ (10%)

**ខ. វិធីសាស្ត្រជ្រើសរើសទំហំគំរូ**

ផ្អែកលើលក្ខខណ្ឌនៃការជ្រើសរើសតំបន់យកមកសិក្សាស្រាវជ្រាវ រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តបន្ទាយមានជ័យ នឹងត្រូវជ្រើសយកមកធ្វើការសិក្សា។

**តារាង ២ : ចំនួន** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់បុរស និងក្រុមស្រីស្រស់ **ដែលចូលរួមក្នុងការស្រាវជ្រាវដើម្បីធ្វើសកម្មភាពបែបបរិមាណ**

| | បណ្តាខេត្តក្រុង | ខេត្តសៀមរាប | | ខេត្តបន្ទាយមានជ័យ | | ខេត្តព្រះសីហនុ | | រាជធានីភ្នំពេញ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ប្រភេទ | N | % | N | % | N | % | N | % | N | % |
| បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ | ស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ | 44 | 16.06% | 69 | 27.60% | 53 | 23.87% | 80 | 21.62% | 246 | 22.04% |
| | ស្ត្រីម៉ាស្សា | 7 | 2.55% | 25 | 10.00% | 1 | 0.45% | 90 | 24.32% | 123 | 11.02% |
| | អ្នករកស៊ីផ្លូវភេទឯករាជ្យ | 20 | 7.30% | 3 | 1.20% | 22 | 9.91% | 81 | 21.89% | 126 | 11.29% |
| | ស្ត្រីខារ៉ាអូខេ | 183 | 66.79% | 132 | 52.80% | 114 | 51.35% | 94 | 25.41% | 523 | 46.86% |

| | | N | % | N | % | N | % | N | % | N | % |
|---|---|---|---|---|---|---|---|---|---|---|---|
| | ស្ត្រីបំរើស្រាបៀរ | 20 | 7.30% | 19 | 7.60% | 26 | 11.71% | 25 | 6.76% | 90 | 8.06% |
| | | | | | | | | | | | 32 |
| | ដទៃទៀត | 0 | 0.00% | 2 | 0.80% | 6 | 2.70% | 0 | 0.00% | 8 | 0.72% |
| | សរុប | 274 | | 250 | | 222 | | 370 | | 1116 | |
| | **ប្រភេទ** | N | % | N | % | N | % | N | % | N | % |
| បុរសស្រឡាញ់បុរស និង អ្នកប្តូរភេទ | បុរសស្រឡាញ់បុរស | 63 | 39.38% | 134 | 77.01% | 40 | 59.70% | 125 | 65.79% | 362 | 61.25% |
| | អ្នកប្តូរភេទ | 97 | 60.63% | 40 | 22.99% | 27 | 40.30% | 65 | 34.21% | 229 | 38.75% |
| | សរុប | 160 | | 174 | | 67 | | 190 | | 591 | |

### គ. នីតិវិធីប្រតិបត្តិ

កម្រងសំណួរបានរៀបចំឡើងចេញពីក្របខ័ណ្ឌទស្សនៈទាន ដោយក្រុមអ្នកពិគ្រោះ យោបល់ និងបានយកទៅធ្វើតេស្តសាកល្បង ព្រមទាំងកែសម្រួលដោយតំណាងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ឬបុរសស្រឡាញ់បុរស និងស្រីស្រស់ (សមាជិកបណ្តាញការងារស្ត្រីរួមគ្នា សហជីពស្ត្រីរកស៊ីផ្លូវភេទ និងបណ្តាញបុរសស្ត្រីអភិវឌ្ឍកម្ពុជា) ដើម្បីធ្វើឱ្យប្រាកដថា អ្នកទាំងនោះអាចយល់សំណួរបានយ៉ាងច្បាស់ហើយព័ត៌មានដែលប្រមូលបានអាចសមស្របទៅនឹងបរិបទ និងស្ថាន ភាពនៅតាមមូលដ្ឋាន។

ការសម្ភាសបានធ្វើឡើងដោយផ្ទាល់ដោយអ្នកសម្ភាសដែលភាគច្រើនជានិស្សិតវ័យក្មេង ផ្នែកវិទ្យាសាស្ត្រសង្គម និងផ្នែកសុខាភិបាល និងមន្ត្រីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ គ្រូបង្គោល និងអ្នកសម្របសម្រួល (តំណាងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់) ត្រូវបានរៀបចំឱ្យសម្របសម្រួល និងត្រួតពិនិត្យការប្រមូលទិន្នន័យក្នុងខេត្តនីមួយៗ។ ចំណែកឯការសិក្សានៅខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាបបានធ្វើឡើងដោយមានការត្រួតពិនិត្យពីថ្នាក់កណ្តាល។ អ្នកត្រួតពិនិត្យបានពិនិត្យមើលកម្រងសំណួរទាំងអស់នៅតាមកន្លែងចុះអនុវត្តផ្ទាល់ដើម្បីធានាគុណភាពទិន្នន័យ មុនពេលទិន្នន័យបានបញ្ចូលក្នុងប្រព័ន្ធកំព្យូទ័រដើម្បីធ្វើការវិភាគ។

ក្រុមសម្ភាសបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីរៀបចំឱ្យមានការសម្ភាសជាលក្ខណៈឯកជន និងក្នុងលក្ខណៈបត់បែនមួយដ៏សមស្រប។

### ឃ. ការវិភាគទិន្នន័យ

រាល់ព័ត៌មាន និងទិន្នន័យទាំងអស់ដែលប្រមូលបានពីប្រភពចាំបាច់ និងបន្ទាប់បន្សំនឹងត្រូវវិភាគតាម វិធីសាស្ត្រផ្សេងៗគ្នាពោលគឺតាមរយៈវិធីសាស្ត្របែបគុណ និងបែបបរិមាណ។

*ឃ.១. វិធីសាស្ត្របែបគុណវិស័យ*

វិធីសាស្ត្រកញ្ចប់ស្ថិតិសម្រាប់វិទ្យាសាស្ត្រសង្គម (SPSS) ត្រូវបានយកមកប្រើប្រាស់ដើម្បីវិភាគទិន្នន័យដែលប្រមូលបានតាមបែបគុណវិស័យ។

**- ស្ថិតិតាមបែបពិពណ៌នា**

ស្ថិតិតាមបែបពិពណ៌នានឹងត្រូវយកមកប្រើប្រាស់ជាមូលដ្ឋានសម្រាប់ទិន្នន័យសង្គមកិច្ច-សេដ្ឋកិច្ចរបស់អ្នកផ្តល់សម្ភាសដោយប្រើប្រាស់ការវិភាគរកចំនួន ភាគរយ តារាងឆ្លង ក្រាហ្វ និងឆាដ។

**- ស្ថិតិតាមបែបវិភាគ**

- **ការវិភាគតាមបែប ANOVA**

វិធីសាស្ត្របែប ANOVA នឹងត្រូវយកមកប្រើប្រាស់ដើម្បីសាកល្បងរកទំនាក់ទំនងរវាងអថេរបន្តមួយ និងអថេរក្នុងក្រុមមួយក្នុងខេត្តក្រុងខុសៗគ្នាចំនួន ៤ ដែលលើកយកមកសិក្សា។ ការសាក ល្បងនឹងផ្តល់ឱ្យយើងនូវព័ត៌មានលម្អិតស្តីពីភាពខុសគ្នាលើមធ្យោបាយក្នុងការកំណត់ពិន្ទុលើការយល់ ឃើញចំពោះកត្តាសំខាន់ៗពាក់ព័ន្ធនឹងសិទ្ធិទទួលបានការងារ និងសិទ្ធិទទួលបានសេវាជាសកល ចំណាប់អារម្មណ៍ចំពោះកម្មវិធីមិត្តអប់រំមិត្ត ការដាក់ពិន្ទុលើភាពរួសរាយចំពោះការផ្តល់សេវាជំងឺកាមរោគ និងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ការដាក់ពិន្ទុលើការយល់ឃើញចំពោះការគាំទ្រពីសង្គមក្នុងករណីមានអំពើហិង្សា។

- **Wight Average Index (WAI)**

WAI បានត្រូវប្រើប្រាស់ដើម្បីកំណត់ពិន្ទុលើកម្រិតនៃការយល់ឃើញលើកត្តាចម្បងៗពាក់ព័ន្ធ នឹងសិទ្ធិទទួលបានការងារ និងសិទ្ធិទទួលបានសេវាជាសកល ចំណាប់អារម្មណ៍ចំពោះកម្មវិធីមិត្ត អប់រំមិត្ត ការដាក់ពិន្ទុលើភាពរីករាយចំពោះការផ្តល់សេវា ជំងឺកាមរោគ និងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ការដាក់ពិន្ទុលើការ យល់ឃើញ ចំពោះការគាំទ្រពីសង្គមក្នុងករណីមានអំពើហិង្សា។

WAI ដែលនឹងយកមកអនុវត្តក្នុងការសិក្សានេះ មានបង្ហាញដូចខាងក្រោម :

(១) សន្ទស្សន៍នៃការយល់ឃើញចំពោះសិទ្ធិទទួលបានការងារ និងសិទ្ធិទទួលបានសេវាជាសកល

| ចំណាត់ថ្នាក់ទី ១<br>(1) | ចំណាត់ថ្នាក់ទី ២<br>(0.66) | ចំណាត់ថ្នាក់ទី ៣<br>(0.33) |
|---|---|---|

ការចាត់ចំណាត់ថ្នាក់ និងសន្ទស្សន៍អាទិភាព នឹងត្រូវអនុវត្តដូចខាងក្រោម :

F1: ហ្វ្រេកង់នៃចំណាត់ថ្នាក់ទី ១

F2: ហ្វ្រេកង់នៃចំណាត់ថ្នាក់ទី ២

F3: ហ្វ្រេកង់នៃចំណាត់ថ្នាក់ទី ៣

(២) សន្ទស្សន៍ចំណាប់អារម្មណ៍លើកម្មវិធីមិត្តអប់រំមិត្ត

| ខ្លាំងណាស់ | ខ្លាំង | ល្មម | តិចតួច | តិចតួចណាស់ |
|---|---|---|---|---|
| (1) | (0.8) | (0.6) | (0.4) | (0.2) |

(៣) សន្ទស្សន៍នៃការដាក់ពិន្ទុលើកម្រិតពេញចិត្តចំពោះភាពរួសរាយនៃសេវាជំងឺកាមរោគ និង VCCT

| រួសរាយខ្លាំងណាស់ | រួសរាយខ្លាំង | ល្មម | មិនសូវរួសរាយ | មិនរួសរាយសោះ |
|---|---|---|---|---|
| (+2) | (+1) | (0) | (-1) | (-1) |

(៤) សន្ទស្សន៍នៃការដាក់ពិន្ទុលើការយល់ឃើញចំពោះការគាំទ្រពីសង្គមក្នុងករណីមានអំពើហិង្សា

| គាំទ្រខ្លាំងណាស់ | គាំទ្រខ្លាំង | គាំទ្រល្មម | គាំទ្រតិចតួច | គាំទ្រតិចតួចណាស់ |
|---|---|---|---|---|
| (1) | (0.8) | (0.6) | (0.4) | (0.2) |

- **Paired Sample T test**

ការសាកល្បងនេះ ត្រូវបានប្រើប្រាស់ដើម្បីពណ៌នាអំពីភាពខុសគ្នាខ្លាំង ឬតិចចំពោះអថេរមួយចំនួន នៅរវាងឆ្នាំ ២០០៧ និងឆ្នាំ២០០៨។ ភាពខុសគ្នាទាំងនេះសំដៅលើ ការបម្លាស់ទីរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ការចាប់ខ្លួន ការប្រើសេវាជំងឺកាមរោគ និងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់។

*ឃ.២. ការវិភាគបែបគុណវិស័យ*

ភាគច្រើនទិន្នន័យប្រមូលតាមរយៈការពិភាក្សាជាក្រុម ការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះ៧ និង ការចុះសង្កេតនៅកន្លែងអនុវត្តផ្ទាល់ ការវិភាគស្ថានភាព ការវិភាគពាក្យសម្តី និងការវិភាគខ្លឹមសារ ទស្សនៈ និងការយល់ឃើញរបស់អ្នកទាំងនោះលើច្បាប់ប្រឆាំងនឹងការជួញដូរមនុស្សថ្មី ការប្រើស្រោមអនាម័យឱ្យបាន១០០ភាគរយ ការបិទផ្ទះបននៅក្នុងរយៈពេលថ្មីៗនេះ សិទ្ធិទទួលបានការងារ និងបញ្ហាក្តៅដែលកំពុងកើតមាននាពេលបច្ចុប្បន្នដទៃទៀត នឹងត្រូវដាក់បញ្ចូលទៅក្នុងដំណាក់កាលវិភាគតាមបែបគុណ។ បន្ថែមពីលើនេះរង្វង់បញ្ហានឹងត្រូវបង្កើតឡើង ដើម្បីស្វែងរកទំនាក់ទំនងកត្តាដែលអាចជះឥទ្ធិពលដល់ការសម្រេចបាននូវលទ្ធភាពទទួលបានសេវាជាសកលនៅឆ្នាំ ២០១០។

**១. ដែនកំណត់**

- អ្នកផ្តល់បទសម្ភាសក្នុងការស្រាវជ្រាវនេះ មិនមែនធ្វើឡើងដោយ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ទេ ដោយសារចំណេះដឹងមូលដ្ឋានរបស់ អ្នកទាំងនោះមានកម្រិត។ ទោះបីជាពួកគេជាអ្នកផ្តល់បទសម្ភាសដ៏សក្តិសមបំផុតក៏ដោយ ប៉ុន្តែភាគច្រើននៃពួកគេ មិន

អាចអាន និងសរសេរបាន។ អាស្រ័យហេតុនេះការសម្ភាសត្រូវបានធ្វើឡើងជាមួយនិស្សិតវិទ្យាសាស្ត្រសង្គម និងសុខាភិបាលក៏ដូចជាមន្ត្រីសុខាភិបាលវិញ។

- ការសម្ភាសនេះភាគច្រើនត្រូវរៀបចំដោយអ្នកសម្របសម្រួលដែលជាតំណាងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ថ្នាក់ខេត្ត។ ក្នុងករណីខ្លះអ្នកផ្តល់សម្ភាសភាគច្រើនមានទំនាក់ទំនងទៅនឹងបណ្តាមូលដ្ឋានរបស់ខ្លួន។
- ជាទូទៅអ្នករកស៊ីផ្លូវភេទ ត្រូវបានរកឃើញថាខ្លួនចាំបាច់ត្រូវផ្តល់ចម្លើយដែល "ត្រឹមត្រូវ" ឬ ចម្លើយដែលសង្គមអាចទទួលយកបានដូចជា ៖
    - រយៈពេលប្រកបរបរផ្លូវភេទៈ ជាធម្មតា អ្នករកស៊ីផ្លូវភេទ ច្រើននិយាយថា ខ្លួនទើបតែចាប់ផ្តើមប្រកបរបររកស៊ីផ្លូវភេទ។
    - បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ទំនងជាមិនអាចចងចាំព្រឹត្តការណ៍ដែលបានកើតឡើង ក្នុងឆ្នាំ២០០៧ (ឧទាហរណ៍ ការបម្លាស់ទី ការចាប់ខ្លួន ការប្រើសេវាជំងឺកាមរោគ និងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់)
    - អ្នករកស៊ីផ្លូវភេទមួយចំនួន មិនអាចនិយាយការពិតអំពីប្រាក់ចំណូលដែលត្រូវចែកជាមួយម្ចាស់បន្ទប់ដែលធ្លាប់ជាអតីតម្ចាស់របស់ខ្លួនទេ។
- អ្នករកស៊ីផ្លូវភេទទាំងអស់ ដែលបានចូលរួមក្នុងការស្រាវជ្រាវសកម្មភាពនេះ ហាក់បីដូចជាមានអាយុលើសពី ១៨ឆ្នាំឡើងទោះបីជាការពិនិត្យផ្ទាល់នៅកន្លែងកម្សាន្ត យើងសង្កេតឃើញថាក្មេងស្រីហាក់បីដូចជាមានអាយុតិចជាងនេះក៏ដោយ។ ការសម្ភាសជាមួយយុវវ័យដែលធ្វើការក្នុងមុខរបរផ្លូវភេទពិតជាមានការលំបាក ជាពិសេសការសួរសំណួរដ៏រសើបដែលទាក់ទងនឹងជីវិតឯកជនរបស់ពួកគេ។

# IV. លទ្ធផល

**គោលបំណង ១: សិទ្ធិទទួលបានការថែទាំសម្រាប់** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រលាញ់បុរស និងស្រីស្រស់

## ១. សង្គម-សេដ្ឋកិច្ច

*១.១. អាយុអ្នកផ្តល់សម្ភាស*

ស្ត្រីជាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ជាមធ្យមមានអាយុតិចជាង បុរសស្រឡាញ់បុរស និងស្រីស្រស់មួយឆ្នាំ។ ចំណុចកត់សម្គាល់ដ៏គួរឱ្យចាប់អារម្មណ៍គឺថាទាំងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់មានអាយុច្រើនជាងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់នៅតាមបណ្តាខេត្តចំនួន៣ទៀត។ ក្រៅពីនេះគួរចងចាំថាការអង្កេតនេះបានរកឃើញថាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយចំនួន ៣៥ នាក់ (ឬ៣.៤ភាគរយ) មានអាយុតិចជាង ១៨ឆ្នាំ។ ក្នុងចំណោមយុវវ័យចំនួន ៣៥នាក់ មាន ២២នាក់ បានសារភាពថា ខ្លួនបានទទួលប្រាក់ពីរបរផ្លូវភេទ។

**តារាង ៣ : អាយុជាមធ្យមរបស់**បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករក ស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់

| | ខេត្តសៀមរាប | ខេត្តបន្ទាយមានជ័យ | ខេត្តព្រះសីហនុ | រាជធានីភ្នំពេញ | សរុប |
|---|---|---|---|---|---|
| ស្ត្រីរកស៊ីដោយ ផ្ទាល់ និងដោយប្រ យោល | 24 | 23 | 24 | 28 | 25 |
| បុរសស្រឡាញ់ បុរស | 21 | 23 | 24 | 25 | 24 |
| ស្រីស្រស់ | 23 | 25 | 24 | 25 | 24 |

*១.២. ស្ថានភាពអាពាហ៍ពិពាហ៍*

ភាគរយនៃស្ត្រីជាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនៅលីវ នៅខេត្តសៀមរាប និងខេត្តព្រះសីហនុមានអត្រាស្រដៀងគ្នាពោលគឺខេត្តសៀមរាប៣៣ភាគរយ និងខេត្តព្រះសីហនុ ៣១ភាគរយ។ ភាគរយរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនៅលីវ នៅខេត្តបន្ទាយមានជ័យមានអត្រាខ្ពស់បំផុត ដោយឡែកភាគរយបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនៅលីវនៅទីក្រុងភ្នំពេញ មានអត្រាតិចបំផុត។




| | សៀមរាប EW/SW | សៀមរាប MSM/អ្នក | បន្ទាយ EW/SW | បន្ទាយ MSM/អ្នក | ព្រះសីហនុ EW/SW | ព្រះសីហនុ MSM/អ្នក | ភ្នំពេញ EW/SW | ភ្នំពេញ MSM/អ្នក | EW/SW ទាំងអស , | MSM/ ស្រីស្រស់ , |
|---|---|---|---|---|---|---|---|---|---|---|
| រស់នៅជាមួយគ្នាដោយមិនរៀបការ | 35.04% | 0.00% | 36.00% | 1.72% | 31.98% | 0.00% | 20.81% | 3.68% | 29.93% | 1.69% |
| មេម៉ាយ/ពោះម៉ាយ | 4.74% | 0.63% | 5.60% | 0.00% | 18.02% | 0.00% | 17.30% | 3.16% | 11.74% | 1.18% |
| រស់នៅជាមួយគ្នាដោយមិនរៀបការ | 6.20% | 6.25% | 8.00% | 7.47% | 13.06% | 17.91% | 24.59% | 3.68% | 14.07% | 7.11% |
| .មេម៉ាយ/ពោះម៉ាយ | 20.80% | 4.38% | 2.80% | 3.45% | 5.86% | 1.49% | 16.49% | 5.79% | 12.37% | 4.23% |
| រៀបការ | 33.21% | 88.75% | 47.60% | 87.36% | 31.08% | 80.60% | 20.81% | 83.68% | 31.90% | 85.79% |

***រូប ៤ : ស្ថានភាពអាពាហ៍ពិពាហ៍របស់*** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករក ស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់

ជាទូទៅអ្នកផ្ដល់សម្ភាសជាបុរសស្រឡាញ់បុរស និងស្រីស្រស់នៅលីវមានអត្រា ៨៥,៨ភាគរយរស់នៅ ជាមួយគ្នា ៧,១ភាគរយ រៀបការរួច ៤,២ភាគរយ លែងលះ និងរស់នៅបែបគ្នា ១,៧ភាគរយ និងមេម៉ាយ និងពោះម៉ាយភាគរយ។ បើប្រៀបធៀបភាគរយស្ត្រីជា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ចំពោះទីតាំងដែលជ្រើសរើសមកសិក្សាទាំងអស់ ឃើញថាស្ថានភាពនៅលីវរបស់ក្រុមទាំងពីរនេះមានភាគរយខ្ពស់ដូចគ្នា។

*១.៣. កម្រិតវប្បធម៌*

ជាទូទៅ កម្រិតវប្បធម៌របស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយក្នុងតំបន់ទាំង ៤ មានកម្រិតទាប។ ភាគរយនៃការចូលរៀន (គិតជាឆ្នាំ) មានកម្រិតទាប។ កម្រិតវប្បធម៌របស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ក្នុងខេត្តសៀមរាបរៀនបានត្រឹម៤,២៧ឆ្នាំ ខេត្តបន្ទាយមានជ័យ ៤,៧៣ ខេត្តព្រះសីហនុ ៣,៣៤ និងរាជធានីភ្នំពេញ ៣,៣៨។ ហេតុដូច្នេះបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយភាគច្រើនរៀនបានត្រឹមបឋមសិក្សា។ ការវិភាគលើប្រភេទការងារបង្ហាញថាអ្នករកស៊ីផ្លូវភេទដោយផ្ទាល់ និងដោយឯករាជ្យ មានកម្រិតវប្បធម៌ទាបបំផុត ពោលគឺអ្នករកស៊ីផ្លូវភេទដោយផ្ទាល់រៀនបានត្រឹម២,៧៣ឆ្នាំ និងអ្នករកស៊ីផ្លូវភេទឯករាជ្យបានត្រឹម ២,៨៧ឆ្នាំ។ ចំណែកឯស្ត្រីខារ៉ាអូខេ និងស្ត្រីបំរើស្រាបៀរ ក៏មានការអប់រំក្នុងកម្រិតស្រដៀងគ្នានេះដែរ ពោលគឺស្ត្រីខារ៉ាអូខេរៀនបានត្រឹម៤,៦៣ឆ្នាំ និងស្ត្រីបំរើស្រាបៀររៀនបានត្រឹម៤,២៩ឆ្នាំ។ ដោយឡែកកម្រិតនៃការអប់រំរបស់ស្ត្រីម៉ាស្សាស្ថិតនៅចន្លោះក្រុម អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ និងអ្នករកស៊ីផ្លូវភេទឯករាជ្យ។




| | ខេត្តសៀមរាប | ខេត្តបន្ទាយមានជ័យ | ខេត្តព្រះសីហនុ | រាជធានីភ្នំពេញ | សរុប |
|---|---|---|---|---|---|
| ស្រីជា EWs/SWs | 4.27 | 4.73 | 3.34 | 3.38 | 3.9 |
| MSM/ស្រីស្រស់ | 9 | 9 | 8 | 9 | 9 |

**រូប ៥ : កម្រិតវប្បធម៌របស់** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ **តាមតំបន់**

ជាធម្យមបុរសស្រឡាញ់បុរស និងស្រីស្រស់រស់នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ រៀនចប់ត្រឹម៩ឆ្នាំ ដោយឡែកបុរសស្រឡាញ់បុរស និងស្រីស្រស់រស់នៅខេត្តព្រះសីហនុរៀនបានត្រឹម៨ឆ្នាំ។ គួរកត់សម្គាល់ផងដែរថាបុរសស្រឡាញ់បុរសរៀនចប់ត្រឹម៩ឆ្នាំ ប៉ុន្តែស្រីស្រស់រៀនចប់ត្រឹម៨ឆ្នាំ។




| | មិនមានការអប់រំ | បឋមសិក្សា | មធ្យមសិក្សាបឋម ភូមិ | មធ្យមសិក្សាទុតិយភូមិ | សាកលវិទ្យាល័យ |
|---|---|---|---|---|---|
| MSM/ ស្រីស្រស់ | 2.88% | 21.49% | 35.36% | 35.36% | 4.91% |
| EW/SW | 26.79% | 50.72% | 18.55% | 3.94% | 0.00% |

**រូប ៦ : កម្រិតវប្បធម៌របស់** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ **តាមកម្រិតដែលបានរៀនចប់**

យោងតាមរូបខាងលើដែលបង្ហាញប្រាប់ថា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ២៧ភាគរយ មិនបានទទួលការសិក្សាគឺជារឿងគួរឱ្យភ្ញាក់ផ្អើលណាស់។ ដោយសារអ្នកទាំងនោះអាចចេះត្រឹមអាន និងសរសេរបាន ដូច្នេះឱកាសការងារសម្រាប់អ្នកទាំងនោះមានកម្រិតតិចតួចណាស់លើកលែងតែការងារដែលមិនត្រូវការជំនាញ ច្បាស់លាស់។

*១.៤. រយៈពេលធ្វើការងារ*

ការវិភាគលើប្រភេទការងារបង្ហាញថា ស្ត្រីម៉ាស្សា និងអ្នករកស៊ីផ្លូវភេទឯករាជ្យធ្វើការបានយូរជាងក្រុមដទៃទៀតពោលគឺស្មើរតែ៣៦ខែ។ ចំណែកឯស្ត្រីខារ៉ាអូខេ និងស្ត្រីបំរើស្រាបៀរ ក៏ធ្វើការក្នុងរយៈពេល ស្រដៀងគ្នានេះដែរ ពោលគឺ២០ខែ។ ជាមធ្យមអ្នករកស៊ីផ្លូវភេទឯករាជ្យបាននឹងកំពុងធ្វើការងាររបស់ខ្លួនអស់រយៈពេល ៣០ឆ្នាំ។




**រូប ៧ : រយៈពេលធ្វើការរបស់** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករក ស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់

ទិន្នន័យដែលបានប្រមូលចេញពីខេត្តក្រុងទាំង៤ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។ ក្រុមស្រីស្រស់បាននឹងកំពុងធ្វើការអស់រយៈពេល ៤០ខែ ចំណែកឯបុរសស្រឡាញ់បុរសបាននឹងកំពុងធ្វើការអស់រយៈពេល ១៥ ខែ ប៉ុណ្ណោះ។

*១.៥. ការងារកន្លងមក*

ក្នុងចំណោមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ទាំងអស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយច្រើនជាងមួយភាគបីមិនមានការងារធ្វើហើយ១៨ភាគរយនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយធ្លាប់ធ្វើការរោងចក្រ។ ការវិភាគតាមតំបន់បង្ហាញថាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ក្នុងចំនួនដ៏ច្រើន នៅរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ឈប់ធ្វើការងាររោងចក្រ ក្នុងនោះភាគរយនៃស្ត្រីម៉ាស្សាមានអត្រា២៥ភាគរយ ស្ត្រីបំរើស្រាបៀរ ២៤ភាគរយ និងស្ត្រីខារ៉ាអូខេ ២០ភាគរយ។




| | អ្នករកស៊ីផ្លូវភេទផ្ទាល់ | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្រីផ្សព្វផ្សាយស្រាបៀរ | ស្ត្រីរកស៊ីផ្លូវភេទទាំងអស់ | MSM | ស្រីស្រស់ | ស្រីស្រស់ទាំងអស់ |
|---|---|---|---|---|---|---|---|---|---|
| ផ្សេងៗ | 40.24% | 26.02% | 36.51% | 25.43% | 43.33% | 31.54% | 16.02% | 22.27% | 18.44% |
| មិនមានការងារធ្វើ | 36.18% | 30.08% | 36.51% | 34.03% | 22.22% | 33.24% | 18.78% | 24.89% | 21.15% |
| ធ្វើការរោងចក្រ | 12.20% | 25.20% | 8.73% | 20.27% | 24.44% | 18.19% | 8.56% | 6.55% | 7.78% |
| ការងារបម្រើការសប្បាយ | 8.94% | 12.20% | 13.49% | 10.52% | 3.33% | 10.04% | 7.18% | 6.99% | 7.11% |
| សិក្សា | 2.44% | 6.50% | 4.76% | 9.75% | 6.67% | 6.99% | 49.45% | 39.30% | 45.52% |

**រូប ៨ :ការងារកន្លងមករបស់** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករក ស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់

បុរសស្រឡាញ់បុរស និងស្រីស្រស់ ពី៤០-៥០ភាគរយ បានចូលរៀន ចំណែកឯបុរសស្រឡាញ់បុរស និងស្រីស្រស់២១ភាគរយគ្មានការងារធ្វើ។ មានបុរសស្រឡាញ់បុរស និងស្រីស្រស់៧ភាគរយប៉ុណ្ណោះ ដែលធ្លាប់ធ្វើ ការងារនៅកន្លែងកម្សាន្ត។

*១.៦. ចំនួនអ្នកនៅក្នុងបន្ទុក*

បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ជាស្ត្រីមានចំនួនអ្នកក្នុងបន្ទុកជាមធ្យម៣,១២នាក់ ចំណែកឯបុរសស្រឡាញ់បុរស និងស្រីស្រស់មានចំនួន ត្រឹមតែ ២នាក់ប៉ុណ្ណោះ។




**រូប ៩ : ចំនួនអ្នកនៅក្នុងបន្ទុកជាមធ្យមរបស់**បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់

### *១.៧. ហេតុផលសំខាន់ៗដែលបណ្តាលឱ្យបម្រើការងារក្នុងសេវាបម្រើការសប្បាយ*

បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ បង្ហាញហេតុផលទៅនឹងសំណួរមួយចំនួនដែលជំរុញឱ្យអ្នកទាំងនោះបម្រើការងារក្នុងមុខរបរផ្លូវភេទ។ ជាមធ្យម បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយម្នាក់ៗផ្តល់ភាគច្រើនផ្តល់នូវចម្លើយ ២ចំពោះសំណួរមួយ។

**តារាង ៤ : ហេតុផលសំខាន់ៗនៃការធ្វើការងារក្នុងគ្រឹះស្ថានកំសាន្តសប្បាយ**

| **ហេតុផលសំខាន់ៗនៃការធ្វើការងារក្នុងគ្រឹះស្ថានកំសាន្តសប្បាយ** | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | | **ស្ត្រីម៉ាស្សា** | | ស្ត្រីរកស៊ីផ្លូវភេទ | | **ស្ត្រីខារ៉ាអូខេ** | | ស្ត្រីបំរើស្រាបៀរ | | **EWs ទាំងអស់** | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| អ្នកជំទៃល្បួងលោម | 15 | 4.55% | 3 | 1.14% | 26 | 13.76% | 36 | 5.09% | 12 | 10.08% | 94 | 6.21% |
| លក់ឱ្យផ្ទះបន | 6 | 1.82% | 1 | 0.57% | 1 | 0.53% | 4 | 0.58% | 0 | 0.00% | 12 | 0.79% |
| ត្រូវគេចាប់រំលោភ | 2 | 0.61% | 1 | 0.57% | 4 | 1.59% | 1 | 0.15% | 1 | 0.84% | 9 | 0.59% |
| គ្រួសារមានបញ្ហា | 139 | 42.12% | 78 | 44.57% | 78 | 41.27% | 262 | 38.08% | 46 | 38.66% | 608 | 40.16% |
| ស្ម័គ្រចិត្តដោយខ្លួនឯង | 166 | 50.30% | 93 | 53.14% | 77 | 40.74% | 381 | 55.38% | 60 | 50.42% | 780 | 51.52% |
| ផ្សេងៗ | 2 | 0.61% | 0 | 0.00% | 4 | 2.12% | 5 | 0.73% | 0 | 0.00% | 11 | 0.73% |
| សរុប | 330 | 100% | 176 | 100% | 190 | 100% | 689 | 100% | 119 | 100% | 1514 | 100% |

ក្នុងចំណោមកត្តាអវិជ្ជមានទាំងនេះគេសង្កេតឃើញថាការចាប់រំលោភជាហេតុផលចម្បងមួយសម្រាប់តែអ្នករកស៊ីផ្លូវភេទដោយផ្ទាល់ប៉ុណ្ណោះ ចំណែកឯការជួញដូរផ្លូវភេទ មានកម្រិតទាបក្នុងចំណោមក្រុមផ្សេងៗគ្នា (តិចជាង ១ភាគរយ)។ ភាគរយនៃបុគ្គលិកបម្រើគ្រឹះស្ថានកំសាន្តសប្បាយ ដែលបានលួងលោមដោយអ្នកដទៃ មិនសូវមានសារៈសំខាន់សម្រាប់គ្រប់ប្រភេទនៃការងារឡើយ លើកលែងតែអ្នករកស៊ីផ្លូវភេទឯករាជ្យមានចំនួន១៤ភាគរយ និងស្ត្រីបំរើស្រាបៀរ ១០ភាគរយ។

ទោះបីជាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ក្នុងចំនួនពាក់កណ្តាលឆ្លើយថា ខ្លួនសម្រេចចិត្តធ្វើការងារនេះដោយស្ម័គ្រចិត្តក៏ដោយ ប៉ុន្តែក្នុងការវិភាគបែបស៊ីជម្រៅត្រូវបង្ហាញឱ្យបានលម្អិតអំពីបញ្ហាដែលជំរុញឱ្យអ្នកទាំង នោះបង្ខំចិត្តធ្វើការក្នុងមុខរបរផ្លូវភេទនោះ ក៏ដោយសារតែដើម្បីការរស់រានមានជីវិត។

ការវិភាគរួមមួយលើបញ្ហាគ្រួសារ (ឪពុកម្តាយលែងលះ ជំពាក់បំណុល និងភាពក្រីក្រ ។ល។) ជាហេតុផលមួយ ដែលតម្រូវឱ្យបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ជ្រើសយកការលក់ខ្លួនដើម្បីធ្វើជាមុខរបរចិញ្ចឹមជីវិត។



ផ្សេងៗ

ស្ម័គ្រចិត្តដោយខ្លួនឯង

| | រកស៊ីផ្លូវភេទ ដោយផ្ទាល់ | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្ត្រីឃោសនាស្រាបៀរ | សរុប |
|---|---|---|---|---|---|---|
| បញ្ហាគ្រួសារ | 0.61% | 0.00% | 2.12% | 0.73% | 0.00% | 0.73% |
| ត្រូវគេចាប់រំលោភ | 50.30% | 53.14% | 40.74% | 55.38% | 50.42% | 51.52% |
| លក់ទៅឱ្យផ្ទះបន | 42.12% | 44.57% | 41.27% | 38.08% | 38.66% | 40.16% |
| អ្នកដទៃលួងលោម | 0.61% | 0.57% | 1.59% | 0.15% | 0.84% | 0.59% |
| | 1.82% | 0.57% | 0.53% | 0.58% | 0.00% | 0.79% |
| | 4.55% | 1.14% | 13.76% | 5.09% | 10.08% | 6.21% |

**រូប ១០ : ហេតុផលសំខាន់ៗបណ្តាលឱ្យ**បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ប្រកបមុខរបរ **ផ្លូវភេទ**

សំណួរនេះ មិនបានយកទៅសួរក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ទេ។

១. *តើ* បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករក ស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ *ដំណើរការរបរផ្លូវភេទរបស់ខ្លួនបានយ៉ាងដូចម្តេច?*

បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយភាគច្រើន (៩ភាគរយ) អះអាងថា ខ្លួនដំណើរការការងារផ្លូវភេទដោយ ខ្លួនឯង។ ចំណែកឯអ្នករកស៊ីផ្លូវភេទដោយផ្ទាល់ ស្ត្រីម៉ាស្សា (៧ភាគរយ) និងស្ត្រីខារ៉ាអូខេ (៥ភាគរយ) មានអ្នកញ៉ោះញ៉ង់ និងមេ៉យ៉ែមជាអ្នកជួយគាំទ្រដល់ការងាររបស់ពួកគេ។ អ្នករកស៊ីផ្លូវភេទឯករាជ្យ និងស្ត្រីបំរើស្រាបៀរ ពឹងផ្អែកលើខ្លួនឯងទាំងស្រុងដើម្បីចាត់ចែងការងាររបស់ខ្លួន។ ជាទូទៅបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយត្រឹម៩ភាគរយប៉ុណ្ណោះ ដែលមានអ្នកញ៉ោះញ៉ង់ និងមេ៉យ៉ែម ជាអ្នកចាំជួយដល់ការងាររបស់ពួកគេ។ ការវិភាគតាមតំបន់បង្ហាញថាតួលេខនៅខេត្តបន្ទាយមានជ័យ មានកម្រិតខ្ពស់បំផុតពោលគឺ ៩ភាគរយ និងខេត្តព្រះសីហនុមានកម្រិត ទាបបំផុត ពោលគឺ ២ភាគរយ។

ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ សក់ខ្លី (៥ភាគរយ) ហាក់ដូចជាដំណើរការការងាររបស់ខ្លួនជាមួយអ្នកញ៉ោះញ៉ង់ និងមេ៉យ៉ែមច្រើនជាងស្រីស្រស់ (សក់វែង) (១,៣៨ភាគរយ)។




| | DSW | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | អ្នករកស៊ីផ្លូវភេទទាំងអស់ | MSM | ស្រីស្រស់ | ស្រីស្រស់ទាំងអស់ |
|---|---|---|---|---|---|---|---|---|---|
| ស្ម័គ្រចិត្តដោយខ្លួនឯង | 91.46 | 92.68 | 100% | 94.46 | 100% | 91.46 | 94.48 | 98.62 | 95.77 |
| មានអ្នកញ៉ោះញ៉ង់/មេ៉យ៉ែម | 8.54% | 7.32% | 0.00% | 5.54% | 0% | 8.54% | 5.52% | 1.38% | 4.23% |

**រូប ១១ : មធ្យោបាយក្នុងការដំណើរការការងារផ្លូវភេទរបស់ អ្នកបម្រើសេវាកំសាន្ត/អ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់បុរស,ស្រីស្រស់**

អ្នករកស៊ីផ្លូវភេទដោយផ្ទាល់មួយចំនួន មិនអាចនិយាយការពិតថា ចំណូលបានមកពីការងាររបស់ខ្លួន ត្រូវចែកជាមួយម្ចាស់បន្ទប់ ដែលធ្លាប់អតីតម្ចាស់របស់ខ្លួនឡើយ។

២. *កន្លែងមួយចំនួនដែល* បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និង ស្រីស្រស់ *ទាក់ទាញអតិថិជនរបស់ខ្លួន នៅអំឡុងពេល១២ខែចុងក្រោយ*

**ក្នុងចំណោម**បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ មិនត្រឹមតែប្រើប្រាស់ផ្ទះបនធ្វើជាកន្លែងទាក់ទាញ អតិថិជនរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែអ្នកទាំងនោះក៏អាចប្រើកន្លែងសាធារណៈ និងកន្លែងឯកជនដទៃទៀត ដើម្បីទាក់ទាញអតិថិជនរបស់ខ្លួនផងដែរ។ អ្នករកស៊ីផ្លូវភេទឯករាជ្យ ប្រើសួនច្បារ និងកន្លែងសាធារណៈ ច្រើនជាងក្រុមដទៃទៀត ប៉ុន្តែក្រុមនេះក៏ប្រើផ្ទះបន និងកន្លែងឯកជនដទៃទៀតផងដែរ។




| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ផ្សេងៗ | 0.41% | 2.44% | 0.00% | 0.19% | 2.22% | 0.72% | 3.87% | 4.80% | 4.23% |
| ហាងកាត់សក់ | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 1.38% | 0.44% | 1.02% |
| ភោជនីយដ្ឋាន/បៀរហ្គាឌិន | 0.41% | 1.63% | 3.17% | 3.06% | 65.56% | 7.62% | 2.21% | 1.31% | 1.86% |
| បារ/ក្លិប | 0.00% | 0.81% | 3.17% | 0.96% | 11.11% | 1.97% | 6.35% | 17.90% | 10.83% |
| កន្លែងឯកជន | 17.48% | 1.63% | 18.25% | 0.57% | 1.11% | 6.45% | 18.23% | 10.48% | 15.23% |
| ខារ៉ាអូខេ | 1.22% | 12.20% | 3.97% | 92.73% | 18.89% | 47.22% | 3.59% | 1.75% | 2.88% |
| កន្លែងម៉ាស្សា | 0.00% | 74.80% | 0.00% | 0.96% | 0.00% | 8.69% | 1.38% | 0.44% | |

**រូប ១២ : កន្លែងមួយចំនួនដើម្បីទាក់ទាញអតិថិជននៅក្នុងរយៈពេល ១២ខែចុងក្រោយ**

ស្ត្រីខារ៉ាអូខេបានយកអតិថិជនរបស់ខ្លួនពីហាងខារ៉ាអូខេដែលជាកន្លែងរបស់ខ្លួនធ្វើការដោយឡែកស្ត្រី បំរើស្រាបៀរទទួលបានជោគជ័យក្នុងការចរចាជាមួយអតិថិជនរបស់ខ្លួនក្នុងភោជនីយដ្ឋាន និងបៀរហ្គាឌិន ដែលជាកន្លែង ខ្លួនបំរើស្រាបៀរ។ ជាធម្មតាស្ត្រីម៉ាស្សា ស្ថិតក្នុងចន្លោះក្រុមទាំងពីរខាងលើនេះ។ អតិថិជនភាគច្រើនរបស់ស្ត្រីម៉ាស្សា គឺយកចេញពីហាងម៉ាស្សា ប៉ុន្តែស្ត្រីម៉ាស្សាក៏អាចទៅរកអតិថិជនរបស់ខ្លួននៅកន្លែងសាធារណៈ និងហាងខារ៉ាអូខេផងដែរ។

តាមរយៈការវិភាគអំពីទីតាំងបង្ហាញថាក្រៅពីរាជធានីភ្នំពេញ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ភាគច្រើនស្វែងរកអតិថិជនរបស់ខ្លួន នៅហាងខារ៉ាអូខេ ភោជនីយដ្ឋាន និងបៀរហ្គាឌិន។ សួន និងកន្លែងសាធារណៈ ជាកន្លែងដែលអ្នករកស៊ីផ្លូវភេទឯករាជ្យនៅរាជធានីភ្នំពេញ (២៩ភាគរយ) និងខេត្តបន្ទាយមានជ័យ (១ភាគរយ) ចូលចិត្តទៅ។

**ក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់** កន្លែងដែលអាចទាក់ទាញអតិថិជនរបស់ខ្លួន គឺនៅសួន កន្លែងឯកជន បារ និងក្លឹប។ បុរសស្រឡាញ់បុរស និងស្រីស្រស់ក្នុងចំនួនតិចតួចបំផុតដែលស្វែងរកអតិថិជនរបស់ខ្លួននៅហាងកាត់សក់ ភោជនីយដ្ឋាន និងបៀរហ្គាឌិន។

*៣. ចំនួនដងនៃការរួមភេទរបស់ស្ត្រីជា* បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករក ស៊ីផ្លូវភេទ *ជាមួយដៃគូផ្សេងៗគ្នានៅក្នុងអំឡុងសប្តាហ៍មុន*

គួរកត់សម្គាល់ថាផ្អែកលើចម្លើយទៅនឹងសំណួរលេខ ១២ របស់អ្នកផ្តល់សម្ភាស អ្នករកស៊ីផ្លូវភេទឯករាជ្យ (១៥,៧២) មានដៃគូរួមភេទផ្សេងៗគ្នាច្រើនជាងអ្នករកស៊ីផ្លូវភេទដោយប្រយោល (២,៦៦)។ អ្នករកស៊ីផ្លូវភេទឯករាជ្យ មានចំនួននៃការរួមភេទក្នុងកម្រិតមួយខ្ពស់ក្នុងមួយសប្តាហ៍ (ស្មើរតែ ១៩នាក់) ធៀបនឹងក្រុមដទៃទៀត។

**តារាង ៥ : ចំនួនការរួមភេទសរុបរបស់** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ **ជាមួយដៃគូផ្សេងៗគ្នាកាលពីសប្តាហ៍មុន**

| ប្រភេទការងារ | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | | អ្នករកស៊ីផ្លូវភេទដោយប្រយោល | | | សរុប |
|---|---|---|---|---|---|---|
| | DSW | FSW | ស្ត្រីម៉ាស្សា | ស្ត្រីខារ៉ាអូខេ | BPG | EW/SWs ទាំងអស់ |
| ចំនួនដងសរុបនៃការរួមភេទជាមួយស្វាមី/ដៃគូ | 57 | 118 | 77 | 220 | 41 | 513 |
| ចំនួនដងសរុបនៃការរួមភេទជាមួយគូសង្សារ | 54 | 77 | 95 | 234 | 83 | 543 |
| អតិថិជនដែលផ្តល់ប្រាក់កម្រៃ | 4552 | 992 | 244 | 824 | 143 | 6755 |
| ចំនួនដងសរុបនៃការរួមភេទជាមួយដៃគូផ្សេងៗគ្នាក្នុងមួយសប្តាហ៍ | 4663 | 1187 | 416 | 1278 | 267 | 7811 |
| **ចំនួន EWs/SWs សរុប** | **246** | **126** | **123** | **523** | **90** | **1108** |
| ចំនួនដងជាមធ្យមនៃការរួមភេទជាមួយដៃគូផ្សេងៗគ្នាកាលពីសប្តាហ៍មុន | 18.95 | 9.42 | 3.38 | 2.44 | 2.96 | 7.05 |
| ចំនួនដៃគូជាមធ្យមកាលពីសប្តាហ៍មុន | 15.72 | | 2.66 | | | 7.05 |

ប្រភព : ការស្រាវជ្រាវសកម្មភាព ខែវិច្ឆិកា ឆ្នាំ២០០៨

ចំនួនដងនៃការរួមភេទជាមួយដៃគូផ្សេងៗគ្នាក្នុងអំឡុងសប្តាហ៍មុនរបស់អ្នករកស៊ីផ្លូវភេទដោយផ្ទាល់គឺ ១៨,៩៥ ដង អ្នករកស៊ីផ្លូវភេទឯករាជ្យ ៩,៤២ដង ស្ត្រីម៉ាស្សា ៣,៣៨ដង ស្ត្រីខារ៉ាអូខេ ២,២៤ដង និងស្ត្រីបំរើស្រាបៀរ ២,៩៦ដង។ គួរកត់សម្គាល់ថាចំនួនដៃគូជាមធ្យមរបស់អ្នកដែលពាក់ព័ន្ធនឹងមុខរបរផ្លូវភេទដោយផ្ទាល់គឺ ១៩,៧២នាក់ ដោយឡែកអ្នកដែលពាក់ព័ន្ធនឹងការរកស៊ីផ្លូវភេទដោយប្រយោល គឺមានត្រឹមតែ ២,៦៦នាក់។

ក្រៅពីនេះគួរស្វែងយល់ថា :

- អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ អ្នករកស៊ីផ្លូវភេទឯករាជ្យ មានភាគរយនៃការរួមភេទជាមួយអតិថិជនប្រមាណ ៩៧ ភាគរយ ដូចគ្នាកាលពីសប្តាហ៍មុន។
- ការរួមភេទជាមួយអតិថិជនរបស់ស្ត្រីម៉ាស្សាគឺ ៥៨ភាគរយ ស្ត្រីខារ៉ាអូខេ ៦៤ភាគរយ និងស្ត្រីបំរើស្រាបៀរ ៥៣ភាគរយ។
- សម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទជាស្ត្រី ការរួមភេទជាមធ្យោបាយដើម្បីការរស់រានមានជីវិត ដោយសារ ៨៦ភាគរយនៃ អ្នកទាំងនោះ បានរួមភេទជាមួយអតិថិជនដែលផ្តល់កម្រៃដល់ពួកគេ (ជាមួយស្វាមី ឬដៃគូរស់នៅជាមួយ គ្នាដោយមិនបានរៀបការ មានត្រឹមតែ ៧ភាគរយប៉ុណ្ណោះ និងជាមួយគូសង្សារ មានត្រឹមតែ ៧ភាគរយ ដូចគ្នា)។




| | DSW | FSW | ស្ត្រីម៉ាស្សា | ស្ត្រីខារ៉ាអូខេ | BPG | EW ទាំងអស់ |
|---|---|---|---|---|---|---|
| អតិថិជន | 97.62% | 83.57% | 58.65% | 64.48% | 53.56% | 86.48% |
| គូសង្សារ | 1.16% | 6.49% | 22.84% | 18.31% | 31.09% | 6.95% |
| ស្វាមី/អ្នករស់នៅជាមួយគ្នាដោយមិនរៀបការ | 1.22% | 9.94% | 18.51% | 17.21% | 15.36% | 6.57% |

**ជាមួយដៃគូផ្សេងៗគ្នាកាលពី សប្តាហ៍មុន**

*៥. ចំនួនដងនៃការរួមភេទរបស់ បុរសស្រលាញ់បុរស និងស្រីស្រស់ ជាមួយដៃគូផ្សេងៗគ្នាកាលពីសប្តាហ៍មុន*

កាលពីសប្តាហ៍មុនបុរសស្រឡាញ់បុរស (សក់ខ្លី) ចំនួន ៣៦២នាក់ បានរួមភេទចំនួន ១៤២៧ដង ភាគច្រើនជាមួយដៃគូបុរសដែលមានបង់ប្រាក់ (៤៧ភាគរយ) និងដៃគូបុរសដោយមិនមានបង់ប្រាក់ (៣៩ភាគរយ)។ ការរួមភេទជាមធ្យមជាមួយក្រុមដៃគូសំខាន់ទាំងពីរនេះពោលគឺក្រុមដៃគូបុរសដែលមានបង់ប្រាក់គឺ ១,៨៧ និងក្រុមដៃគូបុរសដែលមិនមានបង់ប្រាក់គឺ ១,៥៣។

កាលពីសប្តាហ៍មុនស្រីស្រស់ (សក់វែង) ចំនួន ២២៩នាក់ បានរួមភេទចំនួន ១៣៩៩ដង ភាគច្រើនជាមួយដៃគូបុរសដែលមានបង់ប្រាក់ (៦0ភាគរយ) និងដៃគូបុរសដោយគ្មានបង់ប្រាក់ (២៧ភាគរយ)។ ការរួមភេទជាមធ្យមជាមួយក្រុមដៃគូសំខាន់ទាំងពីរនេះ ពោលគឺក្រុមដៃគូបុរសដែលមានបង់ប្រាក់ ៣,៦៧ និងក្រុមដៃគូបុរសដែលមិនមានបង់ប្រាក់ ២,២៤។

**តារាង ៦ : ចំនួនដងនៃការរួមភេទរបស់ បុរសស្រឡាញ់បុរស និងស្រីស្រស់ ជាមួយដៃគូផ្សេងៗកាលពីសប្តាហ៍មុន**

| | បុរសដែលមិនមានបង់ប្រាក់ | បុរសដែលបង់ប្រាក់ | ស្ត្រីដែលមិនមានបង់ប្រាក់ | DSW/IDSW | បុរសស្រលាញ់បុរស | ស្រីស្រស់ | សរុប |
|---|---|---|---|---|---|---|---|
| ចំនួនដងនៃការរួមភេទរបស់ MSM ជាមួយដៃគូផ្សេងៗគ្នាកាលពីសប្តាហ៍មុន | 676 | 554 | 85 | 22 | 49 | 41 | 1427 |
| ចំនួនដងនៃការរួមភេទជាមធ្យមរបស់ MSM ជាមួយដៃគូផ្សេងៗគ្នាកាលពីសប្តាហ៍មុន | 1.87 | 1.53 | 0.23 | 0.06 | 0.14 | 0.11 | **3.94** |
| ចំនួនដងនៃការរួមភេទរបស់ស្រីស្រស់ជាមួយដៃគូផ្សេងៗគ្នាកាលពីសប្តាហ៍មុន | 840 | 513 | 6 | 2 | 38 | 0 | 1399 |
| ចំនួនដងនៃការរួមភេទជាមធ្យមរបស់ស្រីស្រស់ជាមួយដៃគូផ្សេងៗគ្នាកាលពីសប្តាហ៍មុន | 3.67 | 2.24 | 0.03 | 0.01 | 0.17 | 0.00 | **6.11** |

ប្រភព : ការស្រាវជ្រាវសកម្មភាព ខែវិច្ឆិកា ឆ្នាំ២00៨

ការរួមភេទជាមធ្យមរបស់ក្រុមបុរសស្រលាញ់បុរសជាមួយដៃគូផ្សេងៗគ្នាគឺ ៣,៩៤ និងស្រីស្រស់ ៦,១១។

លើសពីនេះទៀត គួរស្វែងយល់ថានៅអំឡុងមួយសប្តាហ៍មុនពេលសម្ភាសក្រុមបុរសស្រឡាញ់បុរស (សក់ខ្លី) ស្ទើរតែពាក់កណ្តាលបានរួមភេទជាមួយដៃគូបុរសដែលមិនបង់ប្រាក់ ចំណែកឯ ៣៩ភាគរយទៀត បានរួមភេទជាមួយបុរសដែលមានបង់ប្រាក់។




**រូប ១៤ : ភាគរយនៃការរួមភេទរបស់បុរសស្រឡាញ់បុរស (សក់ខ្លី) ជាមួយដៃគូផ្សេងៗគ្នាកាលពីសប្តាហ៍មុន**

ស្រីស្រស់ (សក់វែង) ជាងពាក់កណ្តាលបានរួមភេទជាមួយដៃគូបុរសដែលមិនបង់ប្រាក់ ចំណែកឯ ៣៧ភាគរយទៀតបានរួមភេទជាមួយបុរសដែលមានបង់ប្រាក់។




**រូប ១៥ : ភាគរយនៃការរួមភេទរបស់ស្រីស្រស់ (សក់វែង) ជាមួយដៃគូផ្សេងៗគ្នាកាលពីសប្តាហ៍មុន**

*៦. ប្រាក់ចំណូល*

ប្រាក់ចំណូលសរុបរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់គឺចាប់ពី ៩១ដុល្លាសហរដ្ឋអាមេរិកសម្រាប់បុរសស្រឡាញ់បុរស និង ១៩៧ដុល្លាសហរដ្ឋអាមេរិកសម្រាប់ស្ត្រីខារ៉ាអូខេ។

ក្នុងចំណោម បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ស្ត្រីខារ៉ាអូខេ និងស្ត្រីបំរើស្រាបៀរមានប្រាក់ចំណូលច្រើនជាងអ្នករកស៊ីផ្លូវភេទដោយផ្ទាល់ ស្ត្រីម៉ាស្សា និងអ្នករកស៊ីផ្លូវភេទឯករាជ្យ។




**រូប ១៦ : ប្រាក់ចំណូលប្រចាំខែជាមធ្យមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់**

គួរកត់សម្គាល់ថាក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់ទាំងអស់ បុរសស្រឡាញ់បុរសប្រមាណ ៦៦,៦ ភាគរយពិតជាទទួលស្គាល់ថាពួកគេបានទទួលប្រាក់ពីការលក់ផ្លូវភេទ ចំណែកឯស្រីស្រស់ប្រមាណ៨៤,៥ភាគរយក៏បានប្រាក់ពីការសេវាផ្លូវភេទផងដែរ។

**តារាង ៧ : ភាគរយនៃ** បុរសស្រឡាញ់បុរស និងស្រីស្រស់ **ដែលបានចំណូលពីសេវាផ្លូវភេទ**

| | អ្នកដែលមិនបានទទួលចំណូលពីសេវាភេទ | | អ្នកដែលទទួលបានចំណូលពីសេវាភេទ | | សរុប | |
|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| បុរសស្រឡាញ់បុរស | 121 | 33.43% | 241 | 66.57% | 362 | 100% |
| ស្រីស្រស់ | 56 | 15.47% | 173 | 84.53% | 229 | 100% |

ប្រភព : ការស្រាវជ្រាវសកម្មភាព ខែវិច្ឆិកា ឆ្នាំ២០០៨

*៧. ប្រតិបត្តិការថវិកា*

ក្នុងចំណោមប្រភេទការងារផ្សេងៗគ្នាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយជាស្ត្រីម៉ាស្សា មានបំណុលខ្ពស់ជាងគេ(១០០ដុល្លា សហរដ្ឋអាមេរិក)។ គួរចាប់អារម្មណ៍ថាការជំពាក់បំណុលអាចជាហេតុផលមួយដែលជំរុញឱ្យស្ត្រីម៉ាស្សាព្រមរួមភេទជាមួយភ្ញៀវដែលត្រូវការសេវាផ្លូវភេទ។ អ្នករកស៊ីផ្លូវភេទឯករាជ្យ ស្ត្រីខារ៉ាអូខេ និងស្ត្រីបំរើស្រាបៀរមានលំនាំ និងបរិមាណទឹកប្រាក់ដែលបានសន្សំប្រាក់ដែលផ្ញើមកផ្ទះ និងបំណុលក្នុងរូបភាពស្រដៀងគ្នា។ អ្នករកស៊ីផ្លូវភេទដោយផ្ទាល់មានបរិមាណទឹក ប្រាក់សម្រាប់សន្សំ និងផ្ញើមកផ្ទះតិចតួច ប៉ុន្តែក្រុមនេះជំពាក់បំណុលគេតិចជាងក្រុមដទៃទៀត។

ក្នុងចំណោមក្រុម បុរសស្រឡាញ់បុរស និងស្រីស្រស់បានសន្សំប្រាក់ និងផ្ញើប្រាក់មកផ្ទះបានច្រើនជាងក្រុមបុរសស្រឡាញ់បុរស ប៉ុន្តែក្រុមបុរសស្រឡាញ់បុរសជំពាក់បំណុលគេតិចជាងក្រុមស្រីស្រស់ឆ្ងាយណាស់។




| | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | អ្នករកស៊ីផ្លូវភេទទាំងអស់ | MSM | ស្រីស្រស់ | MSM/ស្រីស្រស់ទាំងអស់ |
|---|---|---|---|---|---|---|---|---|---|
| សន្សំប្រាក់ | 19.27 | 14.23 | 26.08 | 28.09 | 26.36 | 24.43 | 12.61 | 27.26 | 18.29 |
| ផ្ញើប្រាក់ | 31.98 | 29.63 | 30.93 | 42.72 | 50.27 | 38.14 | 15.5 | 28.78 | 20.65 |
| ខ្ចីប្រាក់ | 30.17 | 100.53 | 42.66 | 36.61 | 41.78 | 44.35 | 7.64 | 50.68 | 24.35 |

**រូប ១៦ : ប្រតិបត្តិការប្រាក់កាសរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ កាលពីខែមុន**

### *៨. ការស្រវឹងដែលធ្វើឱ្យមិនអាចគ្រប់គ្រងខ្លួនបាន*

ការប្រើគ្រឿងស្រវឹងហួសហេតុអាចនាំឱ្យមានឥរិយាបថមិនអាចគ្រប់គ្រងខ្លួនបាន រាប់បញ្ចូលទាំងការរួមភេទដោយប្រថុយប្រថាន ដោយមិនប្រើប្រាស់ស្រោមអនាម័យជាមួយដៃគូរួមភេទ។

តាមរយៈការវិភាគប្រភេទការងារ បានបង្ហាញថា ស្ត្រីខារ៉ាអូខេ និងស្ត្រីបំរើស្រាបៀរ មានការប្រឈមនឹង ការស្រវឹងដែលមិនអាចគ្រប់គ្រងខ្លួនបានក្នុងកម្រិតមួយខ្ពស់បំផុត ពោលគឺស្ត្រីខារ៉ាអូខេ ៤១ភាគរយ និង ស្ត្រីបំរើស្រាបៀរ ២៩ភាគរយ។ ប្រសិនបើប្រៀបធៀបនឹងក្រុមដទៃទៀត អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ មិនសូវ ប្រឈមនឹងការស្រវឹងប៉ុន្មានឡើយ។

គួរចាប់អារម្មណ៍ថាទោះបីជាគោលនយោបាយនៅកន្លែងការងារតម្រូវឱ្យអនុវត្តក្តីក៏ស្ត្រីបំរើស្រាបៀរត្រូវ បានអតិថិជនជំរុញឱ្យផឹកស្រាបៀជាមួយពួកគេដែរ។ សម្រាប់អ្នកធ្វើការដើម្បីយកកម្រៃជើងសារ មានការប្រថុយប្រថាននឹងគ្រោះថ្នាក់កាន់តែខ្ពស់ ជាងបុគ្គលិកអចិន្ត្រៃយ៍របស់ក្រុមហ៊ុនដូចគ្នា បុគ្គលិកក្រុមហ៊ុន Tiger, Heineken និង Angkor ។

ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស (២៦,៨០ភាគរយ) មានកម្រិតនៃការស្រវឹងខ្ពស់ជាងក្រុមស្រីស្រស់ (២០,១ភាគរយ)។




**រូប ១៧ : ភាគរយនៃការស្រវឹងរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ដែលមិនអាចគ្រប់គ្រងខ្លួនបានកាលពីសប្តាហ៍មុន**

*៩. ការប្រើគ្រឿងញៀន*

អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ (២១ភាគរយ) និងអ្នករកស៊ីផ្លូវភេទឯករាជ្យ បាននឹងកំពុងប្រើថ្នាំញៀន (២៦ភាគរយ) ជាពិសេសតាមរយៈការជក់។ អត្រាប្រេវ៉ាឡង់នៃការប្រើថ្នាំញៀនរបស់ស្ត្រីខារ៉ាអូខេគឺ ៤ភាគរយ និងស្ត្រីបំរើស្រាបៀរគឺ ១ភាគរយ។ អត្រាទាំងនេះហាក់ដូចជាខ្ពស់ជាងអត្រាដែលផ្តល់ដោយការអង្កេតការប្រព្រឹត្តផ្លូវភេទឆ្នាំ ២០០៧។

អ្នកប្តូរភេទ ១០,៤៩ភាគរយ ប្រើគ្រឿងញៀនគប់ប្រភេទតិចជាងក្រុមបុរសស្រឡាញ់បុរស ១៧,៧៦ភាគរយ។




| | DSW | ស្ត្រីម៉ាស្សា | FSW | ស្ត្រីខារ៉ាអូខេ | BPG | អ្នកបម្រើសេវាកំសាន្ត/រួមភេទទាំងអស់ | MSM | ស្រីស្រស់ | ស្រីស្រស់/ MSMទាំងអស់ |
|---|---|---|---|---|---|---|---|---|---|
| ផ្សេងៗ | 0.00% | 0.00% | 0.00% | 0.38% | 1.11% | 0.27% | 0.00% | 0.00% | 0.00% |
| លេប | 0.41% | 0.00% | 0.00% | 0.00% | 0.00% | 0.09% | 1.37% | 1.31% | 1.34% |
| ហឺត | 0.00% | 0.81% | 0.00% | 0.57% | 0.00% | 0.45% | 1.09% | 0.44% | 0.84% |
| ចាក់ | 0.41% | 1.63% | 0.00% | 0.57% | 0.00% | 0.54% | 0.00% | 0.44% | 0.17% |
| ជក់ | 21.14% | 6.50% | 26.19% | 4.40% | 1.11% | 10.57% | 15.30% | 8.30% | 12.61% |
| មិនប្រើ | 78.05% | 91.06% | 73.81% | 94.07% | 97.78% | 88.08% | 82.24% | 89.52% | 85.04% |

**តារាង ១៨ : ភាគរយនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ស្រវឹងដែលមិនអាចគ្រប់គ្រងខ្លួនបានកាលពីសប្តាហ៍មុន**

*១០. បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទបានឃើញមិត្តរបស់ខ្លួនផ្លាស់ប្តូរពីការប្រកបរបរផ្លូវភេទ ទៅធ្វើការងារផ្សេងទៀត*

គួរកត់សម្គាល់ថា ផ្តើមចេញពីការឆ្លើយតបទៅនឹងសំណួរទី ១៩ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ អាចផ្លាស់ប្តូរចេញពីការងារផ្លូវភេទ ទៅរកការងារផ្សេងទៀតនៅតំបន់ដែលពួកគេរស់នៅ។ រូបភាពខាងក្រោមបង្ហាញថា ខេត្តសៀមរាប ជាទីកន្លែងមួយដ៏ប្រសើរសម្រាប់ការធ្វើការងារធៀបនឹងរាជធានីភ្នំពេញ។ ចំណែកឯខេត្តបន្ទាយមានជ័យ និងខេត្តព្រះសីហនុ ជាទីកន្លែងដែលស្ថិតនៅចន្លោះតំបន់ដែលបានលើកឡើងទាំងពីរ។ ឆ្លងតាមការសង្កេតរួម ១ភាគ៤ នៃបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយបានអះអាងថា ពួកគេមិនបានឃើញមិត្តរបស់ខ្លួនផ្លាស់ប្តូរទៅរកការងារថ្មីទេ។




| | ខេត្តសៀមរាប | ខេត្តបន្ទាយមានជ័យ | ខេត្តព្រះសីហនុ | រាជធានីភ្នំពេញ | សរុប |
|---|---|---|---|---|---|
| មិនដែលឃើញសោះ | 25.55% | 27.20% | 35.14% | 75.68% | 25.09% |
| ឃើញតិចតួច | 21.17% | 19.20% | 46.85% | 55.68% | 37.28% |
| ឃើញកម្រិតមធ្យម | 12.77% | 23.20% | 10.36% | 11.89% | 14.34% |
| ឃើញច្រើន | 41.97% | 10.00% | 8.56% | 8.11% | 16.94% |
| ឃើញច្រើនណាស់ | 0.73% | 19.60% | 3.60% | 3.24% | 6.36% |

**រូប ១៩ : ភាគរយនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ដែលបានឃើញមិត្តរបស់ខ្លួនផ្លាស់ប្តូរពីការប្រកបរបរផ្លូវភេទ ទៅរកការងារផ្សេងនៅកន្លែងផ្សេងទៀត**

ការវិភាគលើកកម្រិតនៃការអប់រំបង្ហាញថាសម្រាប់អ្នកដែលមិនទទួលបានការអប់រំ និងអ្នកដែលបានរៀនត្រឹមបឋមសិក្សានិងមធ្យមសិក្សាមិនមានអ្វីខុសគ្នាឡើយ។ ដោយមិនគិតពីកម្រិតនៃការអប់រំចម្លើយរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ស្ទើរតែមិនខុសគ្នា។ ការវិភាគនេះបង្ហាញយ៉ាងច្បាស់ថាឱកាសការងារនៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ជាផ្នែកមួយមិនតម្រូវឱ្យប្រើជំនាញដែលពាក់ព័ន្ធនឹងកម្រិតការអប់រំខ្ពស់ៗ។

**សំណួរទី ១៩ :** បុគលិកគ្រឹះស្ថានកំសាន្ត**បានឃើញមិត្តភ័ក្តិរបស់ខ្លួនផ្លាស់ប្តូរពីការងារផ្លូវភេទទៅរកការងារថ្លៃថ្នូរជាងមុន ទៅតាមកម្រិតនៃការអប់រំ**




| | មិនមានការអប់រំ | ការអប់រំបឋមសិក្សា | ការអប់រំមធ្យមសិក្សាបឋមភូមិ | ការអប់រំមធ្យមសិក្សាទុតិយភូមិ | សរុប |
|---|---|---|---|---|---|
| មិនដែលឃើញសោះ | 27.42% | 24.73% | 21.74% | 29.55% | 25.09% |
| ឃើញតិចតួច | 40.47% | 37.46% | 33.33% | 31.82% | 37.28% |
| ឃើញកម្រិតមធ្យម | 13.71% | 13.60% | 17.87% | 11.36% | 14.34% |
| ឃើញច្រើន | 13.04% | 18.55% | 18.36% | 15.91% | 16.94% |
| ឃើញច្រើនណាស់ | 5.35% | 5.65% | 8.70% | 11.36% | 6.36% |

**រូប ២០ : ភាគរយ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ដែលបានឃើញមិត្តរបស់ខ្លួនផ្លាស់ប្តូរពីការលក់ភេទ ទៅធ្វើការងារផ្សេងទៀតទៅតាមកម្រិតនៃការអប់រំ**

## ២. ការយល់ឃើញ

### *២.១. រាជរដ្ឋាភិបាលមានភារកិច្ចការពារសិទ្ធិពលរដ្ឋគ្រប់រូប រាប់បញ្ចូលទាំងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់*

តាមការសង្កេតរួមស្តីពីការយល់ឃើញរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ៨៣ភាគរយ នៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ មកពីគ្រប់តំបន់សិក្សា យល់ស្របថា រាជរដ្ឋាភិបាលគួរការពារសិទ្ធិរបស់ពលរដ្ឋគ្រប់រូប រាប់បញ្ចូលទាំងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់។ អ្នកផ្តល់សម្ភាសជាបុរសស្រឡាញ់បុរស និងស្រីស្រស់បានផ្តល់ចម្លើយស្រដៀងគ្នាថា រាជរដ្ឋាភិបាលគួរការពារសិទ្ធិរបស់ពលរដ្ឋ គ្រប់រូបរាប់បញ្ចូលទាំងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់។ បុរសស្រឡាញ់បុរស និងស្រីស្រស់មានសំឡេងយ៉ាងច្រើនសន្ធឹកសន្ធាប់ ពោល គឺបុរសស្រឡាញ់បុរស ៩១ភាគរយ និងស្រីស្រស់ ៨៩.៥ភាគរយ។

**រាជរដ្ឋាភិបាលមានតួនាទីការពារប្រជាពលរដ្ឋគ្រប់រូប រាប់បញ្ចូលទាំង** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ **និង បុរសស្រឡាញ់បុរស និងស្រីស្រស់**




| | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | អ្នករកស៊ីផ្លូវភេទទាំងអស់ | MSM | ស្រីស្រស់ | MSM/ស្រីស្រស់ទាំងអស់ |
|---|---|---|---|---|---|---|---|---|---|
| មិនដឹង | 10.98 | 7.32 | 10.32 | 9.94 | 11.11 | 10.13% | 4.91% | 5.24% | 5.24% |
| មិនយល់ស្រប | 7.32 | 3.25 | 13.49 | 5.54 | 4.44 | 6.54% | 4.40% | 5.24% | 5.24% |
| យល់ស្រប | 81.71 | 89.43 | 76.19 | 84.51 | 84.44 | 83.33% | 90.69% | 89.52% | 89.52% |

**រូប ២១ : ភាគរយនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ចំពោះភារកិច្ច របស់រាជរដ្ឋាភិបាល**

១. *តើ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ មានសិទ្ធិ ចូលរួមក្នុងការបង្កើតច្បាប់ និងគោលនយោបាយទាក់ទង នឹងរបរកស៊ីផ្លូវភេទដែរឬទេ?*

តាមការសង្កេតជារួមភាគច្រើននៃបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ គ្រប់ប្រភេទយល់ស្របថាខ្លួនមានសិទ្ធិចូលរួមក្នុងការបង្កើតច្បាប់ និងគោលនយោបាយដែលពាក់ព័ន្ធនឹងការងារផ្លូវភេទ (ស្ត្រីខារ៉ាអូខេ ៨២ភាគរយ និងស្ត្រីម៉ាស្សា ៩៣ភាគរយ)។ បុរសស្រឡាញ់បុរស និងស្រីស្រស់មានសំឡេងយ៉ាងច្រើនសន្ទឹកសន្ធាប់ ពោលគឺ បុរសស្រឡាញ់បុរស៨៩ភាគរយ និងស្រីស្រស់ ៩២ភាគរយ ដែលបានយល់ស្របតាមការលើកឡើងរបស់ស្ត្រីខារ៉ាអូខេ និងស្ត្រីម៉ាស្សា។

**តើ** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ **គួរមានសិទ្ធិចូលរួមបង្កើត ច្បាប់ និងគោលនយោបាយ ពាក់ព័ន្ធនឹងការងារផ្លូវភេទដែរឬទេ?**




| | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | អ្នករកស៊ីផ្លូវភេទទាំងអស់ | MSM | ស្រីស្រស់ | MSM/ស្រីស្រស់ទាំងអស់ |
|---|---|---|---|---|---|---|---|---|---|
| មិនដឹង | 14.63 | 5.69 | 12.70 | 12.24 | 10.00 | 12.01% | 6.91% | 4.80% | 6.09% |
| មិនយល់ស្រប | 1.63 | 0.81 | 4.76 | 5.35 | 3.33 | 3.85% | 3.59% | 3.06% | 3.38% |
| យល់ស្រប | 83.74 | 93.50 | 82.54 | 82.41 | 86.67 | 84.14% | 89.50% | 92.14% | 90.52% |

**រូប ២២ : ការយល់ឃើញរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ស្តីពីសិទ្ធិចូលរួមបង្កើតគោលនយោបាយ**

*២. តើអ្នកដឹងទេថា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់មានសិទ្ធិ ដូចគ្នាទៅនឹងពលរដ្ឋឯទៀត?*

បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ច្រើនជាង ៨៥ ភាគរយពិតជាដឹងថាខ្លួនមានសិទ្ធិដូចគ្នាទៅនឹងពលរដ្ឋដទៃទៀត។ បុរសស្រឡាញ់បុរស និងស្រីស្រស់មានការយល់ដឹងច្រើនជាង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ។

**រាជរដ្ឋាភិបាលមានតួនាទីការពារប្រជាពលរដ្ឋគ្រប់រូប រាប់បញ្ចូលទាំង** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ **និង បុរសស្រឡាញ់បុរស និងស្រីស្រស់**




| | អ្នករកស៊ីផ្លូវភេទផ្ទាល់ | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្ត្រីស្រាបៀរ | សរុប | MSM | ស្រីស្រស់ | MSM/ស្រីស្រស់ |
|---|---|---|---|---|---|---|---|---|---|
| មិនដឹង | 10.16 | 5.69 | 11.11 | 12.43 | 12.43 | 11.11% | 3.04% | 3.93% | 3.38% |
| ដឹង | 89.84 | 94.31 | 88.89 | 87.57 | 87.57 | 88.89% | 96.96% | 96.07% | 96.62% |

**រូប ២៣ : ការយល់ឃើញរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ចំពោះថាតើខ្លួនមានសិទ្ធិដូចពលរដ្ឋឯទៀត ដោយស្មើភាពដែរឬទេ?**

*៣. កត្តាចម្បងៗពាក់ព័ន្ធនឹងសិទ្ធិទទួលបានការងារ*

**៣.១.** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ

តាមរយៈទិន្នន័យដែលប្រមូលបាននិងការវិភាគលើប្រភេទការងារបង្ហាញថា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទទាំងអស់បាននិយាយថា តម្រូវការរបស់អ្នកនៅក្នុងបន្ទុក កង្វះឱកាសការងារ កង្វះតំណាង គំនាបពីមន្ត្រីទទួលបន្ទុក កង្វះវេទិកាសាធារណៈ គោលនយោបាយមិនច្បាស់លាស់ជាមួយការយល់ដឹង និងការអនុវត្តន៍ បញ្ហាសត្តាជាបញ្ហាប្រឈមរបស់ពួកគេ។ ការវិភាគ ANOVA ដោយប្រើប្រភេទការងារជាកត្តាបង្ហាញថា ចម្លើយរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយស្តីពីតម្រូវការអ្នកនៅក្នុងបន្ទុក និងកង្វះវេទិកាសាធារណៈ មានភាពខុសគ្នាខ្លាំង។ ចំណែកឯចម្លើយដទៃទៀត មិនមានភាពខុសគ្នាប៉ុន្មានទេ។

**តារាង ៨ : កត្តាសំខាន់ៗពាក់ព័ន្ធនឹងសិទ្ធិទទួលបានការងាររបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ**

| ប្រភេទ EW/SWs | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | | ស្ត្រីម៉ាស្សា | | អ្នករកស៊ីផ្លូវភេទឯករាជ្យ | | ស្ត្រីខារ៉ាអូខេ | | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | | ANOVA |
|---|---|---|---|---|---|---|---|---|---|---|---|
| | WAI | OA | WAI | OA | WAI | OA | WAI | OA | WAI | OA | Sig. |
| អ្នកក្នុងបន្ទុក | 0.93 | H | 0.91 | H | 0.82 | H | 0.91 | H | 0.9 | H | 0.000*** |
| កង្វះឱកាសការងារ | 0.88 | H | 0.87 | H | 0.83 | H | 0.88 | H | 0.9 | H | 0.34 |
| កង្វះតំណាង | 0.82 | H | 0.78 | H | 0.8 | H | 0.82 | H | 0.79 | H | 0.67 |
| គំនាបពីមន្ត្រីទទួលបន្ទុក | 0.91 | H | 0.87 | H | 0.89 | H | 0.86 | H | 0.85 | H | 0.1 |
| កង្វះវេទិកាសាធារណៈ | 0.82 | H | 0.71 | H | 0.75 | H | 0.80 | H | 0.74 | H | 0.01* |
| គោលនយោបាយមិនច្បាស់លាស់ជាមួយការយល់ដឹង និងការអនុវត្តបញ្ញាសត្វា | 0.87 | H | 0.88 | H | 0.85 | H | 0.85 | H | 0.86 | H | 0.83 |

ប្រភព : ការអង្កេតនៅកន្លែងអនុវត្តផ្ទាល់
ខែវិច្ឆិកា ឆ្នាំ២០០៨

កំណត់សម្គាល់ : ការវិភាគរួម (OA), ខ្ពស់ (H) = 1.00 – 0.66; មធ្យម (N) = 0.65 - 0.33; ទាប (L) = 0.32 - 0.00

### ៣.២. បុរសស្រឡាញ់បុរស និងស្រីស្រស់

បុរសស្រឡាញ់បុរស និងស្រីស្រស់ បានលើកឡើងស្រដៀងគ្នាទៅនឹង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ដែរថាតម្រូវការរបស់អ្នកនៅក្នុងបន្ទុក កង្វះឱកាសការងារ កង្វះតំណាង គំនាបពីមន្ត្រីទទួលបន្ទុក កង្វះវេទិកាសាធារណៈ គោលនយោបាយមិនច្បាស់លាស់ រួមជាមួយការយល់ដឹង និងការអនុវត្តន៍បញ្ញាសត្វា ជាបញ្ហាប្រឈមមុខរបស់ពួកគេ។ ការវិភាគ ANOVA ដោយប្រើប្រភេទការងារជាកត្តាបង្ហាញថាចម្លើយរបស់ បុរសស្រឡាញ់បុរស និងស្រីស្រស់ ចំពោះកត្តាទាំងអស់ពាក់ព័ន្ធនឹងសិទ្ធិទទួលបានការងារមិនខុសគ្នាប៉ុន្មានទេ។

**តារាង ៩ : កត្តាសំខាន់ៗពាក់ព័ន្ធនឹងសិទ្ធិទទួលបានការងាររបស់បុរសស្រឡាញ់បុរស និងស្រីស្រស់**

| ប្រភេទបុរសស្រឡាញ់បុរស និងស្រីស្រស់ | បុរសស្រឡាញ់បុរស | | ស្រីស្រស់ | | ANOVA |
|---|---|---|---|---|---|
| | WAI | OA | WAI | OA | Sig. |
| អ្នកក្នុងបន្ទុក | 0.89 | H | 0.84 | H | 0.051363 |
| កង្វះឱកាសការងារ | 0.86 | H | 0.85 | H | 0.869502 |
| កង្វះតំណាង | 0.79 | H | 0.73 | H | 0.025902 |
| គំនាបពីមន្ត្រីទទួលបន្ទុក | 0.83 | H | 0.81 | H | 0.371795 |
| កង្វះវេទិកាសាធារណៈ | 0.83 | H | 0.78 | H | 0.027456 |
| គោលនយោបាយមិនច្បាស់លាស់ជាមួយការយល់ដឹង និងការអនុវត្តបញ្ញាសត្ថា | 0.90 | H | 0.88 | H | 0.34674 |

ប្រភព : ការអង្កេតនៅកន្លែងអនុវត្តផ្ទាល់ ខែវិច្ឆិកា ឆ្នាំ២០០៨

កំណត់សម្គាល់ : ការវិភាគរួម (OA), ខ្ពស់ (H) = 1.00 – 0.66; មធ្យម (N) = 0.65 - 0.33; ទាប (L) = 0.32 - 0.00

## ៣. ការអនុវត្តន៍ច្បាប់ និងគោលនយោបាយ

*១. ការមើលងាយ និងការរើសអើងលើ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់:មានការ កើនឡើង ឬថយចុះ?*

អ្នកប្រកបរបររកស៊ីផ្លូវភេទដោយផ្ទាល់បានលើកឡើងថា ការមើលងាយ និងការរើសអើង បានកើនឡើងតិចជាង ១២ភាគរយ។ ចំណែកឯអ្នករកស៊ីផ្លូវភេទដោយប្រយោលពោលគឺស្ត្រីខារ៉ាអូខេប្រមាណ ១៥ភាគរយបានកត់សម្គាល់ថា ការមើលងាយ និងការរើសអើង មានការកើនឡើង។

ស្ថានភាពរបស់បុរសស្រឡាញ់បុរស និងស្រីស្រស់មានភាពប្រសើរជាង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទដោយសារការមើលងាយ និងការរើសអើងចំពោះពួកគេបានថយចុះពី ៦៨ភាគរយទៅ ៦៤ភាគរយ។

**តើការមើលងាយ និងរើសអើងចំពោះ** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ **និង បុរសស្រឡាញ់បុរស និងស្រីស្រស់ កើនឡើង ឬថយចុះ?**




| | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | អ្នករកស៊ីផ្លូវភេទទាំងអស់ | MSM | ស្រីស្រស់ | MSM/ ស្រីស្រស់ ទាំងអស់ |
|---|---|---|---|---|---|---|---|---|---|
| ថយចុះ | 45.53 | 59.35 | 59.35 | 60.61 | 64.44 | 55.11% | 64.09% | 67.69% | 65.48% |
| ដូចធម្មតា | 42.68 | 33.33 | 33.33 | 23.52 | 26.67 | 30.82% | 28.73% | 24.89% | 27.24% |
| កើនឡើង | 11.79 | 7.32 | 7.32 | 15.87 | 8.89 | 14.07% | 7.18% | 7.42% | 7.28% |

**រូប ២៤ : ការមើលងាយ និងការរើសអើងលើ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់**

*២. ការបៀតបៀន និងអំពើហិង្សាលើបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយក្នុងឆ្នាំ ២០០៨ ធៀបនឹងឆ្នាំ ២០០៧*

តាមការសង្កេតជាទូទៅមួយឃើញថា ការបៀតបៀន និងការប្រើអំពើហិង្សាលើបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយក្នុងឆ្នាំ២០០៨ បានថយចុះយ៉ាងខ្លាំងធៀបនឹងឆ្នាំ២០០៧។ ចម្លើយនេះបានផ្តល់ដោយក្រុម បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់។




| | អតិថិជន | គូសង្សារ | កងឯកសណ្ឋាន | ក្រុមស្ទាវ | ម្ចាស់បន | អ្នកផ្តល់សេវា |
|---|---|---|---|---|---|---|
| ថយចុះ | 59.32% | 33.60% | 29.12% | 31.72% | 37.28% | 33.06% |
| ដូចធម្មតា | 11.02% | 3.94% | 15.41% | 10.75% | 3.32% | 1.34% |
| កើនឡើង | 7.80% | 1.88% | 8.24% | 6.45% | 0.54% | 0.54% |
| មិនដឹង | 21.86% | 60.57% | 47.22% | 51.08% | 58.87% | 65.05% |

**រូប ២៥ : ការបៀតបៀនលើ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ក្នុងឆ្នាំ២០០៨ ធៀបនឹងឆ្នាំ២០០៧**

**ការបៀតបៀន និងអំពើហិង្សាមកលើ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងឆ្នាំ២០០៨ ធៀបនឹងឆ្នាំ ២០០៧**




| | អតិថិជន | គូសង្សារ | កងឯកសណ្ឋាន | ក្រុមស្មាវ | ម្ចាស់បន | អ្នកផ្តល់សេវា |
|---|---|---|---|---|---|---|
| ថយចុះ | 51.61% | 33.50% | 24.87% | 28.09% | 24.70% | 24.87% |
| ដូចធម្មតា | 42.13% | 64.81% | 65.48% | 63.62% | 68.70% | 69.71% |
| កើនឡើង | 6.26% | 1.69% | 9.64% | 8.29% | 6.60% | 5.41% |
| មិនដឹង | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% |

**រូប ២៧ : ការបៀតបៀនលើបុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងឆ្នាំ២០០៨ ធៀបនឹងឆ្នាំ២០០៧**

## ៤. <u>ការចូលរួម</u>

*១. តើអ្នកមានដែលបានឮ ឃើញ ឬអានគោលនយោបាយ និងច្បាប់ពាក់ព័ន្ធនឹងសិទ្ធិទទួលបានការងារសម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ដែរឬទេ? តើអ្នកដែលចូលរួមពិភាក្សាលើឯកសារច្បាប់ទាំងនោះដែរ ឬទេ? សំណួរទី ២០*

**បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ:** តាមការអង្កេតជារួម ភាគច្រើន បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយធ្លាប់បានឮ ឃើញ និងអានច្បាប់ស្តីពីការបង្ការ និងត្រួតពិនិត្យការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ច្រើនជាងគោលនយោបាយស្តីពីការប្រើប្រាស់ស្រោមអនាម័យឱ្យបាន ១០០ ភាគរយ។ ច្បាប់ស្តីពីការប្រឆាំងការជួញដូរមនុស្ស និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយក៏ធ្លាប់បានឮមើល និងអានក្នុងលំនាំស្រដៀងគ្នានេះដែរ ពោលគឺបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ បានដឹងពីច្បាប់ប្រឆាំងការជួញដូរមនុស្សច្រើនជាងច្បាប់ស្តីពី អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី។ បើធៀបនឹងច្បាប់ និងគោលនយោបាយដែលបានរៀបរាប់ខាងដើម បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ធ្លាប់បានឮអនុក្រឹត្យស្តីពីកន្លែងការងារសម្រាប់អ្នកផ្ទុកមេរោគអេដស៍ក្នុងកម្រិតមួយតិចតួចបំផុត។ គួរកត់សម្គាល់ថាអត្រាការចូលរួមពិភាក្សាលើបញ្ហាច្បាប់ ខ្ពស់ជាងអត្រាអានឯកសារច្បាប់។

**បុរសស្រឡាញ់បុរស និងស្រីស្រស់** មានលំនាំស្រដៀងគ្នាទៅនឹង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ដែរបើគិត ទៅលើលទ្ធភាពទទួលបានព័ត៌មានពាក់ព័ន្ធនឹង គោលនយោបាយ និងច្បាប់ស្តីពីសិទ្ធិទទួលបានការងារ

សម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ និងការចូលរួមរបស់អ្នកទាំងនោះក្នុងការពិភាក្សាអំពីគោលនយោបាយទាំងនេះ។ ទោះបីជាយ៉ាងនេះក្តី ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់មានភាគរយ ការឆ្លើយតបទៅនឹងគ្រប់ប្រភេទច្បាប់ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ និងគោលនយោបាយស្តីពីការប្រើប្រាស់ស្រោមអនាម័យឱ្យបាន ១០០ភាគរយ ច្រើនជាងក្រុម បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ។

**រូប ២៨: បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ៎ តើអ្នកមានដែលបានឮ ឃើញ ឬអានគោលនយោបាយ និងច្បាប់ពាក់ព័ន្ធនឹងសិទ្ធិទទួលបានការងារសម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ដែរឬទេ? តើអ្នកដែលចូលរួមពិភាក្សាលើឯកសារច្បាប់ទាំងនោះដែរឬទេ?**




| | ច្បាប់ស្តីពីការប្រឆាំងការជួញដូរ | ច្បាប់ស្តីពី AIDS | គោលនយោបាយប្រើស្រោម ១០០% | CEDAW | អនុក្រឹត្យស្តីពីកន្លែងការងារសម្រាប់អ្នកផ្ទុក |
|---|---|---|---|---|---|
| ធ្លាប់ឮ | 86.29% | 89.00% | 82.74% | 70.39% | 47.21% |
| ធ្លាប់ឃើញ | 53.30% | 68.36% | 70.90% | 44.33% | 28.09% |
| ធ្លាប់អាន | 42.47% | 52.28% | 58.71% | 29.78% | 20.64% |
| បានចូលរួមពិភាក្សា | 32.15% | 39.76% | 50.25% | 22.50% | 21.15% |

**រូប ២៩ : បុរសស្រឡាញ់បុរស និងស្រីស្រស់ : តើអ្នកមានដែលបានឮ ឃើញ ឬអានគោលនយោបាយ និងច្បាប់ពាក់ព័ន្ធនឹងសិទ្ធិទទួលបានការងារសម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ដែរឬទេ? តើអ្នកដែលចូលរួមពិភាក្សាលើឯកសារច្បាប់ទាំងនោះដែរឬទេ?**

ការរៀបចំការសម្ភាសសម្រាប់ការស្រាវជ្រាវសកម្មភាពនេះ ភាគច្រើនរៀបចំឡើងដោយអ្នកសម្របសម្រួលដែលជាតំណាង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ថ្នាក់ខេត្ត។ ភាគច្រើននៃអ្នកផ្តល់សម្ភាសក្នុងការស្រាវជ្រាវដើម្បីធ្វើសកម្មភាពនេះ មានជាប់ពាក់ព័ន្ធនឹងបណ្តាញមូលដ្ឋានរបស់ខ្លួនដើម្បីពិភាក្សាលើគោលនយោបាយ និងច្បាប់ទាក់ទិននឹងការងាររបស់ខ្លួន។ ទោះបីជាយ៉ាងណា គួររំលឹកផងដែរថាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ភាគច្រើនគ្មានទំនាក់ទំនងទៅនឹងបណ្តាញមូលដ្ឋានរបស់ខ្លួនឡើយ។

*២. តើអ្នកដែលចូលរួមសកម្មភាពគាំទ្រលើសិទ្ធិទទួលបានការងារដែរឬទេ? (សំណួរ ២១)*

**បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ** ប្រមាណ ៥០ភាគរយ ផ្តល់ចម្លើយលើសំណួរជ្រើសរើស។ តារាងខាង ក្រោម បង្ហាញយ៉ាងច្បាស់ថា ការធ្វើសិក្ខាសាលាជាវិធីសាស្រ្តមួយដែលត្រូវបានប្រើញឹកញាប់ដើម្បីទទួលបានការងារពីគ្រប់តំបន់ បន្ទាប់មកគឺការធ្វើញ្ញុះហយាត្រា និងការធ្វើយុទ្ធនាការ។ លិខិតសុំការអនុញ្ញាត និងសន្និ

សីទសារព័ត៌មាន ជាវិធីសាស្ត្រដែលមិនសូវនិយម ប្រើដើម្បីទទួលបានការគាំទ្រលើសិទ្ធិទទួលបានការងាររបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយទេ។




**រូប ៣០ : ការចូលរួមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ក្នុងការគាំទ្រលើសកម្មភាពសិទ្ធិទទួលបានការងារតាមតំបន់**

ការវិភាគតាមប្រភេទការងារបង្ហាញថា ស្ត្រីបំរើស្រាបៀរ និងស្ត្រីម៉ាស្សា មានចំណែកចូលរួមក្នុងសកម្ម ភាពគាំទ្រក្នុងកម្រិតមួយខ្ពស់ធៀបនឹងក្រុមដទៃទៀត។ តាមរយៈការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ១ បង្ហាញថា សកម្មភាពដែលធ្វើឡើងដោយស្ត្រីបំរើស្រាបៀរតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានធ្វើឡើងដើម្បីប្រឆាំងនឹងការបៀតបៀនលើស្ត្រីរកស៊ីផ្លូវភេទ។ ការចូលរួមលើសកម្មភាពស្វែងរកការគាំទ្ររបស់អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ និងស្ត្រីខារ៉ាអូខេ មិនសូវមានសារៈសំខាន់ប៉ុន្មានទេ។

## ការចូលរួមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ក្នុងសកម្មភាពស្វែងរកការគាំទ្រ



| | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | សរុប |
|---|---|---|---|---|---|---|
| ចំនួនអ្នកបម្រើសេវាកំសាន្ត | 246 | 123 | 126 | 523 | 90 | 1116 |
| ចំនួនអ្នកបម្រើការសប្បាយដែលចូលរួមក្នុងសកម្មភាពតស៊ូមតិ | 26 | 133 | 90 | 85 | 156 | 511 |

**រូប ៣១ : ប្រៀបធៀបសមាមាត្ររបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ដែលចូលរួមសកម្មភាពស្វែងរកការគាំទ្រដើម្បីសិទ្ធិទទួលបានការងារ**

**បុរសស្រឡាញ់បុរស និងស្រីស្រស់** ប្រមាណ ៥១ភាគរយបានអះអាងចំពោះការចូលរួមក្នុងសកម្មភាពស្វែងរកការគាំទ្រដើម្បីសិទ្ធិទទួលបានការងារ ពួកគេចូលរួមតាមធ្វើរយៈសិក្ខាសាលា។ អ្នកផ្តល់សម្ភាសនៅខេត្តសៀមរាប បានផ្តល់ចម្លើយអំពីការចូលរួមរបស់ខ្លួនក្នុងយុទ្ធនាការ និងក្បួនព្យុះហយាត្រា។




| | SR | BMC | SHV | PHN | សរុប |
|---|---|---|---|---|---|
| | 50 | 17 | 13 | 22 | 102 |
| សិក្ខាសាលា | 29 | 54 | 54 | 84 | 221 |
| ក្បួនព្យុះហយាត្រា | 61 | 34 | 17 | 23 | 135 |
| លិខិតអនុញ្ញាត | 0 | 1 | 1 | 0 | 2 |
| សន្និសីទសារព័ត៌មាន | 0 | 4 | 1 | 3 | 8 |

**រូប ៣២ : ការចូលរួមរបស់បុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងសកម្មភាពស្វែងរកការគាំទ្រដើម្បីសិទ្ធិទទួលបានការងារ តាមតំបន់**

### *៣. លទ្ធផលនៃសកម្មភាពស្វែងរកការគាំទ្រ*

ក្នុងចំណោមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ដែលផ្តល់ចម្លើយចំពោះសំណួរនេះបង្ហាញថាលទ្ធផលជារួមនៃសកម្មភាពស្វែងរកការគាំទ្រធ្វើឱ្យស្ថានភាពការងារមានភាពប្រសើរឡើង។ ទោះបីជាយ៉ាងនេះក្តី គួរកត់សម្គាល់ផងដែរថាស្ថានភាពការងាររបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ នៅរាជធានីភ្នំពេញហាក់ដូចជាមិនផ្លាស់ប្តូរនៅពេលដែលអ្នកផ្តល់សម្ភាសប្រមាណ៤៩ភាគរយលើកឡើងថា ស្ថានភាពការងាររបស់ខ្លួនហាក់ដូចជាមិនផ្លាស់ប្តូរ ដោយឡែកអ្នកផ្តល់សម្ភាសប្រមាណ ៤៦ភាគរយ ទទួលស្គាល់ថា ស្ថានភាពការងាររបស់ខ្លួនមានភាពប្រសើរជាងមុន។

**លទ្ធផលនៃសកម្មភាពស្វែងរកការគាំទ្ររបស់**បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ




| | SRP | BMC | SHV | PNP | Total |
|---|---|---|---|---|---|
| អាក្រក់ជាងមុន | 6.00% | 1.05% | 1.19% | 4.61% | 3.15% |
| ដូចធម្មតា | 18.00% | 17.89% | 21.43% | 49.34% | 31.23% |
| ល្អជាងមុន | 76.00% | 81.05% | 77.38% | 46.05% | 65.62% |

**រូប ៣៣ : លទ្ធផលនៃសកម្មភាពស្វែងរកការគាំទ្ររបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ដើម្បីសិទ្ធិទទួលបាន ការងារនៅតាមតំបន់ដែលយកមកសិក្សា**

តាមរយៈចម្លើយដែលផ្តល់ដោយបុរសស្រឡាញ់បុរស និងស្រីស្រស់ ស្ថានភាពការងារជាទូទៅរបស់អ្នកទាំងនោះហាក់ដូចជាមានភាពកាន់តែតឹងតែងជាងស្ថានភាពការងាររបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ។ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ (43.99%) និងអ្នករកស៊ីផ្លូវភេទ (43.49%) មានភាគរយ ស្រដៀងគ្នាក្នុងការឆ្លើយតបទៅនឹងស្ថានភាពការងាររបស់ខ្លួន។ ការពិនិត្យកាន់តែស៊ីជម្រៅលើស្ថានភាពការងាររបស់ បុរសស្រឡាញ់បុរស និងស្រីស្រស់នៅថ្នាក់ខេត្តបង្ហាញថាខេត្តព្រះសីហនុ មានស្ថានភាពល្អប្រសើរជាងគេ។ ខេត្តបន្ទាយមានជ័យ (៥៣ភាគរយ) និងរាជធានីភ្នំពេញ (៤៧ភាគរយ) មានលំនាំស្រដៀងគ្នា ដែលអ្នកទាំងនោះបាននិយាយថា ស្ថានភាពការងាររបស់ខ្លួនមិនផ្លាស់ប្តូរ។ បន្ថែមពីលើនេះ១ភាគ៤នៃអ្នកផ្តល់សម្ភាសជាបុរសស្រឡាញ់បុរស និងស្រីស្រស់នៅរាជធានីភ្នំពេញបាននិយាយថា ស្ថានភាពការងាររបស់ខ្លួន កាន់តែអាក្រក់ជាងមុន។




| | សៀមរាប | បន្ទាយមានជ័យ | ព្រះសីហនុ | ភ្នំពេញ | សរុប |
|---|---|---|---|---|---|
| អាក្រក់ជាងមុន | 1.25% | 12.07% | 2.99% | 25.79% | 12.52% |
| ដូចធម្មតា | 41.88% | 53.45% | 11.94% | 46.84% | 43.49% |
| ល្អជាងមុន | 56.88% | 34.48% | 85.07% | 27.37% | 43.99% |

**រូប ៣៤ : បុរសស្រឡាញ់បុរស និងស្រីស្រស់ : លទ្ធផលនៃសកម្មភាពស្វែងរកការគាំទ្រដើម្បីសិទ្ធិទទួលបានការងារតាមតំបន់**

*៤. ការចូលរួមជាសមាជិកក្នុងយន្តការសកម្មភាពស្វែងរកការគាំទ្រ(ថ្នាក់កណ្តាល ថ្នាក់ខេត្ត ថ្នាក់មូលដ្ឋាន) (សំណួរទី ៣០)*

ការវិភាគតាមតំបន់បង្ហាញថាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ នៅខេត្តព្រះសីហនុ មានភាគរយ នៃការចូលរួមជាសមាជិកក្នុងយន្តការស្វែងរកការគាំទ្រដើម្បីសិទ្ធិទទួលបានការងារតិចបំផុតដោយឡែកបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនៅរាជធានីភ្នំពេញ មានភាគរយនៃការចូលរួមច្រើនបំផុតប្រមាណ ៤២ភាគរយ។ ការចូលរួមរបស់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ក្នុងយន្តការស្វែងរកការគាំទ្រមានកម្រិតខ្ពស់ ជាងក្រុមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ នៅគ្រប់តំបន់ទាំងអស់ជាពិសេសនៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។




**រូប ៣៥ : ការចូលរួមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ក្នុងសកម្មភាពស្វែងរកការគាំទ្រដើម្បីសិទ្ធិទទួលបានការងារតាមតំបន់**

ក្នុងចំណោមអ្នកចូលរួមក្នុងយន្តការនេះភាគច្រើនធ្វើឡើងនៅថ្នាក់មូលដ្ឋាន។ អ្នកផ្តល់សម្ភាសជា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ៥៤ នាក់ក្នុងចំណោម ៣៧០នាក់ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ៣២នាក់ ក្នុងចំណោម ១៩០នាក់នៅថ្នាក់កណ្តាល ក្នុងរាជធានីភ្នំពេញបានលើកឡើងថាខ្លួនជាសមាជិកនៃក្រុមសកម្មភាពស្វែងរកការគាំទ្រដើម្បីសិទ្ធិទទួលបានការងារសម្រាប់ខ្លួនដែលជាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់។

**ការចូលរួមរបស់** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ **និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងយន្តការស្វែងរកការគាំទ្រតាមតំបន់**




| | EW/SW | MSM/ស្រីស្រស់ | EW/SW | MSM/ស្រីស្រស់ | EW/SW | MSM/ស្រីស្រស់ | EW/SW | MSM/ស្រីស្រស់ | EW/SW | MSM/ស្រីស្រស់ |
|---|---|---|---|---|---|---|---|---|---|---|
| | សៀមរាប | | បន្ទាយមានជ័យ | | ព្រះសីហនុ | | ភ្នំពេញ | | សរុប | |
| □ | 1 | 3 | 0 | 4 | 0 | 5 | 54 | 32 | 67 | 44 |
| ■ | 2 | 3 | 10 | 10 | 0 | 4 | 3 | 2 | 32 | 19 |
| ■ | 68 | 83 | 82 | 67 | 51 | 42 | 106 | 75 | 499 | 267 |

**រូប ៣៦ : ការចូលរួមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ក្នុងសកម្មភាពស្វែងរកការគាំទ្រដើម្បីសិទ្ធិទទួលបានការងារ នៅតាមតំបន់ដែលយកមកសិក្សា និងតាមកម្រិត**

គួរកត់សម្គាល់ថាការចូលរួមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយដែលជាអ្នករកស៊ីផ្លូវភេទដោយផ្ទាល់ ដូចជាអ្នករកស៊ីផ្លូវភេទដោយផ្ទាល់ ស្ត្រីម៉ាស្សា និងអ្នករកស៊ីផ្លូវភេទឯករាជ្យ បានកើនឡើងពី ៣៨ភាគរយ ទៅ ៤៣ភាគរយ ធៀបនឹងអ្នករកស៊ីផ្លូវភេទដោយប្រយោល ដូចជា ស្ត្រីខារ៉ាអូខេ និងស្ត្រីបំរើស្រាបៀរដែលបានកើនឡើងពី ២៧ភាគរយ ទៅ ៣០ភាគរយ។ ភាគរយនៃការចូលរួមរបស់ស្រីស្រស់ មានលក្ខណៈស្រដៀងគ្នាទៅនឹងក្រុមអ្នករកស៊ី ផ្លូវ

ភេទដោយប្រយោល ដូចជាស្ត្រីខារ៉ាអូខេ និងស្ត្រីបំរើស្រាបៀរ ។ ទោះបីជាយ៉ាងនេះក្តី គ្រប់ប្រភេទ បុគ្គលិកគ្រឹះ ស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់មានការចូលរួមច្រើនជាងមុនទាំងអស់ ។




**រូប ៣៧ : ភាគរយនៃការចូលរួមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ក្នុងសកម្មភាពស្វែងរកការគាំទ្រដើម្បីសិទ្ធិទទួលបានការងារ**

**គោលបំណង ២ : បរិយាកាសអំណោយផលស្តីពីការបង្កើត និងជំរុញ ការអនុវត្តគោលនយោបាយមានស្រាប់ និង បទដ្ឋានសង្គមទាក់ទងនឹងការទទួលបានជាសកលសម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ**

**ការចូលរួមក្នុងយន្តការស្វែងរកការគាំទ្រដើម្បីលទ្ធភាពទទួលបានជាសកល (ឧទាហរណ៍ កម្មវិធីប្រើប្រាស់ស្រោមអនាម័យឱ្យបាន ១០០ ភាគរយ កម្មវិធីមិត្តអប់រំមិត្ត ការថែទាំតាមផ្ទះ ។ល។) (សំណួរទី ៣០)**

ការចូលរួមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ក្នុងយន្តការស្វែងរកការគាំទ្រ ដើម្បីទទួលបានសេវាជាសកលមានភាពខុសគ្នាពីខេត្តមួយទៅខេត្តមួយទៀត ដោយមានការចូលរួមច្រើនគឺក្នុងខេត្តសៀមរាប (៤៦ភាគរយ) និងខេត្តព្រះសីហនុ (៤០ភាគរយ)។ ការចូលរួមនៅខេត្តបន្ទាយមានជ័យ និងរាជធានីភ្នំពេញមានកម្រិតតិចតួចបំផុត ពោលគឺ ១៦ភាគរយ និង២៣ភាគរយ។

ផ្ទុយទៅវិញ ការចូលរួមរបស់**បុរសស្រឡាញ់បុរស និងស្រីស្រស់** នៅខេត្តបន្ទាយមានជ័យ និងនៅរាជធានីភ្នំពេញមានកម្រិតខ្ពស់គួរឱ្យកត់សម្គាល់ ពោលគឺ ៦៣ភាគរយ និង ៧៤ភាគរយ ប៉ុន្តែការចូលរួមនៅខេត្តសៀមរាប និងខេត្តព្រះសីហនុ មានកម្រិតទាប ពោលគឺ ២៩ភាគរយ និង១៩ភាគរយ។




**រូប ៣៨ : ការចូលរួមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ក្នុងយន្តការស្វែងរកការគាំទ្រដើម្បីទទួលបានសេវាជាសកល**

ការវិភាគលើការចូលរួមរបស បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់នៅថ្នាក់កណ្តាល ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ក្នុងបណ្តាខេត្តក្រុងទាំង ៤ ដែលយកមកសិក្សាបង្ហាញថា ទំនាក់ទំនងពីថ្នាក់មួយទៅថ្នាក់មួយទៀត មានកម្រិតតិចតួច លើកលែងនៅរាជធានីភ្នំពេញ។ ការចូលរួមនៅថ្នាក់មូលដ្ឋានភាគច្រើនមានភាពលម្អៀង។




| | EW/SW សៀមរាប | MSM/ស្រីស្រស់ សៀមរាប | EW/SW បន្ទាយមានជ័យ | MSM/ស្រីស្រស់ បន្ទាយមានជ័យ | EW/SW ព្រះសីហនុ | MSM/ស្រីស្រស់ ព្រះសីហនុ | EW/SW ភ្នំពេញ | MSM/ស្រីស្រស់ ភ្នំពេញ | EW/SW សរុប | MSM/ស្រីស្រស់ សរុប |
|---|---|---|---|---|---|---|---|---|---|---|
| ថ្នាក់ជាតិ | 0 | 3 | 1 | 2 | 0 | 4 | 34 | 38 | 35 | 47 |
| ថ្នាក់ខេត្ត | 3 | 5 | 5 | 6 | 3 | 2 | 30 | 3 | 41 | 16 |
| សហគមន៍ | 124 | 110 | 38 | 56 | 84 | 48 | 29 | 11 | 275 | 225 |

**រូប ៣៩ : ការចូលរួមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ក្នុងយន្តការស្វែងរកការគាំទ្រដើម្បីទទួលបានសេវាជាសកលតាមតំបន់សិក្សា**

ភាគរយនៃការចូលរួមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ មានកម្រិតតិចតួច លើកលែងការចូលរួមរបស់ស្ត្រីបំរើស្រាបៀរ ។ ចំណែកឯការចូលរួមរបស់ បុរសស្រឡាញ់បុរស និងស្រីស្រស់ មានកម្រិតខ្ពស់ជាងពោលគឺបុរសស្រឡាញ់បុរស ៥៨ភាគរយ និងស្រីស្រស់ ៤៣ ភាគរយ ។




**រូប ៤០ : ភាគរយនៃការចូលរួមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ក្នុងយន្តការស្វែងរកការគាំទ្រដើម្បីទទួលបានសេវាជាសកល តាមប្រភេទការងារ**

## ១. ការយល់ឃើញ

*១. តើបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ មានសិទ្ធិបម្រើសេវាផ្លូវភេទដោយស្ម័គ្រចិត្តដែរឬទេ?*

ភាគច្រើននៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ(៨៤ភាគរយ) មកពីគ្រប់ប្រភេទការងារទាំងអស់យល់ស្របថា ខ្លួនមានសិទ្ធិប្រកបមុខរបរផ្លូវភេទដោយស្ម័គ្រចិត្ត។

បុរសស្រឡាញ់បុរស និងស្រីស្រស់ ក៏បានផ្តល់ចម្លើយស្រដៀងគ្នានេះផងដែរ ពោលគឺប្រមាណ ៨៦ភាគរយនៃអ្នកទាំងនោះ បញ្ជាក់ថាខ្លួនមានសិទ្ធិប្រកបរបររកស៊ីផ្លូវភេទដោយស្ម័គ្រចិត្ត។

**ការយល់ឃើញរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ទាក់ទងសិទ្ធិប្រកបរបរផ្លូវភេទដោយស្ម័គ្រចិត្ត**




| | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្ត្រីឃោសនាស្រាបៀរ | អ្នករកស៊ីផ្លូវភេទទាំងអស់ | MSM | ស្រីស្រស់ | MSM/ស្រីស្រស់ទាំងអស់ |
|---|---|---|---|---|---|---|---|---|---|
| មិនដឹង | 7.72% | 2.43% | 3.17% | 4.97% | 8.89% | 5.56% | 4.14% | 4.80% | 4.40% |
| មិនគិតថា EW/SW និង MSM/ស្រីស្រស់ មានសិទ្ធតប្រកបរបរផ្លូវភេទដោយស្ម័គ្រចិត្ត | 10.56% | 9.75% | 11.11% | 8.99% | 10.00% | 9.77% | 9.12% | 10.92% | 9.81% |
| គិតថា EW/SW និង MSM/ស្រីស្រស់ មានសិទ្ធិប្រកបរបរផ្លូវភេទដោយស្ម័គ្រចិត្ត | 81.70% | 87.80% | 85.70% | 86.04% | 81.11% | 84.68% | 86.74% | 84.28% | 85.79% |

**រូប ៤១ : ការយល់ឃើញរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ទាក់ទង នឹងសិទ្ធិប្រកបរបរផ្លូវភេទដោយស្ម័គ្រចិត្ត**

*២. តើបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ដែលបក់ដៃហៅភ្ញៀវគួរដាក់ពិន័យដែរឬទេ?*

មាត្រា ២៤ នៃច្បាប់ថ្មីស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទចែងថា *"បុគ្គលទាំងឡាយណាដែលមានបំណងញ៉ោះញ៉ង់មនុស្សដទៃទៀតនៅតាមទីសាធារណៈឱ្យមករួមភេទជាមួយខ្លួន ត្រូវពិន័យជាការដាក់ពន្ធនាគារពី ១ ទៅ ៦ថ្ងៃ និងពិន័យជាទឹកប្រាក់ចំនួន ១០.០០០ រៀល"*។

ក្នុងចំណោម បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ការជំទាស់ និងការយល់ស្របទៅនឹងមាត្រា ២៤ នៃ LSHSE មានចំនួនស្មើគ្នា។ ការវិភាគតាមប្រភេទការងារបង្ហាញថា អ្នកដែលប្រកបរបររកស៊ីផ្លូវភេទដោយផ្ទាល់ ដូចជាអ្នករកស៊ីផ្លូវភេទដោយផ្ទាល់ ស្ត្រីម៉ាស្សា និងអ្នករកស៊ីផ្លូវភេទឯករាជ្យ មានភាគរយនៃការយល់

ស្រប និងមិនយល់ស្របទៅនឹងការលើកឡើងនេះ ក្នុងចំនួនមួយស្មើរតែដូចគ្នា។ ចំណែកឯការវិភាគតាមប្រភេទការងារបង្ហាញថាអ្នកដែលប្រកបរបររកស៊ីផ្លូវភេទ ដោយប្រយោល ដូចជាស្ត្រីខារ៉ាអូខេ និងស្ត្រីបំរើស្រាបៀរ យល់ស្របតាមមាត្រានេះតិចជាងក្រុមទាំង ៣ ខាងលើ។ ទោះបីជាយ៉ាងណា ស្ត្រីបំរើស្រាបៀរ មិនយល់ស្រប ច្រើនជាងស្ត្រីខារ៉ាអូខេ។




| | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្ត្រីស្រាបៀរ | សរុប | MSM | ស្រីស្រស់ | MSM/ស្រីស្រស់ |
|---|---|---|---|---|---|---|---|---|---|
| មិនដឹង | 9.35 | 4.88 | 7.14 | 21.22 | 23.33 | 15.68% | 10.50% | 8.30% | 9.64% |
| មិនយល់ស្រប | 42.68 | 47.97 | 47.62 | 39.01 | 45.56 | 42.03% | 67.40% | 74.67% | 70.22% |
| យល់ស្រប | 47.97 | 47.15 | 45.24 | 39.77 | 31.11 | 42.29% | 22.10% | 17.03% | 20.14% |

**រូប ៤២ : ការយល់ឃើញរបស់** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ **ទាក់ទងនឹងសេចក្តីបង្គាប់ជាសាធារណៈ (ការបក់ដៃហៅភ្ញៀវ)**

បុរសស្រឡាញ់បុរស និងស្រីស្រស់ មិនយល់ស្របទាល់តែសោះទៅលើការលើកឡើងក្នុងមាត្រា ២៤ថ្មីនៃច្បាប់ស្តីពីការជួញដូរមនុស្ស (បុរសស្រឡាញ់បុរស ៦៧ភាគរយ និង ស្រីស្រស់៧៤ភាគរយ)។

**ការវិភាគតាមតំបន់របស់**បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ

បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនៅរាជធានីភ្នំពេញ និងខេត្តសៀមរាបមានលំនាំនៃការយល់ឃើញស្រដៀងគ្នា។ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយប្រមាណ ១ភាគ ៣ យល់ស្របថា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ដែលបក់ដៃហៅភ្ញៀវគួរត្រូវដាក់ពិន័យ ចំណែកឯប្រមាណពាក់កណ្តាលនៃអ្នកទាំងនោះមិនយល់ស្របលើការដាក់ពិន័យទេ។ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយប្រមាណ៨០ភាគរយនៅខេត្តបន្ទាយមានជ័យ យល់ស្របលើការដាក់ពិន័យ ចំណែកឯនៅខេត្តព្រះសីហនុវិញ មានបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយប្រមាណ២០ភាគរយប៉ុណ្ណោះដែលយល់ស្រប។ ជាក់ស្តែងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយមិនបានដឹងអំពីមាត្រា ២៤ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ដោយសារចំនួនពាក់កណ្តាលនៃអ្នកទាំងនោះ មិនបានដឹងអំពីការបង្កើតមាត្រាថ្មីនេះ។

តើ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ដែលបក់ដៃហៅភ្ញៀវ គួរដាក់ពិន័យដែរឬទេ?




| | SRP | BMC | SHV | PNP | Total |
|---|---|---|---|---|---|
| មិនដឹង | 9.85 | 4.80 | 51.80 | 5.68 | 15.68 |
| មិនយល់ស្រប | 54.38 | 13.20 | 26.58 | 61.62 | 42.03 |
| យល់ស្រប | 35.77 | 82.00 | 21.62 | 32.70 | 42.29 |

**រូប ៤៣ : ការយល់ឃើញរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ទាក់ទង នឹងសេចក្តីបង្គាប់ជាសាធារណៈតាមតំបន់ដែលយកមកសិក្សា**

*៣. ការយល់ឃើញរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ស្តីពីកត្តាសំខាន់ៗពាក់ព័ន្ធនឹងការទទួលបានសេវាជាសកល (សំណួរទី ៥០)*

តាមចម្លើយរបស់អ្នកផ្តល់សម្ភាសបង្ហាញថា ការមើលងាយ និងការរើសអើងចំពោះ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ កង្វះការតំណាងក្នុងកម្មវិធីអភិវឌ្ឍ កង្វះការសម្របសម្រួលពីបណ្តាភាគីពាក់ព័ន្ធដើម្បីធ្វើការជាមួយ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន កង្វះការចូលរួមក្នុងការប្រឆាំងការជួញដូរមនុស្ស ការបង្ក្រាបការជួញដូរគ្រឿងញៀន កង្វះបណ្តាញសិទ្ធិមនុស្សក្នុងការអនុវត្តន៍កម្មវិធីប្រើប្រាស់ស្រោមអនាម័យឱ្យបាន ១០០ភាគរយ ត្រូវបានរកឃើញថាជា កត្តាប្រឈមមួយដ៏ខ្ពស់ពាក់ព័ន្ធនឹងលទ្ធភាពទទួលបានសេវាជាសកល។ ការវិភាគ ANOVA ដោយប្រើប្រាស់ប្រភេទការងារជាកត្តាបង្ហាញចម្លើយខុសគ្នាខ្លាំងតែទៅលើការមើលងាយ និងការរើសអើង។ ចំណែកឯ ចម្លើយដទៃទៀត ចំពោះប្រភេទការងារមួយទៅប្រភេទការងារមួយទៀតមិនសូវខុសគ្នាប៉ុន្មានទេ។

**តារាង ១០ : កត្តាសំខាន់ៗពាក់ព័ន្ធនឹងការទទួលបានសេវាជាសកលរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ**

| ប្រភេទ EW/SWs | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | | ស្ត្រីម៉ាស្សា | | អ្នករកស៊ីផ្លូវភេទឯករាជ្យ | | ស្ត្រីខារ៉ាអូខេ | | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | | ANOVA |
|---|---|---|---|---|---|---|---|---|---|---|---|
| | WAI | OA | WAI | OA | WAI | OA | WAI | OA | WAI | OA | Sig. |
| ការមើលងាយ និងការរើសអើង រារាំង EW/SWs មិនឱ្យទទួលបានព័ត៌មាន និងសេវា | 0.91 | H | 0.87 | H | 0.79 | H | 0.86 | H | 0.82 | H | 0.001 |
| កង្វះតំណាង EW/SW ក្នុងការបង្កើតគោលនយោបាយ និងកម្មវិធី | 0.87 | H | 0.88 | H | 0.85 | H | 0.81 | H | 0.81 | H | 0.02 |
| កង្វះការសម្របសម្រួលរវាងថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន | 0.86 | H | 0.87 | H | 0.81 | H | 0.82 | H | 0.81 | H | 0.11 |
| កង្វះការចូលរួមក្នុងការប្រឆាំងការជួញដូរមនុស្ស ការទប់ស្កាត់គ្រឿងញៀន និងបណ្តាញសិទ្ធិមនុស្ស ក្នុងកម្មវិធីប្រើប្រាស់ស្រោមអនាម័យឱ្យបាន ១០០ភាគរយ | 0.9 | H | 0.87 | H | 0.81 | H | 0.85 | H | 0.87 | H | 0.06 |

ប្រភព : ការអង្កេតនៅកន្លែងអនុវត្តផ្ទាល់ ខែវិច្ឆិកា ឆ្នាំ២០០៨

ចម្លើយរបស់បុរសស្រឡាញ់បុរស និងស្រីស្រស់ ដែលជាអ្នកផ្តល់សម្ភាសមានពិន្ទុខ្ពស់សម្រាប់គ្រប់សំណួរ ដែលដូចគ្នាទៅនឹងការសាកសួរបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ។ ការវិភាគដោយប្រើ ANOVA បង្ហាញថា ចម្លើយដែលផ្តល់ដោយបុរសស្រឡាញ់បុរស និងស្រីស្រស់ មិនសូវខុសគ្នាប៉ុន្មានទេ។

**តារាង ១១ : កត្តាសំខាន់ៗពាក់ព័ន្ធនឹងការទទួលបានសេវាជាសកលរបស់បុរសស្រឡាញ់បុរស និងស្រីស្រស់**

| ប្រភេទ MSM/Transgender | MSM | | ស្រីស្រស់ | | ANOVA |
|---|---|---|---|---|---|
| | WAI | OA | WAI | OA | Sig. |
| ការមើលងាយ និងការរើសអើង រាំងEW/SWs មិនឱ្យទទួលបានព័តិមាន និងសេវា<br>កង្វះតំណាង EW/SW ក្នុងការបង្កើតគោលនយោបាយ និងកម្មវិធី | 0.91 | H | 0.92 | H | 0.777 |
| កង្វះការសម្របសម្រួលរវាងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន | 0.89 | H | 0.85 | H | 0.032 |
| ការមើលងាយ និងការរើសអើង រាំងEW/SWs មិនឱ្យទទួលបានព័តិមាន និងសេវា<br>កង្វះតំណាង EW/SW ក្នុងការបង្កើតគោលនយោបាយ និងកម្មវិធី | 0.88 | H | 0.84 | H | 0.016 |
| កង្វះការសម្របសម្រួលរវាងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន | 0.91 | H | 0.88 | H | 0.118 |

ប្រភព : ការអង្កេតនៅកន្លែងអនុវត្តផ្ទាល់ ខែវិច្ឆិកា ឆ្នាំ២០០៨

កំណត់សម្គាល់ : ការវិភាគរួម (OA), ខ្ពស់ (H) = 1.00 – 0.66; មធ្យម (N) = 0.65 - 0.33; ទាប (L) = 0.32 - 0.00

## ២. ការអនុវត្តជាក់ស្តែងលើគោលនយោបាយ

*១. តើអ្នកធ្លាប់ឃើញអាជ្ញាធរដាក់ពិន័យអតិថិជនរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ដែរឬទេ?*

តាមរយៈប្រភេទការងារគេដឹងថាជាង៨០ភាគរយនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទទាំងអស់មិនដែលឃើញអាជ្ញាធរដាក់ពិន័យអតិថិជនរបស់ខ្លួនទេ។ ចំណែកឯភាគរយនៃបុរសស្រឡាញ់បុរស និងស្រីស្រស់ ដែលមិនធ្លាប់ឃើញអាជ្ញាធរដាក់ពិន័យដល់ អតិថិជនរបស់ខ្លួន ក៏មានលក្ខណៈស្រដៀងគ្នានេះផងដែរ។




| | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | អ្នករកស៊ីផ្លូវភេទទាំងអស់ | MSM | ស្រីស្រស់ | MSM/ស្រីស្រស់ទាំងអស់ |
|---|---|---|---|---|---|---|---|---|---|
| ដែលឃើញ | 82.11 | 85.37 | 80.95 | 84.13 | 85.56 | 83.42 | 85.08% | 79.91% | 83.08% |
| មិនដែលឃើញ | 17.89 | 14.63 | 19.05 | 15.87 | 14.44 | 16.58 | 14.92% | 20.09% | 16.92% |

**រូប ៤៤ :ការយល់ឃើញរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់  ទាក់ទងនឹងការដាក់ពិន័យអតិថិជនដោយអាជ្ញាធរ**

*២. តើកងឯកសណ្ឋាន និងអាជ្ញាធរមូលដ្ឋាន ពិតជាបានបំបែកក្រុមអ្នកដែលត្រូវបានជួញដូរ និងអ្នករកស៊ីផ្លូវភេទ ដោយស្ម័គ្រចិត្តដែរឬទេ?*

**បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ:** ការវិភាគតាមតំបន់បង្ហាញថា កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរមូលដ្ឋាន មិនបានបំបែកក្រុមអ្នកដែលត្រូវបានជួញដូរ និងអ្នកដែលត្រូវបានកេងប្រវ័ញ្ចផ្លូវភេទចេញពីអ្នករកស៊ីផ្លូវភេទដោយស្ម័គ្រចិត្តទេ។ លំនាំនៃការផ្តល់ចម្លើយនៅខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងរាជធានីភ្នំពេញ គឺប្រហាក់ប្រហែលគ្នា។ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនៅខេត្តព្រះសីហនុ ជាង៧០ភាគរយ មិនបានដឹងអំពីបញ្ហានេះប៉ុន្តែបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទប្រមាណ ១១ភាគរយ លើកឡើងថា នៅពេលមានអន្តរាគមន៍កើតឡើងការបំបែកក្រុមចេញពីគ្នាមិនមានភាពច្បាស់លាស់ឡើយ។ តាមការសង្កេតរួមបង្ហាញថា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយប្រមាណ ១៣ភាគរយប៉ុណ្ណោះ ដែលបានយល់ស្របថា រវាងអ្នកដែលត្រូវបានកេងប្រវ័ញ្ចផ្លូវភេទ និងអ្នករកស៊ីផ្លូវដោយខ្លួនឯងត្រូវបានបំបែកចេញពីគ្នាឱ្យបានច្បាស់។

សំណួរ ៣៣ : តើសេវាកងកម្លាំងប្រដាប់អាវុធនិងអាជ្ញាធរមូលដ្ឋានពិតជាបានបំបែកអ្នកដែលត្រូវបានជួញដូរ និងអ្នករកស៊ីផ្លូវភេទដោយស្ម័គ្រចិត្តមែនឬយ៉ាងណា?




| | សៀមរាប | បន្ទាយមានជ័យ | ព្រះសីហនុ | ភ្នំពេញ | សរុប |
|---|---|---|---|---|---|
| មិនដឹង | 25.55% | 23.20% | 73.42% | 20.81% | 32.97% |
| មិនបានបំបែក | 53.28% | 68.00% | 15.77% | 69.19% | 54.39% |
| បានបំបែក | 21.17% | 8.80% | 10.81% | 10.00% | 12.63% |

រូប ៤៥ : ការយល់ឃើញរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ទាក់ទងនឹងការបំបែកអ្នកដែលត្រូវបានជួញដូរ និងអ្នកដែលមិនត្រូវបានជួញដូរដោយកងកម្លាំងប្រដាប់អាវុធនិងអាជ្ញាធរមូលដ្ឋាន

**បុរសស្រឡាញ់បុរស និងស្រីស្រស់:** ចម្លើយដែលផ្តល់ដោយបុរសស្រឡាញ់បុរស និងស្រីស្រស់នៅខេត្តសៀមរាប បន្ទាយមានជ័យ និងខេត្តព្រះសីហនុ មានលក្ខណៈស្រដៀងគ្នា។ ទោះបីជាយ៉ាងនេះក្តី អ្នកផ្តល់ចម្លើយនៅរាជធានីភ្នំពេញបានលើកឡើងថាខ្លួនមិនអាចញែកឱ្យដាច់ពីគ្នារវាងអ្នកដែលត្រូវបានជួញដូរ និងអ្នករកស៊ីផ្លូវភេទដោយស្ម័គ្រចិត្តឡើយ ។

បុរសស្រឡាញ់បុរសនិងស្រីស្រស់ : តើសេវាកងកម្លាំងប្រដាប់អាវុធនិងអាជ្ញាធរមូលដ្ឋានពិតជាបានបំបែកអ្នកដែលត្រូវបានជួញដូរ និងអ្នករកស៊ីផ្លូវភេទដោយស្ម័គ្រចិត្តមែនឬយ៉ាងណា?




| | សៀមរាប | បន្ទាយមានជ័យ | ព្រះសីហនុ | ភ្នំពេញ | សរុប |
|---|---|---|---|---|---|
| មិនដឹង | 26.88% | 31.61% | 31.61% | 12.63% | 25.04% |
| មិនបានបំបែក | 48.75% | 45.98% | 45.98% | 78.95% | 57.19% |
| បានបំបែក | 24.38% | 22.41% | 22.41% | 8.42% | 17.77% |

រូប ៤៦ : ការយល់ឃើញរបស់បុរសស្រឡាញ់បុរស និងស្រីស្រស់ទាក់ទងនឹងការបំបែកអ្នកដែលត្រូវបានជួញដូរ និងអ្នកដែលមិនត្រូវ បានជួញដូរដោយកងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរមូលដ្ឋាន

## គោលបំណង ៣ ៖ ការវាយតម្លៃភាពគ្របដណ្តប់ និងសេវាប្រកបដោយគុណភាពពាក់ព័ន្ធនឹងលទ្ធភាពទទួលបានជាសកលសម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ

### ១. កំរិតគ្របដណ្តប់នៃសេវា

*១.១. អត្រានៃការប្រើប្រាស់ស្រោមអនាម័យ*

អត្រានៃការប្រើប្រាស់ស្រោមអនាម័យខាងក្រោមបានគណនាចេញពីចម្លើយដែលសួរពីចំនួនដៃគូដែលបានរួមភេទជាមួយគ្នាកាលពីសប្តាហ៍មុន និងការប្រើស្រោមអនាម័យជាមួយដៃគូម្នាក់ៗ។ តាមការសង្កេតជារួម អត្រានៃការប្រើស្រោមអនាម័យគ្រប់ប្រភេទនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ជាមួយអតិថិជនដែលបង់ប្រាក់គឺពី៨៨ ទៅ ៩៩ភាគរយ ជាមួយគូសង្សារ ពី ៧០ ទៅ ៩១ភាគរយ និងជាមួយស្វាមី និងអ្នករស់នៅជាមួយគ្នាដោយមិនបានរៀបការ ពី ៤១ ទៅ ៧៨ភាគរយ។ អត្រានៃការប្រើស្រោមអនាម័យ គឺ៧០ភាគរយសម្រាប់ស្ត្រីខារ៉ាអូខេ និង៧៨ ភាគរយសម្រាប់ស្ត្រីបំរើស្រាបៀរក្នុងការរួមភេទជាមួយគូសង្សារ។




| | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | EWs ទាំងអស់ |
|---|---|---|---|---|---|---|
| ស្វាមី/អ្នករស់នៅជាមួយគ្នាដោយមិនការ | 58.00% | 41.00% | 58.00% | 44.00% | 78.00% | 51.00% |
| គូសង្សារ | 90.00% | 91.00% | 91.00% | 70.00% | 78.00% | 83.00% |
| អតិថិជនដែលបង់ប្រាក់ | 99.00% | 88.00% | 98.00% | 90.00% | 89.00% | 97.00% |

**រូប ៤៧ ៖ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ អត្រាប្រើប្រាស់ស្រោមអនាម័យជាមួយប្រភេទដៃគូផ្សេងៗគ្នា**

អត្រាប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមបុរសស្រឡាញ់បុរស (សក់ខ្លី) គឺលើសពី ៨០ភាគរយ។ អត្រាការប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមស្រីស្រស់ (សក់វែង) ជាមួយដៃគូ គឺលើសពី ៨០ភាគរយ លើកលែងតែការរួមភេទជាមួយដៃគូបុរសដែលមិនបង់ប្រាក់គឺ ៦៩ភាគរយ។




| | MSM (សក់ខ្លី) | ស្រីស្រស់ (សក់វែង) | MSM និងស្រីស្រស់ |
|---|---|---|---|
| ដៃគូបុរសដែលមិនផ្តល់កម្រៃ | 84.91% | 65.48% | 74.14% |
| ដៃគូបុរសដែលផ្តល់កម្រៃ | 91.52% | 86.94% | 89.32% |
| ដៃគូស្ត្រីដែលមិនផ្តល់កម្រៃ | 89.41% | 83.33% | 89.01% |
| ស្ត្រីរកស៊ីផ្លូវភេទ (D/ID) | 90.91% | NA | 90.91% |
| បុរសរកស៊ីផ្លូវភេទ | 89.80% | 86.84% | 88.51% |
| ស្រីស្រស់ | 85.37% | NA | 85.37% |

**រូប ៤៨ : បុរសស្រឡាញ់បុរស និងស្រីស្រស់ : អត្រាប្រើប្រាស់ស្រោមអនាម័យជាមួយប្រភេទដៃគូផ្សេងៗគ្នា**

*១.២. មិត្តអប់រំមិត្ត*

**ក. តើអ្នកទទួលបានការបណ្តុះបណ្តាលពីក្រុមមិត្តអប់រំមិត្តញឹកញាប់កម្រិតណា? (សំណួរទី ៤០)**

បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ក្នុងខេត្តសៀមរាប បន្ទាយមានជ័យ ក្នុងចំនួនតិចតួចបំផុតដែលទទួលបានការបណ្តុះបណ្តាលពីក្រុមអប់រំមិត្ត។ ដោយឡែកកំរិតគ្របដណ្តប់នេះ បានកើនឡើង នៅខេត្តព្រះសីហនុ ចំណែកឯនៅរាជធានីភ្នំពេញបានថយចុះបន្តិចបន្តួច។ កំរិតគ្របដណ្តប់ជារួមក្នុងខេត្តក្រុងទាំង ៤ បានកើនឡើងបន្តិចពោលគឺពី ៦៣ភាគរយ ក្នុងឆ្នាំ ២០០៧ ទៅ ៦៥ភាគរយ ក្នុងឆ្នាំ ២០០៨។ គួរកត់សម្គាល់ផងដែរថា កំរិតគ្របដណ្តប់ក្នុងខេត្តសៀមរាបក្នុងឆ្នាំ ២០០៧ និងឆ្នាំ ២០០៨ មានកម្រិត មួយទាបបើធៀបទៅនឹងតំបន់ដទៃទៀត (ត្រឹមតែ ៣១ភាគរយ ទាំងនៅឆ្នាំ ២០០៧ និង ឆ្នាំ ២០០៨) ។




**រូប ៤៩ : កំរិតគ្របដណ្តប់នៃកម្មវិធីមិត្តអប់រំមិត្តក្នុងឆ្នាំ ២០០៧ និង ២០០៨**

កំរិតគ្របដណ្តប់នៃកម្មវិធីមិត្តអប់រំមិត្តសម្រាប់បុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងខេត្តសៀមរាប ក៏មានកម្រិតទាបដែរ ក្នុងឆ្នាំ ២០០៧ (៥៣ភាគរយ) និងឆ្នាំ ២០០៨ (៤៩ភាគរយ)។ សម្រាប់តំបន់ដទៃទៀត ភាពគ្របដណ្តប់ ខុសគ្នាពី ៧៩ ទៅ ៩៤ភាគរយ។




**រូប ៥០ : កំរិតគ្របដណ្តប់នៃកម្មវិធីមិត្តអប់រំមិត្តសម្រាប់ បុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងឆ្នាំ ២០០៧ និងឆ្នាំ២០០៨**

### ខ. ចំណាប់អារម្មណ៍លើកម្មវិធីមិត្តអប់រំមិត្ត (សំណួរទី ៤១)

បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ: ការវិភាគតាមតំបន់បង្ហាញថា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ នៅខេត្តបន្ទាយមានជ័យ ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញចាប់អារម្មណ៍លើកម្មវិធីនេះខ្លាំង។ ចំណែកឯបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនៅខេត្តសៀមរាប ចាប់អារម្មណ៍លើ

កម្មវិធីនេះក្នុងកម្រិតធម្មតា។ ការវិភាគ ANOVA បង្ហាញថា រវាងតំបន់ និងចំណាប់អារម្មណ៍ លើកម្មវិធីមិត្តអប់រំមិត្តមានភាពខុសគ្នាខ្លាំង។

**តារាង ១២ : ចំណាប់អារម្មណ៍របស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ លើកម្មវិធីមិត្តអប់រំមិត្តតាមតំបន់ យកមកសិក្សា**

| ខេត្តក្រុង | សៀមរាប | | បន្ទាយមានជ័យ | | ព្រះសីហនុ | | ភ្នំពេញ | | ANOVA |
|---|---|---|---|---|---|---|---|---|---|
| | WAI | OA | WAI | OA | WAI | OA | WAI | OA | Sig. |
| ការចាប់អារម្មណ៍លើកម្មវិធីមិត្តអប់រំមិត្ត | 0.78 | I | 0.90 | HI | 0.83 | HI | 0.82 | HI | 0.000** |

ប្រភព : ការអង្កេតនៅកន្លែងអនុវត្តផ្ទាល់ ខែវិច្ឆិកា ឆ្នាំ២០០៨

កំណត់សម្គាល់ : ការវិភាគរួម (OA), ខ្ពស់ (H) = 1.00 – 0.66; មធ្យម (N) = 0.65 - 0.33; ទាប (L) = 0.32 - 0.00

ការវិភាគតាមប្រភេទការងារបង្ហាញថា អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ ស្ត្រីម៉ាស្សា ស្ត្រីខារ៉ាអូខេ និងស្ត្រី បំរើស្រាបៀរ ចាប់អារម្មណ៍លើកម្មវិធីនេះខ្លាំង។ អ្នករកស៊ីផ្លូវភេទឯករាជ្យ ក៏ចាប់អារម្មណ៍លើកម្មវិធីនេះដែរ។ ការវិភាគ ANOVA បង្ហាញថា រវាងប្រភេទការងារ និងការចាប់អារម្មណ៍លើកម្មវិធីមិត្តអប់រំមិត្ត មិនខុសគ្នាខ្លាំង ទេ។

**តារាង ១៣ : ចំណាប់អារម្មណ៍របស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ លើកម្មវិធីមិត្តអប់រំមិត្តតាម ប្រភេទការងារ**

| ខេត្តក្រុង | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | | ស្ត្រីម៉ាស្សា | | អ្នករកស៊ីផ្លូវភេទឯករាជ្យ | | ស្ត្រីខារ៉ាអូខេ | | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | | ANOVA |
|---|---|---|---|---|---|---|---|---|---|---|---|
| | WAI | OA | WAI | OA | WAI | OA | WAI | OA | WAI | OA | OA |
| ការចាប់អារម្មណ៍លើកម្មវិធីមិត្តអប់រំមិត្ត | 0.83 | HI | 0.85 | HI | 0.80 | I | 0.83 | HI | 0.85 | HI | 0.000*** |

ប្រភព : ការអង្កេតនៅកន្លែងអនុវត្តផ្ទាល់ ខែវិច្ឆិកា ឆ្នាំ២០០៨

កំណត់សម្គាល់ : ការវិភាគរួម (OA), ខ្ពស់ (H) = 1.00 – 0.66; មធ្យម (N) = 0.65 - 0.33; ទាប (L) = 0.32 - 0.00

## បុរសស្រឡាញ់បុរស និងស្រីស្រស់

ការវិភាគតាមតំបន់បង្ហាញថាបុរសស្រឡាញ់បុរស និងស្រីស្រស់នៅគ្រប់បណ្តាខេត្តមានចំណាប់អារម្មណ៍លើកម្មវិធីមិត្តអប់រំមិត្ត លើកលែងតែនៅរាជធានីភ្នំពេញដោយពួកគេចាប់អារម្មណ៍លើកម្មវិធីនេះក្នុងកម្រិតមួយ។ ការវិភាគ ANOVA បង្ហាញថារវាងប្រភេទការងារ និងការចាប់អារម្មណ៍លើកម្មវិធីមិត្តអប់រំមិត្ត មានភាពខុសគ្នាខ្លាំង។

**តារាង ១៤ : ចំណាប់អារម្មណ៍របស់ បុរសស្រឡាញ់បុរស និងស្រីស្រស់ លើកម្មវិធីមិត្តអប់រំមិត្តតាមតំបន់**

| ខេត្តក្រុង | សៀមរាប | | បន្ទាយមានជ័យ | | ព្រះសីហនុ | | ភ្នំពេញ | | ANOVA |
|---|---|---|---|---|---|---|---|---|---|
| | WAI | OA | WAI | OA | WAI | OA | WAI | OA | Sig. |
| ចំណាប់អារម្មណ៍លើកម្មវិធីមិត្តអប់រំមិត្ត | 0.83 | HI | 0.90 | HI | 0.82 | HI | 0.770 | I | 0.000*** |

ប្រភព : ការអង្កេតនៅកន្លែងអនុវត្តផ្ទាល់ ខែវិច្ឆិកា ឆ្នាំ២០០៨

កំណត់សម្គាល់ : ការវិភាគរួម (OA), ខ្ពស់ (H) = 1.00 – 0.66; មធ្យម (N) = 0.65 - 0.33; ទាប (L) = 0.32 - 0.00

ការវិភាគតាមប្រភេទការងារបង្ហាញថា បុរសស្រឡាញ់បុរស និងស្រីស្រស់ ចាប់អារម្មណ៍លើកម្មវិធី មិត្តអប់រំមិត្តជាខ្លាំង ។ ការវិភាគ ANOVA បង្ហាញថា រវាងអនុក្រុមនានា បុរសស្រឡាញ់បុរស និងស្រីស្រស់ មានភាពខុសគ្នាខ្លាំង ។

**តារាង ១៥ : ចំណាប់អារម្មណ៍របស់បុរសស្រឡាញ់បុរស និងស្រីស្រស់ លើកម្មវិធីមិត្តអប់រំមិត្តតាមប្រភេទការងារ**

| ប្រភេទ MSM/ស្រីស្រស់ | MSM | | ស្រីស្រស់ | | | ANOVA |
|---|---|---|---|---|---|---|
| | WAI | OA | WAI | | OA | Sig. |
| ចំណាប់អារម្មណ៍លើកម្មវិធីមិត្តអប់រំមិត្ត | 0.82 | HI | 0.84 | | HI | 0.001*** |

ប្រភព : ការអង្កេតនៅកន្លែងអនុវត្តផ្ទាល់ ខែវិច្ឆិកា ឆ្នាំ២០០៨

កំណត់សម្គាល់ : ការវិភាគរួម (OA), ខ្ពស់ (H) = 1.00 – 0.66; មធ្យម (N) = 0.65 - 0.33; ទាប (L) = 0.32 - 0.00

*៣. ការប្រើសេវា*

### ៣.១. ភាគរយនៃការប្រើសេវាដោយ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ? (សំណួរទី ៤២)

បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទការប្រើសេវាជំងឺកាមរោគ សម្រាប់អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ ស្រ្តីម៉ាស្សា អ្នករកស៊ីផ្លូវភេទឯករាជ្យ កើន ឡើងពី ៧២ភាគរយ ទៅ៨៣ភាគរយ ខ្ពស់ជាងក្រុមអ្នករកស៊ីផ្លូវភេទដោយប្រយោល ដូចជាក្រុម ស្រ្តីខារ៉ាអូខេ ៥៨ភាគរយ និងស្រ្តីឃោសនាស្រាបៀរ ៦១ភាគរយ ។ ការប្រើសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ក៏ដូចគ្នា ផងដែរ ពោលគឺភាគ

រយនៃក្រុមទាំងអស់ បានកើនឡើងពី ៧០ភាគរយ ទៅ៩០ភាគរយ។ ការប្រើ សេវារំលូតកូន មានកម្រិតខ្ពស់ក្នុងចំណោមអ្នករកស៊ីផ្លូវភេទឯករាជ្យ និងស្ត្រីបំរើស្រាបៀរ ពោលគឺអ្នករកស៊ីផ្លូវភេទឯករាជ្យ ១៧ភាគរយ និងស្ត្រីបំរើស្រាបៀរ ១១ភាគរយ។

តាមការសង្កេតជារួម ការប្រើសេវារបស់ **បុរសស្រឡាញ់បុរស និងស្រីស្រស់** មានកម្រិតតិចជាងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ។ ការប្រើសេវារបស់បុរសស្រឡាញ់បុរស និងស្រីស្រស់គឺតិចជាង ៥០ភាគរយ ចំណែកឯការប្រើសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់មាន ភាពខុសគ្នា ពោលគឺក្រុមបុរសស្រឡាញ់បុរស ៧១ភាគរយ និងស្រីស្រស់ ៧៦ភាគរយ។




| | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | អ្នករកស៊ីផ្លូវភេទទាំងអស់ | MSM | ស្រីស្រស់ | MSM/ស្រីស្រស់ទាំងអស់ |
|---|---|---|---|---|---|---|---|---|---|
| STI | 82% | 72% | 83% | 58% | 61% | 68% | 45% | 49% | 46% |
| VCCT | 89% | 80% | 90% | 70% | 77% | 78% | 71% | 76% | 73% |
| ស្រោមឥតគិតថ្លៃ | 72% | 50% | 57% | 47% | 49% | 55% | 49% | 58% | 53% |
| PMTCT | 6% | 6% | 13% | 4% | 11% | 6% | 0% | 0% | 0% |
| រំលូតកូន | 4% | 5% | 17% | 9% | 11% | 9% | 0% | 0% | 0% |

**រូប ៥១ : សេវាដែលប្រើដោយបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនិង បុរសស្រឡាញ់បុរស និងស្រីស្រស់ តាមប្រភេទការងារ**

ការវិភាគតាមតំបន់ រកឃើញថា ការប្រើសេវាជំងឺកាមរោគ ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ និងស្រោមអនាម័យដោយឥតគិតថ្លៃ នៅខេត្ត បន្ទាយមានជ័យ ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញមានភាពខុសគ្នាពី ៦០ ទៅ៨៨ភាគរយ។ ការប្រើសេវាទាំងនេះ នៅខេត្តសៀមរាប មានកម្រិតទាប ពោលគឺពី ៤៤ ទៅ៦១ភាគរយ។ គួរកត់សម្គាល់ថា ការប្រើសេវារំលូតកូននៅ ខេត្តព្រះសីហនុ មានកម្រិតខ្ពស់បំផុត ពោលគឺ ២២ភាគរយ។




**តារាង ៥២ : សេវាដែលប្រើដោយ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទតាមតំបន់យកមកសិក្សា**

ក្នុងចំណោម**បុរសស្រឡាញ់បុរស និងស្រីស្រស់** ការប្រើសេវាសុខភាពទាំងអស់នៅខេត្តបន្ទាយមានជ័យ មានកម្រិតទាប ចំណែកឯបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅខេត្តព្រះសីហនុបានលើកឡើងថាពួកគេបានប្រើសេវាទាំងអស់ក្នុងកម្រិតមួយខ្ពស់ លើកលែងតែសេវាជំងឺកាមរោគ ។ ការប្រើសេវាជំងឺកាមរោគនិងសេវាសំចត នៅរាជធានីភ្នំពេញមានកម្រិតខ្ពស់ ។ ទោះបីជាយ៉ាងនេះក្តី ការប្រើសេវានៅគ្រប់តំបន់ទាំងអស់មានកម្រិតទាបជាង ៨០ភាគរយ ។




| | សៀមរាប | បន្ទាយមានជ័យ | ព្រះសីហនុ | ភ្នំពេញ | សរុប |
|---|---|---|---|---|---|
| STI | 37.50% | 37.93% | 22.39% | 70.00% | 44.75% |
| VCCT | 65.63% | 64.94% | 91.04% | 79.47% | 70.72% |
| ស្រោមឥតគិតថ្លៃ | 73.75% | 22.99% | 80.60% | 52.11% | 49.17% |
| មណ្ឌលសំចត | 29.38% | 4.02% | 35.82% | 37.37% | 21.27% |
| ART/OI | 1.88% | 0.00% | 0.00% | 5.26% | 2.49% |
| ចំណីអាហារ | 0.63% | 0.00% | 0.00% | 4.21% | 1.38% |
| ផ្សេងៗ | 1.25% | 0.00% | 1.49% | 5.79% | 1.66% |

**រូប ៥៣ : សេវាដែលប្រើដោយបុរសស្រឡាញ់បុរស និងស្រីស្រស់ តាមតំបន់យកមកសិក្សា**

### ខ. ការប្រើសម្ភារៈដែលផ្តល់ដោយសេវាដោយជំងឺកាមរោគក្នុងឆ្នាំ២០០៨? (សំណួរទី ៤៣)

តាមរយៈទិន្នន័យដែលប្រមូលបានក្នុងខេត្តទាំង ៤ បង្ហាញថា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ប្រើសេវាជំងឺកាមរោគភាគច្រើន ដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល (៥០ភាគរយ) និងគ្លីនិកជំងឺកាមរោគ របស់រដ្ឋ។ ការប្រើសេវាជំងឺកាមរោគនៅតាមគ្លីនិកឯកជន មានចំនួន ៥ភាគរយ និងការព្យាបាលដោយខ្លួនឯងមាន ចំនួន ២ភាគរយ ។




**រូប ៥៤ : ទីកន្លែងដែល បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទស្វែងរកសេវាព្យាបាលជំងឺកាមរោគ**

ការវិភាគតារាងឆ្លង តាមប្រភេទការងារបង្ហាញថាស្ត្រីបំរើស្រាបៀរ ប្រើសេវាជំងឺកាមរោគ នៅតាមគ្លីនិកច្រើន ជាងក្រុមដទៃទៀត (១៩ភាគរយ) ។ អ្នករស់នៅខេត្តបន្ទាយមានជ័យ ប្រើសេវាជំងឺកាមរោគ នៅតាមគ្លីនិកឯកជន ច្រើនជាងក្រុមដទៃក្នុងខេត្តផ្សេងទៀត ។

ការប្រើសេវាជំងឺកាមរោគដោយ បុរសស្រឡាញ់បុរស និងស្រីស្រស់មិនខុសគ្នាពីបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទប៉ុន្មានឡើយ ពោលគឺអ្នកទាំងនោះប្រើ សេវាជំងឺកាមរោគដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលច្រើនជាងរបស់រដ្ឋ ។




**រូប ៥៦ : កន្លែងដែលបុរសស្រឡាញ់បុរស និងស្រីស្រស់ ស្វែងរកសេវាព្យាបាល**ជំងឺកាមរោគ

### គ. ភាពគ្របដណ្តប់នៃការប្រើសេវាជំងឺកាមរោគ ក្នុងឆ្នាំ២០០៧ និងឆ្នាំ២០០៨ (សំណួរទី ៤៣)

ភាពគ្របដណ្តប់នៃសេវាជំងឺកាមរោគ និង ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ **ក្នុងចំណោម** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទមានការកើនឡើងនៅគ្រប់ខេត្តលើកលែងតែនៅរាជធានីភ្នំពេញ។ ការគ្របដណ្តប់នៃសេវា ទាំងពីរនេះនៅខេត្តបន្ទាយមានជ័យ និង ខេត្តព្រះសីហនុមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ទោះបីជាយ៉ាងណាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនៅខេត្តសៀមរាប មិនសូវទទួលបានសេវាទាំងនេះដូចបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនៅខេត្តក្រុងដទៃទៀតទេ។ តួលេខរួមបញ្ចូលគ្នាក្នុងខេត្តទាំង៤បង្ហាញថាការប្រើសេវាជំងឺកាមរោគបានកើនឡើងពី ៥៦ភាគរយក្នុងឆ្នាំ២០០៧ ទៅ៦២ភាគរយក្នុងឆ្នាំ ២០០៨ ចំណែកឯការប្រើសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់បានកើនឡើងពី ៦១ភាគរយ ក្នុងឆ្នាំ២០០៧ ទៅ ៦៧ភាគរយ ក្នុងឆ្នាំ២០០៨។

**សំណួរទី ៤៤ : សេវាជំងឺកាមរោគនិង ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ដែលប្រើដោយបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ឆ្នាំ២០០៧ និង ២០០៨**




**រូប ៥៧ : ការគ្របដណ្តប់នៃសេវាជំងឺកាមរោគនិង ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ដែលប្រើដោយបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទក្នុងឆ្នាំ២០០៧ និងឆ្នាំ២០០៨ តាមបណ្តាខេត្តក្រុង (សំណួរទី ៤៣)**

ការវិភាគតាមប្រភេទការងារ បង្ហាញថា ជាទូទៅការគ្របដណ្តប់នៃសេវាជំងឺកាមរោគនិង ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់សម្រាប់ក្រុមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយទាំងអស់មានការកើនឡើងលើកលែងអ្នករកស៊ីផ្លូវភេទឯករាជ្យ (សេវា ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ថយចុះ) ហើយស្ត្រីបំរើស្រាបៀរ (ការគ្របដណ្តប់នៃសេវាជំងឺកាមរោគនៅដដែល)។




**រូប ៩៨ : ការគ្របដណ្តប់នៃការប្រើសេវាជំងឺកាមរោគនិង ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ដោយបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទក្នុងឆ្នាំ២០០៧ និង ឆ្នាំ២០០៨ តាមប្រភេទការងារ (សំណួរទី ៤៣)**

សម្រាប់អ្នកដែលបានប្រើសេវាជំងឺកាមរោគនិង ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ការប្រើជាមធ្យមរបស់អ្នកទាំងនោះ បានថយចុះនៅគ្រប់ ខេត្តក្រុងទាំង ៤ លើកលែងតែសេវាជំងឺកាមរោគនៅរាជធានីភ្នំពេញ។




**រូប ៩៩ : ការប្រើសេវាជំងឺកាមរោគនិង ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ជាមធ្យមដោយបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទក្នុងឆ្នាំ២០០៧ និង ឆ្នាំ២០០៨ តាមប្រភេទតំបន់ (សំណួរទី ៤៣)**

ទោះបីជាការប្រើសេវានៅខេត្តបន្ទាយមានជ័យរបស់ក្រុម**បុរសស្រឡាញ់បុរស និងស្រីស្រស់** មានការកើនឡើង ប៉ុន្តែការគ្របដណ្តប់នៃសេវាជំងឺកាមរោគ និង ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់នៅមានកម្រិតទាបនៅឡើយ បើធៀបនឹងខេត្តដទៃទៀត។ នៅខេត្តសៀមរាប និងខេត្តព្រះសីហនុ ការប្រើសេវាទាំងនេះនៅដដែល។ ការប្រើសេវាជំងឺកាមរោគមានការកើនឡើង បន្តិចបន្តួច ហើយការប្រើសេវា ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់នៅរាជធានីភ្នំពេញ បានកើនឡើងតិចតួច។ ក្រៅពីសេវា ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់នៅខេត្តព្រះសីហនុ គ្រប់សេវា នៅគ្រប់តំបន់ទាំងអស់មានកម្រិតទាបជាង ៥០ភាគរយ។




**រូប ៦០ : ភាពគ្របដណ្តប់នៃការប្រើសេវាជំងឺកាមរោគនិង ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់សម្រាប់ បុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងឆ្នាំ២០០៧ និង ឆ្នាំ២០០៨ តាមបណ្តាខេត្តក្រុង**

តាមរយៈទិន្នន័យប្រមូលបានបង្ហាញថា ការគ្របដណ្តប់នៃសេវាជំងឺកាមរោគសម្រាប់បុរសស្រឡាញ់បុរស បានកើនឡើងពី ៣៨ ទៅ៤៣ភាគរយ។ ចំណែកឯការគ្របដណ្តប់នៃសេវា ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់សម្រាប់ស្រីស្រស់ បានកើនឡើង តិចតួច ពោលគឺពី ៦៤ ទៅ ៦៨ភាគរយ។

ទោះបីជាយ៉ាងណា ការប្រើគ្រប់សេវាទាំងអស់សម្រាប់ក្រុម បុរសស្រឡាញ់បុរស និង ស្រីស្រស់នៅមានកម្រិតក្រោម ៨០ភាគរយ ។




ស្ម័គ្រចិត្ត និងរក្សាការសម្ងាត់សម្រាប់ បុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងឆ្នាំ២០០៧ និង ឆ្នាំ២០០៨

ការពិនិត្យកាន់តែលម្អិតលើការប្រើសេវាជំងឺកាមរោគ និងផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ជាមធ្យមដោយ បុរសស្រឡាញ់បុរស និងស្រីស្រស់ បង្ហាញថាការប្រើគ្រប់ សេវាទាំងអស់មានការធ្លាក់ចុះ លើកលែងតែនៅខេត្តបន្ទាយមានជ័យ ។ នៅរាជធានីភ្នំពេញការប្រើសេវាជំងឺកាមរោគមិនប្រែប្រួល ចំណែកឯ ការប្រើសេវា ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់បានធ្លាក់ចុះបន្តិច ។



**រូប ៦២ : ការប្រើសេវាជំងឺកាមរោគនិង ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ជាមធ្យមដោយ បុរសស្រលាញ់បុរស,ស្រីស្រស់ ក្នុងឆ្នាំ២០០៧ និង ឆ្នាំ២០០៨ តាមតំបន់**

### ឃ. ការទំនាក់ទំនងជាមួយបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនិងបុរសស្រឡាញ់បុរស និងស្រីស្រស់ តាមរយៈកម្មវិធីអប់រំអំពីគ្រឿងញៀន និងក្រុមថៃទាំតាមផ្ទះក្នុងចំណោមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ

**បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ** ប្រមាណ ៥៥ ទៅ ៦១ភាគរយ នៅខេត្តបន្ទាយមានជ័យ ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ ត្រូវបានទំនាក់ទំនងដោយបុគ្គលិកផ្សព្វផ្សាយដែលធ្វើការងារ ទាក់ទងនឹងការបំពានគ្រឿងញៀន។ ដោយឡែក បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយប្រមាណ ៣២ភាគរយ ប៉ុណ្ណោះ ដែលបុគ្គលិកផ្សព្វផ្សាយអាចទំនាក់ទំនងបាន។

ការទំនាក់ទំនងដោយក្រុមថៃទាំតាមផ្ទះ (ការថៃទាំតាមផ្ទះ) នៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យមានកម្រិតទាបពោលគឺប្រមាណ ១៦ភាគរយ នៅខេត្តព្រះសីហនុ កម្រិតមធ្យម ប្រមាណ ៣០ ភាគរយ និងកម្រិតខ្ពស់នៅរាជធានីភ្នំពេញ។




**រូប ៦៣ : ការឈានទៅរកការអប់រំអំពីគ្រឿងញៀន និងការថៃទាំតាមផ្ទះនៅតាមតំបន់**

ស្ត្រីម៉ាស្សា អ្នករកស៊ីផ្លូវភេទឯករាជ្យ ស្ត្រីខារ៉ាអូខេ និងស្ត្រីបំរើស្រាបៀរ ប្រមាណពី ៤៤ ទៅ៥២ ភាគរយ ត្រូវបានបុគ្គលិកផ្សព្វផ្សាយដែលធ្វើការពាក់ព័ន្ធនឹងការបំពានគ្រឿងញៀនទំនាក់ទំនងផ្សព្វផ្សាយ។ ទោះបីជាយ៉ាងណា អ្នករកស៊ីផ្លូវភេទឯករាជ្យ ៦៥ភាគរយ ត្រូវបានបុគ្គលិកផ្សព្វផ្សាយទំនាក់ទំនង។

ការទំនាក់ទំនងដោយក្រុមថែទាំតាមផ្ទះ មានកម្រិតខ្ពស់ចំពោះអ្នកទាំងឡាយណាដែលប្រកបរបររកស៊ីផ្លូវភេទដោយផ្ទាល់ (ពី២៨ ទៅ៤៣ភាគរយ) និងមានកម្រិតទាបសម្រាប់អ្នកប្រកបរបររកស៊ីផ្លូវភេទដោយប្រយោល (១៩ភាគរយ សម្រាប់ស្ត្រីខារ៉ាអូខេ និង ២២ភាគរយ សម្រាប់ស្ត្រីបំរើស្រាបៀរ) ។




**រូប ៦៤ : ការឈានទៅអប់រំអំពីគ្រឿងញៀន និងការថែទាំតាមផ្ទះដល់**
**បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ/រកស៊ីផ្លូវភេទ តាមប្រភេទការងារ**

ការឈានទៅរក បុរសស្រឡាញ់បុរស និងស្រីស្រស់ តាមរយៈកម្មវិធីអប់រំអំពីគ្រឿងញៀន មានភាពខុសគ្នាពី៤២ភាគរយ ក្នុងខេត្តព្រះសីហនុ ទៅ៦៦ភាគរយក្នុងរាជធានីភ្នំពេញ។ ការទំនាក់ទំនងបុរសស្រឡាញ់បុរស និងស្រីស្រស់ដោយក្រុមថែទាំតាមផ្ទះមានភាពខុសគ្នាខ្លាំង ពោលគឺ ៥៥ភាគរយធៀបនឹង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយប្រមាណ ៧ភាគរយ ប៉ុណ្ណោះនៅខេត្តបន្ទាយមានជ័យ ។



រូប ៦៥ : ការឈានទៅអប់រំក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ តាមតំបន់ដោយក្រុមអប់រំអំពីគ្រឿងញៀន និងការថែទាំតាមផ្ទះ

ការវិភាគតាមប្រភេទការងារបង្ហាញថា ៥៤ភាគរយនៃក្រុមបុរសស្រឡាញ់បុរសបានទទួលការអប់រំស្តីពីកម្មវិធីអប់រំគ្រឿងញៀន ចំណែកឯ ៥៨ភាគរយនៃស្រីស្រស់ ក៏បានទទួលដែរ។ ចំពោះការថែទាំ ព្យាបាល និងគាំទ្រក្រុម បុរសស្រឡាញ់បុរស (២០ភាគរយ) មិនសូវបានទទួលដូចស្រីស្រស់ (៣៥ភាគរយ) ឡើយ។




រូប ៦៦ : ការទំនាក់ទំនង បុរសស្រឡាញ់បុរស និងស្រីស្រស់ តាមរយៈការអប់រំអំពីគ្រឿងញៀន និងការថែទាំតាមផ្ទះ

### ង. ការបញ្ជូនទៅរកដៃគូ

ជាទូទៅភាគរយនៃការបញ្ជូនទៅរកដៃគូដោយបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទមានភាពខុសគ្នាតិចជាងការបញ្ជូនទៅរកដៃគូដោយ បុរសស្រឡាញ់បុរស និងស្រីស្រស់ ។ ក្នុងខេត្តព្រះសីហនុ ការបញ្ជូនទៅរកដៃគូជាបុរសស្រឡាញ់បុរស និងស្រីស្រស់ ស្ថិតក្នុងកម្រិតមួយខ្ពស់បំផុត។ ការបញ្ជូនទៅរកដៃគូសរុបសម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទមានចំនួន ២៦ភាគរយ និងសម្រាប់ស្រីស្រស់មានចំនួន ២២ភាគរយ។




**រូប ៦៧ : ការបញ្ជូនទៅរកដៃគូរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនិង បុរសស្រឡាញ់បុរស និងស្រីស្រស់តាមតំបន់**

**គុណភាពសេវា**

១. **ភាពរួសរាយរាក់ទាក់នៃបុគ្គលិកសុខភាពនៅគ្លីនិកជំងឺកាមរោគនិងមណ្ឌល** ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ (**សំណួរទី ៤៥**) បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ

តាមរយៈទិន្នន័យប្រមូលបាន និងការវិភាគតាមតំបន់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ គ្រប់ខេត្តក្រុងទាំងអស់និយាយថាបុគ្គលិកថែទាំសុខភាពនៅ គ្លីនិកជំងឺកាមរោគ និងមណ្ឌល ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ មានភាពរួសរាយចំពោះពួកគេ។ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ នៅខេត្តសៀមរាបបង្ហាញថាបុគ្គលិកថែទាំសុខភាព សម្រាប់សេវាទាំង ២ មានភាពរួសរាយចំពោះពួកគេ។ ការវិភាគ ANOVA ដោយប្រើតំបន់ជាកត្តាបង្ហាញថា រវាងសេវាដែលផ្តល់ដោយបុគ្គលិកថែទាំសុខភាព ទាំងនៅគ្លីនិកជំងឺកាមរោគ និងមណ្ឌល ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់មានភាពខុសគ្នាខ្លាំង។

**តារាង ១៦ : ការយល់ឃើញរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទចំពោះសេវាជំងឺកាមរោគ និងសេវា ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់តាមតំបន់**

| ខេត្តក្រុង | សៀមរាប | | បន្ទាយមានជ័យ | | ព្រះសីហនុ | | ភ្នំពេញ | | ANOVA |
|---|---|---|---|---|---|---|---|---|---|
| | WAI | OA | WAI | OA | WAI | OA | WAI | OA | Sig. |
| HCWs ក្នុងគ្លីនិកជំងឺកាមរោគ | 0.72 | F | 0.87 | VF | 0.83 | VF | 0.81 | VF | 0.000** |
| HCWs ក្នុងបណ្ឌុល VCCT | 0.74 | F | 0.86 | VF | 0.84 | VF | 0.81 | VF | 0.000** |

ប្រភព : ការអង្កេតនៅកន្លែងអនុវត្តផ្ទាល់ ខែវិច្ឆិកា ឆ្នាំ២០០៨

កំណត់ចំណាំ : ការវាយតម្លៃជារួម (OA), រួសរាយណាស់ (VF) = 1.00 - 0.81; រួសរាយ (F) = 0.80 - 0.61; ធម្មតា (N) = 0.60 - 0.41 ; រួសរាយខ្លះៗ (SR) = 0.40 - 0.21 ; មិនរួសរាយទាល់តែសោះ (NF) = 0.20 - 0.00

តាមរយៈទិន្នន័យប្រមូលបាន និងការវិភាគតាមប្រភេទការងារ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ គ្រប់ប្រភេទទាំងអស់ និយាយថាបុគ្គលិកថែទាំសុខភាព នៅគ្លីនិកជំងឺកាមរោគនិងមណ្ឌល ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់រួសរាយណាស់ចំពោះពួកគេ។ មានតែស្ត្រីខារ៉ាអូខេទេដែល យល់ថា បុគ្គលិកថែទាំសុខភាព នៅ គ្លីនិកជំងឺកាមរោគរួសរាយចំពោះពួកគេ។ ការវិភាគបែប ANOVA ដោយប្រើប្រភេទការងារ បង្ហាញថា រវាងសេវាដែលផ្តល់ដោយគ្លីនិកជំងឺកាមរោគនិងមណ្ឌល ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ មិនខុសគ្នាខ្លាំងទេ។

**តារាង ១៧ : ការយល់ឃើញរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ/អ្នករកស៊ីផ្លូវភេទ ចំពោះសេវាជំងឺកាមរោគ និង ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ តាមប្រភេទការងារ**

| ខេត្តក្រុង | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | | ស្ត្រីម៉ាស្សា | | អ្នករកស៊ីផ្លូវភេទឯករាជ្យ | | ស្ត្រីខារ៉ាអូខេ | | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | | ANOVA |
|---|---|---|---|---|---|---|---|---|---|---|---|
| | WAI | OA | WAI | OA | WAI | OA | WAI | OA | WAI | OA | Sig. |
| HCWs ក្នុងគ្លីនិក STI | 0.81 | VF | 0.81 | VF | 0.81 | VF | 0.79 | F | 0.82 | VF | 0.219 |
| HCWs ក្នុងបណ្ឌុល VCCT | 0.81 | VF | 0.81 | VF | 0.81 | VF | 0.81 | VF | 0.83 | VF | 0.437 |

ប្រភព : ការអង្កេតនៅកន្លែងអនុវត្តផ្ទាល់ ខែវិច្ឆិកា ឆ្នាំ២០០៨

កំណត់ចំណាំ : ការវាយតម្លៃជារួម (OA), រួសរាយណាស់ (VF) = 1.00 - 0.81; រួសរាយ (F) = 0.80 - 0.61; ធម្មតា (N) = 0.60 - 0.41 ; រួសរាយខ្លះៗ (SR) = 0.40 - 0.21 ; មិនរួសរាយទាល់តែសោះ (NF) = 0.20 - 0.00

### ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់

លទ្ធផលនៃការប្រមូលទិន្នន័យពី បុរសស្រឡាញ់បុរស និងស្រីស្រស់ បង្ហាញថាការថែទាំតាមផ្ទះ នៅគ្លីនិកជំងឺកាមរោគ និងមណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់មានភាពរួសរាយចំពោះពួកគេ។ ទោះបីជាយ៉ាងនេះក្តី ពិន្ទុរបស់ពួកគេតិចជាងក្រុម បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ។ ការវិភាគបែប ANOVA ដោយយកតំបន់ជាកត្តាបង្ហាញថា រវាងសេវាដែលផ្តល់ដោយការថែទាំតាមផ្ទះ នៅគ្លីនិកជំងឺកាមរោគនិងមណ្ឌល ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់មានភាពខុសគ្នា។

**តារាង ១៨ : ការយល់ឃើញរបស់ បុរសស្រឡាញ់បុរស និងស្រីស្រស់ ចំពោះសេវាជំងឺកាមរោគ និង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ តាមតំបន់**

| ខេត្តក្រុង | សៀមរាប | | បន្ទាយមានជ័យ | | ព្រះសីហនុ | | ភ្នំពេញ | | ANOVA |
|---|---|---|---|---|---|---|---|---|---|
| | WAI | OA | WAI | OA | WAI | OA | WAI | OA | Sig. |
| HCWs ក្នុងគ្លីនិក STI | 0.76 | F | 0.72 | F | 0.67 | F | 0.74 | F | 0.000*** |
| HCWs ក្នុងមណ្ឌល VCCT | 0.76 | F | 0.72 | F | 0.67 | F | 0.74 | F | 0.000*** |

ប្រភព : ការអង្កេតនៅកន្លែងអនុវត្តផ្ទាល់ ខែវិច្ឆិកា ឆ្នាំ២០០៨

កំណត់ចំណាំ : ការវាយតម្លៃជារួម (OA), រួសរាយណាស់ (VF) = 1.00 - 0.81; រួសរាយ (F) = 0.80 - 0.61; ធម្មតា (N) = 0.60 - 0.41 ; រួសរាយខ្លះៗ (SR) = 0.40 - 0.21 ; មិនរួសរាយទាល់តែសោះ (NF) = 0.20 - 0.00

ស្រដៀងគ្នានេះដែរ ការវិភាគតាមប្រភេទការងារ ក៏បានបង្ហាញថា រវាង បុរសស្រឡាញ់បុរស និងស្រីស្រស់មានភាពខុសគ្នា។ អ្នកទាំងនោះនិយាយថា បុគ្គលិកសេវាជំងឺកាមរោគ និងផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់មានភាពរួសរាយចំពោះពួកគេ។

**តារាង ១៩ : ការយល់ឃើញរបស់ បុរសស្រឡាញ់បុរស និងស្រីស្រស់ ចំពោះសេវាជំងឺកាមរោគនិង ផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់**

| ប្រភេទ MSM/ស្រីស្រស់ | MSM | | ស្រីស្រស់ | | ANOVA |
|---|---|---|---|---|---|
| | WAI | OA | WAI | OA | Sig. |
| HCWs ក្នុងគ្លីនិក STI | 0.73 | F | 0.74 | F | 0.807 |
| HCWs ក្នុងមណ្ឌល VCCT | 0.76 | F | 0.79 | F | 0.007** |

ប្រភព : ការអង្កេតនៅកន្លែងអនុវត្តផ្ទាល់ ខែវិច្ឆិកា ឆ្នាំ២០០៨

កំណត់ចំណាំ : ការវាយតម្លៃជារួម (OA), រួសរាយណាស់ (VF) = 1.00 - 0.81; រួសរាយ (F) = 0.80 - 0.61; ធម្មតា (N) = 0.60 - 0.41 ; រួសរាយខ្លះៗ (SR) = 0.40 - 0.21 ; មិនរួសរាយទាល់តែសោះ (NF) = 0.20 - 0.00

## ២. ការបង់ថ្លៃសេវា (សំណួរទី ៤៨)

### បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ

យោងតាមចម្លើយផ្តល់ដោយអ្នកផ្តល់សម្ភាស ការបង់ថ្លៃសម្រាប់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍និងសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមិនមានសារៈសំខាន់ទេ។ ទោះបីជាយ៉ាងនេះក្តីសមាមាត្រនៃការចំណាយរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនៅខេត្តសៀមរាបលើសេវា ជំងឺកាមរោគ និងផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ហាក់ដូចជាមាន កម្រិតខ្ពស់ដែលបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយមានចំនួន ២៦.៦ភាគរយ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយចំនួន ៣៧.២ ភាគរយ។ ផ្ទុយទៅវិញការចំណាយទាំងនេះមានកម្រិតទាប បើធៀបនឹងការចំណាយនៅតំបន់ដទៃទៀត។




**តារាង ៦៨ : បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ/អ្នករកស៊ីផ្លូវភេទ ភាគរយបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទដែលចេញថ្លៃសេវាតាមតំបន់**

**តារាង ២០ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ/អ្នករកស៊ីផ្លូវភេទ : ការចេញថ្លៃសេវាជាមធ្យម**

| | សៀមរាប | បន្ទាយមានជ័យ | ព្រះសីហនុ | ភ្នំពេញ | សរុប |
|---|---|---|---|---|---|
| STI | 1.15 | 4 | 1.07 | 2.31 | 1.57 |
| VCCT | 1.5 | 3.97 | 2.7 | 2.43 | 2.07 |
| ART | 0.5 | 0 | 1.25 | 0 | 0.87 |
| PMTCT | 2.08 | 0 | 0 | 3 | 2.16 |

ប្រភព : ការអង្កេតនៅកន្លែងអនុវត្តផ្ទាល់ ខែវិច្ឆិកា ឆ្នាំ២០០៨

បើប្រៀបធៀបទៅនឹងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ចំណាយលើសេវាជំងឺកាមរោគ និងផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ អស់តិចជាង។ ការបង់ថ្លៃសម្រាប់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ក៏មិនសំខាន់ ដែរ។




**តារាង ៦៩ : បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ: ភាគរយបុរសស្រឡាញ់បុរស និងស្រីស្រស់ ដែលបង់ថ្លៃសេវាតាមតំបន់**

## គោលបំណង ៤: កំណត់បញ្ហា (និងបញ្ហាដែលអាចកើតមាន) ពាក់ព័ន្ធនឹងការអនុវត្តន៍ច្បាប់ថ្មីស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចផ្លូវភេទលើបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ

### ១. បញ្ហាមួយចំនួនដែលអាចកើតមានពាក់ព័ន្ធនឹងការអនុវត្តន៍ LSHSE

#### *ក. ការបម្លាស់ទីរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទនិង បុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងឆ្នាំ២០០៧ និងឆ្នាំ២០០៨*

ការវិភាគតាមប្រភេទការងារបង្ហាញថាអ្នករកស៊ីផ្លូវភេទដោយផ្ទាល់ បានផ្លាស់ប្តូរកន្លែងនៅឆ្នាំ២០០៨ច្រើនជាងនៅឆ្នាំ២០០៧ ចំណែកឯការផ្លាស់ប្តូររបស់ស្រ្តីខារ៉ាអូខេ ក្នុងឆ្នាំ២០០៨មានការកើនឡើងតិចតួចធៀបនឹងឆ្នាំ ២០០៧។ ការផ្លាស់ប្តូររបស់ក្រុមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយដទៃទៀតបានធ្លាក់ចុះពីឆ្នាំ ២០០៧ ដល់ឆ្នាំ២០០៨។




| | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | ស្រ្តីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្រ្តីខារ៉ាអូខេ | ស្រ្តីផ្សព្វផ្សាយស្រាបៀរ | អ្នករកស៊ីផ្លូវភេទទាំងអស់ | MSM | ស្រីស្រស់ | MSM/ស្រីស្រស់ទាំងអស់ |
|---|---|---|---|---|---|---|---|---|---|
| ការផ្លាស់ទីក្នុងឆ្នាំ ២០០៧ | 32.11% | 37.40% | 37.30% | 30.02% | 32.22% | 32.17% | 31.49% | 43.67% | 36.21% |
| ការផ្លាស់ទីក្នុងឆ្នាំ ២០០៨ | 39.84% | 26.83% | 32.54% | 31.36% | 16.67% | 31.63% | 28.73% | 44.54% | 34.86% |

រូប ៧០ : ការបម្លាស់ទីរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងឆ្នាំ ២០០៧ និង ឆ្នាំ២០០៨

ក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់ ការបម្លាស់ទីរបស់ស្រីស្រស់មានការកើនឡើងបន្តិចបន្តួចនៅឆ្នាំ ២០០៨ ធៀបនឹងឆ្នាំ ២០០៧។ ការបម្លាស់ទីរបស់បុរសស្រឡាញ់បុរស មានចំនួនតិចតួចក្នុងឆ្នាំ២០០៨ ធៀបនឹងឆ្នាំ២០០៧។

#### *ខ. ការបម្លាស់ទីរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងឆ្នាំ២០០៧ និងឆ្នាំ២០០៨*

**បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ:** ការវិភាគតាមតំបន់បង្ហាញថាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទក្នុងខេត្តចំនួន ៣ (សៀមរាប បន្ទាយមានជ័យ និង ក្រុងព្រះសីហនុ) ត្រូវបានចាប់ខ្លួនក្នុងចំនួនមួយតិចតួច ពោលគឺក្នុងឆ្នាំ២០០៧ ២ភាគរយ និងឆ្នាំ២០០៨ ៤ភាគរយ ។ ចំណែកឯ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនៅរាជធានីភ្នំពេញដែលត្រូវបានចាប់ខ្លួន មានចំនួន ១០៣នាក់ ឬស្មើនឹង ១៩ភាគរយនៃបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ដែលបានសម្ភាសនៅរាជធានីភ្នំពេញ ក្នុងឆ្នាំ២០០៧ និងមានចំនួន ៨០នាក់ ឬស្មើនឹង ១៤ភាគរយ ក្នុងឆ្នាំ២០០៨ ។ ការចាប់ខ្លួនក្នុងតំបន់ទាំងអស់មានទំនោរទៅរកការថយចុះ ចាប់ពីឆ្នាំ ២០០៧ ដល់ឆ្នាំ២០០៨ លើកលែងតែនៅខេត្តព្រះសីហនុ ។




**រូប ៧១ : ការចាប់ខ្លួន បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងឆ្នាំ ២០០៧ និង ឆ្នាំ២០០៨**

**បុរសស្រឡាញ់បុរស និងស្រីស្រស់:** ការចាប់ខ្លួន បុរសស្រឡាញ់បុរស និងស្រីស្រស់ នៅតំបន់ទាំង ៤ មានការកើនឡើងលើកលែងនៅខេត្តបន្ទាយមានជ័យ ។ ការចាប់ខ្លួននៅរាជធានីភ្នំពេញមានការលំបាកដោយសារបុរសស្រឡាញ់បុរស និងស្រីស្រស់ ស្វែងរកអតិថិជន របស់ខ្លួននៅតាមសួន និងទីសាធារណៈ ។

### *ឥ. ការដោះលែងពីការចាប់ខ្លួន*

**បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ:** ទិន្នន័យប្រមូលបានពីខេត្តក្រុងទាំង ៤ បង្ហាញថាចំនួនពាក់កណ្តាលនៃបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទដែលបានចាប់ខ្លួនត្រូវបានដោះលែងដោយមានការធ្វើអន្តរាគមន៍ និងគ្មានអន្តរាគមន៍ពីអង្គការមិនមែនរដ្ឋាភិបាល ។ ថវិកា ឬ របស់មាន

តម្លៃបានប្រើប្រាស់ក្នុងអំឡុងពេល (៧ភាគរយ) ឬក្រោយពេលចាប់ខ្លួន (២៧ភាគរយ)។ អ្នកដែលត្រូវបានចាប់ខ្លួនប្រមាណ ៦ភាគរយ លើកឡើងថា ខ្លួនយល់ព្រមរួមភេទជាមួយដើម្បីជាថ្នូរនឹងការដោះលែង។

**សំណួរទី ៣៦ : មធ្យោបាយដែល បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ប្រើប្រាស់ដើម្បីរួចផុតពីការចាប់ខ្លួន**




**រូប ៧២ : មធ្យោបាយដែល បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ប្រើប្រាស់ដើម្បីរួចផុតពីការចាប់ខ្លួន**

**បុរសស្រឡាញ់បុរស និងស្រីស្រស់:** ក្រុមនេះក៏ប្រើវិធីសាស្ត្រស្រដៀងគ្នាទៅនឹងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទដែរដើម្បីរួចផុតពីការចាប់ខ្លួនដែរ ដោយពួកគេប្រគល់វត្ថុមានតម្លៃ ឬប្រគល់ប្រាក់ភ្លាមនៅពេលចាប់ខ្លួន។

**មធ្យោបាយដែល បុរសស្រឡាញ់បុរស និងស្រីស្រស់ប្រើប្រាស់ដើម្បីរួចផុតពីការចាប់ខ្លួន**




**រូប ៧៣ : មធ្យោបាយដែលបុរសស្រឡាញ់បុរស និងស្រីស្រស់ ប្រើប្រាស់ដើម្បីរួចផុតពីការចាប់ខ្លួន**

## ២. ការគាំទ្រ

### ១. *ការយល់ឃើញចំពោះនរណាម្នាក់ដែលនឹងត្រូវជួយបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយភ្លាមៗ នៅពេលពួកគេរងការបំពាន (សំណួរទី ៣៧) និងការយល់ឃើញចំពោះប៉ូលីស និងអាជ្ញាធរមូលដ្ឋានដែលត្រូវជួយបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយភ្លាមៗនៅពេលពួកគេរងការបំពាន (សំណួរទី ៣៨)*

តាមចម្លើយរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទបង្ហាញថា ឱកាសដែលពួកគេអាចទទួលបានការគាំទ្រពីនរណាម្នាក់ដែលជា ប្រជាពលរដ្ឋ ឬជាកងកម្លាំងប្រដាប់អាវុធ អាជ្ញាធរមូលដ្ឋាននៅពេលពួកគេរងការបំពាននៅខេត្តសៀមរាប និងខេត្តព្រះសីហនុ មានកម្រិតមធ្យម និងមានកម្រិតទាបនៅខេត្តបន្ទាយមានជ័យ និងរាជធានីភ្នំពេញ។ ការវិភាគ បែប ANOVA បង្ហាញថាសំណួរ ២ (សំណួរទី ៣៧ និងទី ៣៨) ដែលបានសួរសម្រាប់ខេត្តក្រុងទាំង ៤ មានភាពខុសគ្នាខ្លាំង។

**តារាង ២១ : ការយល់ឃើញរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ទាក់ទងនឹងការគាំទ្រក្នុងករណីមានការបំពានតាមតំបន់**

| ខេត្ត | សៀមរាប | | បន្ទាយមានជ័យ | | ព្រះសីហនុ | | ភ្នំពេញ | | ANOVA |
|---|---|---|---|---|---|---|---|---|---|
| | WAI | OA | WAI | OA | WAI | OA | WAI | OA | Sig. |
| គិតថានឹងមានមនុស្សណាម្នាក់មកជួយនៅពេល EWs រងការបំពាន | 0.45 | M | 0.37 | L | 0.52 | M | 0.37 | L | 0.000*** |
| គិតថាប៉ូលីស និងអាជ្ញាធរមូលដ្ឋាននឹងជួយនៅពេល EWs រងការបំពាន | 0.42 | M | 0.35 | L | 0.51 | M | 0.32 | L | 0.000*** |

ប្រភព : ការអង្កេតកន្លែងចុះអនុវត្តផ្ទាល់ ឆ្នាំ២០០៨

កំណត់ចំណាំ : ការវិភាគជារួម (OA), ខ្ពស់ណាស់ (VH) = 1.00 - 0.81; ខ្ពស់ (H) = 0.80 - 0.61; ល្មម (M) = 0.60 - 0.41 ; ទាប (L) = 0.40 - 0.21 ; ទាបណាស់ (VL) = 0.20 – 0.00

ការវិភាគតាមប្រភេទការងារបង្ហាញថា ឱកាសនៃការជួយពីប្រជាពលរដ្ឋ ឬកងកម្លាំងប្រដាប់អាវុធ អាជ្ញាធរមូលដ្ឋានដល់អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ ស្ត្រីម៉ាស្សា និងស្ត្រីបំរើស្រាបៀរមានកម្រិតតិចតួច។ ទោះបីជាយ៉ាង នេះក្តី ស្ត្រីខារ៉ាអូខេបានលើកឡើងថា ឱកាសនៃការជួយចំពោះខ្លួនមានកម្រិតមធ្យម ដោយឡែកអ្នករកស៊ីផ្លូវភេទ ឯករាជ្យទំនងជាមានប្រជាពលរដ្ឋចាំជួយ ប៉ុន្តែប្រហែលជាមិនមែនកងកម្លាំងប្រដាប់អាវុធ ឬអាជ្ញាធរមូលដ្ឋានទេ។ ការវិភាគ

បែប ANOVA ដោយយកប្រភេទការងារជាកត្តាបង្ហាញថា ចម្លើយទៅនឹងសំណួរទាំងពីរ (ទី ៣៧ និង ទី៣៨) មិនសូវខុសគ្នាប៉ុន្មានទេ។

**តារាង ២២ : ការយល់ឃើញរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ទាក់ទងនឹងការគាំទ្រក្នុងករណីមានការបំពានតាមប្រភេទការងារ**

| ខេត្ត | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | | ស្ត្រីម៉ាស្សា | | អ្នករកស៊ីផ្លូវភេទឯករាជ្យ | | ស្ត្រីខារ៉ាអូខេ | | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | | ANOVA |
|---|---|---|---|---|---|---|---|---|---|---|---|
| | WAI | OA | WAI | OA | WAI | OA | WAI | OA | WAI | OA | Sig. |
| គិតថានឹងមានមនុស្សណាម្នាក់មកជួយនៅពេល EWs រងការបំពាន | 0.4 | L | 0.37 | L | 0.46 | M | 0.44 | M | 0.4 | L | 0.008 |
| គិតថាប៉ូលីស និងអាជ្ញាធរមូលដ្ឋាននឹងជួយនៅពេល EWs រងការបំពាន | 0.36 | L | 0.34 | L | 0.40 | L | 0.42 | M | 0.37 | L | 0.004 |

ប្រភព : ការអង្កេតកន្លែងចុះអនុវត្តផ្ទាល់ ឆ្នាំ២០០៨

កំណត់ចំណាំ : ការវិភាគជារួម (OA), ខ្ពស់ណាស់ (VH) = 1.00 - 0.81; ខ្ពស់ (H) = 0.80 - 0.61; ល្មម (M) = 0.60 - 0.41 ; ទាប (L) = 0.40 - 0.21 ; ទាបណាស់ (VL) = 0.20 – 0.00

**បុរសស្រឡាញ់បុរស និងស្រីស្រស់ :**

តាមចម្លើយរបស់ បុរសស្រឡាញ់បុរស និងស្រីស្រស់បង្ហាញថាឱកាសដែលពួកគេអាចទទួលបានការគាំទ្រពីប្រជាពលរដ្ឋ ឬកងកម្លាំងប្រដាប់អាវុធ អាជ្ញាធរមូលដ្ឋាន នៅពេលដែលពួកគេរងការបំពាននៅគ្រប់ខេត្តក្រុង មានកម្រិតតិចតួច លើកលែងនៅខេត្តព្រះសីហនុ ដែលប្រជាពលរដ្ឋអាចជួយពួកគេបាន។ ការវិភាគបែប ANOVA បង្ហាញថា សំណួរទាំង ២ (ទី ៣៧ និងទី៣៨) សម្រាប់ខេត្តក្រុងទាំង ៤ មានភាពខុសគ្នាខ្លាំង។

**តារាង ២៣ ៖ ការយល់ឃើញរបស់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់**

**ទាក់ទងនឹងការគាំទ្រក្នុងករណីមានការបំពានតាមតំបន់**

| ខេត្ត | សៀមរាប | | បន្ទាយមានជ័យ | | ព្រះសីហនុ | | ភ្នំពេញ | | ANOVA |
|---|---|---|---|---|---|---|---|---|---|
| | WAI | OA | WAI | OA | WAI | OA | WAI | OA | Sig. |
| គិតថានឹងមានមនុស្សណាម្នាក់មកជួយនៅពេល MSM/ ស្រីស្រស់ រងការ បំពាន | 0.32 | L | 0.36 | L | 0.58 | M | 0.38 | L | 0.000*** |
| គិតថាប៉ូលីស និងអាជ្ញាធរមូលដ្ឋាននឹងជួយនៅពេល MSM/ស្រីស្រស់រងការបំពាន | 0.28 | L | 0.34 | L | 0.34 | L | 0.40 | L | 0.000*** |

ប្រភព ៖ ការអង្កេតកន្លែងចុះអនុវត្តផ្ទាល់ ឆ្នាំ២០០៨

កំណត់ចំណាំ ៖ ការវិភាគជារួម (OA), ខ្ពស់ណាស់ (VH) = 1.00 - 0.81; ខ្ពស់ (H) = 0.80 - 0.61; ល្មម (M) = 0.60 - 0.41 ; ទាប (L) = 0.40 - 0.21 ; ទាបណាស់ (VL) = 0.20 – 0.00

ការវិភាគតាមអនុក្រុមនៃ បុរសស្រលាញ់បុរស/ស្រីស្រស់ បង្ហាញថា ឱកាសនៃការជួយពីប្រជាពលរដ្ឋ ឬកងឯកសណ្ឋាន/ អាជ្ញាធរមូលដ្ឋាន មានកម្រិតតិចតួចទាំងសម្រាប់ បុរសស្រលាញ់បុរស/ស្រីស្រស់ ។ ការវិភាគ ANOVA ដោយយកប្រភេទ ការងារជាកត្តា បង្ហាញថា មានតែសំណួរទី ៣៨ប៉ុណ្ណោះដែលខុសគ្នាខ្លាំង។

**តារាង ២៤ ៖ ការយល់ឃើញរបស់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់**

**ទាក់ទងនឹងការគាំទ្រក្នុងករណីមានការបំពានតាមតំបន់**

| ខេត្ត | MSM | | ស្រីស្រស់ | | ANOVA |
|---|---|---|---|---|---|
| | WAI | OA | WAI | OA | Sig. |
| គិតថានឹងមានមនុស្សណាម្នាក់មកជួយនៅពេល MSM/ ស្រីស្រស់រងការបំពាន | 0.3829 | L | 0.3764 | L | 0.241 |
| គិតថាប៉ូលីស និងអាជ្ញាធរមូលដ្ឋាន នឹងជួយនៅពេល MSM/ស្រីស្រស់ រងការបំពាន | 0.3552 | L | 0.3135 | L | 0.010** |

ប្រភព ៖ ការអង្កេតកន្លែងចុះអនុវត្តផ្ទាល់ ឆ្នាំ២០០៨

កំណត់ចំណាំ ៖ ការវិភាគជារួម (OA), ខ្ពស់ណាស់ (VH) = 1.00 - 0.81; ខ្ពស់ (H) = 0.80 - 0.61; ល្មម (M) = 0.60 - 0.41 ; ទាប (L) = 0.40 - 0.21 ; ទាបណាស់ (VL) = 0.20 – 0.00

## ២. តើនរណាដែលទំនងជាអាចជួយអ្នកឱ្យទទួលបានសិទ្ធិមកវិញបន្ទាប់ពីមានការបំពាន? (សំណួរទី ៣៩)

ចំពោះការស្វែងរកជំនួយផ្សេងៗគ្នាក្រោមពេលមានការបំពាន បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ មកពីបណ្តាខេត្តក្រុងទាំង ៤ បានលើកឡើងថាការចូលរួមគាំទ្រពីប៉ូលីស និងអាជ្ញាធរមូលដ្ឋាន មានកម្រិតតិចជាង ៤០ភាគរយ។ ភាគច្រើន អ្នកទាំងនោះចូលចិត្តទៅពឹងអង្គការមិនមែនរដ្ឋាភិបាល និងប្រជាជនមូលដ្ឋានដើម្បីឱ្យគេជួយ។

**តើនរណាដែលទំនងជាអាចជួយអ្នកឱ្យទទួលបានសិទ្ធិមកវិញបន្ទាប់ពីមានការបំពាន?**




| | អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ | ស្ត្រីម៉ាស្សា | អ្នករកស៊ីផ្លូវភេទឯករាជ្យ | ស្ត្រីខារ៉ាអូខេ | ស្ត្រីផ្សព្វផ្សាយស្រាបៀរ | អ្នករកស៊ីផ្លូវភេទទាំងអស់ | MSM | ស្រីស្រស់ | MSM/ស្រីស្រស់ទាំងអស់ |
|---|---|---|---|---|---|---|---|---|---|
| ផ្សេងៗ | 57 | 16 | 25 | 165 | 15 | 279 | 27 | 37 | 64 |
| NGOs | 142 | 65 | 79 | 252 | 43 | 588 | 211 | 155 | 366 |
| តុលាការ | 5 | 1 | 2 | 7 | 0 | 15 | 20 | 8 | 28 |
| ប្រជាជន | 12 | 6 | 5 | 43 | 14 | 80 | 63 | 40 | 103 |
| ប៉ូលីស | 54 | 11 | 29 | 135 | 31 | 262 | 99 | 36 | 135 |
| អាជ្ញាធរមូលដ្ឋាន | 25 | 12 | 9 | 91 | 24 | 162 | 54 | 28 | 82 |

**រូប ៧៤ : ការយល់ឃើញរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ចំពោះការគាំទ្រផ្នែកសង្គមដើម្បីទទួលបាន សិទ្ធិមកវិញក្រោយពេលមានការបំពាន**

ចម្លើយបានមកពីបុរសស្រឡាញ់បុរស និងស្រីស្រស់ មានលក្ខណៈស្រដៀងគ្នាទៅនឹង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទដែរ។

បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនិងអ្នករកស៊ីផ្លូវភេទ៖

**តើនរណាដែលទំនងជាអាចជួយអ្នកឱ្យទទួលបានសិទ្ធិមកវិញបន្ទាប់ពីមានការបំពាន?**




**រូប ៧៥ : ការយល់ឃើញរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ចំពោះការគាំទ្រផ្នែកសង្គមដើម្បីទទួលបាន សិទ្ធិមកវិញក្រោយពេលមានការបំពាន**




**រូប ៧៦ : ការយល់ឃើញរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ចំពោះការគាំទ្រផ្នែកសង្គមដើម្បីទទួលបានសិទ្ធិមកវិញក្រោយពេលមានការបំពាន**

## ៣. ការផ្លាស់ប្តូរអថេរសំខាន់ៗមួយចំនួននៅរវាងឆ្នាំ ២០០៧ និង ឆ្នាំ២០០៨

នៅរវាងឆ្នាំ ២០០៧ និងឆ្នាំ២០០៨ អថេរសំខាន់ៗមួយចំនួនត្រូវបានផ្លាស់ប្តូរទាំងក្នុងចំណោម បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់។

សម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ:

- កាត់បន្ថយមធ្យោបាយនៃការបម្លាស់ទីមានភាពខុសគ្នាខ្លាំងពោលគឺ ពី ០,៥៩ ក្នុងឆ្នាំ ២០០៧ មកនៅត្រឹម ០,៤៩ ក្នុង ឆ្នាំ២០០៨។
- កាត់បន្ថយឱ្យបានច្រើននូវមធ្យោបាយនៃការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ពី ១,៤៦ ក្នុងឆ្នាំ២០០៧ ទៅ ១,៣៣ ក្នុងឆ្នាំ២០០៨។
- មធ្យោបាយនៃការចាប់ខ្លួន និងការមកប្រើសេវាជំងឺកាមរោគ របស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទ នៅរវាងឆ្នាំ ២០០៧ និង ឆ្នាំ ២០០៨ មិនខុសគ្នាប៉ុន្មានទេ។

**តារាង ២៥ : ការផ្លាស់ប្តូរអថេរសំខាន់ៗចំពោះ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ នៅរវាងឆ្នាំ២០០៧ និងឆ្នាំ២០០៨**

| អថេរគូរ | មធ្យម | គម្លាតស្តង់ដា | Paired Samples T Test |
|---|---|---|---|
| | | | Sig. |
| ចំនួនការបម្លាស់ទីក្នុងឆ្នាំ២០០៧ | .59 | 1.256 | |
| ចំនួនការបម្លាស់ទីក្នុងឆ្នាំ២០០៨ | .49 | .900 | |
| ការបម្លាស់ទីក្នុងឆ្នាំ២០០៧ ធៀបនឹង ឆ្នាំ២០០៨ | | | 0.007 |
| ចំនួនការចាប់ខ្លួនក្នុងឆ្នាំ២០០៧ | .12 | .476 | |
| ចំនួនការចាប់ខ្លួនក្នុងឆ្នាំ២០០៨ | .10 | .467 | |

| | | | |
|---|---|---|---|
| ការចាប់ខ្លួនក្នុងឆ្នាំ២០០៧ ធៀបនឹងឆ្នាំ២០០៨ | | | 0.213 |
| ចំនួនដងនៃការប្រើសេវាជំងឺកាមរោគក្នុងឆ្នាំ២០០៧<br>ចំនួនដងនៃការប្រើសេវាជំងឺកាមរោគក្នុងឆ្នាំ២០០៨<br>ការប្រើសេវាជំងឺកាមរោគ ក្នុងឆ្នាំ២០០៧ ធៀប នឹងឆ្នាំ២០០៨ | 2.18<br>2.22 | 3.532<br>4.119 | 0.734 |
| ចំនួនដងនៃការប្រើប្រាស់សេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ឆ្នាំ២០០៧<br>ចំនួនដងនៃការប្រើប្រាស់សេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ឆ្នាំ២០០៨<br>ការប្រៀបធៀបការ ប្រើប្រាស់សេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយ ស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ក្នុងឆ្នាំ២០០៧ ធៀបនឹងឆ្នាំ២០០៨ | 1.46<br>1.33 | 1.986<br>1.636 | 0.021 |

ប្រភព : ការស្រាវជ្រាវសកម្មភាព : ខែវិច្ឆិកា ឆ្នាំ២០០៨

## គោលបំណង ៥ : តំបន់គោលដៅ (សម្រាប់ការបណ្ដុះបណ្ដាល) និងអតិថជនគោលដៅ ពាក់ព័ន្ធ និងដៃគូសំខាន់ៗ រាប់បញ្ចូលទាំង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវ ភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់

### ១. ការកសាងសមត្ថភាពលើភាពជាអ្នកដឹកនាំដើម្បីទទួលបានលទ្ធផល

តាមរយៈការវិភាគស្ថានភាពបង្ហាញថា ទំហំការងារដែលជាប់ទាក់ទងទៅនឹងគោលនយោបាយ បរិយាកាស ទាក់ទងនឹងលទ្ធភាពទទួលបានជាសកល និងសិទ្ធិទទួលបានការងាររបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទជាបញ្ហាសង្គមស្មុគស្មាញដែលតម្រូវឱ្យមានការចូលរួមពីគ្រប់បណ្ដាភាគីពាក់ព័ន្ធ។ បញ្ហាភាពជា អ្នកដឹកនាំ ជាបញ្ហាចម្បងដែលតម្រូវឱ្យមានការដោះស្រាយ។ លោកវេជ្ជបណ្ឌិត Peter Poit នាយកប្រតិ បត្តិអង្គការ UNAIDS បានលើកឡើងកាលពីឆ្នាំ២០០១ ថា "ប្រសិន បើ *យើងនៅតែបណ្ដោយឱ្យស្ថានភាពនៅ តែជាបែបនេះក្នុងមួយឆ្នាំៗ យើងនឹងបាត់បង់មនុស្សបន្តិចម្ដងៗ ហើយយើងនឹងមិនអាចដោះស្រាយអ្វីបាន ឡើយ ។ នៅទីបំផុត ពិភពលោកនឹងពោរពេញដោយភាពឈឺចាប់ និងទុក្ខព្រួយ រងការខាតបង់ដែលមិនអាចនឹងថ្លែង បានព្រមទាំងពោរពេញដោយភាពអាម៉ាស់បន្ទាប់មកយើងទាំងអស់គ្នានឹងមិនអាចការពារប្រជាជនងាយរង គ្រោះប្រជាជនគ្មានអំណាចក្នុងសង្គម ប្រជាជនដែលមានជំងឺ និងក្មេងកំព្រាបានឡើយ។*"

ទស្សនៈទាន និងការរៀបចំការឆ្លើយតបនៅតាមតំបន់ដើម្បីសិទ្ធិទទួលបានការងារ និងលទ្ធភាពទទួលសេវាជា សកលសម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ មានភាពខុសគ្នា។

- ទស្សនៈទានដំបូងនៃការរៀបចំឱ្យមានកម្មវិធីប្រើស្រោមអនាម័យឱ្យបាន ១០០ភាគរយ ដែលបាន បង្កើតឡើងតាមរយៈការស្វែងយល់ស៊ីជម្រៅលើបញ្ហាឬសគល់របស់សង្គម ទាមទារឱ្យមានការ ពិភាក្សាជាចំហ និងដោយស្មោះត្រង់ពីបណ្ដាមន្ត្រីគោលនយោបាយ អ្នកអនុវត្តកម្មវិធី និង អ្នកទទួល ប្រយោជន៍។ ទោះបីជាយ៉ាងណាបន្ទាប់ពីការអនុវត្តន៍គម្រោងរយៈពេល១០ឆ្នាំការបកប្រែនូវទស្សនៈ ទានដំបូងនេះ នឹងជួបប្រទះនូវការប្រឈមថ្មីៗបន្ថែមទៀត។
- តាមការសម្ភាសអ្នកផ្ដល់ព័ត៌មានគន្លឹះៗបង្ហាញថា បណ្ដាភាគីពាក់ព័ន្ធសំខាន់ៗ ជាពិសេសតំណាង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ខ្វះការចូលរួមក្នុងការ បង្កើតច្បាប់ ស្ដីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ។

ការផ្លាស់ប្ដូរវិធីសាស្ត្រចំពោះការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ គិតចាប់តាំងពីវិធីសាស្ត្រផ្នែក សុខាភិបាលរហូតដល់ការបង្កើតវិធីសាស្ត្រត្រូវធ្វើឡើងនៅតាមស្ថាប័ន។ ប្រជាជនក្រីក្រជួបការលំបាក មិនត្រូវ ចាត់

## គោលបំណង ៥ : តំបន់គោលដៅ (សម្រាប់ការបណ្តុះបណ្តាល) និងអតិថិជនបណ្តាញពាក់ព័ន្ធ និងដៃគូសំខាន់ៗ រាប់បញ្ចូលទាំង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់

### ១. ការកសាងសមត្ថភាពលើភាពជាអ្នកដឹកនាំដើម្បីទទួលបានលទ្ធផល

តាមរយៈការវិភាគស្ថានភាពបង្ហាញថា ទំហំការងារដែលជាប់ទាក់ទងទៅនឹងគោលនយោបាន បរិយាកាសទាក់ទងនឹងលទ្ធភាពទទួលបានជាសកល និងសិទ្ធិទទួលបានការងាររបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទជាបញ្ហាសង្គមស្មុគស្មាញដែលតម្រូវឱ្យមានការចូលរួមពីគ្រប់បណ្តាភាគីពាក់ព័ន្ធ។ បញ្ហាភាពជាអ្នកដឹកនាំ ជាបញ្ហាចម្បងដែលតម្រូវឱ្យមានការដោះស្រាយ។ លោកវេជ្ជបណ្ឌិត Peter Poit នាយកប្រតិបត្តិអង្គការ UNAIDS បានលើកឡើងកាលពីឆ្នាំ២០០១ ថា "ប្រសិន បើ *យើងនៅតែបណ្តោយឱ្យស្ថានភាពនៅតែជាបែបនេះក្នុងមួយឆ្នាំៗ យើងនឹងបាត់បង់មនុស្សបន្តិចម្តងៗ ហើយយើងនឹងមិនអាចដោះស្រាយអ្វីបាន ឡើយ ។ នៅទីបំផុត ពិភពលោកនឹងពោរពេញដោយភាពឈឺចាប់ និងទុក្ខព្រួយ រងការខាតបង់ដែលមិនអាចនឹងថ្លែងបានព្រមទាំងពោរពេញដោយភាពអាម៉ាស់បន្ទាប់មកយើងទាំងអស់គ្នានឹងមិនអាចការពារប្រជាជនងាយរងគ្រោះប្រជាជនគ្មានអំណាចក្នុងសង្គម ប្រជាជនដែលមានជំងឺ និងក្មេងកំព្រាបានឡើយ ។*"

ទស្សនៈទាន និងការរៀបចំការឆ្លើយតបនៅតាមតំបន់ដើម្បីសិទ្ធិទទួលបានការងារ និងលទ្ធភាពទទួលសេវាជាសកលសម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់មានភាពខុសគ្នា។

- ទស្សនៈទានដំបូងនៃការរៀបចំឱ្យមានកម្មវិធីប្រើស្រោមអនាម័យឱ្យបាន ១០០ភាគរយ ដែលបានបង្កើតឡើងតាមរយៈការស្វែងយល់ស៊ីជម្រៅលើបញ្ហាឬសគល់របស់សង្គម ទាមទារឱ្យមានការពិភាក្សាជាចំហ និងដោយស្មោះត្រង់ពីបណ្តាមន្ត្រីគោលនយោបាយ អ្នកអនុវត្តកម្មវិធី និង អ្នកទទួលប្រយោជន៍។ ទោះបីជាយ៉ាងណាបន្ទាប់ពីការអនុវត្តន៏គម្រោងរយៈពេល១០ឆ្នាំការបកប្រែនូវទស្សនៈទានដំបូងនេះ នឹងជួបប្រទះនូវការប្រឈមថ្មីៗបន្ថែមទៀត។
- តាមការសម្ភាសអ្នកផ្តល់ព័តិមានគន្លឹះៗបង្ហាញថា បណ្តាភាគីពាក់ព័ន្ធសំខាន់ៗ ជាពិសេសតំណាងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ខ្វះការចូលរួមក្នុងការ បង្កើតច្បាប់ ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ។

ការផ្លាស់ប្តូរវិធីសាស្រ្តចំពោះការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ គិតចាប់តាំងពីវិធីសាស្រ្តផ្នែកសុខាភិបាលរហូតដល់ការបង្កើតវិធីសាស្រ្តត្រូវធ្វើឡើងនៅតាមស្ថាប័ន។ ប្រជាជនក្រីក្រជួបការលំបាក មិនត្រូវ ចាត់

ទុកថាគ្រាន់តែជាអ្នកទទួលផលប្រយោជន៍ពីសេវានោះទេ។ សមាជិកភាពពីបណ្តាយន្តការផ្សេងៗដើម្បីឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ចាប់ពីថ្នាក់កណ្តាលរហូតដល់ថ្នាក់មូលដ្ឋាន ត្រូវធ្វើការកែសម្រួលដើម្បីបញ្ចូលតំណាងរបស់ក្រុមដែលងាយរងគ្រោះបំផុត។

មន្ត្រីគោលនយោបាយ និងអ្នកអនុវត្តកម្មវិធី ត្រូវពិចារណាលើការគាំទ្រការផ្លាស់ប្តូរវិធីសាស្ត្រនេះ។ មន្ត្រីសំខាន់ៗមកពីបណ្តាស្ថាប័នពាក់ព័ន្ធដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬប្រយោលទៅនឹង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់និងលទ្ធភាពរបស់អ្នកទាំងនោះក្នុងការទទួលបាន សេវាមូលដ្ឋានដូចជាការទទួលបានសេវាជាសកលសេវាស្របច្បាប់ សេវាសង្គម ។ល។ គួរចូលរួមក្នុងកម្មវិធីភាពជា អ្នកដឹកនាំដើម្បីសម្រេចបាននូវលទ្ធផលនៃវគ្គកសាងសមត្ថភាព។ តំណាងមកពីក្រុមដែលងាយរងគ្រោះបំផុតត្រូវចូលរួមក្នុងកម្មវិធីនេះជាដាច់ខាត។ លទ្ធផលរំពឹងទុកនៃ កម្មវិធីភាពជាអ្នកដឹកនាំដើម្បីសម្រេចបាននូវលទ្ធផល គឺដើម្បីបង្កើតបណ្តាញមួយដែលមានអំណាច និងមានរយៈពេលយូរ ចេញពីមន្ត្រីគោលនយោបាយ អ្នកអនុវត្តកម្មវិធី និងអ្នកទទួលប្រយោជន៍ ដែលអាចសម្របសម្រួលការអនុវត្តន៍គោលនយោបាយ ជាពិសេសនៅថ្នាក់មូលដ្ឋាន។

*អ្នករៀបចំកម្មវិធីប្រកបដោយសក្តានុពល:* អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដោយមានការសហការពីកម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ

*អ្នកចូលរួមដ៏មានសក្តានុពល:* មន្ត្រីមកពីក្រសួងមហាផ្ទៃ (សមាជិកគណៈកម្មាធិការអេដស៍ថ្នាក់ក្រសួង) ក្រសួងយុត្តិធម៌ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ/ក្រសួងសុខាភិបាល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គណៈកម្មាការទី៦ និងទី៨នៃរដ្ឋសភាជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាជ្ញាធរមូលដ្ឋាន និងក្រុមដែលងាយរងគ្រោះបំផុតនៅតាមបណ្តាខេត្ត ដែលមានបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ច្រើន វិស័យឯកជន (ក្រុមហ៊ុនស្រាបៀរ ភោជនីយដ្ឋាន ខារ៉ាអូខេ កាស៊ីណូ ។ល។) តំណាងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារជាមួយ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ អ្នកប្រើប្រាស់គ្រឿងញៀន អង្គការ HACC, LICADHO, AFESIP។

## ២. ការកសាងសមត្ថភាពក្នុងការរៀបចំ និងផ្សព្វផ្សាយកម្មវិធី BCC ជាយុទ្ធសាស្ត្រដែលមានលក្ខណៈច្នៃប្រឌិត និងសមស្របសម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ និង អតិថិជនរបស់ពួកគេ

ផ្តើមចេញពីលទ្ធផលនៃការស្រាវជ្រាវនេះបង្ហាញថា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រឈមនឹងបញ្ហាដែលមិនធ្លាប់ជួបប្រទះកាលពីពេលកន្លងមក។ ឧទាហរណ៍ ស្ត្រីខារ៉ាអូខេប្រមាណ ៤១ភាគរយ និងស្ត្រីបំរើស្រាបៀរ ២៩ភាគរយបុរសស្រឡាញ់បុរស ២៦,៨ភាគរយ និងស្រីស្រស់

គាំទ្រ របស់សហគមន៍ ក្នុងការគាំទ្រការផ្ដល់សេវាមេរោគអេដស៍ និងជំងឺអេដស៍។ តួនាទីរបស់ ***ចលករសហគមន៍*** នឹងរាប់បញ្ចូល :

- ការចូលរួមរបស់ប៉ូលីសក្នុងការអប់រំ និងការឆ្លើយតបនៅក្នុងសហគមន៍ ជាពិសេសការកាត់បន្ថយការ មើលងាយ និងការរើសអើងទៅនឹងក្រុមដែលងាយរងគ្រោះបំផុត និងគាំទ្រឱ្យមាន "ទីធ្លាសហគមន៍" ដើម្បីអនុវត្តកម្មវិធី។
- ប៉ូលីសចូលរួមក្នុងការស្វែងរកការគាំទ្រលើសេវាមេរោគអេដស៍ និងជំងឺអេដស៍
- ការបញ្ជូនរបស់ប៉ូលីសសម្រាប់អ្នកទាំងឡាយណាដែលត្រូវការសេវា

វិស័យនានាសម្រាប់ការកសាងសមត្ថភាពរបស់ចលករសហគមន៍មាន :

- សិទ្ធិមនុស្ស
- គោលនយោបាយ និងច្បាប់ពាក់ព័ន្ធនឹងការងារផ្លូវភេទ ដូចជាច្បាប់ស្ដីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ រដ្ឋធម្មនុញ្ញ។
- គោលនយោបាយ និងបទបញ្ញតិទាក់ទងទៅនឹងសិទ្ធិទទួលបានសេវាជាសកល ដូចជា ច្បាប់ស្ដីពី HIV/AIDS ការប្រើស្រោមអនាម័យ ១០០ភាគរយ។
- គោលនយោបាយ និងបទបញ្ញត្តិទាក់ទងទៅនឹងការប្រើគ្រឿងញៀន ដូចជាការកាត់បន្ថយគ្រោះថ្នាក់។
- កិច្ចសន្ទនាក្នុងសហគមន៍ (ក្នុងកម្មវិធីភាពជាអ្នកដឹកនាំដើម្បីសម្រេចបាននូវលទ្ធផល)

*អ្នករៀបចំប្រកបដោយសក្ដានុពល:* អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងមហាផ្ទៃ អង្គការសុខភាពគ្រួសារអន្តរជាតិ កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍អង្គការសហប្រជាជាតិ

*អ្នកចូលរួមសំខាន់ :* ប៉ូលីស អាជ្ញាធរមូលដ្ឋានក្នុងបណ្ដាខេត្តដែលមានបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការជាមួយ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ តំណាងក្រុមដែលងាយរងគ្រោះបំផុត។

៤. **ការពង្រឹងសមត្ថភាពតាមស្ថាប័ន និងសមត្ថភាពស្វែងរកការគាំទ្ររបស់បណ្ដាញ** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់

ការសម្ភាសជាមួយអ្នកផ្ដល់ព័តិមានគន្លឹះ១បង្ហាញថា បណ្ដាញ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ មានក្នុងខេត្តចំនួន ៩ ដូចជា :

- បាត់ដំបង កណ្ដាល ភ្នំពេញ ដោយធ្វើការជាមួយ WHN
- បន្ទាយមានជ័យ កំពត ក្រុងព្រះសីហនុ និងតាកែវ ដោយធ្វើការជាមួយ WNU
- សៀមរាប កំពង់ស្ពឺ និងកំពង់ឆ្នាំង ដោយធ្វើការជាមួយ WHN ទាំង WNU

ទោះបីជាការស្រាវជ្រាវសកម្មភាពបង្ហាញថា ការអប់រំកម្រិតមូលដ្ឋានរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ មានកម្រិតទាបក្តី (ជាមធ្យមថ្នាក់ទី ៣,៩) ហើយ ២៩ភាគរយក្នុងចំណោមអ្នកទាំងនោះ មិនទទួលបានការអប់រំទាល់តែសោះ ការតាំងចិត្តកសាងសមត្ថភាពតាមស្ថាប័នរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ត្រូវបន្តឱ្យបានជាប់លាប់។ កន្លងមកក្រុមបណ្តាញទាំងពីរនេះ កំពុងប្រឈមនូវបញ្ហាមួយចំនួន ៖

- ការស្វែងយល់ និងទិសដៅសម្រាប់ការស្វែងរកការគាំទ្ររវាងបណ្តាញទាំងនេះ មិនបានធ្វើឱ្យមានលក្ខណៈរួមគ្នា។ WNU ផ្តោតខ្លាំងតែទៅលើសិទ្ធិទទួលបានការងារ ចំណែកឯ WHU ផ្តោតតែទៅលើលទ្ធភាពទទួលបានសេវាជាមូលដ្ឋាន។
- បណ្តាញទាំងពីរនេះមិនមានយន្តការធ្វើការជាមួយរដ្ឋាភិបាលឱ្យបានជាប់លាប់ជាពិសេសនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ។ សកម្មភាពរបស់បណ្តាញទាំងពីរនេះ ត្រួតពិនិត្យដោយរដ្ឋាភិបាល និងដៃគូ អភិវឌ្ឍដើម្បីគ្រាន់ជាយន្តការបង្ហាញគំនិតជំទាស់ ជាជាងយន្តការធ្វើការមួយដ៏ទៀងទាត់ដើម្បីបន្ត សិទ្ធិទទួលបានការងារ និងសិទ្ធិទទួលបានសេវាជាសកល។

ក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលចំនួន ១៤ ដែលធ្វើការជាមួយក្រុមបុរសស្រឡាញ់បុរស អ្នករកស៊ីផ្លូវភេទ គឺអង្គការមិនមែនរដ្ឋាភិបាលទាំងនោះធ្វើការជាន់គ្នារវាងអង្គការសហគមន៍ជាក្រុមបុរសស្រឡាញ់បុរស និងអង្គការសហគមន៍ដែលធ្វើការជាមួយក្រុមបុរសស្រឡាញ់បុរសនៅតំបន់មានបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍។ ទោះបីជាអ្នកទាំងនោះមានការអប់រំកម្រិតមូលដ្ឋានជាមធ្យម ៩ឆ្នាំ ប៉ុន្តែសមត្ថភាពតាមស្ថាប័នរបស់អ្នកទាំង នោះនៅមានកម្រិតដោយសារបុរសស្រឡាញ់បុរស និងស្រីស្រស់ បានបង្កើតឡើងដើម្បីធៀបទៅនឹងបណ្តាញ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ។

លទ្ធផលរំពឹងទុក គឺត្រូវបង្កើតបណ្តាញ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់មួយដ៏រឹងមាំដែលអាចធ្វើការប្រកបដោយសាមគ្គីភាពជាមួយស្ថាប័នរដ្ឋាភិបាល និងអង្គការ មិនមែនរដ្ឋាភិបាលនិងមិនត្រឹមតែអាច ស្វែងរកការគាំទ្រលើសុវត្ថិភាពផ្លូវភេទប៉ុណ្ណោះទេ ថែមទាំងអាចផ្តោតបានកាន់ តែទូលំទូលាយលើទិដ្ឋភាព សិទ្ធិមនុស្ស រាប់បញ្ចូលទាំង ការគាំទ្រផ្នែកច្បាប់ និងសង្គម។

*អ្នកចូលរួមប្រកបដោយសក្តានុពល* លើការកសាងសមត្ថភាពតាមស្ថាប័នសម្រាប់បណ្តាញ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់: WHN, WNU, WAC, CPU បណ្តាញចតុមុខ

## ៥. ការពង្រឹងសមត្ថភាពតាមស្ថាប័ន និងការស្វែងរកការគាំទ្រសម្រាប់បណ្តាញធ្វើការជាមួយ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់

ដើម្បីដោះស្រាយស្ថានភាពនាពេលបច្ចុប្បន្នរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ គំនិតផ្តួចផ្តើមដូចខាងក្រោមមានសារៈសំខាន់ណាស់ :

- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគកំពុងបង្កើតនិតិវិធីអនុវត្តស្តង់ដាថ្មីមួយស្តីពីការបន្តបង្ការថែទាំនិងគាំទ្រការដោះស្រាយបញ្ហារបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបង្កើតផែនការយុទ្ធសាស្ត្រមួយដើម្បីបង្ការ និងត្រួតពិនិត្យការចម្លងមេរោគអេដស៍ក្នុងចំណោមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយអតិថិជន និងសង្សាររបស់ពួកគេ។ ស្របគ្នាទៅនឹងគំនិតផ្តួចផ្តើមនេះអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ជាអ្នកដឹកនាំក្រុមបង្គោលបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញប្រកាសលេខ ០៨៦ កាលពីខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការអេដស៍នៅតាមសហគ្រាស មណ្ឌលកម្សាន្ត និងគ្រប់គ្រងការចម្លងមេ រោគអេដស៍នៅកន្លែងធ្វើការ ។
- ក្រសួងមហាផ្ទៃទើបតែបានបញ្ចប់ការបង្កើតផែនការយុទ្ធសាស្ត្រដើម្បីឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០០៩-២០១៣ ដោយរួមបញ្ចូលសកម្មភាពសមាជិកសំខាន់ៗរបស់គណៈកម្មាធិការអេដស៍របស់ក្រសួងដូចជាអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងគណៈកម្មការជាតិវិមជ្ឈការ និងវិសហមជ្ឈការ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ការពារអនិតិជននិងសុខាភិបាល ។ ផែនការនេះបានលើកឡើងនូវសំណើរឱ្យស្នងការនគរបាលនៅតាមបណ្តាខេត្តនីមួយៗធ្វើជាអនុប្រធានគណៈកម្មាធិការអេដស៍ថ្នាក់ខេត្តដើម្បីបន្ស៊ី និងការធ្វើសុខដុមនីយកម្មនូវសកម្មភាពថ្នាក់មូលដ្ឋានប្រកបដោយប្រសិទ្ធភាពស្តីពីការប្រឆាំងការជួញដូរមនុស្ស និងកម្មវិធីប្រើស្រោមអនាម័យឱ្យបាន ១០០ភាគរយ ។
- គួររំលឹកផងដែរថាក្រៅពីគំនិតផ្តួចផ្តើមតាមវិស័យទាំងនេះក្រុមការងារបច្ចេកទេសចំនួន ៣ ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងការដោះស្រាយបញ្ហាជាក់លាក់របស់ក្រុមដែលងាយរងគ្រោះបំផុត ដូចជាក្រុមការងារបច្ចេកទេស OPC ក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរសថ្នាក់ជាតិ ក្រុមការងារបច្ចេកទេសគ្រឿងញៀន និងជំងឺអេដស៍ ។

ដើម្បីសម្របសម្រួលលើយន្តការ និងគំនិតផ្តួចផ្តើមដែលមានស្រាប់ទាំងនេះ ការដឹកនាំដ៏រឹងមាំមួយមានសារៈសំខាន់ណាស់ក្នុងការធានាឱ្យបាននូវការផ្សារភ្ជាប់សមាសធាតុផ្សេងៗគ្នានៃយន្តការដ៏ស៊ាំញ៉ាំនេះ ។ ក្នុងន័យនេះ សមត្ថភាពជំនាញ និងសមត្ថភាពតាមអង្គភាពផ្សេងៗគ្នា ដូចបានរៀបរាប់ខាងលើ ត្រូវពង្រឹងបន្ថែមទៀត។ ការគាំទ្រតាម

លេខាធិការដ្ឋានត្រូវបង្កើតឱ្យមានសម្រាប់សមាសធាតុប្រព័ន្ធនីមួយៗ ដើម្បីអនុវត្តការងារឱ្យមានភាពរលូន។ សមាសធាតុសំខាន់ៗមួយចំនួនអាចត្រូវការនូវគោលការណ៍ណែនាំដ៏ជិតស្និទ្ធពីសំណាក់អ្នកពិគ្រោះយោបល់រយៈ ពេលខ្លីដើម្បីឱ្យការអនុវត្តន៏មុខងារប្រកបដោយភាពជឿទុកចិត្ត និងប្រសិទ្ធភាព ពោលគឺជំរុញភាពជាម្ចាស់នៅតាមមូលដ្ឋាន។

## V. ការវិភាគ

### ១. ការផ្លាស់ប្តូរលក្ខណៈទូទៅនៃមុខរបរផ្លូវភេទ

ការវិភាគទៅលើសិទ្ធិទទួលបានការងារ និងសិទ្ធិទទួលបានសេវាជាសកលរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ គួរលើកយកមកពិភាក្សាក្នុងបរិបទទូទៅនៃមុខរបរ ផ្លូវភេទ។ អស់រយៈពេលជាងមួយទសវត្សរ៍កន្លងទៅនេះលក្ខណៈទូទៅនៃមុខរបរផ្លូវភេទដែលគួរលើកយកមក ពិចារណា រួមមានដូចខាងក្រោម ៖

១.១. ចំនួនស្ត្រីដែលបម្រើការងារក្នុងមុខរបរផ្លូវភេទ បានកើនឡើង៥០ភាគរយ ពោលគឺចាប់ពី ១១.៣១១ នាក់ នៅឆ្នាំ១៩៩៧ រហូតដល់ ១៧.១៥៣នាក់ នៅឆ្នាំ២០០៧[១]។ វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោក បាន និងកំពុងធ្វើឱ្យកម្មការិនីរោងចក្រកាត់ដេរសម្រេចចិត្តទៅធ្វើការនៅកន្លែងគ្រឹះស្ថានកំសាន្តសប្បាយ ដើម្បីស្វែងរកប្រាក់មកចិញ្ចឹមជីវិត មានចំនួនកាន់តែច្រើនទៅៗ។

១.២. បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយដែលធ្លាប់បម្រើការងារក្នុងផ្ទះបន បានផ្លាស់ប្តូរមកធ្វើការនៅកន្លែងផ្សេងទៀតដែលមិនមែនជាផ្ទះបនជាបន្តបន្ទាប់។ នៅឆ្នាំ១៩៩៧ អ្នករកស៊ីផ្លូវភេទក្នុងផ្ទះបន មានចំនួនច្រើនជាងអ្នកធ្វើការផ្សេងពីនេះ (៥៣ភាគរយនៃចំនួន បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទសរុប)។ អ្វីដែលជាការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ នៅឆ្នាំ២០០៧នោះគឺថាអ្នករកស៊ីផ្លូវភេទនៅតាមផ្ទះបន មានចំនួន ១ ភាគ ៥ នៃចំនួនអ្នកធ្វើការសរុបក្នុងមុខរបរផ្លូវភេទ។

១.២. ទំនាក់ទំនងរវាង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងអតិថិជនដែលធ្លាប់ទៅស្វែងរកការសប្បាយម្តងម្កាលកំពុងក្លាយទៅជាគូសង្សារនឹងគ្នា (ឬរស់នៅជាមួយគ្នាដោយមិនរៀបការ)។

១.៣. តំបន់ដែលធ្លាប់ប្រមូលផ្តុំដោយក្លឹបរាត្រីកំសាន្តកាលពី ១០ឆ្នាំមុន បានប្រែក្លាយមកជាតំបន់ប្រកបអាជីវកម្ម ឬកន្លែងផ្សេងៗទៀត (ដូចជា ទីសាធារណៈ សួនច្បារជាដើម)។

១.៤. បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយកាន់តែប្រឈមនឹងគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ ការប្រើប្រាស់ថ្នាំញៀន និង/ឬទំនាក់ទំនងភេទសម្ពន្ធភេទដូចគ្នាកាន់តែច្រើន។

---

[1] ការអង្កេតដោយប្រយោល និងការគ្រប់គ្រងទិន្នន័យរបស់ NCHADS

១.៥. កាលពី១០ឆ្នាំមុនការប្រកបរបរខុសច្បាប់របស់អ្នករកស៊ីផ្លូវភេទ មិនបង្កឱ្យមានបញ្ហាចោទឡើយ ហើយក្នុងពេលនោះដែរកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០ភាគរយ ទទួលបានការគាំទ្រយ៉ាងពេញទំហឹង និងស្របគ្នាផងដែរ។ នាពេលបច្ចុប្បន្ននេះ អាជ្ញាធរមូលដ្ឋាន និងប៉ូលីស កំពុងអនុវត្តច្បាប់ថ្មីស្តីពីការ បង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ។ ការអនុវត្តន៏ច្បាប់ថ្មីនេះ បង្កការលំបាកដល់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទក្នុងការប្រកបអាជីវកម្មរបស់ខ្លួន ហើយបុគ្គលិកអប់រំផ្សព្វផ្សាយ ក៏ប្រឈម នឹងការលំបាកក្នុងការសហការជាមួយអ្នកទាំងនោះផងដែរ។ម្យ៉ាងវិញទៀត កាលពី២ឆ្នាំមុន កង្វះការឧបត្ថម្ភមូលនិធិ ជះឥទ្ធិពលដល់ ការគ្រប់គ្រងជាប្រចាំលើកម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ នៅតាមបណ្ដា ខេត្តជាច្រើន។

| **លក្ខណៈ** | **នៅឆ្នាំ១៩៩៧** | | **នៅឆ្នាំ២០០៧** |
|---|---|---|---|
| **ចំនួន EWs** | ចំនួនទាបបំផុតគឺ ១១.៣១១ | → | ចំនួនខ្ពស់បំផុត គឺ ១៧.១៥៣ |
| **ប្រភេទ EWs** | ភាគច្រើន ធ្វើការនៅតាមផ្ទះបន (៥៣ភាគរយនៃ EWs) | → | ភាគច្រើន ធ្វើការនៅកន្លែងផ្សេងក្រៅពីបនស្រីពេស្យា (៨០ភាគរយនៃEW) |
| **ប្រភេទអតិថិជន** | អតិថិជនមិនជាប់លាប់ | → | គូសង្សារ និងស្រីកំណាន់ចិត្តរបស់គាត់ |
| **របាយទីកន្លែងប្រកបរបររកស៊ីតាមមូលដ្ឋាន** | ប្រមូលផ្តុំនៅតាមតំបន់ក្លឹបរាត្រីកំសាន្ត | → | នៅតាមកន្លែងជាច្រើន ឬមិនមានកន្លែងច្បាស់លាស់ |
| **ប្រភេទគ្រោះថ្នាក់** | សម្ព័ន្ធភេទផ្ទុយគ្នា | → | សម្ព័ន្ធភេទផ្ទុយគ្នា និងដូចគ្នា ការប្រើប្រាស់ថ្នាំញៀន (IDU និងមិនមែន IDU) |
| **បរិស្ថានជំរុញ** | ផ្ទះបនអាចបើកបម្រើអាជីវកម្មរបស់ខ្លួនបាន។ | → | ច្បាប់ថ្មីស្តីពីការបញ្ឈប់ការជួញដូរផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទ |
| | បរិស្ថានគាំទ្រដល់កម្មវិធី CUP ១០០ភាគរយ | → | កង្វះការគាំទ្រ និងការដឹកនាំ ជះឥទ្ធិពលដល់កម្មវិធី CUP ១០០ភាគរយ |

**រូប ៧៧ : ការផ្លាស់ប្តូរលក្ខណៈទូទៅនៃមុខរបរផ្លូវភេទនៅប្រទេសកម្ពុជាក្នុងរវាងឆ្នាំ១៩៩៧ និងឆ្នាំ២០០៧**

## ១. <u>សិទ្ធិទទួលបានការងារ</u>

ការសិក្សាស្រាវជ្រាវទៅលើសេដ្ឋកិច្ចសង្គមកិច្ច និងប្រជាសាស្ត្រ បង្ហាញពីលក្ខខណ្ឌនានាដែលនាំឱ្យបុរស និងស្ត្រីវ័យក្មេងជាច្រើនបានសម្រេចចិត្តទៅធ្វើការក្នុងមុខរបរបម្រើសេវាកំសាន្ត និងស្វែងរកប្រាក់ចិញ្ចឹមជីវិតតាមរយៈការលក់ផ្លូវភេទ។ បុរស ស្ត្រីទាំងនោះមានប្រវត្តិមកពីគ្រួសារក្រីក្រ និង/ឬគ្រួសារធ្លាប់បែកបាក់។ ម្យ៉ាងវិញទៀត យុវវ័យទាំងនោះទទួលបានការអប់រំទាប (៣.៩ឆ្នាំ ចំពោះ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង៩ឆ្នាំ

ចំពោះបុរសស្រឡាញ់បុរស និងស្រីស្រស់ ) ហើយភាគច្រើនគ្មានការងារធ្វើ (៣៣ភាគរយ ចំពោះបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង ២១ភាគរយចំពោះបុរសស្រឡាញ់បុរស និងស្រីស្រស់ ) ។

- បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទភាគច្រើន បានសម្រេចចិត្តមកធ្វើការក្នុងមុខរបរបម្រើសេវាកំសាន្តដោយសារតែបញ្ហាគ្រួសារ ។ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ដែលត្រូវបានលក់ទៅឱ្យបនស្រីពេស្យា មានចំនួនតិចជាង ១ភាគរយ ។ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទចាំបាច់ត្រូវផ្ញើប្រាក់ពី ៣០ ទៅ ៥០ដុល្លារសហរដ្ឋអាមេរិក ទៅឱ្យគ្រួសាររបស់ខ្លួនជារៀងរាល់ខែ សម្រាប់យកទៅផ្គត់ផ្គង់សមាជិកគ្រួសារក្នុងបន្ទុកដែលមានជាមធ្យម ៣.១២នាក់ ។
- អ្វីដែលគួរឱ្យចាប់អារម្មណ៍ក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់ គឺថា ៦៦.៦ភាគរយនៃក្រុមបុរសស្រឡាញ់បុរសបានទទួលស្គាល់ថាខ្លួនរកប្រាក់បានតាមរយៈការលក់ផ្លូវភេទ រីឯស្រីស្រស់វិញ មានចំនួន ៨៤.៥ភាគរយ ដែលបានធ្វើដូច្នោះ ។ ទោះជាយ៉ាងនេះក្តីក្រុមនេះចាំបាច់ត្រូវផ្ញើប្រាក់ទៅឱ្យគ្រួសាររបស់ខ្លួន ជាមធ្យម ២០ដុល្លារសហរដ្ឋអាមេរិក ដោយសារខ្លួនមានសមាជិកគ្រួសារក្នុងបន្ទុកតែ២នាក់ប៉ុណ្ណោះ ។

ព័ត៌មានខាងលើនេះបង្ហាញពីភស្តុតាងមួយចំនួនស្តីពីល័ក្ខខ័ណ្ឌនានាដែលបណ្តាលឱ្យបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់សម្រេចចិត្តមកធ្វើការក្នុងមុខរបរផ្លូវភេទ ។ ទោះជាយ៉ាងនេះក្តី ការស្រាវជ្រាវនេះ បង្ហាញថា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ មានបំណងឈប់ធ្វើការដែលផ្តល់សេវាផ្លូវភេទ (៤៣ភាគរយនៅខេត្តសៀមរាប និង២៩ភាគរយនៅខេត្តបន្ទាយមានជ័យ) ប្រសិនបើខ្លួនមានឱកាសអាច ស្វែងរកការងារផ្សេងបាន ។

យោងតាមសន្និបាតឆ្នាំ២០០៨របស់ក្រសួងមហាផ្ទៃ បានឱ្យដឹងថា នៅឆ្នាំ២០០៧ ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទចំនួន ២១៨ករណី ត្រូវបានជួយសង្គ្រោះ និងប្រមូលផ្តុំជាសហគមន៍មួយសម្រាប់អ្នកទាំងនោះ រីឯបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយភាគច្រើនក្នុងចំណោម ២០.០០០នាក់ បានលក់សេវាផ្លូវភេទរបស់ខ្លួន (ដោយផ្ទាល់ ឬប្រយោល) ដើម្បីចិញ្ចឹមក្រពះ ឬបង្កើនប្រាក់ចំណូល ក្រៅពីប្រាក់ចំណូលដែលខ្លួនរកបានមកពីការងារផ្សេងទៀតសម្រាប់យកទៅផ្គត់ផ្គង់សមាជិកគ្រួសារក្នុងបន្ទុក ។

ភាពដឹកនាំដ៏រឹងមាំក្នុងការដោះស្រាយបញ្ហាប៉ះពាល់នានា ដូចជា ការជួញដូរមនុស្ស និងទម្លាប់រួមភេទដោយសុវត្ថិភាព ដែលមានទំនាក់ទំនងជិតយ៉ាងជ្រាលជ្រៅទៅនឹងការងាររកស៊ីផ្លូវភេទ កំពុងប្រឈមនឹងការខ្វះខាត ។ ប៉ូលីស និងអាជ្ញាធរមូលដ្ឋាន មានភាពប្រទាញប្រទង់គ្នារវាងកាតព្វកិច្ចពីរដែលពិបាកនឹងសម្របសម្រួលតាមគ្នាទៅវិញទៅមក ។




**ប្រភព : MOI, NCHADS/MOH ឆ្នាំ២០០៧**

**រូប ៧៨ : តុល្យភាពរវាងការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងការរកស៊ីផ្លូវភេទ**

## ២. ភាពខុសគ្នារវាងការយល់ឃើញ និងការពិតជាក់ស្តែង

- ៨៣ភាគរយនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង៩០ភាគរយនៃ បុរសស្រឡាញ់បុរស និងស្រីស្រស់ ជឿជាក់ថារដ្ឋាភិបាលមានភារកិច្ចការពារសិទ្ធិពលរដ្ឋគ្រប់ៗរូប រាប់ បញ្ចូលទាំងសិទ្ធិរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ផងដែរ ។

*ទស្សនៈស្តីពីការបញ្ឈប់មន្ត្រីទទួលខុសត្រូវមួយចំនួនដោយសារកត្តាសំខាន់ៗដែលជះឥទ្ធិពលដល់សិទ្ធិក្នុងការអនុវត្តន៏ការងាររបស់មន្ត្រីទាំងនោះមានកម្រិតខ្ពស់ជាងសិទ្ធិគ្រប់ប្រភេទរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់(សំណួរទី ៤៩ សម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងសំណួរទី ៤៨ សម្រាប់បុរសស្រឡាញ់បុរស និងស្រីស្រស់ ) ។*

- ៨៤ភាគរយនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង ៩០ភាគរយនៃបុរសស្រឡាញ់បុរស និងស្រីស្រស់ មានសិទ្ធិចូលរួមក្នុងការបង្កើតច្បាប់ និងគោលនយោបាយនានាដែលទាក់ទងទៅនឹងការរកស៊ីផ្លូវភេទ ។

*បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់បានបញ្ជាក់ថាខ្លួនបានចូលរួមពិភាក្សាអំពីច្បាប់ និងគោលនយោបាយនានាទាក់ទងនឹងការរកស៊ីផ្លូវភេទ ដូចជាច្បាប់ស្តីពីការបង្ការ និងត្រួតពិនិត្យការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ច្បាប់ស្តីពីការ បញ្ឈប់ការជួញដូរ*

*មនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ CEDAW គោលនយោបាយស្តីពីការប្រើប្រាស់ស្រោមអនាម័យ ១០០ ភាគរយ និងគោលនយោបាយស្តីពីមេរោគអេដស៍និងជំងឺអេដស៍នៅកន្លែងការងារ (សំណួរទី២០ សម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់) ។ តួនាទី របស់ជនទាំងនោះ មិនត្រូវបានគេទទួល ស្គាល់ពេញលេញឡើយ ។ តាមរយៈការសម្ភាសដ៏ស៊ីជម្រៅជាមួយ អ្នកផ្តល់ព័ត៌មានបានបង្ហាញថា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់ បុរស និងស្រីស្រស់មិនមានតំណាងគ្រប់គ្រាន់ក្នុងដំណើរការពិគ្រោះយោបល់សម្រាប់ការបង្កើតគោលនយោ បាយទាំងនោះឡើយ ។ ការបំពេញតួនាទីរបស់អ្នកទាំងនេះ ក្នុងនាមជាអតីត OPC SOP គឺក្នុងគោលបំណងស្វែងរកតំណាងអ្នកទទួលបានប្រយោជន៍ពីសេវានានា ជាជាងការបំពេញតួនាទីយ៉ាង សកម្មក្នុងការការពារសិទ្ធិដ៏ទូលំទូលាយរបស់ខ្លួន រាប់បញ្ចូលទាំងសិទ្ធិមានការងារធ្វើ និងសិទ្ធិរស់រានមាន ជីវិត (តំណាង WNU ក្នុង OPC TWG មិនមាននៅថ្នាក់ជាតិឡើយ ហើយគណៈកម្មការសម្របសម្រួលកម្មវិធីប្រើប្រាស់ស្រោមអនាម័យ100 ភាគរយ នៅថ្នាក់ខេត្ត ក៏ មិនមានដែរ) ។*

*ការលើកឡើងគួរឱ្យកត់សម្គាល់តាមរយៈការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ គឺថាការបង្កើតច្បាប់ស្តីពីការ បញ្ជប់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ត្រូវបានបញ្ចប់ដោយមានការចូលរួមពិគ្រោះយោបល់ពី តំណាងរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ។*

*ទោះបីជា WNU និង WHN មានសកម្មភាពក្នុងខេត្ត ៩ ក៏ដោយ ប៉ុន្តែទំនាក់ទំនងរវាងថ្នាក់មូលដ្ឋាន និង ថ្នាក់ជាតិ នៅតែមានកង្វះខាតដដែល ។ ការពិតជាក់ស្តែងនៃការចូលរួមចំណែកក្នុងការបង្កើត ឬពិនិត្យវាយ តម្លៃគោលនយោបាយនៅថ្នាក់មូលដ្ឋាន មិនអាចរាយការណ៍ទៅកាន់ថ្នាក់ខេត្ត និង/ឬថ្នាក់ជាតិ បានដោយ ងាយស្រួលឡើយ ។*

- ៨៩ភាគរយនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង ៩៦ភាគរយនៃ បុរសស្រឡាញ់ បុរស និងស្រីស្រស់ កំពុងទទួលបានសិទ្ធិស្មើភាព គ្នាដូចពលរដ្ឋដទៃទៀតមែនទេ?

*ទោះបីជាការរកស៊ីផ្លូវការដែលជាអំពើខុសច្បាប់មិនទាន់ត្រូវបានលើកឡើងច្បាស់លាស់ក្នុងច្បាប់ស្តីពីការ បញ្ជប់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទក្តី ប៉ុន្តែមាត្រាជាច្រើននៃច្បាប់នេះ បានកាត់បន្ថយ ឱកាសរបស់អ្នកបម្រើការសប្បាយ ក្នុងការស្វែងរកប្រាក់ចំណូលសម្រាប់ចិញ្ចឹមជីវិតពីការរកស៊ីផ្លូវភេទ ។ ម្យ៉ាងវិញទៀត អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា នៅប្រទេសកម្ពុជា មានបុរសចំនួន ២២០.០០០នាក់ ដែលបានយកប្រាក់ទៅទិញសេវាផ្លូវភេទរបស់ស្ត្រីរកផ្លូវភេទ (CHDH 2005) ។ ការជួញដូរផ្លូវភេទដែល ជាអំពើខុសច្បាប់គួរលើកយកមកពិភាក្សាដើម្បីចាត់វិធានការដោះស្រាយចំពោះតម្រូវការចាំបាច់ ។ ទោះ ជាយ៉ាងនេះក្តី ៨៣ភាគរយនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរស*

*ស្រឡាញ់បុរស និងស្រីស្រស់មិនធ្លាប់បានឃើញអតិថិជនដែលមករកសេវាបម្រើផ្លូវភេទ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ត្រូវបានចាប់ខ្លួនឡើយ ។*

## ៣. សិទ្ធិទទួលបានសេវាជាសកល

ភាគរយនៃការចូលរួមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ក្នុងយន្តការស្វែងរកការគាំទ្រដើម្បីការទទួលបានសេវាជាសកលមានប្រហែលជា ៣០ភាគរយ លើកលែងតែស្រីម៉ាស្សាតែប៉ុណ្ណោះ។ ដៃគូ បុរសស្រឡាញ់បុរស និងស្រីស្រស់ មានភាគរយនៃការចូលរួមខ្ពស់ជាងនេះ (៥៨ភាគរយ សម្រាប់ក្រុមបុរសស្រឡាញ់បុរស និង ៤៣ភាគរយសម្រាប់ស្រីស្រស់) (សំណួរទី៣១ សម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់)។ ទោះជាយ៉ាងនេះក្តី ការចូលរួមរបស់អ្នកទាំងនោះ ភាគច្រើនមានតែនៅក្នុងមូលដ្ឋានប៉ុណ្ណោះ។

*ទោះបីជា WNU និង WHN មានសកម្មភាពក្នុងខេត្ត ៩ ក៏ដោយ ប៉ុន្តែទំនាក់ទំនងរវាងថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ នៅតែមានកង្វះខាតដដែល។ ក្រៅពីស្ថាប័នផ្តល់ជំនួយនានា អង្គការសហគមន៍បុរសស្រឡាញ់បុរស ដែលធ្វើការនៅថ្នាក់មូលដ្ឋានដូចជាអង្គការ MHC, MHSS, Kanhnha ជាដើមមិនទាន់មានទំនាក់ទំនងជាប្រព័ន្ធជាមួយក្រុមការងារបច្ចេកទេសក្រុមបុរសស្រឡាញ់បុរសថ្នាក់ជាតិដើម្បីរាយការណ៍អំពី បញ្ហានានាទាក់ទងទៅនឹងវិសាលភាពនៃការធ្វើអន្តរាគមន៍ក្នុងតំបន់ប្រតិបត្តិការរបស់ខ្លួននៅឡើយទេ។*

*អង្គការមិនមែនរដ្ឋាភិបាលជាច្រើន កំពុងប្រើប្រាស់វិធីសាស្ត្រធ្វើអន្តរាគមន៍ និងមធ្យោបាយរាយការណ៍ផ្សេងៗគ្នា។ ក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងក្រុមការងារបច្ចេកទេសគ្រឿងញៀន និងជំងឺអេដស៍ កំពុង ខិតខំយ៉ាងស្វិតស្វាញដើម្បីកំណត់សូចនាករប្រមូល និងចងក្រងទិន្នន័យស្តីពីការគ្របដណ្តប់របស់សេវាសម្រាប់បុរសស្រឡាញ់បុរស និងស្រីស្រស់ និងការប្រើនិងចាក់គ្រឿងញៀន។*

## ៤. គុណភាពសេវាដែលទទួលបានជាសកល

ទោះបីជាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ត្រូវបានចាត់ទុកថាជាអ្នកទទួលប្រយោជន៍ពីសេវាភាគច្រើនក្តី ប៉ុន្តែស្ទើរតែគ្រប់ពេលបញ្ហាទាក់ទងនឹងគុណភាពសេវាជាសកល (ដូចជា សេវាដែលមានភាពរាក់ទាក់ ការចំណាយលើសេវានៅតំបន់មួយចំនួនជាដើម) មិនទាន់ត្រូវបានលើកយកមកពិភាក្សា ដោយបើកចំហនៅឡើយទេ។

បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ទទួលរងភាពអាម៉ាស់ និងការ រើសអើងក្នុងកម្រិតស្មើៗគ្នា និង មិនមានតំណាងគ្រប់គ្រាន់ កង្វះការសម្របសម្រួលរវាងថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ព្រមទាំងកង្វះការចូលរួមពីតំណាង មកពីអាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការជួញដូរមនុស្ស

នៅក្នុងយន្តការកម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ ដោយសារតែ កត្តាធ្ងន់ធ្ងរដែលជះឥទ្ធិពលដល់លទ្ធភាពរបស់អ្នកទាំងនោះក្នុងការទទួលបានសេវាជាសកល (សំណួរទី៥០ សម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងសំណួរទី៤៩ សម្រាប់បុរសស្រឡាញ់បុរស និងស្រីស្រស់ )។

## ៥. បញ្ហាអាចកើតមានឡើងទាក់ទងទៅនឹងការអនុវត្តន៍ច្បាប់ថ្មីស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ

ការវិភាគទៅលើសំណួរទី២៥ (តើ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ដែលបក់ដៃហៅអតិថិជន គួរដាក់ពិន័យដែរឬទេ?) នៅតាមកន្លែងរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទបានរកឃើញថា ការបកស្រាយ និងការអនុវត្តមាត្រា ២៤នៃច្បាប់ ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ មានភាពខុសគ្នាយ៉ាងខ្លាំង។ តាមរយៈការសម្ភាស ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ៧ បានបង្ហាញថា ប៉ូលីសមូលដ្ឋាន មិនទាន់ទទួលបានការបណ្តុះបណ្តាលអំពីការប្រើប្រាស់ គោលការណ៍ណែនាំស្របគ្នាសម្រាប់ការអនុវត្តន៍ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ឱ្យបានគ្រប់គ្រាន់ និងសមស្រប នៅឡើយទេ។

ទោះបីជា ៥៤ភាគរយនៃ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង ៥៧ភាគរយនៃ បុរសស្រឡាញ់បុរស និងស្រីស្រស់បានបញ្ជាក់ថា កងកម្លាំងប៉ូលីស មិនបានបែងចែកឱ្យច្បាស់លាស់រវាងអ្នករកស៊ីផ្លូវភេទដោយស្ម័គ្រចិត្ត និងអ្នករងការជួញដូរក៏ដោយ ប៉ុន្តែករណីទាំងនោះមិនអាចគេចផុតពីសំណាញ់ច្បាប់បានឡើយ។ មាត្រាជាច្រើននៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ដូចជាការលោងលោមបញ្ចុះបញ្ចូល ការជួលបន្ទប់ និងការបញ្ជាជាសាធារណៈ អាចជាភស្តុតាងគ្រប់គ្រាន់សម្រាប់ឈានដល់ការចាប់ខ្លួនជនទាំងនោះ។ យោងតាមការ សម្ភាសស៊ីជម្រៅជាមួយអ្នកដែលត្រូវចាប់ខ្លួន បានរកឃើញថា បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ភាគច្រើនត្រូវប៉ូលីសចាប់ខ្លួនដោយ មិនប្រាប់ពីមូលហេតុនៃការចាប់ខ្លួននេះឡើយ។ ចំពោះការដោះលែងជនទាំងនោះវិញ ៣៤ភាគរយ នៃអ្នកឆ្លើយសំណួរបានបញ្ជាក់ថា ខ្លួនត្រូវផ្តល់សំណូកដល់ប៉ូលីសដើម្បីជាថ្នូរនឹងការដោះលែងនេះ។

ការរំពឹងទុករបស់អ្នកទាំងនោះចំពោះសេវាគាំទ្រដែលប៉ូលីស និងអាជ្ញាធរមូលដ្ឋាននឹងផ្តល់ឱ្យនៅពេលដែលខ្លួនទទួលរងការរំលោភបំពាន

- មានកម្រិតទាបចំពោះ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទគ្រប់ប្រភេទ (លើកលែងតែស្រីខារ៉ាអូខេ) (សំណួរទី៣៨)។
- មានកម្រិតទាបចំពោះបុរសស្រឡាញ់បុរស និងស្រីស្រស់(សំណួរទី៣៦)។

ពួកគេទាំងនោះរំពឹងថាខ្លួននឹងទទួលបានជំនួយពីបណ្តាអង្គការមិនមែនរដ្ឋាភិបាល ច្រើនជាងពីប៉ូលីស និងអាជ្ញាធរមូលដ្ឋាន ដើម្បីជួយពួកគេឱ្យទទួលបានសិទ្ធិរបស់ខ្លួនវិញ បន្ទាប់ពីត្រូវគេរំលោភបំពាន (សំណួរទី៣៩ សម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងសំណួរទី៣៧ សម្រាប់បុរសស្រឡាញ់បុរស និងស្រីស្រស់)។

តារាងខាងក្រោមនេះសង្ខេបអំពីការផ្លាស់ប្តូរដែលកើតមានចំពោះលទ្ធភាពទទួលបានសេវាជាសកលនៅចន្លោះឆ្នាំ២០០៧-២០០៨ និងព្រឹត្តិការណ៍ និងវិធានការដែលរារាំងដល់ការធ្វើអន្តរាគមន៍ទប់ស្កាត់នានា។

តាមរយៈការសង្កេតទូទៅដូចមានបង្ហាញក្នុងតារាងខាងក្រោមនេះការកើនឡើងនូវវិសាលភាពនៃការធ្វើ អន្តរាគមន៍ មិនជាប់ទាក់ទងជាចាំបាច់ទៅនឹងភាពញឹកញាប់នៃការធ្វើអន្តរាគមន៍ ឬព្រឹត្តិការណ៍ និងវិធានការនានាឡើយ។

*សម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទវិសាលភាពនៃមិត្តអប់រំមិត្ត ជំងឺកាមរោគ និងការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់កំពុងមានការកើនឡើង។ ទោះបីជាប្រេកង់នៃការប្រើប្រាស់សេវា ជំងឺកាមរោគ និង ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់កំពុងថយចុះក៏ដោយ ប៉ុន្តែវត្តមានមិត្តអប់រំមិត្តកំពុងកើនឡើង។ ទន្ទឹមនឹងនោះដែរ ទោះបីជាការផ្លាស់ទី និងការចាប់ខ្លួន បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ កំពុងថយចុះក៏ដោយ ប៉ុន្តែការប្រើប្រាស់សេវាជំងឺកាមរោគ និង ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ក៏កំពុងថយចុះផងដែរ។*

*សម្រាប់បុរសស្រឡាញ់បុរស និងស្រីស្រស់វិសាលភាពនៃមិត្តអប់រំមិត្ត មិនមានការផ្លាស់ប្តូរឡើយ ប៉ុន្តែវិសាលភាព នៃការប្រើប្រាស់សេវាជំងឺកាមរោគ និងការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ កំពុងមានការកើនឡើង។ ប្រេកង់នៃការប្រើប្រាស់សេវាទាំងបីនេះមានទំនោរកំពុងតែថយចុះ។ ទោះជាយ៉ាងនេះក្តីវិសាលភាពនៃការប្រើប្រាស់សេវាទាំងបីនេះ មិនមានការ ថយចុះខ្លាំងក្លាឡើយ។ ការកើនឡើងយ៉ាងខ្លាំងនូវការចាប់ខ្លួនបុរសស្រឡាញ់បុរស និងស្រីស្រស់ អាចជាហេតុផល មួយដែលនាំឱ្យប្រេកង់ នៃការប្រើប្រាស់សេវាទាំងបីនេះថយចុះ។*

**តារាងទី២៧ : ការផ្លាស់ប្តូរកំរិតគ្របដណ្តប់ និងភាពញឹកញាប់នៃវត្តមានមិត្តអប់រំមិត្ត** ជំងឺកាមរោគ **និងការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ក្នុងចំណោម អ្នកបម្រើសេវាកំសាន្ត/អ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់បុរស/ ស្រីស្រស់និងការផ្លាស់ទី ព្រមទាំងការចាប់ខ្លួនជនទាំងនេះ នៅឆ្នាំ២០០៧-២០០៨**

| ប្រជាជនគោលដៅ | ប្រភេទអថេរ | មិត្តអប់រំមិត្ត | ជំងឺកាមរោគ | VCCT | | ការផ្លាស់ទី | ការចាប់ខ្លួន |
|---|---|---|---|---|---|---|---|
| បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អ្នករកស៊ីផ្លូវភេទ | វិសាលភាព | កើនឡើង | កើនឡើង | កើនឡើង | | ថយចុះ | ថយចុះ |
| | វត្តមានសេវាទាំងនោះ ឬព្រឹត្តិការណ៍/ វិធានការជាមធ្យម | កើនឡើងខ្លាំង | ថយចុះ តិចតួច | ថយចុះខ្លាំង | | កាត់បន្ថយ ច្រើន | កាត់បន្ថយ តិចតួច |
| **បុរសស្រឡាញ់ បុរស និងស្រីស្រស់** | វិសាលភាព | មិនផ្លាស់ប្តូរ | កើនឡើង | កើនឡើង | | កើនឡើង | កើនឡើង |
| | វត្តមានសេវាទាំងនោះ ឬព្រឹត្តិការណ៍/ វិធានការជាមធ្យម | ថយចុះតិចតួច | ថយចុះ តិចតួច | ថយចុះតិចតួច | | កាត់បន្ថយ ច្រើន | កើនឡើងខ្លាំង |

## VI. អនុសាសន៍

អនុសាសន៍ខាងក្រោមនេះ បានមកពីលទ្ធផលនៃការស្រាវជ្រាវសកម្មភាព និងការខិតខំប្រឹងប្រែង ព្រមទាំងធនធានមានស្រាប់របស់ភាគីពាក់ព័ន្ធ ទាក់ទងទៅនឹងសិទ្ធិរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ និងលទ្ធភាព របស់ជនទាំងនោះ ក្នុងការទទួលបានសេវាជាសកល ។ ទម្រង់ណែនាំស្តីពី មេរោគអេដស៍ និងការរកស៊ីផ្លូវភេទដែលផ្តល់ដោយ UNAIDS ចេញផ្សាយកាលពីខែកុម្ភៈ ឆ្នាំ២០០៩ ត្រូវបាន ប្រើប្រាស់សម្រាប់ការដាក់ចេញនូវអនុសាសន៍ទាំងនេះ។ កំណត់ចំណាំណែនាំនេះបានពិពណ៌នាអំពីសសរស្តម្ភបី ដូចខាងក្រោម :

- ***គោលដៅទី ១ : ធានាឱ្យបាននូវលទ្ធភាពទទួលបានជាសកល ដើម្បីការបង្ការ ការព្យាបាល ការថែទាំ និងគាំទ្រមេរោគអេដស៍ឱ្យបានទូលំទូលាយ***
- ***គោលដៅទី ២ : បង្កើតបរិយាកាសគាំទ្រ ពង្រឹងភាពជាដៃគូ និងបង្កើនជម្រើស***
- ***គោលដៅទី ៣ : កាត់បន្ថយភាពងាយរងគ្រោះ និងដោះស្រាយបញ្ហារចនាសម្ព័ន្ធ***

សសរស្តម្ភនីមួយៗពិតជាមានភាពសំខាន់ចាំបាច់ណាស់ ហើយសសរស្តម្ភទាំងបីនេះ ពឹងអាស្រ័យគ្នាទៅវិញទៅមក និងគួរសម្របសម្រួល និងយកទៅអនុវត្តក្នុងពេលដំណាលគ្នា។ សសរស្តម្ភទាំងបីនេះ ចាំបាច់ត្រូវមានវិធីសាស្ត្រភ្លាមៗសម្រាប់រយៈពេលខ្លី និងការចាត់វិធានការសម្រាប់រយៈពេលវែង។

### ៤. <u>សសរស្តម្ភទី១ : ធានាឱ្យបាននូវលទ្ធភាពទទួលបានជាសកល ដើម្បីការបង្ការ ការព្យាបាល ការថែទាំ និងគាំទ្រមេរោគអេដស៍ឱ្យបានទូលំទូលាយ</u>

#### ក. ការជម្នះឧបសគ្គតាមរចនាសម្ព័ន្ធ ដើម្បីទទួលបានលទ្ធភាពជាសកល

*បណ្តា CBO តំណាងឱ្យបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ គួរ ចងក្រងទុកជាប្រចាំនូវឯកសារទាក់ទង នឹងបញ្ហាអាម៉ាស់ ការរើសអើង អំពើហិង្សា និងការរំលោភបំពានមកលើជន ទាំងនោះ ព្រមទាំងលើកយកបញ្ហាទាំងនោះ មកពិភាក្សាក្នុងវេទិការថ្នាក់ខេត្ត ដើម្បីស្វែងរកដំណោះស្រាយ សមស្របសម្រាប់បញ្ហាទាំងនោះ។ ទំនាក់ទំនង រវាង CBO ទាំងនោះជាមួយនឹងយន្តការថ្នាក់ជាតិ (ដូចជា ក្រុមបង្គោលរបស់ EW, OPC TWG, NMSMTWG និង DHA TWG) គួរត្រូវបានលើកកម្ពស់ ដើម្បីសម្របសម្រួលស្វែងរកដំណោះស្រាយសម្រាប់ករណីទាំងនោះ ។*

#### ខ. ឥរិយាបថ ការផ្លាស់ប្តូរ និងការប្រាស្រ័យទាក់ទង

- *OPC TWG, NMSMTWG និង DHA TWG គួរពិនិត្យវាយតម្លៃវិធីសាស្ត្រ និងយុទ្ធសាស្ត្រដែលកំពុងអនុវត្ត ដើម្បីផ្លាស់ប្តូរឥរិយាបថរបស់ MARRPs ។*
- *ការកំណត់កញ្ចប់ស្តង់ដាររបស់ BCC គួរធ្វើឡើងដើម្បីឱ្យសមាជិកទាំងអស់របស់ OPC TWG, NMSMTWG និង DHA TWG អាចយកទៅប្រើប្រាស់បាន ។*

- *សមាជិកទាំងអស់របស់ OPC TWG, NMSMTWG និង DHA TWG គួរកំណត់ទម្រង់ និងប្រព័ន្ធរាយការណ៍ស្តង់ដារ សម្រាប់យកមកអនុវត្តក្នុងក្រុមរបស់ខ្លួន ។*

**គ. ទំនាក់ទំនង និងការដាក់បញ្ជូលគ្នានៃសេវា**

- *គាំទ្រដល់ការអនុវត្ត SOP ថ្មី ដើម្បីបន្តបង្ការ ថែទាំ និងព្យាបាលស្ត្រីគ្រឹះស្ថានកំសាន្តសប្បាយ (NCHADS) ដែលបើកទូលាយសម្រាប់ទំនាក់ទំនងជាមួយសេវាផ្សេងទៀតក្រៅពីសេវាសុខភាព (ដូចជា សេវា សង្គម ច្បាប់ និងសេដ្ឋកិច្ចជាដើម) ។*
- *ផ្តល់យោបល់អំពីការដាក់បញ្ចូល បុរសស្រឡាញ់បុរស និងស្រីស្រស់ ទៅក្នុង SOP ថ្មី ដើម្បីបន្តការបង្ការ ការថែទាំ និងការព្យាបាលដល់ជនទាំងនោះ ។*
- *ទម្រង់ និងប្រព័ន្ធរាយការណ៍ស្តង់ដារ គួរកំណត់ក្នុង SOP ថ្មី ដើម្បីឱ្យភាគីពាក់ព័ន្ធយកទៅប្រើប្រាស់ ។*

**ឃ. ការលុបបំបាត់អំពើហិង្សាលើអ្នករកស៊ីផ្លូវភេទ**

- *ផ្តល់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ ដល់ការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រសួងមហាផ្ទៃ ជាពិសេសស្តីពី ការកសាងសមត្ថភាពរបស់កងកម្លាំងប៉ូលីស និងអាជ្ញាធរមូលដ្ឋាន ដើម្បីក្លាយទៅជាចលករសហគមន៍ ។*
- *ពង្រីក និងពង្រឹងបន្តការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីការពារ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទពីអតិថិជនដែលសេពគ្រឿងស្រវឹង និងគ្រឿងញៀនមិនបានសមស្រប នាំឱ្យមានអំពើហិង្សា កើតឡើងចំពោះជនទាំងនេះ ។*

**ង.** បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ **ដែលមានផ្ទុកមេរោគ អេដស៍/ជំងឺអេដស៍**

- *ផ្តល់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុដល់ CBO និង NGO នានាដែលធ្វើការជាមួយ* បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ *(ដូចជា WHN, WNU, CCW,CNMWD, CPU , WAC, BC ជាដើម) ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់ជន ដែលមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ។*

**៥. <u>សសរស្តម្ភទី២ : បង្កើតបរិយាកាសគាំទ្រ ពង្រឹងភាពជាដៃគូ និងបង្កើនជម្រើស</u>**

**ក. បរិស្ថានគាំទ្រ**

- *ក្រុមងាយរងគ្រោះបំផុតមិនគួរចាត់ទុកថាជាអ្នកទទួលប្រយោជន៍ពីសេវានានាឡើយ ប៉ុន្តែសំឡេងរបស់ជនទាំងនេះគួរ មាននៅតាមស្ថាប័ននានា ដើម្បីធ្វើជាយន្តការឆ្លើយតបចាប់ពីថ្នាក់បង្កើត និងអនុវត្តគោលនយោបាយ រហូតដល់ថ្នាក់មូលដ្ឋាន ។ អ្នកទាំងនេះគួរទទួលបានការលើកទឹកចិត្តឱ្យចូលរួមយ៉ាងសកម្មក្នុងវេទិកានានា ដើម្បីដោះស្រាយបញ្ហានៃការរើសអើង ការបៀតបៀន និងការរំលោភបំពាន*

*នានា។ បណ្តា ក្រុមងាយរងគ្រោះបំផុត អង្គការសហគមន៍ គួរទទួលបានសិទ្ធិអំណាច ដើម្បីធ្វើជាម្ចាស់លើខ្លួនឯង និងអាចគ្រប់គ្រងការលំបាក និង គោលដៅរបស់ខ្លួនដោយផ្ទាល់បាន។*

- *ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុគួរធ្វើឡើងឱ្យបានខ្លាំងក្លា ដើម្បីកសាងសមត្ថភាពរបស់ អង្គការមិនមែនរដ្ឋាភិបាល និង ក្រុមងាយរងគ្រោះបំផុត ដែលតំណាងឱ្យ ឬធ្វើការជាមួយ ក្រុមងាយរងគ្រោះបំផុត។ សមត្ថភាពរបស់អង្គការទាំងនេះ ចាំបាច់ត្រូវទទួលបានការគាំទ្រផងដែរ។*

### ខ. ភាពជាដៃគូយុទ្ធសាស្ត្រ

- *ត្រៀមតរេធនធានដើម្បីរៀបចំភាពជាអ្នកដឹកនាំសម្រាប់លទ្ធផល នៃការកសាងភាពជាដៃគូយុទ្ធសាស្ត្ររបស់ក្រុមងាយរងគ្រោះបំផុត អង្គការសហគមន៍ និងការបង្កើតបណ្តាញជាមួយភាគីពាក់ព័ន្ធនានាមកពីស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល វិស័យ ឯកជន ចាប់ពីថ្នាក់ជាតិ ដល់ថ្នាក់មូលដ្ឋាន។*
- *ភាពជាដៃគូរបស់រចនាសម្ព័ន្ធដែលមានស្រាប់ដូចជាក្រុមការងារបច្ចេកទេសចុះអប់រំផ្ទាល់ និងស្រោមអនាម័យ១០០ភាគរយ ក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរសថ្នាក់ជាតិ ក្រុមការងារបច្ចេកទេសគ្រឿងញៀន និងជំងឺអេដស៍ ក្រុមបង្គោលរបស់អ្នករកស៊ីផ្លូវភេទ វេទិការថ្នាក់ជាតិស្តីពីភាពជាដៃគូ និងមូលនិធិសកល គួរលើកយកមកពិនិត្យវាយតម្លៃ ដើម្បីដាក់បញ្ចូលតំណាងរបស់ ក្រុមងាយរងគ្រោះ បំផុត។*

### គ. ការមើលងាយ និងការរើសអើង

- *ដើម្បីកាត់បន្ថយការមើលងាយ និងទម្លាប់រើសអើងនាពេលបច្ចុប្បន្ននេះ អន្តរាគមន៍តាមសហគមន៍ដើម្បីទទួលបានការអនុញ្ញាតឱ្យចូលរួមក្នុងសង្គម និងការកសាងសមត្ថភាព គួរផ្តោតការយកចិត្តទុកដាក់ទៅលើក្រុមស្ត្រី ប្រធានសហគមន៍ និងមេដឹកនាំសាសនា។*
- *ដើម្បីដោះស្រាយបញ្ហាទាំងនេះ ការត្រៀមគរជំនួយ គួរអនុវត្តដើម្បីរៀបចំកិច្ចពិភាក្សាតាមសហគមន៍ យ៉ាងហោចណាស់នៅតំបន់ក្លឹបរាត្រីកំសាន្តជុំវិញសហគមន៍។*

### ឃ. ការផ្តល់ជម្រើសកាន់តែច្រើន

- *ទំនាក់ទំនងរវាងកម្មវិធីស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ និងកិច្ចខិតខំប្រឹងប្រែងរបស់បណ្តោលការពារសុវត្ថិភាពសង្គមជាតិគួរលើកយកមកសិក្សាស្វែងយល់ ដើម្បីផ្តល់ជម្រើសដល់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ឱ្យបានកាន់តែច្រើនតាមរយៈការផ្តល់ឱកាស ការងារ និងការប្រកបរបរចិញ្ចឹមជីវិតចម្រុះ ដូចជា ការងារ ការផ្តល់ជំនួយជាសាច់ប្រាក់ឥណទានខ្នាតតូច និងមីក្រូហិរញ្ញវត្ថុ។*

## ៦. គោលដៅទី៣ : កាត់បន្ថយភាពងាយរងគ្រោះ និងដោះស្រាយបញ្ហារចនាសម្ព័ន្ធ

ការខិតខំប្រឹងប្រែងដើម្បីបង្ការការឆ្លងមេរោគអេដស៍ នឹងមិនអាចសម្រេចបានជោគជ័យសម្រាប់រយៈពេលវែងបានឡើយ ប្រសិនបើគ្រោះថ្នាក់ និងភាពងាយរងគ្រោះដោយសារមេរោគអេដស៍ មិនត្រូវបានដោះស្រាយប្រកបដោយ

ប្រសិទ្ធភាពទេនោះ ។ គោលដៅនេះ អាចដោះស្រាយបញ្ហានៃភាពក្រីក្រ ជម្រើសសេដ្ឋកិច្ចដែលមានកម្រិត វិសមភាពយែនឌ័រ បទដ្ឋាន និងទំនាក់ទំនង នាំឱ្យមានគ្រោះថ្នាក់ កង្វះលទ្ធភាពទទួលបានការអប់រំ ការផ្លាស់ទី និងការធ្វើចំណាកស្រុក និងស្ថានភាពទាក់ទងនឹងមនុស្សធម៌ ។

**ក. ការលើកកម្ពស់ការអប់រំសម្រាប់ទាំងអស់គ្នា**

- *ការវិនិយោគជាច្រើន គួរធ្វើឡើងសម្រាប់ការអប់រំដល់កុមារ ដែលគាំទ្រដោយគោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នា ប្រសិនបើការអប់រំសកលកម្មបឋមសិក្សា និងមធ្យមសិក្សាត្រូវបានផ្តល់ជាអាទិភាព ។ ការខិតខំប្រឹងប្រែងជានិរន្តរភាព នឹងធានាដល់ការកាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រី និងកុមារី ពីមេរោគអេដស៍បានយូរអង្វែង ។*

**ខ. សមភាពយែនឌ័រ បទដ្ឋាន និងទំនាក់ទំនងយែនឌ័រ**

- *ដើម្បីធានាសម្រេចឱ្យបានជោគជ័យក្នុងការដោះស្រាយបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍សម្រាប់ រយៈពេលវែង ការដោះស្រាយបញ្ហារំលោភបំពានលើសិទ្ធិមនុស្ស វិសមភាពយែនឌ័រ ភាពអាម៉ាស់ និងការរើសអើងគួរបន្តអនុវត្តជានិរន្តរភាព ។*
- *ដើម្បីកាត់បន្ថយតម្រូវការផ្លូវភេទរបស់បុរសដែលមានដៃគូរួមភេទច្រើន កម្មវិធីផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់បង្ហាញពីភស្តុតាងនានាដល់បុរសទាំងនោះ គួរដាក់បញ្ចូលទៅក្នុងអន្តរាគមន៍ដែលកំពុងអនុវត្តដើម្បីពង្រឹងបទដ្ឋាននានាដែលបង្ហាញពីផ្នត់គំនិតចាស់គំរិលរបស់បុរស ។*

**គ. ការដោះស្រាយភាពក្រីក្រ និងជម្រើសសេដ្ឋកិច្ចដែលនៅមានកម្រិត**

- *ការខិតខំប្រឹងប្រែង គួរធ្វើឡើងដើម្បីបង្កើនភាពឯករាជ្យរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច សម្រាប់ផ្តល់ឱកាសការងារជាច្រើនដល់ស្ត្រីទាំងនោះ ។*

**ឃ. ការដោះស្រាយតម្រូវការរបស់ប្រជាជនចំណាកស្រុក**

- *ធនធានគួរត្រូវបានកៀរគរដើម្បីគាំទ្រដល់ការបង្កើតគោលនយោបាយស្តីពីកន្លែងធ្វើការរបស់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ដោះស្រាយភាពអាម៉ាស់របស់ប្រជាជនចំណាកស្រុកដែលទទួលរងគ្រោះថ្នាក់ ។*

## VII. សេចក្ដីសន្និដ្ឋាន

តាមរយៈការប្រមូលទិន្នន័យចាំបាច់ និងទិន្នន័យបន្ទាប់បន្សំជាច្រើន នៅខេត្តព្រះសីហនុ បន្ទាយមានជ័យ សៀមរាប និងរាជធានីភ្នំពេញ ព្រមទាំងការវិភាគទៅលើទិន្នន័យទាំងនោះ ការស្រាវជ្រាវនេះ អាចទាញចេញនូវសេចក្ដីសន្និដ្ឋានដូចខាងក្រោម ដើម្បីបង្ហាញពីគោលបំណងជាក់លាក់នៃការស្រាវជ្រាវដើម្បីធ្វើសកម្មភាពនេះ ។

### ១. ការយល់ដឹងអំពីភាពងាយរងគ្រោះរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ និងសិទ្ធិរស់រានមានជីវិត និងសិទ្ធិមានការងារធ្វើរបស់ពួកគេ

ការស្រាវជ្រាវដើម្បីសកម្មភាពនេះបង្ហាញពីល័ក្ខខ័ណ្ឌនិងបរិយាកាសដែលនាំឱ្យបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ធ្លាក់ទៅក្នុងស្ថានភាពងាយរងគ្រោះ ។ ល័ក្ខខ័ណ្ឌទាំងនោះមានដូចជាល័ក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គមកិច្ច និងបរិយាកាសធ្វើការរបស់ជនទាំងនោះ ។ ម្យ៉ាងវិញទៀត ការស្រាវជ្រាវនេះក៏បង្ហាញពីការយល់ឃើញរបស់ពួកគេទាំងនោះ ចំពោះគោលនយោបាយទាក់ទងនឹងការរកស៊ីផ្លូវភេទ ការពិតជាក់ស្ដែងក្នុងការអនុវត្តន៍ ច្បាប់ និងគោលនយោបាយនានានៅកន្លែងបម្រើសេវាកំសាន្តសប្បាយ ។

### ២. ការទទួលបានសេវាជាសកល និងគុណភាពសេវា

កំរិតគ្របដណ្ដប់នៃសេវាជាសកល ដែលបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ទទួលបាន នៅឆ្នាំ២០០៨ អាចត្រូវ បានសង្ខេបដូចខាងក្រោម :

- កំរិតគ្របដណ្ដប់នៃកម្មវិធីមិត្តអប់រំមិត្តដល់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់មិនទាន់កើនឡើងគួរឱ្យកត់សម្គាល់នៅឡើយទេចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៨ (សម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ វិសាលភាពនេះបានកើនឡើងពី៦៣ភាគរយ ដល់ ៦៥ភាគរយ និងសម្រាប់បុរសស្រឡាញ់បុរស និងស្រីស្រស់ មានស្ថិរភាពត្រឹម ៧៤ ភាគរយ) ។
- កំរិតគ្របដណ្ដប់នៃជំងឺកាមរោគនៅឆ្នាំ២០០៨ មានចំនួន ៦៨ភាគរយ សម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់មានតែ ៤៦ភាគរយប៉ុណ្ណោះ ។
- ភាពគ្របដណ្ដប់នៃសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់នៅឆ្នាំ ២០០៨ មានចំនួន ៧៨ភាគរយ សម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង ៧៣ភាគរយ បុរសស្រឡាញ់បុរស និងស្រីស្រស់ ។

- ពេលវេលាជាមធ្យមនៃការចូលរួមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងកម្មវិធី ជំងឺកាមរោគនិងផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត មានចំនួនថយចុះបន្តិចបន្តួច។
- វិសាលភាពនៃកម្មវិធីអប់រំអំពីគ្រឿងញៀន ក្នុងការឈានទៅដល់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទមានអត្រា ២៩ភាគរយ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ មានអត្រា៥៥ភាគរយ រីឯក្រុមថែទាំតាមផ្ទះវិញ មានអត្រា៥៥ភាគរយ ចំពោះបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង ២៥ភាគរយ ចំពោះ បុរសស្រឡាញ់បុរស និងស្រីស្រស់។
- ការបញ្ជូនដៃគូរបស់ខ្លួនទៅព្យាបាលនៅឆ្នាំ២០០៨ មានអត្រា២៦ភាគរយ សម្រាប់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង២២ ភាគរយសម្រាប់បុរសស្រឡាញ់បុរស និងស្រីស្រស់តែប៉ុណ្ណោះ។
- ភាពរួសរាយរាក់ទាក់របស់អ្នកផ្តល់សេវា ថ្លៃចំណាយលើសេវា និងកត្តាផ្សេងៗទៀតទាក់ទងទៅនឹងគុណភាពសេវាបានសង្ខេបដូចខាងក្រោម :
- បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់គ្រប់ប្រភេទទាំងអស់ បានបញ្ជាក់ថា អ្នកផ្តល់សេវា ជំងឺកាមរោគនិងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់មានភាពរួសរាយរាក់ទាក់ចំពោះខ្លួន រីឯបុរសស្រឡាញ់បុរស និងស្រីស្រស់ ក៏បានបញ្ជាក់ដូច្នោះដែរ។
- ភស្តុតាងជាច្រើន បានបង្ហាញពីថ្លៃចំណាយលើសេវាជំងឺកាមរោគនិងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ នៅតាមបណ្តាខេត្តមួយចំនួន។ ទោះបីជាយ៉ាង នេះក្តីថ្លៃចំណាយលើសេវាទាំងនោះ មានចំនួនតិចជាង ២០ដុល្លារសហរដ្ឋអាមេរិក។
- បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ទាំងអស់បានលើកឡើងពីអត្រានៃការមើលងាយ និងការរើសអើងមកលើខ្លួន ហើយកង្វះខាតតំណាង ការសម្របសម្រួលរវាងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងការចូលរួមរបស់ជនទាំងនោះ ក្នុងការប្រឆាំងនឹងការជួញដូរមនុស្ស និង ការទប់ស្កាត់គ្រឿងញៀន និងកង្វះខាតបណ្តាញសិទ្ធិមនុស្សក្នុងការអនុវត្តកម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយត្រូវបានរកឃើញថាជាកត្តាខ្វះខាតធ្ងន់ធ្ងរទាក់ទងទៅនឹងលទ្ធភាព ទទួលបានសេវាជាសកល។

## ៣. ផលប៉ះពាល់នៃការអនុវត្តច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ

ការស្រាវជ្រាវនេះ ក៏បានវាយតម្លៃទៅលើផលប៉ះពាល់នៃការអនុវត្តច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ មកលើលទ្ធភាពទទួលបានជាសកលទាក់ទងទៅនឹងកម្មវិធីស្តីពីការបង្ការ ការព្យាបាល ការថែទាំ និងការឧបត្ថម្ភគាំទ្រ និងទៅលើការកាត់បន្ថយផលប៉ះពាល់ទាំងនោះផងដែរ។ ការស្រាវជ្រាវនេះ បានរក

ឃើញថា ការកើនឡើងនូវវិសាលភាពនៃការធ្វើអន្តរាគមន៍ មិនទាន់មានទំនាក់ទំនងសំខាន់ចាំបាច់ទៅនឹងប្រេកង់នៃការធ្វើអន្តរាគមន៍ ឬព្រឹត្តការណ៍/វិធានការនានាទេ។

- ភាពគ្របដណ្តប់នៃកម្មវិធីមិត្តអប់រំមិត្ត STI និង VCCT មានការកើនឡើងសម្រាប់ អ្នកបម្រើសេវាកំសាន្ត/ អ្នករកស៊ីផ្លូវភេទ ។ ទោះបីជាយ៉ាងនេះក្តី ប្រេកង់នៃការចូលរួមក្នុងកម្មវិធី STI និង VCCT កំពុងមានការថយចុះ រីឯការប្រេកង់ នៃការចូលរួមក្នុងកម្មវិធីមិត្តអប់រំមិត្ត កំពុងមានការកើនឡើង។ ប្រេកង់នៃការផ្លាស់ទី និងការចាប់ខ្លួន អ្នកបម្រើសេវាកំសាន្ត/អ្នករកស៊ីផ្លូវភេទកំពុងមានការកើនឡើង។
- ភាពគ្របដណ្តប់នៃកម្មវិធីមិត្តអប់រំមិត្ត មិនមានការផ្លាស់ប្តូរឡើយ ចំពោះ បុរសស្រលាញ់បុរស/ស្រីស្រស់ រីឯ ភាពគ្របដណ្តប់នៃកម្មវិធី STI និង VCCT វិញ កំពុងមានការកើនឡើង។ ប្រេកង់នៃការចូលរួមក្នុងកម្មវិធីផ្តល់សេវាទាំងបីនេះ មានទំនោរថយចុះ។ ទោះបីជាយ៉ាងនេះក្តី ការថយចុះទាំងនោះ មិនមានចំនួនច្រើនឡើយ។ ការកើនឡើងយ៉ាងខ្លាំងនៃការចាប់ខ្លួន បុរសស្រលាញ់បុរស/ស្រីស្រស់ អាចជាហេតុផលមួយដែល នាំឱ្យប្រេកង់នៃការប្រើប្រាស់សេវាទាំងនេះ មានការថយចុះ។

ការស្រាវជ្រាវសកម្មភាពនេះ បានផ្តល់ការក្រើនរំលឹកដ៏សំខាន់មួយគឺថា លទ្ធផលរកឃើញពីការស្រាវជ្រាវនេះ មិនអាចយកទៅប្រើសម្រាប់បកស្រាយអំពីផលប៉ះពាល់ពីការអនុវត្ត LSHES តែប៉ុណ្ណោះទេ ថែមទាំងអាចយល់អំពីលក្ខណៈទូលំទូលាយទូទៅនៃឧស្សាហកម្មផ្លូវភេទនៅប្រទេសកម្ពុជា ដែលមានការវិវត្តក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ។ ក្នុងអំឡុងប៉ុន្មានទសវត្សរ៍កន្លងទៅនេះ ផលប៉ះពាល់ជារួមនៃកត្តាខុសៗគ្នាក្នុងឧស្សាហកម្មផ្លូវភេទ និងកន្លែងបម្រើការសប្បាយ និងការអនុវត្តច្បាប់ស្តីពីការបញ្ឈប់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ នៅឆ្នាំ២០០៨ កំពុងជះឥទ្ធិពលទៅលើលទ្ធភាពរបស់ អ្នកបម្រើសេវាកំសាន្ត/អ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់បុរស/ស្រីស្រស់ ក្នុងការទទួលបានសេវា។ ទោះបីជា ភាពគ្របដណ្តប់របស់សេវាជាច្រើន កំពុងមានការកើនឡើងក្នុងអំឡុងពេល១ឆ្នាំកន្លងទៅនេះក៏ដោយ ប៉ុន្តែប្រេកង់ នៃការចូលរួមរបស់ អ្នកបម្រើសេវាកំសាន្ត/អ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់បុរស/ស្រីស្រស់ ក្នុងកម្មវិធីផ្តល់សេវាទាំងនោះ កំពុងចាប់ផ្តើមថយចុះ។

ប្រសិនបើបរិស្ថានមិនគាំទ្រអូសបន្លាយពេលកាន់តែយូរ ហើយវិធានការតស៊ូមតិរបស់ NGOs និង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ/អ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់បុរស/ស្រីស្រស់ មិនអាចលេចឮបានទេ ហើយផលប៉ះពាល់ទៅ លើសេវាជាសកល អាចមានកម្រិតកាន់តែខ្ពស់ជាងអ្វីដែលលទ្ធផលរកឃើញថ្មីៗនេះ បានបង្ហាញក្នុងរបាយការណ៍នេះ។

តាមរយៈលទ្ធផលនៃការស្រាវជ្រាវសកម្មភាពនេះ សក្តានុពលនៃការឆ្លងមេរោគអេដស៍នៅតាមផ្ទះបន មិនអាចកំណត់បានឡើយ ដោយសារតែ DSW ស្ត្រីម៉ាស្សា និងរកស៊ីផ្លូវភេទដោយឯករាជ្យ មានចំនួនដៃគូកាន់តែច្រើន បើប្រៀបធៀបទៅនឹង មិត្តភ័ក្តិរបស់ខ្លួន (ស្ត្រីខារ៉ាអូខេ និងស្ត្រីផ្សព្វផ្សាយស្រាបៀរ)។

## ៤. អនុសាសន៍សម្រាប់ការចាត់វិធានការនាពេលអនាគត

### ១. បរិស្ថានជំរុញសម្រាប់ការទទួលបានសេវាជាសកល

## ៤. អនុសាសន៍សម្រាប់ការចាត់វិធានការនាពេលអនាគត

### ១. បរិស្ថានជំរុញសម្រាប់ការទទួលបានសេវាជាសកល

ការយល់ឃើញដ៏ល្អសម្រាប់អាជ្ញាធរមូលដ្ឋាន និងកងកម្លាំងប៉ូលីស ទៅលើស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ/អ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់បុរស/ស្រីស្រស់ នឹងជួយសម្របសម្រួល ដល់ការ ចូលរួមរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ/អ្នករកស៊ីផ្លូវភេទ និងបុរសស្រលាញ់បុរស/ស្រីស្រស់ ក្នុងយន្តការការពារសិទ្ធិ រស់រានមានជីវិត និងសិទ្ធិមានការងារធ្វើរបស់ជនទាំងនោះ។

កិច្ចការរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ/អ្នករកស៊ីផ្លូវភេទ និង បុរសស្រលាញ់បុរស/ស្រីស្រស់ ក្នុងយន្តការនានា នៅថ្នាក់ណាមួយ មិនគួរត្រូវបានអនុវត្តឡើយ ប្រសិនបើអ្នកទាំងនោះជាអ្នកទទួលប្រយោជន៍ពីសេវា ប៉ុន្តែមានតួនាទីដ៏ សកម្មក្នុងការការពារសិទ្ធិ របស់ខ្លួនឱ្យបានកាន់តែទូលំទូលាយ រាប់បញ្ចូលទាំងសិទ្ធិមានការងារធ្វើ និងសិទ្ធិរស់រាន មានជីវិតផងដែរ។ ជនទាំងនោះ គួររស់នៅក្នុងបរិស្ថានមួយដែលខ្លួនអាចបញ្ចេញមតិបាន ទាក់ទងទៅនឹងក្តីកង្វល់របស់ ខ្លួនដែលប៉ះពាល់ដល់សិទ្ធិ រស់រានមានជីវិត និងសិទ្ធិក្នុងការទទួលបានសេវាជាសកល ។ សម្រាប់បរិស្ថានជំរុញ ដែលអាចមានភាពជាដៃគូយុទ្ធសាស្ត្រ រវាងតំណាង ក្រុមដែលងាយរងគ្រោះបំផុត អ្នកតាក់តែងគោលនយោបាយ និងអ្នកអនុវត្ត កម្មវិធីនានា គួរត្រូវបានពង្រឹង។

### ២. ការកសាងសមត្ថភាព

អនុសាសន៍សំខាន់ៗសម្រាប់ការកសាងសមត្ថភាពមានដូចខាងក្រោម :

- កញ្ចប់ធនធានសម្រាប់រៀបចំភាពជាអ្នកដឹកនាំ ដើម្បីទទួលបានលទ្ធផលសម្រាប់ភាពជាដៃគូយុទ្ធសាស្ត្រនៃក្រុមដែលងាយរងគ្រោះបំផុត អង្គការសហគមន៍ និងសម្រាប់បង្កើតបណ្តាញជាមួយភាគីពាក់ព័ន្ធមកពីស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និង វិស័យឯកជនចាប់ពី ថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន។
- ការកសាងសមត្ថភាពសម្រាប់ការប្រាស្រ័យទាក់ទងឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត ចាំបាច់ត្រូវធ្វើឱ្យស្របតាមល័ក្ខខ័ណ្ឌបច្ចុប្បន្ន និងបរិយាកាសរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្ត សប្បាយ និងអ្នករកស៊ីផ្លូវភេទ និងបុរសស្រឡាញ់បុរស និងស្រីស្រស់។ ល័ក្ខខ័ណ្ឌទាំងនោះ រួមមានដូចជា ការសេពគ្រឿងស្រវឹង និងគ្រឿងញៀន សិទ្ធិមនុស្សជាមូលដ្ឋាន ការបង្ការជាវិជ្ជមាន ការបន្តថែទាំ និងបរិកាសជំរុញ។ កម្មវិធីគួសង្សារ ចាំបាច់ត្រូវតាមដាន និងវាយតម្លៃ រៀបចំឡើងវិញ និងពន្យល់ដោយមានការចូលរួមយ៉ាង សកម្មពីបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ។
- ដើម្បីគាំទ្រដល់សិទ្ធិរបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ និងដើម្បីបង្កើនលទ្ធភាព ទទួលបានសេវាជាសកលដល់ក្រុមទាំងនោះ កងកម្លាំងប៉ូលីស និងអាជ្ញាធរមូលដ្ឋាននៅតំបន់ក្លឹបរាត្រីកំសាន្តសប្បាយ ចាំបាច់ត្រូវទទួលបានការកសាងសមត្ថភាពបច្ចេកទេស ដើម្បីបង្កើតបរិយាកាសជំរុញដល់កម្មវិធីបង្ការដែលរៀបចំឡើងដោយ ស្ថាប័ន

រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។ ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ គួរបានទទួលសម្រាប់រៀបចំការបណ្តុះបណ្តាលប៉ូលីស និងអាជ្ញាធរមូលដ្ឋានដើម្បីឱ្យក្លាយជា**ចលករសហគមន៍។**

- បណ្តាញដែលធ្វើការជាមួយ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ គួរទទួលបានការពង្រឹងសមត្ថភាព ក្នុងការរៀបចំ និងការស្វែងរកការគាំទ្រ។ ក្នុងន័យនេះ សមត្ថភាព បច្ចេកទេស និងការរៀបចំរបស់ផ្នែក ផ្សេងៗគ្នាក្នុងយន្តការថ្នាក់ជាតិដែលធ្វើការជាមួយក្រុមដែលងាយរងគ្រោះបំផុតចាំបាច់ត្រូវតែពង្រឹងឡើង។ ផ្នែកសំខាន់ៗក្នុងប្រព័ន្ធជាច្រើនចាំបាច់ត្រូវទទួលបានការគាំទ្រពីលេខាធិការដ្ឋាន ដើម្បីធ្វើឱ្យការអនុវត្តន៍អាណត្តិ ភារកិច្ចរបស់អ្នកទាំងនោះ ប្រព្រឹត្តិទៅដោយរលូន។

## ៣. ភាពជាអ្នកដឹកនាំ និងការសម្របសម្រួលការឆ្លើយតប

ដោយសារមានការលេចឡើងនូវរលកទីពីរនៃការឆ្លងមេរោគអេដស៍ ការដឹកនាំដ៏រឹងមាំ មានសារៈសំខាន់ណាស់ក្នុងការរៀបចំ បន្សុំ និងធ្វើសុខដុមនីយកម្មរាល់គំនិតផ្តួចផ្តើមនៃវិស័យផ្សេងៗគ្នា ដែលធ្វើការពាក់ព័ន្ធទៅនឹងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងលទ្ធភាពទទួលបានសេវាជាសកលរបស់អ្នកទាំងនោះ។ វិស័យ និងយន្តការនីមួយៗ ចាំបាច់ត្រូវគាំទ្រដល់វិធានការនានាដែលបានលើកឡើងក្នុងគោលដៅទាំងបី។ គំនិតផ្តួចផ្តើមដែលមានស្រាប់ដូចជាយុទ្ធសាស្ត្រជាតិបង្ការ និងត្រួតពិនិត្យការចម្លងមេរោគអេដស៍ក្នុងចំណោមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ អតិថិជន និងសង្សាររបស់ពួកគេ (NAA) ផែនការយុទ្ធសាស្ត្ររបស់ក្រសួងមហាផ្ទៃដើម្បីឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០០៩-២០១៣ (MOI) ប្រកាសលេខ ០៨៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និតិវិធីអនុវត្តស្តង់ដាថ្មីសម្រាប់ការបន្តការបង្ការ ការថែទាំ និងការព្យាបាលជនទាំងនោះ វិធីសាស្ត្រសម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្ត សប្បាយនៅប្រទេសកម្ពុជា (NCHADS) បណ្តាញ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ និង បុរសស្រឡាញ់បុរស និងស្រីស្រស់ និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការជាមួយក្រុមដែលងាយរងគ្រោះបំផុត គួរទទួលបានការគាំទ្រ។

ខ្លឹមសារសង្ខេបនៃរបកគំហើញគន្លឹះ

សម្រាប់ ប្រទេសកម្ពុជាប្រយុទ្ធនឹងមេរោគអេដស៍ និងជម្ងឺអេដស៍

# សហការណ៍ដោយអជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការសម្ព័នកម្ពុជាប្រយុទ្ធនឹង មេរោគអេដស៍ និងជំងឺអេដស៍ (CACHA)

គាំទ្រដោយ UNFPA, UNAIDS, WAC
ICASO/APNSW and ActionAid

ខែ ឧសភា ឆ្នាំ ២០០៩

33 page.indd 1 7/14/2009 8:04:48 AM

33 page.indd 2 7/14/2009 8:03:34 AM

# Table of Contents


១. សាវតារពាក់ព័ន្ធនឹងការស្រាវជ្រាវ ............ ១
២. ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ............ ៤
៣. លទ្ធភាពទទួលបានសេវាជាសាកលនូវសេវាប្រយុទ្ធនឹងជំងឺអេដស៍ចំពោះបុគ្គលិក គ្រឹះស្ថានកំសាន្តសប្បាយ ............ ៦
ក) របកគំហើញស្តីពីបរិយាកាសអំណោយផលចំពោះលទ្ធភាពទទួលបានសេវាជាសកល ............ ៦
ខ) ផលប៉ះពាល់នៃច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្សចំពោះលទ្ធភាពទទួលបានសេវាជាសកល ..១០
៤.គោលបំណងនៃច្បាប់ស្តីពីអំពើប្រឆាំងការជួញដូរមនុស្ស ............ ១២
ក) ពិធីសារ Palermo ............ ១៣
ខ) ចំណោទបញ្ហា និងនិយមន័យ ............ ១៥
គ) គោលការណ៍ណែនាំសម្រាប់ប៉ូលីស ............ ១៦
៥. ផលប៉ះពាល់នៃច្បាប់ប្រឆាំងអំពើជួញដូរមនុស្សចំពោះបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ............ ១៧
ក) ផលប៉ះពាល់ចំពោះសិទ្ធិប្រកបការងារ ............ ១៧
ខ) ផលប៉ះពាល់ផ្នែកសិទ្ធិមនុស្សមកលើបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ............ ២១
៦. ផលប៉ះពាល់ដទៃទៀតនៃច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស ............ ២២
៧. ភាពស៊ីសង្វាក់ជាមួយច្បាប់អន្តរជាតិ ............ ២៣
៨. អនុសាសន៍ ............ ២៦
ក) វិធីសាស្ត្រដែលផ្អែកលើសិទ្ធិចំពោះកម្មវិធីប្រើស្រោមអនាម័យ ១០០% ............ ២៦
ខ)វិធីសាស្ត្រដទៃទៀតចំពោះការប្រយុទ្ធនឹងអំពើជួញដូរ និងអំពើធ្វើអាជីវកម្មផ្លូវភេទ ............ ៣០
គ) ការកសាងសមត្ថភាពចំពោះបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ............ ៣៣

# ពាក្យកាត់

| | | |
|---|---|---|
| **AIDS** | ជម្ងឺអេដស៍ | Acquired Immunodeficiency Syndrome |
| **APNSW** | បណ្តាញការងាររកស៊ីផ្លូវភេទនៅអាស៊ីប៉ាស៊ីហ្វិក | Asia Pacific Network of Sex Work |
| **ART** | ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ | Antiretroviral Therapy |
| **BCC** | ការប្រាស្រ័យទាក់ទាក់អំពីការផ្លាស់ប្តូរការប្រព្រឹត្ត | Behavior Change Communication |
| **CACHA** | សម្ព័ន្ធប្រជាជនកម្ពុជាប្រយុទ្ធនឹងមេរោគអេដស៍និងជម្ងឺអេដស៍ | Cambodian Alliance for Combating HIVand AIDS |
| **CCW** | សហគមន៍ស្ត្រីផ្ទុកមេរោគអេដស៍-ជំងឺអេដស៍កម្ពុជា | Cambodian Community of Women Living with HIV/AIDS |
| **CEDAW** | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើង ប្រឆាំងស្ត្រី | Convention on the Elimination of all forms of Discrimination Against Women |
| **CNMWD** | បណ្តាញបុរសស្ត្រីអភិវឌ្ឍន៍កម្ពុជា | Cambodian Network for Men and Women Development |
| **CUP** | កម្មវិធីប្រើស្រោមអនាម័យ | Condom Use Programme |
| **CPU** | សហជីបស្ត្រីរកស៊ីផ្លូវភេទ | Cambodian Prostitute Union |
| **DHATWG** | ក្រុមការងារបច្ចេកទេសស្តីពីគ្រឿងញៀននិងមេរោគអេដស៍ | Drug and HIV Technical Working Group |
| **EW** | ស្ត្រីបំរើសេវាកំសាន្ត | Entertainment Worker |
| **FHI** | អង្គការសុខភាពគ្រួសារអន្តរជាតិ | Family Health International |
| **HCW** | បុគ្គលិកថែទាំសុខភាព | Health Care Worker |
| **HIV** | មេរោគអេដស៍ | Human Immunodeficiency Virus |
| **ICASO** | ក្រុមប្រឹក្សាអន្តរជាតិស្តីពីអង្គការប្រយុទ្ធនឹងជម្ងឺអេដស៍ | International Council on AIDS Organisations |
| **IDU** | អ្នកប្រើគ្រឿងញៀនចាក់តាមសរសៃ | Intravenous Drug Users |
| **KHANA** | អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជម្ងឺអេដស៍ | Khmer HIV/AIDS NGO Alliance |
| **LICADHO** | អង្គការជំរឿន និងការពារសិទ្ធិមនុស្ស | Cambodian League for the Promotion and Defense of Human Rights |
| **MOI** | ក្រសួងមហាផ្ទៃ | Ministry of Interior |
| **MOLVT** | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | Ministry of Labor and Vocational Training |
| **MSM** | បុរសស្រឡាញ់បុរស | Men who have Sex with Men |
| **NGOs** | អង្គការមិនមែនរដ្ឋាភិបាល | Non Government Organisations |
| **Palermo Protocol** | ពិធីសារបង្ការ បង្ក្រាប និងដាក់ទោសអំពើជួញដូរមនុស្សពិសេសស្ត្រី និងកុមារបន្ថែមលើអនុសញ្ញាអង្គការសហ-ប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង | Protocol to Prevent, Suppress and Punish Trafficking in Persons, Especially Women and Children, supplementing the United Nations Convention against Transnational Organized Crime |
| **SOP** | នីតិវិធីអនុវត្តស្តង់ដា | Standard Operating Procedure |
| **STI** | ជម្ងឺកាមរោគ | Sexually Transmitted Infection |
| **SW** | អ្នករកស៊ីផ្លូវភេទ | Sex Worker |
| **TWG** | ក្រុមការងារបច្ចេកទេស | Technical Working Group |
| **UA** | លទ្ធភាពទទួលបានសេវាជាសកល | Universal Access |
| **UNAIDS** | កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍អង្គការសហប្រជាជាតិ | Joint United Nations Programme on HIV/AIDS |
| **VCCT** | ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សការសម្ងាត់ | Voluntary Confidential Counseling and Testing |
| **WHN** | បណ្តាញសុខភាពស្ត្រី | Women Health Network |
| **WAC** | កម្មវិធីស្ត្រីសម្រាប់ការផ្លាស់ប្តូរ | Womyns Agenda for Change |
| **WNU** | បណ្តាញស្ត្រីដើម្បីឯកភាព | Women Network for Unity |

## ១. សាវតារពាក់ព័ន្ធនឹងការស្រាវជ្រាវ

ទោះបីជាអត្រាប្រេវ៉ាឡង់ទូទៅនៃមេរោគអេដស៍នៅកម្ពុជាបានធ្លាក់ចុះពី ២% (ឆ្នាំ ១៩៩៨)មកត្រឹម 0.៩% (ឆ្នាំ ២00៦)ក្តី ប្រេវ៉ាឡង់ក្នុងចំណោមក្រុមគោលដៅ ជាពិសេសគឺបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនៅមានកម្រិតខ្ពស់នៅឡើយគឺប្រហែលជា ១២.៦៩% នៅឆ្នាំ២00៦។ នៅឆ្នាំ ២00៨ សិទ្ធិធ្វើការងាររបស់ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយត្រូវបានប៉ះពាល់ជាខ្លាំងដោយសារកត្តាមួយចំនួន រួមមានកិច្ចប្រឹងប្រែងក្នុងការប្រយុទ្ធនឹងអំពើជួញដូរមនុស្ស និងការដាក់ឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើជួញដូរផ្លូវភេទ។ ជាមួយគ្នានេះផងដែរ សិទ្ធិក្នុងការទទួលសេវាបង្ការ និងព្យាបាលមេរោគអេដស៍ក៏រងផលប៉ះពាល់យ៉ាងខ្លាំងផងដែរ។ មានការប៉ាន់ស្មានថាមានផ្ទះបនចំនួនជាងពាក់កណ្តាលនៅកម្ពុជាបានបិទនៅដើមឆ្នាំ ២00៨ ហើយនៅតាមទីកន្លែងមួយចំនួនអ្នករកស៊ីផ្លូវភេទ (អ្នកដែលត្រូវបានសង្ស័យថាជាអ្នករកស៊ីផ្លូវភេទ)បានត្រូវឃាត់ខ្លួនដោយសារពួកគេមានស្រោមអនាម័យជាប់ខ្លួន។ វិធានការប្រឆាំងអំពើជួញដូរមនុស្សបានរួមចំណែកធ្វើឱ្យរបររកស៊ីផ្លូវភេទដោយឯករាជ្យម្ចាស់ការ និងដោយប្រយោលរីកដុះដាលក្រៅផ្ទះបន ធ្វើឱ្យការអនុវត្តកម្មវិធីបង្ការមេរោគអេដស៍ត្រូវកាត់ផ្តាច់។

ឆ្លើយតបនឹងបញ្ហានេះ **ឯកឧត្តម សុខ អាន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណរដ្ឋមន្ត្រីនាឱកាសថ្លែងសន្ទរកថាបិទសន្និសីទជាតិលើកទីបីស្តីពីជម្ងឺអេដស៍នៅថ្ងៃ ទី ១២ ខែ កញ្ញា ឆ្នាំ ២00៨ នៅសាលសន្និសីទចតុមុខបានជម្រុញឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ និងអគ្គនាយកដ្ឋានប្រយុទ្ធនឹងជម្ងឺអេដស៍នៃក្រសួងមហាផ្ទៃធ្វើការជិតស្និទ្ធជាមួយគ្នា ដើម្បីឱ្យមានការយល់ដឹងរួម និងរកវិធីសាស្ត្រដែលអាចដោះស្រាយជាមួយបញ្ហារសើបទាំងនេះ និងដើម្បីធានាដល់ការបន្តអនុវត្តគោលនយោបាយប្រើប្រាស់ស្រោមអនាម័យ ១00%របស់រាជរដ្ឋាភិបាលកម្ពុជា។ ឯកឧត្តមបានទទួលស្គាល់ថានៅកម្ពុជា ឬនៅប្រទេសដទៃ ក៏គេមិនអាចលុបបំបាត់ឧស្សាហកម្មផ្លូវភេទបានទេ។ សំខាន់ឯកឧត្តមបានគូសបញ្ជាក់សារជាថ្មីថាអាជ្ញាធរប្រយុទ្ធនឹងជម្ងឺអេដស៍ គប្បីសហការជិតស្និទជាមួយអង្គការសង្គមស៊ីវិលដែលជាប្រតិបត្តិករ និងជាអ្នកអនុវត្តសកម្មនូវកម្មវិធីបង្ការ និងព្យាបាលមេរោគអេដស៍នៅទូទាំងប្រទេស។

នៅខែវិច្ឆិកា ឆ្នាំ ២00៨ ក្រុមមួយនៃអង្គការប្រយុទ្ធនឹងមេរោគអេដស៍ និងអង្គការចាត់តាំងរបស់អ្នករកស៊ីផ្លូវភេទ បានចាប់ផ្តើមនូវគម្រោងស្រាវជ្រាវដើម្បីធ្វើសកម្មភាពដោយពិនិត្យមើលបរិយាកាសគោលនយោបាយស្តីពីសិទ្ធិទទួល បានសេវាជាសកល (ចំពោះការបង្ការមេរោគអេដស៍ ការធ្វើតេស្តឈាមរកមេរោគអេដស៍ និងសេវាព្យាបាលជម្ងឺ



33 page.indd 5 7/14/2009 8:03:35 AM

អេដស៍) និងសិទ្ធិធ្វើការងាររបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនៅកម្ពុជា។ ល័ក្ខខ័ណ្ឌការងារពិស្តារនៃការសិក្សានេះមានភ្ជាប់មកជាមួយនៅឧបសម្ព័ន្ធទី ៥។ សកម្មភាពស្រាវជ្រាវនេះរួមមាន:

- ការចុះអង្កេតទៅលើស្ត្រីរកស៊ីផ្លូវភេទ និងស្ត្រីគ្រឹះស្ថានកំសាន្តសប្បាយចំនួន ១១១៦ នាក់ បុរសស្រលាញ់បុរស និងស្រីស្រស់ចំនួន ៥៩១ នាក់ (នៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ)។
- ការរៀបចំជាករណីសិក្សា ( នៅរាជធានីភ្នំពេញ ) និងកិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះមួយចំនួន
- ការស្រាវជ្រាវស្តីពីលទ្ធភាពដែលច្បាប់អាចអនុវត្តបាន ផលប៉ះពាល់នៃការអនុវត្តច្បាប់ និងផលប៉ះពាល់នៃច្បាប់ស្រដៀងគ្នានេះនៅក្នុងតំបន់
- ការស្រាវជ្រាវអំពីភាពត្រូវគ្នានៃច្បាប់នេះជាមួយច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់អន្តរជាតិដទៃទៀត
- ការស្រាវជ្រាវទៅលើទិន្នន័យដែលមានស្រាប់ (ឯកសារសំណៅ របាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល របាយការណ៍សារព័ត៌មាន)

ទីប្រឹក្សាបច្ចេកទេសដែលធ្វើការស្រាវជ្រាវនេះរួមមាន **ឯកឧត្តម.វេជ្ជ. ទា ផលា** លោក **កែវ ចិន្តា** (LLM) និងអ្នកស្រី Sally Low (LLM)។ សាស្ត្រាចារ្យ Bebe Loff មកពីសាលកវិទ្យាល័យមូណាស្ហ (អូស្ត្រាលី) ក៏បានផ្តល់ជាមតិអំពីផលប៉ះពាល់នៃច្បាប់នេះ និងផលប៉ះពាល់មកលើសិទ្ធិមនុស្សផងដែរ។ ខ្លឹមសារសង្ខេបនៃរបកគំហើញនៅក្នុងរបាយការណ៍នេះបានសរសេរឡើងដោយ Sally Low ហើយរាល់កំហុសនានាទាក់ទងនឹងរបកគំហើញ គឺជាការទទួលខុសត្រូវរបស់លោកស្រី Sally Low។ អនុសាសន៍ទាំងឡាយដែលឈរលើរបកគំហើញនេះគឺជាការទទួលខុសត្រូវរបស់បណ្តាអង្គការទាំងឡាយ ដែលបាន ធ្វើការស្រាវជ្រាវនេះ។ របាយការណ៍ពិស្តារនៃផ្នែកនីមួយៗរបស់ការស្រាវជ្រាវបានភ្ជាប់មកជាមួយនឹងអត្ថបទសង្ខេបនេះ។

អ្នកស្រាវជ្រាវ និងអង្គការនានាដែលធានារ៉ាប់រងចំណាយចំពោះការស្រាវជ្រាវនេះស្វាគមន៍ និងទទួលស្គាល់ថារាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់យកជំហាននានាដ៏មានសារៈសំខាន់ ដើម្បីដោះស្រាយបញ្ហាមួយចំនួន ជាមួយនិងការអនុវត្តន៍ និងការបកស្រាយអំពីច្បាប់ស្តីពីការប្រឆាំងការជួញដូរមនុស្សដែលបានលើកយកមកពិភាក្សានៅក្នុងរបាយការណ៍នេះ។ ជាពិសេសសូមថ្លែងអំណរគុណ និងស្វាគមន៍ចំពោះផែនការយុទ្ធសាស្ត្រថ្មីរបស់ក្រសួងមហាផ្ទៃ ដែលមានបំណងអនុវត្តវិធីតាមដានសហគមន៍ (អ្នកបង្កលក្ខ័ណអំណោយផលដល់សហគមន៍) ក្នុងការអនុវត្តន៍កម្មវិធីប្រើស្រោមអនាម័យ ១០០%។ កាលពី ថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០០៩ ការពិគ្រោះយោបល់ថ្នាក់ជាតិមួយ បានប្រព្រឹត្តទៅបន្ទាប់



33 page.indd 6 7/14/2009 8:03:35 AM

ពិសន្និសីទជាតិលើកទីបីស្តីពីជម្ងឺអេដស៍ បានរៀបចំយុទ្ធសាស្ត្រវិជ្ជមាននានាដើម្បីចាប់ផ្តើមដោះស្រាយបញ្ហា មួយចំនួនអំពីបរិយាកាសអំណោយផលនេះ។ សេចក្តីណែនាំឆ្នាំ ២០០៨ [សម្រាប់ប៉ូលីស] ស្តីពីការអនុវត្តន៍ច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានឆ្លើយតបទៅនឹងការយល់ខុសមួយចំនួនដែលថាអ្នករកស៊ីផ្លូវភេទជាឧក្រិដ្ឋជន។ យើងក៏យល់ផងដែរថាក្រសួងមួយចំនួនកំពុងធ្វើសេចក្តីព្រាងណែនាំពេញលេញមួយអំពីច្បាប់ស្តីពីការ ប្រឆាំងនឹងអំពើជួញដូរមនុស្សសម្រាប់ឱ្យចៅក្រម និងព្រះរាជអាជ្ញាប្រើប្រាស់។ របកគំហើញមួយចំនួនដែលបានពិភាក្សាខាងក្រោមកំពុងបានដោះស្រាយដោយវិធានការទាំងនេះ។

យើងសង្ឃឹមថាអនុសាសន៍នៅក្នុងផ្នែកទី ៧ នៃរបាយការណ៍នេះនឹងបន្ថែមលើកិច្ចប្រឹងប្រែងទាំងនោះ ដើម្បីស្វែងរកដំណោះស្រាយចំពោះច្បាប់ សិទ្ធិទទួលបានសេវាជាសកល និងសិទ្ធិក្នុងការប្រកបរបរជាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយដែលពាក់ព័ន្ធនឹងការរកស៊ីផ្លូវភេទ។ គោលបំណងរបស់ក្នុងការសិក្សានេះគឺដើម្បីរួមវិភាគទានជាវិជ្ជមានដល់ការរៀបចំគោលនយោបាយ។ របាយការណ៍នេះក៏សង្ខេបផងដែរពីរបកគំហើញសំខាន់ៗនៃការស្រាវជ្រាវ។ ព័ត៌មានលំអិតបន្ថែមមាននៅក្នុងឯកសារស្រាវជ្រាវនីមួយៗ ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃរបាយការណ៍នេះ។

## ***<u>សារៈសំខាន់អំពីសិទ្ធិក្នុងការប្រកបការងារ</u>***

លទ្ធផលនៃការស្រាវជ្រាវនេះពង្រឹងបន្ថែមនូវទំនាក់ទំនងជិតស្និទ្ធរវាងសិទ្ធិក្នុងការប្រកបមុខរបរ ជាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយដែលពាក់ព័ន្ធនឹងការរកស៊ីផ្លូវភេទ។ ព្រមទាំងបង្កើតបរិយាកាសអំណោយផលដើម្បីឱ្យមានសិទ្ធិទទួលបានសេវាជាសកល។ ទោះជាយ៉ាងណាក៏ដោយ សិទ្ធិក្នុងការប្រកបមុខរបរសម្រាប់ ជាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយដែលពាក់ព័ន្ធនឹងការរកស៊ីផ្លូវភេទក៏ជាការងារដែលគេចង់ធ្វើដោយសារមូលហេតុផ្សេងៗទៀតផងដែរ។ **ការទទួលស្គាល់ជាផ្លូវការនូវសិទ្ធិក្នុងការប្រកបរបរនិងការពង្រឹងអ្នករកស៊ីផ្លូវភេទដោយស្ម័គ្រចិត្តគឺជាភាពតម្រូវសំខាន់បំផុតដើម្បីបង្ការការធ្វើអាជីវកម្មផ្លូវភេទ និងបង្ការទម្រង់ដទៃទៀតនៃការធ្វើអាជីវកម្មមកលើអ្នករកស៊ីផ្លូវភេទ។** អ្នករកស៊ីផ្លូវភេទក៏ដូចជាអ្នកធ្វើការនៅក្នុងផ្នែកតូចតាចដទៃទៀតដែរ ពួកគេគឺជាអ្នកងាយរងគ្រោះពីអំពើហឹង្សា និងពីការធ្វើអាជីវកម្ម។ ទោះជាយ៉ាងណាក៏ដោយ ប្រការសំខាន់គឺត្រូវទទួលស្គាល់ ថាពុំមែនរាល់ទំនាក់ទំនងពាណិជ្ជកម្មជុំវិញការងារផ្លូវភេទសុទ្ធតែ ឬត្រូវតែមានលក្ខណៈកេងប្រវ័ញ្ច ឬហឹង្សានោះទេ។ ការពង្រឹងសមត្ថភាពអ្នករកស៊ីផ្លូវភេទនឹងជួយដល់ការប្រយុទ្ធនឹងការធ្វើអាជីវកម្ម និងប្រយុទ្ធនឹងអំពើហឹង្សាយ៉ាងពិតប្រាកដ។ ជាមួយគ្នានេះ វាក៏ជួយធានាដល់តម្រូវការជាខ្លាំងដែលជាតម្រូវការពិតប្រាកដរបស់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយដែលពាក់ព័ន្ធនឹងការរកស៊ីផ្លូវភេទជាច្រើនក្នុងការគាំទ្រគ្រួសាររបស់ពួកគេផងដែរ។ ហើយប្រសិនបើសិទ្ធិក្នុងការប្រកបរបរត្រូវបានទទួលស្គាល់ជាបុគ្គលិកគ្រឹះ



33 page.indd 7 7/14/2009 8:03:35 AM

ស្ថានកំសាន្តសប្បាយដែលពាក់ព័ន្ធនឹងការរកស៊ីផ្លូវភេទអាចដើរតួឈានមុខក្នុងការបង្ការពេស្យាចារកុមារ អំពើជួញដូរ និងទម្រង់ដទៃទៀតនៃការធ្វើអាជីវកម្មផងដែរ។

ការនិយាយបែបនេះពុំមែនបានសេចក្ដីថាយើងលើកកំពស់របររកស៊ីផ្លូវភេទនោះទេ។ យើងទទួលស្គាល់ថារបររកស៊ីផ្លូវភេទពុំមែនជាស្ថានភាពផ្នែកចរិយាធម៌ឡើយ ប៉ុន្តែវាជាទម្រង់តូចមួយនៃការងារ។ អ្នករកស៊ីផ្លូវភេទដូចអ្នកធ្វើការក្នុងទម្រង់មុខរបរតូចតាចដែលគ្មានការរៀបចំគ្រប់គ្រងដូច្នោះដែរ ពួកគេងាយរងគ្រោះពីការធ្វើអាជីវកម្មកាមគុណ និងការរើសអើង[១]។ ការទទួលស្គាល់សិទ្ធិរបស់អ្នករកស៊ីផ្លូវភេទ និងការពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការការពារសិទ្ធិទាំងនោះគឺជាវិធីដ៏ល្អបំផុតក្នុងការកាត់បន្ថយនូវភាពងាយរងគ្រោះរបស់ពួកគេ។ យើងស្វាគមន៍ការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះការអប់រំដល់ក្មេងស្រី ធ្វើជាមធ្យោបាយមួយដើម្បីបង្កើនជម្រើសផ្នែកមុខរបរសម្រាប់ស្ត្រីងាយរងគ្រោះ។ យើងក៏ស្វាគមន៍ផងដែរចំពោះកិច្ចប្រឹងប្រែងក្នុងការផ្ដល់ជម្រើសការងារផ្សេងៗចំពោះអ្នកទាំងឡាយណាដែលសម្រេចចិត្តដោយសេរីក្នុងការឈប់ប្រកបរបររកស៊ីផ្លូវភេទ។ យើងក៏សូមស្វាគមន៍ជាពិសេសចំពោះវិធានការនានាដើម្បីដោះស្រាយតម្រូវការរបស់ ជាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយដែលពាក់ព័ន្ធនឹងការរកស៊ីផ្លូវភេទចាស់ៗ ដែលលែងមានលទ្ធភាពរកប្រាក់ចំណូលពីការផ្ដល់សេវាផ្លូវភេទ។

## ២. ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ

ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ” (ច្បាប់ប្រឆាំងការជួញដូរមនុស្ស) បានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃ ទី១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨។ ច្បាប់នេះជំនួសឱ្យច្បាប់ស្ដីពីការបង្ក្រាបអំពើចាប់ជម្រត់ និងជួញដូរ លក់មនុស្ស និងធ្វើអាជីវកម្មមនុស្ស[២]។

នៅក្នុងការអនុម័តច្បាប់ឆ្នាំ ១៩៩៦ ប្រទេសកម្ពុជាជាប្រទេសឈានមុខក្នុងការចាត់វិធានការផ្លូវច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស។ នៅឆ្នាំ ២០០០ រាជរដ្ឋាភិបាលក៏បានពិចារណាវិធីដែលមានលក្ខណៈច្នៃប្រឌិតខ្ពស់ក្នុងការប្រយុទ្ធនឹង

---

[1] Nandinee Bandyopadhyay ”អ្នកដើរតាមផ្លូវបង្ហាញផ្លូវៈ ការពិនិត្យមើលសារឡើងវិញនូវការជជែកដេញដោលជាទូទៅអំពីទស្សនៈរបស់ស្ត្រីរកស៊ីផ្លូវភេទចំពោះអំពើជួញដូរមនុស្ស” ទំព័រទី ៤

[2] កាសែតរស្មីកម្ពុជា ឆ្នាំ ២០០៧ *រដ្ឋសភាពិភាក្សាសេចក្ដីស្នើច្បាប់ថ្មីស្ដីពីការប្រឆាំងអំពើជួញដូរមនុស្ស* ឆ្នាំ ទី ១៥ លេខ ៤៤៦៦ ថ្ងៃ ពុធ ទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ក២



33 page.indd 8 7/14/2009 8:03:35 AM

អំពើជួញដូរមនុស្សរួមមានការដកចេញនូវការចាត់ទុកជាបទឧក្រិដ្ឋ និងការរៀបចំគ្រប់គ្រងអាជីវកម្មរកស៊ីផ្លូវភេទ[៣]។ ទោះជាយ៉ាងណាក៏ដោយចាប់តាំងពីចុងទសវត្ស ១៩៩០ មកមានការចាប់អារម្មណ៍ជាខ្លាំងពីសំណាក់ទីភ្នាក់ងារអន្តរជាតិ និងពីរដ្ឋាភិបាលមួយចំនួនចំពោះអំពើជួញដូរមនុស្ស មានស្ថាប័នជាច្រើនជំទាស់នឹងសិទ្ធិរបស់ស្ត្រីក្នុងការប្រកបរបររកស៊ីផ្លូវភេទ។ ក្នុងសម័យរបស់ប្រធានាធិបតី ជច ប៊ូស្ហ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានប្រើវិធានការម៉ឹងម៉ាត់ក្នុងការប្រឆាំងនឹងអំពើជួញដូរមនុស្ស ដែលផ្តោតលើការត្រួតពិនិត្យចំណាកស្រុក ហើយជំទាស់ជាខ្លាំងចំពោះទស្សនៈដែលចាត់ទុកថារបររកស៊ីផ្លូវភេទជាការងារ[៤]។ នៅឆ្នាំ ២០០១ ក្រសួងការបរទេសរបស់សហរដ្ឋអាមេរិកបានចាប់ផ្តើមបោះផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស និងចាត់ប្រភេទប្រទេសនានាទៅក្នុងលំដាប់ថ្នាក់ផ្សេងៗ[៥]។ ដោយសាររដ្ឋាភិបាលសហរដ្ឋអាមេរិកមានសមត្ថភាពក្នុងការដាក់ទណ្ឌកម្មពួកគេមានលទ្ធភាពប្រើប្រាស់ដំណើរការរាយការណ៍ស្តីពីអំពើជួញដូរមនុស្ស ដើម្បីធ្វើឱ្យមានឥទ្ធិពលជាខ្លាំងទៅលើការរៀបចំគោលនយោបាយ នៅក្នុងប្រទេសជាច្រើន។ ទោះបីជានៅឆ្នាំ២០០៦ ការិយាល័យគណនេយ្យភាពរបស់សហរដ្ឋអាមេរិកផ្ទាល់បានចោទសួរអំពីភាពត្រឹមត្រូវ និង តម្លាភាពនៃដំណើរការជួញដូរមនុស្សក្តី[៦]។ នៅឆ្នាំ ២០០៥ ប្រទេសកម្ពុជាបានបញ្ចុះថ្នាក់មកដល់លំដាប់ថ្នាក់ទី ៣ អមដោយការគម្រាមដាក់ទណ្ឌកម្មផងដែរ ហើយពីរឆ្នាំបន្តបន្ទាប់មក (២០០៦-០៧) កម្ពុជាត្រូវបានដាក់ឱ្យឋិតក្នុងលំដាប់ថ្នាក់ទី២ នៃបញ្ជីឃ្លាំមើល និងត្រូវបានបង្ខំឱ្យចាត់វិធានការជាបន្ទាន់ ដើម្បីជៀសវាង ការទម្លាក់ទៅក្នុងលំដាប់ថ្នាក់ទី ៣។

នៅដើមឆ្នាំ ២០០២ របាយការណ៍ស្តីពីអំពើជួញដូរមនុស្សរបស់សហរដ្ឋអាមេរិកបានស្នើឱ្យកម្ពុជាធ្វើសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស។ គេឃើញមានរបាយការណ៍នានាដែលបញ្ជាក់ឱ្យដឹងថា ច្បាប់ថ្មីមួយពិត

---

3 សូមអាន "ពេស្យាចារទទួលការយល់ព្រមពីរដ្ឋាភិបាល " ដោយ Phelim Kyne កាសែត Phnom Penh Post ថ្ងៃ សុក្រ ទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០០ គេហទំព័រ E:\Trafficking law\report\summary report\ppp articles\The Phnom Penh Post - Prostitution gets Government okay.mht

4 សូមអាន Huckerby, Jane" សហរដ្ឋអាមេរិក (ស.រ.អា)" នៅក្នុងអត្ថបទ *Collateral Damage: The Impact of Anti-Trafficking Measures on Human Rights Around the World* សម្ព័ន្ធភាពពិភពលោកប្រឆាំងអំពើជួញដូរស្ត្រី បាងកក ឆ្នាំ ២០០៧ ទំព័រ ២៣០-២៥៦ និងទំព័រ ២៣៤

5 គេឃើញមានលំដាប់ថ្នាក់ចំនួន ៤: ១ គឺជាការចាត់ថ្នាក់ដែលមានលក្ខណៈអំណោយផងជាងគេបំផុត បន្ទាប់មកគឺលំដាប់ថ្នាក់ទី ២ បញ្ជីឃ្លាំមើល ទី ២ និងចុងក្រោយគេគឺលំដាប់ថ្នាក់ទី ៣

6 Huckerby. Op.cit. សំណៅលេខ ៤ ទំព័រ ២៣៥



33 page.indd 9 7/14/2009 8:03:36 AM

ជាបានចេញជាសេចក្តីព្រាងនាពេលនោះ [7] ។ ទោះបីជារហូតដល់ឆ្នាំ ២០០៧ ច្បាប់នោះនៅមិនទាន់បានអនុម័តក្តី គ្មានអង្គការមិនមែនរដ្ឋាភិបាលណាមួយផ្តល់សេវាប្រឆាំងមេរោគអេដស៍ ឬគ្មានក្រុមអ្នករកស៊ីផ្លូវភេទណា មានលទ្ធភាពផ្តល់មតិដែលមានសារៈសំខាន់ចំពោះសេចក្តីព្រាងច្បាប់នោះឡើយ ។ អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ និងក្រសួងសុខាភិបាល អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាប្រឆាំងមេរោគអេដស៍ និងអង្គការចាត់តាំងរបស់ស្ត្រីរកស៊ីផ្លូវភេទក៏មិនបានគេដាក់បញ្ចូលទៅក្នុងលេខាធិការដ្ឋានជាតិរបស់រាជរដ្ឋាភិបាល និងមិនបានដាក់បញ្ចូលឱ្យទៅក្នុងក្រុមការងារស្តីពីការប្រឆាំងអំពើជួញដូរមនុស្សឡើយ ខណៈដែលក្រសួងជាច្រើន និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន [8] បានដាក់បញ្ចូលឱ្យទៅនៅក្នុងក្រុមនោះក៏ដោយ ។ មានការស្រាវជ្រាវបានរកឃើញថាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយជាង ៨០% យល់ថាពួកគេមានសិទ្ធិផ្តល់មតិអំពីគោលនយោបាយនានាដែលមានផលប៉ះពាល់មកលើពួកខ្លួន ។ ការពិគ្រោះយោបល់ប្រកបដោយខ្លឹមសារជាច្រើនបន្ថែមទៀត អាចជួយបង្ការនូវការយល់ដឹងមិនបានត្រឹមត្រូវ និងអាចទប់ស្កាត់បញ្ហាផ្សេងៗ ដែលទាក់ទងនឹងច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស ។

## ៣. សិទ្ធិទទួលបានជាសកលនូវសេវាប្រឆាំងមេរោគអេដស៍សម្រាប់បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ

### ក) របកគំហើញស្តីពីបរិយាកាសអំណោយផលចំពោះសិទ្ធិទទួលបានសេវាជាសកល

ការអង្កេតអ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយបានរកឃើញបញ្ហាសំខាន់ៗមួយចំនួន ដែលប៉ះពាល់ដល់បរិយាកាសអំណោយផលក្នុងការទទួលបានសេវាជាសកល ។ របកគំហើញសំខាន់ៗមានសង្ខេបដូចខាងក្រោម ។ សូមអានឧបសម្ព័ន្ធទី ២ ចំពោះរបាយការណ៍ពិស្តារស្តីពីរបកគំហើញនៃការអង្កេតនេះ ។

ក.១. ក្រុមស្រីស្រស់ ក្រុមបុរសស្រលាញ់បុរស និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយមានជំនឿយ៉ាងមុតមាំថា ឧបសគ្គសំខាន់ ៧ ចំពោះលទ្ធភាពទទួលបានសេវាជាសកលគឺ:

- ការមាក់ងាយ និងការរើសអើង
- ខ្វះការចូលរួមច្បាស់លាស់ពីអ្នករកស៊ីផ្លូវភេទ និងពីបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយក្នុងការរៀបចំ និងអនុវត្ត គោលនយោបាយ និងកម្មវិធីនានា
- ការសម្របសម្រួលមិនបានល្អរវាងរដ្ឋាភិបាលកណ្តាល និងអាជ្ញាធរមូលដ្ឋាន
- ខ្វះការចូលរួមច្បាស់លាស់ពីបណ្តាញប្រឆាំងអំពើជួញដូរមនុស្ស បណ្តាញគ្រប់គ្រងគ្រឿងញៀន និងបណ្តាញសិទ្ធិមនុស្សនៅក្នុងកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

---

[7] សូមអាន ដូចជា “US threatens sanctions over human trafficking,”សរសេរដោយ Bill Bainbridge នៃកាសែត Phnom Penh Post ថ្ងៃ ទី ០៧ ខែ មិថុនា ឆ្នាំ ២០០២ ម៉ោង ២ រសៀល

[8] ”សេចក្តីសម្រេចស្តីពីការកែសម្រួលសមាសភាព និងរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាននៃក្រុមប្រតិបត្តិដឹកនាំការងារស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស អំពើរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មលើពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទចំពោះស្ត្រីនិងកុមារ ” លេខ ០០៧ សសរ/បជរពព ចុះហត្ថលេខាដោយ ឯ.ឧ. ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានក្រុមប្រតិបត្តិដឹកនាំការងារ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨

ក.២. ស្ត្រីចំនួនប៉ែតសិបបួនភាគរយ និង ៩០% នៃបុរសនិងបុរសស្រលាញ់បុរសសក់វែង ដែលបានផ្តល់ការសម្ភាសន៍ យល់ថា ពួកគេមានសិទ្ធិចូលរួមក្នុងការរៀបចំច្បាប់ និងគោលនយោបាយនានាដែលទាក់ទងនឹងការងាររកស៊ីផ្លូវភេទ។ ទស្សនៈ និងឆន្ទៈក្នុងការចូលរួមនេះមិនបានឆ្លុះបញ្ចាំងនៅក្នុងតថភាពជាក់ស្តែងឡើយ។ រហូតមកដល់ពេលនេះ ការចូលរួមពីសំណាក់អ្នករកស៊ីផ្លូវភេទ និងការចូលរួមពីបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនៅក្នុងសកម្មភាពជម្រុញឱ្យមានការគាំទ្រក្នុងគោលដៅលើកកំពស់សិទ្ធិទទួលបានសេវាជាសកល មានលក្ខណៈអកម្មជាខ្លាំងពោលគឺ ចូលរួម ក្នុងសិក្ខាសាលា ហើយស្តាប់អ្នកឯទៀតនិយាយ។ ការសម្ភាសន៍ស៊ីជម្រៅជាមួយជនបង្គោលសំខាន់ៗ ពង្រឹងបន្ថែមទូវ របកគំហើញនេះ។ គេឃើញមានឧទាហរណ៍មួយចំនួនដែលអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនជួយសម្រួលសកម្មភាពដែលមានការចូលរួមដូចជាការដើរជាក្បួន សិក្ខាសាលា និងសន្និសីទសារព័ត៌មានដែលអ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយបានដឹកនាំ។ សកម្មភាពទាំងនេះមានប្រសិទ្ធិភាពកាន់តែខ្លាំង។ រហូតមកដល់ពេលនេះ មុខងាររបស់អ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនៅក្នុងនីតិវិធីអនុវត្តស្តង់ដាររបស់ OPC ជាអ្នក ទទួលផលដែលមានលក្ខណៈអកម្ម។ ពួកគេគ្មានមុខងារសកម្មឡើយលើកលែងតែមុខងារជួយសម្រួលចំពោះការផ្តល់ សេវា។ ពួកគេមិនបានទទួលការលើកទឹកចិត្តឱ្យចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំគោលនយោបាយឡើយ។

ក.៣. អត្រាប្រើប្រាស់ស្រោមអនាម័យចំពោះភ្ញៀវបង់ប្រាក់បានរាយការណ៍ថាមានអត្រាពី ៨៨% ទៅ ៩៩% ជាមួយសង្សារ មានអត្រា ៧០% ទៅ ៩១% និងចំពោះប្តី-ប្រពន្ធ ឬដៃគូរួមរស់ជាមួយគ្នាមានអត្រាត្រឹមតែ ៤១% ទៅ ៧៨% ប៉ុណ្ណោះ។ ចំពោះ ក្រុមបុរសស្រលាញ់បុរសសក់វែង ដែលរកស៊ីផ្លូវភេទ អត្រានៃការប្រើស្រោមអនាម័យជាមួយដៃគូ មិនបង់ប្រាក់មានកម្រិតទាបគឺត្រឹមតែ ៦៥% ប៉ុណ្ណោះ។

ក.៤. លើកលែងសៀមរាបចេញ សកម្មភាពមិត្តអប់រំមិត្តអំពីសិទ្ធិទទួលបានសេវាជាសកលមានកម្រិតតិចតួច គេឃើញមាន ចំណាប់អារម្មណ៍ជាខ្លាំងចំពោះកម្មវិធីមិត្តអប់រំមិត្ត។ ប្រការនេះពង្រឹងរបកគំឃើញត្រង់ចំណុចទី១ ដែលថាកម្មវិធី ដែលមានការចូលរួម គឺជាកម្មវិធីដែលមានប្រសិទ្ធភាពបំផុត។

ក.៥. ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ គេឃើញថាស្ត្រីរកស៊ីផ្លូវភេទនៅតាមផ្ទះបន កន្លែងម៉ាស្សា និងអ្នករកស៊ីផ្លូវភេទឯករាជ្យ ម្ចាស់ការដោយខ្លួនឯងមានអត្រាប្រើប្រាស់សេវាជម្ងឺកាមរោគ (៧២-៨៣%) ខ្ពស់ជាងអ្នក



33 page.indd 11 7/14/2009 8:03:36 AM

ធ្វើការនៅតាមហាង ខារ៉ា អូខេ និងខ្ពស់ជាងនារីបំរើស្រាបៀរ (ស្រីឡង់សេដែលទទួលសេវាជម្ងឺកាមរោគគឺមានអត្រាពី ៥៨%-៦១%)។ ចំពោះការប្រើសេវាធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ក៏មានលំនាំដូចគ្នាដែរ។ ក្រុមបុរសស្រលាញ់បុរសដែលរកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយជាទូទៅ មិនសូវប្រើប្រាស់សេវានេះឡើយ ពិសេសគឺមិនសូវប្រើប្រាស់សេវាជម្ងឺកាមរោគទេ (តិចអត្រាជាង ៥០%)។ ការផ្តល់សេវា ចំពោះស្ត្រីនៅសៀមរាបមានកម្រិតទាប ហើយការផ្តល់សេវាចំពោះក្រុមបុរសស្រលាញ់បុរស នៅ ខេត្តបន្ទាយមាន ជ័យ និងនៅ ខេត្តសៀមរាបក៏មានកម្រិតទាបដែរ។

ក.៦. នៅឆ្នាំ ២០០៨ កាប្រើសេវា ធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់និង សេវាជម្ងឺកាមរោគពីសំណាក់ស្ត្រីបានកើនឡើងនៅតាមបណ្តាខេត្តទាំងឡាយលើកលែងតែនៅរាជធានីភ្នំ ពេញ។

ក.៧. នៅឆ្នាំ ២០០៨ គេបានកត់សម្គាល់ឃើញមានការកើនឡើងនូវចលនាពីសំណាក់អ្នករកស៊ីផ្លូវភេទដោយផ្ទាល់ ដែល ប្រការនេះផ្ទុយគ្នាទៅនឹងលំនាំចំពោះស្ត្រីរកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ។ ជាមួយគ្នានេះក៏មានការកើនឡើងខ្លះ។អំពីចលនាបង្កឡើងដោយក្រុមបុរសស្រលាញ់បុរស ដែលជាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទផងដែរ។

ក.៨. ជារួមចំនួននៃការឃាត់ខ្លួនអ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយបានចុះថយតិចតួចរវាងឆ្នាំ ២០០៧ និង ២០០៨ លើកលែងតែនៅក្រុងព្រះសីហនុ។ នៅក្នុងទីតាំងទាំងបី (ក្រៅពីខេត្តបន្ទាយមានជ័យ) គេឃើញមានការកើនឡើងនូវការឃាត់ខ្លួន ក្រុមបុរសស្រលាញ់បុរស និងជាក្រុមស្រីស្រស់។ នៅរាជធានីភ្នំពេញ ការឃាត់ខ្លួនមានការកើនឡើងយ៉ាងច្រើន។

ក.៩. អ្នកផ្តល់ចម្លើយទាំងឡាយបានរាយការណ៍អំពីការគាំទ្រតិចតួចពីរដ្ឋាភិបាល និងពីផ្នែកមិនមែនរដ្ឋាភិបាល នៅពេលដែល ពួកគេប្រឈមមុខជាមួយការរំលោភបំពាន ។ កម្រិតគាំទ្រច្រើនបំផុតគឺមាននៅខេត្តព្រះសីហនុ។ អង្គការមិនមែនរដ្ឋាភិបាលជាអង្គការផ្តល់ការគាំទ្រច្រើនជាងប៉ូលីស ឬច្រើនជាងអាជ្ញាធរមូលដ្ឋាន។



33 page.indd 12 7/14/2009 8:03:36 AM

## ខ) ផលប៉ះពាល់នៃច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្សចំពោះសិទ្ធិទទួលបានសេវាជាសកល

- **ការបិទផ្ទះបន**

ចាប់តាំងពីច្បាប់នេះបានប្រកាសឱ្យប្រើប្រាស់មក គេឃើញមានការកើនឡើងនូវយុទ្ធនាការបង្ក្រាប និងការបិទផ្ទះបន។ ប្រតិបត្តិការទាំងនេះភាគច្រើនមាននៅឆ្នាំ ២០០៨ ប៉ុន្តែនៅតំបន់ខ្លះដូចជានៅរាជធានីភ្នំពេញ ជាដើមគេនៅតែបន្តអនុវត្តប្រតិបត្តិការនេះ។ យុទ្ធនាការបង្ក្រាបផ្ទះបន និងការភ័យខ្លាចចំពោះខ្លឹមសារនៃច្បាប់ទំនងជាបានរួមចំណែក រួចហើយចំពោះនិន្នាការនៃការចាកចេញពីផ្ទះបន ក្នុងការទិញលក់សេវាផ្លូវភេទ[៩]។ អង្គការអន្តរជាតិបំរើសុខភាពប្រជាជន (PSI) រាយការណ៍ អំពី កំណើនចំនួន ៤៤% នៃចំនួនបៀហ្គាឌិន[១០]។ ភ្នាក់ងារដៃគូនៃអង្គការសុខភាពគ្រួសារអន្តរជាតិ បានរាយការណ៍ នៅដើមឆ្នាំ ២០០៨ ថានៅក្នុងខេត្តមួយចំនួន អ្នករកស៊ីផ្លូវភេទមកពីផ្ទះបនដែលបានបិទទ្វារ បានមករកការធ្វើនៅតាម ហាងខារ៉ាអូខេ កន្លែងម៉ាស្សា និងបៀហ្គាដិន[១១]។ ដៃគូរបស់អង្គការនេះក៏បានរាយការណ៍ផងដែរអំពីកំណើនបន្ទុក ចំពោះអ្នករកស៊ីផ្លូវភេទ និង បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយក្នុងការលក់សេវាផ្លូវភេទនៅតាមគ្រឹះស្ថាននានាក្រៅពីផ្ទះបន[១២]។ នៅក្នុងរយៈពេលបីខែដើមឆ្នាំ ២០០៨ ទីភ្នាក់ងារដៃគូអភិវឌ្ឍន៏នានារបស់

អង្គការសុខភាពគ្រួសារអន្តរជាតិបានរាយការណ៏ថា:

- ផ្ទះបនចំនួន ៣៣ បានបិទទ្វារ (អ្នករកស៊ីផ្លូវភេទ ១៨០ នាក់) នៅ ៣ ខណ្ឌ នៅរាជធានីភ្នំពេញ
- ផ្ទះបនចំនួន ២០ (អ្នករកស៊ីផ្លូវភេទ ៩៣ នាក់) នៅភូមិចំនួនបីក្នុងខេត្តកំពង់ចាម
- យុទ្ធនាការនៅខេត្តសៀមរាប ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៨ បានបំបាត់វត្តមានអ្នករកស៊ីផ្លូវភេទនៅតាមផ្ទះបនចំនួន ៦៥នាក់ក្នុងចំណោម១០០នាក់ដែលអ្នកទាំងនោះធ្លាប់មានទំនាក់ទំនងជាមួយអង្គការសុខភាពគ្រួសារ អន្តរជាតិ
- នៅខេត្តបន្ទាយមានជ័យ ផ្ទះបនចំនួន ៣៣ (អ្នករកស៊ីផ្លូវភេទ ១៧៤ នាក់)
- នៅខេត្តកំពង់ឆ្នាំង[១៣] ផ្ទះបនចំនួន ១៥ បានបិទទ្វារ

---

[9] PSI, "ការវិវត្តបរិយាកាសចំពោះស្រោមអនាម័យនៅក្នុងអន្តរាគមន៏បង្ការមេរោគអេដស៏," បទបង្ហាញរបស់ DFPA ខែ កុម្ភៈ ឆ្នាំ ២០០៩។ របាយការណ៏ផ្ទៃក្នុងរបស់ FHI ផងដែរ

[10] PSI, "ការវិវត្តបរិយាកាសចំពោះស្រោមអនាម័យនៅក្នុងអន្តរាគមន៏បង្ការមេរោគអេដស៏," ដូចខាងលើ កំណត់សម្គាល់លេខ ៩

[11] របាយការណ៏របស់អង្គការសុខភាពគ្រួសារអន្តរជាតិ

[12] ព័ត៌មានទាំងនេះត្រូវបានដកស្រង់ចេញពីរបាយការណ៏របស់អង្គការសុខភាពគ្រួសារអន្តរជាតិ

[13] ព័ត៌មានទាំងនេះត្រូវបានដកស្រង់ចេញពីរបាយការណ៏របស់អង្គការសុខភាពគ្រួសារអន្តរជាតិ

អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាប្រឆាំងមេរោគអេដស៍ចំពោះអ្នករកស៊ីផ្លូវភេទនៅតាមផ្ទះបនបានឱ្យដឹងថាយុទ្ធនាការទាំងនេះបានធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានចំពោះលទ្ធភាពរបស់ពួកគេក្នុងការទទួលបានសេវាជាសកល ។ អង្គការសុខភាពគ្រួសារអន្តរជាតិបានរាយការណ៍ពីចំនួនអ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយដែលអង្គការបានផ្តល់ សេវានៅ ១០ ខេត្តនៅឆ្នាំ ២០០៨ បានធ្លាក់ចុះពី ១០-៤០% ។ អ្នករកស៊ីផ្លូវភេទដែលបានចូលរួមសម្ភាសន៍បាន បដិសេធ អំពីលទ្ធភាពទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ ម្ចាស់ផ្ទះបនមិនសូវស្វាគមន៍ក្នុងការអនុញ្ញាតឱ្យមានសេវាប្រឆាំងមេរោគអេដស៍នៅក្នុងគ្រឹះស្ថានរបស់ខ្លួនទេ ។

- **បម្លាស់ទី**

ការអង្កេតបានរកឃើញថាបម្លាស់ទីបានកើនឡើងក្នុងចំណោមអ្នករកស៊ីផ្លូវភេទដោយផ្ទាល់ ។ ប្រការនេះអាចបណ្តាលមកពីច្បាប់ដែលបានបង្កើនការភ័យខ្លាចចំពោះការឃាត់ខ្លួនក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ ។ អង្គការសុខភាពគ្រួសារអន្តរជាតិបានរាយការណ៍ថាមានកន្លែងមួយដែល ពួកគេបាត់បង់អ្នកជម្ងឺមកទទួលឱសថប្រឆាំងមេរោគអេដស៍ដល់ទៅ៧%[១៤] ។

- **ការភ័យខ្លាចចំពោះសិទ្ធិទទួលបានសេវាជាសកល និងការភ័យខ្លាចក្នុងកិច្ចសហការជាមួយអ្នកផ្តល់សេវា**

ការអង្កេតបានរកឃើញថាក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ ៧៨,២% ធ្លាប់បានឮច្បាប់ស្តីពីការប្រឆាំងការជួញដូរប៉ុន្តែមានតែ ២១,៧% ប៉ុណ្ណោះដែលធ្លាប់បានចូលរួមនៅក្នុងការពិភាក្សាច្បាប់នេះ ។ នៅក្នុងអំឡុងពេលធ្វើអង្កេតគេបានរកឃើញថា ស្ត្រីរកស៊ីផ្លូវភេទជាច្រើននាក់កំពុងមានការភ័យខ្លាចក្នុងការនិយាយជាចំហអំពីសកម្មភាព របស់ពួកគេ ពីអ្វីដែលពួកគេបានដឹងអំពីច្បាប់នេះ ។ ការអង្កេតក៏បានរកឃើញផងដែរថា ក្រុមស្ត្រីរកស៊ីផ្លូវភេទភាគច្រើនមិនបានចូលរួមដោយផ្ទាល់ជាមួយភាគីពាក់ព័ន្ធដទៃទៀយ ពិសេសនៅកម្រិតមូលដ្ឋាន ។ ព័ត៌មានដែលទទួលបានពីអង្គការមិនមែនរដ្ឋាភិបាលបង្ហាញថាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនិងអ្នករកស៊ីផ្លូវភេទជាច្រើននាក់ក៏កំពុងភ័យខ្លាចចំពោះការទទួលសេវាប្រឆាំងមេរោគអេដស៍ផងដែរ ។ អង្គការ CARE បានរាយការណ៍ថា ជាលទ្ធផលនៃដំណើរការបិទផ្ទះបនចំនួនអ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយដែលមកកាន់គ្លីនិកជម្ងឺកាមរោគនៅតំបន់គោលដៅមួយគឺ

---

[14] របាយការណ៍របស់អង្គការសុខភាពគ្រួសារអន្តរជាតិ



33 page.indd 14 7/14/2009 8:03:37 AM

“មិនសូវបានមកញឹកញាប់ ហើយស្ត្រីជាច្រើនបានឈប់មកកាន់គ្លីនិកទាំងនោះ” ”[១៥] ។ នៅក្នុងអំឡុងត្រីមាសទីមួយ និងត្រីមាសទីពីរឆ្នាំ ២០០៨ ចំនួនស្ត្រីដែលស្វែងរកការថែទាំ និងព្យាបាលជម្ងឺកាមរោគរបស់អង្គការសុខភាពគ្រួសារអន្តរជាតិបានធ្លាក់ចុះ ២៦%។ ប្រសិនបើសភាពការណ៍នេះបន្តទៅទៀត បរិយាកាសភ័យខ្លាច និងមន្ទិលសង្ស័យ នឹងនាំទៅរកការកាត់បន្ថយលទ្ធភាពសហការក្នុងចំណោមភាគីពាក់ព័ន្ធនានា។ ចាំបាច់ត្រូវមានជំហានសកម្មនានាដើម្បីបង្កើតបរិយាកាសអំណោយផលចំពោះស្ត្រីរកស៊ីផ្លូវភេទ ក្នុងការចូលរួមនៅគ្រប់កម្រិតនៃបណ្តាសកម្មភាពដែលទាក់ទងនឹងសិទ្ធិទទួលបាន សេវាជាសកល ព្រមទាំងបណ្តាសកម្មភាពពាក់ព័ន្ធដទៃទៀតផងដែរ។

## ៤. គោលបំណងនៃច្បាប់ស្តីពីអំពើប្រឆាំងការជួញដូរមនុស្ស

មាត្រា ១ នៃច្បាប់បានចែងថាគោលបំណងនៃច្បាប់គឺ:

*...មានគោលបំណងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងបង្កើនសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងរក្សាការពារ លើកកម្ពស់នូវទំនៀមទម្លាប់ប្រពៃណីដ៏ល្អរបស់ជាតិ និងមានគោលបំណងអនុវត្តឱ្យបានសមស្របផងដែរ តាមពិធីសារអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន [ពិធីសារ Palermo] ឬឧបករណ៍ ឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀត ទាក់ទងនឹងការជួញដូរមនុស្សដែលព្រះរាជាណាចក្រកម្ពុជាបានឱ្យសច្ចាប័ន ឬចុះហត្ថលេខា*[១៦] ។

ការស្រាវជ្រាវនេះបានរកឃើញថាច្បាប់ស្តីពីការប្រឆាំងនឹងអំពើជួញដូរមនុស្ស បានធ្វើឱ្យប៉ះពាល់ដល់សុខភាព សុខុមាលភាព ភាពថ្លៃថ្នូរ និងសិទ្ធិរបស់ក្រុមប្រជាពលរដ្ឋងាយរងគ្រោះបំផុត ពិសេសប៉ះពាល់តាមបែបដែលច្បាប់នេះបានអនុវត្តលើកដំបូងនៅដើមឆ្នាំ ២០០៨។ ច្បាប់នេះមិនបានកំណត់ន័យដូចម្តេចដែលហៅថាប្រពៃណីជាតិ ល្អឡើយ។ ការអនុវត្តប្រពៃណីជាតិមួយចំនួនអាចធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃ ឧទាហរណ៍ ប្រពៃណីជាតិអំពីសិទ្ធិ និងភារកិច្ចរបស់មាតាបិតាក្នុងការទ្រទ្រង់បុត្រធីតារបស់ខ្លួន (ដូចមានចែងនៅក្នុងមាត្រា ៤៧ នៃរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា) ហើយការដកហូតសិទ្ធិប្រកបការងាររបស់ពលរដ្ឋមួយចំនួនដែលជាមាតាបិតា អាចចាត់ទុកថាធ្វើឱ្យ ប៉ះពាល់ដល់ប្រពៃណីជាតិ។ ជារឿយៗ ប្រពៃណីប្រែប្រួលទៅតាមក្រុមនានាដែលមានសេដ្ឋកិច្ច សង្គមកិច្ច និង ជាតិពិន្ទុខុសៗគ្នានៅក្នុងប្រ

---

15 *យេនឌ័រ ភេទ និងអំណាចដើម្បីរស់រានមានជីវិត: ផលប៉ះពាល់ និងបច្ច័យនៃការពង្រឹងសមត្ថភាពស្ត្រីដែលប្រឈមមុខនឹងមេរោគអេដស៍និងជម្ងឺអេដស៍* ការស៊ើបអង្កេត ផលប៉ះពាល់ផ្នែកយុទ្ធសាស្ត្រ អង្គការ CARE ខែ កញ្ញា ឆ្នាំ ២០០៨ ទំព័រ ៤៧

16 វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ រាល់ឯកសារយោងចំពោះច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ ២០០៨ ជាឯកសារបកប្រែក្រៅផ្លូវការរបស់យូនីសែហ្វ



33 page.indd 15 7/14/2009 8:03:37 AM

ជាជាតិមួយ[១៧] ។ ការស្រាវជ្រាវនេះក៏បានរកឃើញផងដែរថា ច្បាប់ស្តីពីការប្រឆាំងអំពើ ជួញដូរមនុស្សមិនបានអនុវត្ត ត្រឹមត្រូវតាម *ពិធីសារអង្គការសហប្រជាជាតិដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទោសទណ្ឌ អំពើជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹង ឧក្រិដ្ឋកម្មឆ្លងដែនដែលមាន ការចាត់តាំង* ឡើយ ( ពិធីសារ Palermo ) ។

ច្បាប់នេះដោះស្រាយបញ្ហាជាច្រើនដែលមិនមែនទាក់ទងតែនឹងអំពើជួញដូរមនុស្ស ពេស្យាចារ រូបភាពនិង សម្ភារៈអាសអាភាស និងការរំលោភបំពានផ្លូវភេទនៃអនីតិជនប៉ុណ្ណោះទេ ។ ការដាក់បញ្ហាអស់ទាំងនេះឱ្យស្ថិតនៅ ក្រោមច្បាប់មួយទំនងជាបង្កើតឱ្យមានការច្របូកច្របល់ ។ ភាពច្របូកច្របល់នេះអាចកើតមានដោយសារកង្វះនិយម ន័យចំពោះពាក្យគន្លឹះផ្សេងៗ និងនិយមន័យនៃពាក្យដទៃទៀតដែលមានលក្ខណៈទូលាយពេក ។ បទល្មើសមួយចំនួនក៏ បានដាក់ទណ្ឌកម្មនៅក្នុងច្បាប់ដទៃទៀតផងដែរ ដូចជា មាត្រា ២៩៨ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌកម្ពុជា ដែលដាក់ ទោសទណ្ឌចំពោះអំពើអូសទាញដើម្បីរួមភេទ ។

មានមាត្រាមួយ ( មាត្រា ២៤) ដែលចែងអំពីសណ្តាប់ធ្នាប់សាធារណៈ ហើយគ្មានទំនាក់ទំនងជាមួយ អំពើជួញដូរមនុស្ស ឬអំពើធ្វើអាជីវកម្មផ្លូវភេទឡើយ ។ សណ្តាប់ធ្នាប់សាធារណៈអាចគ្របដណ្តប់បញ្ហាច្រើនយ៉ាង ដូចជា ការរំខានអ្នកជិតខាងដោយបង្កសម្លេងលាន់រំពង ការបោះសម្រាមចោល ការចតរថយន្តនៅកន្លែងមិនត្រឹមត្រូវជាដើម ។ តាមធម្មតា បទល្មើសប្រឆាំងសណ្តាប់ធ្នាប់សាធារណៈមិនត្រូវបានដាក់ទោសដោយដាក់ពន្ធនាគារឡើយ ។ មាត្រា ២៤ បានដាក់ទោសអ្នករកស៊ីផ្លូវភេទដែលអូសទាញភ្ញៀវជាសាធារណៈដើម្បីរួមភេទ ដោយការផាកពិន័យ និង/ឬដោយដាក់ ពន្ធនាគាររហូតដល់ ៦ ថ្ងៃ ។

### ក) ពិធីសារ Palermo

ពិធីសារនេះ ( មាត្រា ៣ ( ក) ) កំណត់និយមន័យអំពើការជួញដូរថាជា**អំពើមួយដែលតម្រូវឱ្យមានធាតុបីយ៉ាងៈ**

*ក) ការជ្រើសរើស ដឹកជញ្ជូន ផ្តល់កន្លែងស្នាក់នៅ ឬទទួលមនុស្ស*

---

17 Ratna Kapur "សោកនាដកម្មនៃភាសាសព័ចោទប្រកាន់ៈ ការចាប់កំណើតសារជាថ្មីអំពីប្រធានបទ "ដើម " នៅក្នុងនយោបាយអន្តរជាតិផ្នែក គតិយុត្តនៃសកម្មជនក្រោយសម័យអាណានិគម" (ឆ្នាំ 2002) 15 ឯកសារទិនានុប្បវត្តន៍សិទ្ធិមនុស្សលេខ ១ នៅ Harvard



33 page.indd 16 7/14/2009 8:03:38 AM

*ដោយការប្រើ*

*ខ) ការគម្រាមកំហែង ឬការប្រើកម្លាំង ឬទម្រង់ដទៃទៀតនៃការបង្ខិតបង្ខំ ការចាប់ពង្រត់ ក្លែងបន្លំ បោកប្រាស់ ការរំលោភអំណាច ឬការរំលោភបំពានឋានៈចំពោះភាពងាយរងគ្រោះ ឬចំពោះការផ្តល់ ឬការទទួលប្រាក់ ឬ អត្ថប្រយោជន៍ផ្សេងៗដើម្បីបានទទួលការព្រមព្រៀងរបស់បុគ្គលណាមួយដែលគ្រប់គ្រងលើបុគ្គលម្នាក់ផ្សេងទៀតៈ*

*ក្នុងគោលបំណង*

*គ) ធ្វើអាជីវកម្ម*

ច្បាប់នេះមានបញ្ញត្តិដែលចាត់ជាបទឧក្រិដ្ឋចំពោះជនណាដែលបោកបញ្ឆោត ចាប់ពង្រត់ និងបំពារបំពានអ្នកដទៃក្នុងដំណើរនៃពេស្យាចារ ឬក្នុងទម្រង់ដទៃទៀតនៃពលកម្ម ស៊ុំកូន ជាដើមតាមកិច្ចតម្រូវនៃពិធីសារនេះ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារបញ្ញត្តិទាំងនោះខ្វះធាតុទាំងបីនៃនិយមន័យ បទឧក្រិដ្ឋមួយចំនួនដែលត្រូវបានកំណត់នៅក្នុងច្បាប់ក៏អាចដាក់ទោសទណ្ឌបុគ្គល និងអង្គការចាត់តាំងដូចគ្នាដែរដូចជាការផ្តល់ការបណ្តុះបណ្តាលអំពីការរួមភេទដែលមានសុវត្ថិភាព ឬជួយនីតិជនដែលមិនចង់ទៅមណ្ឌលស្តារនីតិសម្បទា ឬធ្វើឱ្យគេបញ្ជូនទៅមណ្ឌល "ស្តារនីតិសម្បទា" ។

## ***ការតួបផ្សំរបវរកស៊ីផ្លូវភេទជាមួយការធ្វើអាជីវកម្ម***

មាត្រា ១០ នៃច្បាប់ស្តីពីអំពើជួញដូរមនុស្សផ្តល់និយមន័យដោយរួមបញ្ចូល ‘‘ការធ្វើអាជីវកម្មពេស្យាចារទៅលើអ្នកដទៃរូបភាពនិងសម្ភារៈអាសអាភាស **សកម្មភាពរកស៊ីផ្លូវភេទ** ពលកម្ម ឬសេវាដោយបង្ខំ ទាសភាព ឬការអនុវត្តន៍ស្រដៀងទាសភាព ទាសភាពបំណុល សេវភាពមិនស្ម័គ្រចិត្ត ពលកម្មកុមារ ឬការវះយកផ្នែកនានា នៃសារពាង្គកាយ ។

*មាត្រា ៣ (ក) នៃពិធីសារ Palermo ចែងថាៈ ការធ្វើអាជីវកម្ម យ៉ាងហោចណាស់ត្រូវរួមមាន* ***ការធ្វើអាជីវកម្មពេស្យាចារអ្នកដទៃ ឬទម្រង់ដទៃនៃការធ្វើអាជីវកម្មផ្លូវភេទ*** *ពលកម្ម ឬសេវាដោយបង្ខំ ទាសភាព ឬការអនុវត្តស្រដៀងទាសភាព សេវាភាព ឬការវះកាត់យកផ្នែកនានានៃសារពាង្គកាយ ។*

តាមរយៈការប្រើពាក្យ ‘‘អំពើជួញដូរផ្លូវភេទ’’ ជំនួស ‘‘ការធ្វើអាជីវកម្មផ្លូវភេទ ’’ ច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្សរាប់បញ្ចូលនូវទង្វើដោយស្ម័គ្រចិត្តរវាងនីតិជនដែលមានការព្រមព្រៀង ដែលគ្មានអ្នកពាក់ព័ន្ធនរណាមួយយល់ថាពួកគេត្រូវបានធ្វើអាជីវកម្ម។ ការអង្កេតបានរកឃើញថាអ្នករកស៊ីផ្លូវភេទជា នីតិជនដែលមានការព្រម

ព្រៀង គឺជាអ្នករកស៊ីផ្លូវភេទ ភាគច្រើនហើយនៅពេលដែលមានការឃាត់ខ្លួន តាមធម្មតា គ្មានការព្យាយាមកំណត់ថា តើនរណាខ្លះ ដែលត្រូវបានគេជួញដូរ ហើយនរណាខ្លះជាអ្នករកស៊ីផ្លូវភេទដោយស្ម័គ្រចិត្តនោះទេ (លើកលែងតែនៅខេត្តព្រះសីហនុ)។ ប្រការនេះក៏ធ្វើឱ្យអ្នកខ្លះចាត់ទុករបររកស៊ីផ្លូវភេទថាជាអំពើជួញដូរមនុស្ស ហើយធ្វើឱ្យមានការយល់ខុសដែលថា អ្នករកស៊ីផ្លូវភេទទាំងឡាយសុទ្ធសឹងតែជាឧក្រិដ្ឋជន។

***ភាពមិនស៊ីសង្វាក់គ្នាដទៃទៀតជាមួយពិធីសារ Palermo***

ភាពមិនស៊ីសង្វាក់គ្នាដទៃទៀតជាមួយពិធីសារ Palermo រួមមាន កង្វះលក្ខខ័ណ្ឌស្តីពីចេតនារម្មណ៍នៅក្នុងបទល្មើសដែលបានកំណត់នៅក្នុងមាត្រា ១៩ និង ២០ (ការទទួលមនុស្ស និងការទទួលមនុស្សក្នុងគោលបំណងជួយជនល្មើស)។ មាត្រា ៥១ នៃពិធីសារនេះបានអំពាវនាវឱ្យរដ្ឋាភិបាលនានាចាត់ទុកបទល្មើសស្តីពីអំពើជួញដូរមនុស្សថាជាឧក្រិដ្ឋកម្ម នៅពេលណាដែលពួកគេប្រព្រឹត្តដោយចេតនា។ ទន្ទឹមនឹងនេះពាក្យ "លួងលោម" នៅក្នុងមាត្រា ៨ នៃច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស ចាំបាច់ត្រូវមាននិយមន័យបន្ថែម ព្រោះពាក្យថា "ការលួងលោម" មិនប្រាកដជាមានន័យ ថាជាការប្រព្រឹត្តដែលមានចរិតបង្ខិតបង្ខំ ឬបោកបញ្ឆោត ដូចមានចែងនៅក្នុងនិយមន័យនៃពិធីសារស្តីពីអំពើជួញដូរមនុស្សឡើយ។

**ខ) ចំណោទបញ្ហាទាក់ទងនឹងនិយមន័យ**

ជំពូក ២ នៃច្បាប់នេះមិនបានញែកចេញពីគ្នានូវពេស្យាចារដោយស្ម័គ្រចិត្តដោយនីតិជន និងពេស្យាចារ និងអំពើជួញដូរមនុស្សដោយបង្ខំឡើយ (មាត្រា ១)។ មាត្រាមួយចំនួននៅក្នុងជំពូក ៤ នៃច្បាប់នេះក៏មិនបានញែកចេញពីគ្នារវាងទំនាក់ទំនងអាជីវកម្មដោយសេរីដែលនីតិជនរកស៊ីផ្លូវភេទដោយស្ម័គ្រចិត្ត និងទំនាក់ទំនងដែលមានចរិតជាការធ្វើអាជីវកម្មឡើយ។

***និយមន័យនៃសញ្ចារកម្ម***

មាត្រា ២៥-២៩ នៃច្បាប់នេះបានកំណត់ និងដាក់ទោសទណ្ឌចំពោះបទល្មើសទាំងឡាយណាដែលពាក់ព័ន្ធជាមួយសញ្ចារកម្ម។ ពាក្យសញ្ចារកម្មបានកំណត់ឡើងដែលមានលក្ខណៈទូទៅ និងមានលក្ខណៈទូលាយជាខ្លាំង ហើយពាក្យនេះ អាចជួយសម្រួលដល់ការអនុវត្តន៍តាមទំនើងចិត្ត និងការអនុវត្តន៍បែបពុករលួយ។ ប្រសិនបើគ្មានការបំភ្លឺបន្ថែមទៀតទេនោះ បញ្ញត្តិទាំងនេះ អាចចាត់ជាបទឧក្រិដ្ឋចំពោះការជួញដូរស្ទើរតែទាំងអស់របស់អ្នករកស៊ីផ្លូវភេទ



33 page.indd 18 7/14/2009 8:03:38 AM

ដោយស្ម័គ្រចិត្តរបស់នីតិជន ទំនាក់ទំនងបុគ្គលនិងគ្រួសារជាមួយនីតិជនរកស៊ីផ្លូវភេទដោយស្ម័គ្រចិត្ត និងការងាររបស់អង្គការចាត់តាំងដែល ផ្តល់សេវាសុខភាព និងសេវាសុខុមាលភាពដទៃទៀតចំពោះអ្នករកស៊ីផ្លូវភេទ ។

***ការគ្រប់គ្រងពេស្យាចារ***

ច្បាប់នេះក៏ផ្តល់និយមន័យអំពីការគ្រប់គ្រងពេស្យាចារផងដែរ ដែលនិយមន័យនោះមានលក្ខណៈទូលាយជាខ្លាំង គឺថាជាមធ្យោបាយតែមួយគត់ ដែលអ្នករកស៊ីផ្លូវភេទអាចប្រកបរបរដោយស្របច្បាប់គឺប្រកបរបរនោះនៅក្នុងផ្ទះ ដែលជាកម្មសិទ្ធិរបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ ការលក់ផ្ទះទៅឱ្យអ្នករកស៊ីផ្លូវភេទ ឬអ្នកដែលជាប់មន្ទិលថាជាអ្នករកស៊ីផ្លូវភេទ គឺជាអំពើខុសច្បាប់ ។ (សូមអានមាត្រា ៣០ និង ៣១ នៃច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស) ។

ប្រសិនបើអ្នកដទៃទៀតបានរកឃើញថារស់នៅជាមួយអ្នករកស៊ីផ្លូវភេទ ឬស្ថិតនៅកន្លែងពេស្យាចារ ពួកគេទាំងនោះមានភាពងាយរងគ្រោះចំពោះការចោទប្រកាន់ តាមខ្លឹមសារមាត្រា ២៦ ២៧ ២៨ ឬ ២៩ អាស្រ័យទៅតាមស្ថានភាព និងអាយុរបស់អ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ។

***គ្មានការកំណត់ន័យអំពីអំពើអាសអាភាសជាសាធារណៈឡើយ***

មាត្រា ២៤ ដាក់ទោសអំពើអាសអាភាសជាសាធារណៈដោយផាកពិន័យ និង/ឬដោយដាក់ពន្ធនាគាររហូតដល់ ៦ ថ្ងៃ ។ គេពុំឃើញមាននិយមន័យអំពី "អំពើអាសអាភាស" ឬនិយមន័យអំពី "សាធារណៈ" ឡើយ ។ ប្រការនេះធ្វើឱ្យមានការ ឃាត់ខ្លួនមនុស្សចំពោះការបញ្ជូនសារនៅលើទូរស័ព្ទដៃរបស់ពួកគេ ការយកស្រោមអនាម័យតាមខ្លួន ឬការដើរ ឬការអង្គុយនៅតាមសួនច្បារសាធារណៈ ។ បុគ្គលិកផ្សព្វផ្សាយស្ត្រី និងស្ត្រីដែលរស់នៅជិតតំបន់ដែលប្រជុំទៅដោយរបររក ស៊ីផ្លូវភេទ ត្រូវបានឃាត់ខ្លួនដោយសារតែពួកគេស្ថិតនៅទីសាធារណៈក្នុងពេលរាត្រី ។ ការអង្កេតនេះបានរកឃើញថានៅទីកន្លែងផ្សេងគ្នា មានការយល់ ច្រឡំអំពីអ្វីដែលបានបង្កើតជាអំពើអាសអាភាសជាសាធារណៈក្នុងចំណោមអ្នករកស៊ីផ្លូវភេទ និងក្នុងចំណោមប៉ូលីស ។

## គ) សេចក្តីណែនាំសម្រាប់ប៉ូលីស

កាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨ ក្រុមការងារស្តីពីអំពើជួញដូរមនុស្ស រត់ពន្ធមនុស្ស ការធ្វើអាជីវកម្មលើកម្លាំងពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទចំពោះស្ត្រី និងកុមារបានចេញ "សេចក្តីណែនាំសម្រាប់អនុវត្ត ច្បាប់ស្តីពីការ



33 page.indd 19 7/14/2009 8:03:38 AM

បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ[១៨]"។ សេចក្តីណែនាំនេះចែងអំពីបទបញ្ជា សំខាន់១បួនយ៉ាង ដើម្បីឱ្យសមត្ថកិច្ចគោរពតាម[១៩]:

ចំណុចសំខាន់បំផុតគឺការបំភ្លឺដែលថា *ពេស្យាចារពុំមែនជាឧក្រិដ្ឋកម្មឡើយ ហើយត្រូវចាត់ទុកអ្នករកស៊ីផ្លូវភេទដូចជាជនរងគ្រោះ*។ ប្រការនេះជួយបញ្ជាក់អំពីការយល់មិនត្រឹមត្រូវដែលថាពេស្យាចារជាអំពើខុសច្បាប់ ហេតុនេះអ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយជាឱ្យក្រិដ្ឋជន។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលបានពិភាក្សាខាងក្រោម ការកំណត់ន័យថាអ្នករកស៊ីផ្លូវភេទទាំងឡាយប្រៀបបានទៅនឹងជនរងគ្រោះ មានន័យថាគ្មានការញែកចេញពីគ្នារវាង អ្នករកស៊ីផ្លូវភេទដោយស្ម័គ្រចិត្តជានីតិជន និងជនរងគ្រោះពិតប្រាកដពីអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឡើយ។

## ៥. ផលប៉ះពាល់នៃច្បាប់ប្រឆាំងអំពើជួញដូរមនុស្សចំពោះបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយនិងអ្នករកស៊ីផ្លូវភេទ

ផលប៉ះពាល់អវិជ្ជមាននៃច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្សមកលើបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ បានចាត់ថ្នាក់ជាបីប្រភេទធំ១: ការលុបចោលដ៏មានប្រសិទ្ធិភាពនូវសិទ្ធិប្រកបការងារ ការរំលោភសិទ្ធិមនុស្ស និងការបង្កើនការមាក់ងាយ។

### ក) ផលប៉ះពាល់ចំពោះសិទ្ធិប្រកបការងារ

ដោយពិចារណាអំពីផលប៉ះពាល់នៃច្បាប់នេះចំពោះសិទ្ធិប្រកបការងាររបស់អ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ជាចាំបាច់ត្រូវពិចារណាអំពីអ្វីដែលច្បាប់ចែង និងវិធីដែលអនុវត្តច្បាប់នោះ។

លើផ្នែកបច្ចេកទេស ច្បាប់ស្តីពីការជួញដូរមិនបានចាត់ទុករបររកស៊ីផ្លូវភេទថាជាឧក្រិដ្ឋកម្មឡើយ។ ទោះជាយ៉ាងណាក៏ដោយ គេឃើញមានករណីតិចតួចប៉ុណ្ណោះដែលអ្នករកស៊ីផ្លូវភេទអាចបំពេញបានតាមល័ក្ខខ័ណ្ឌដើម្បីឱ្យរបររកស៊ីផ្លូវភេទមានលក្ខណៈស្របច្បាប់ ដូចមានចែងនៅក្នុងច្បាប់។

---

18 ព្រះរាជាណាចក្រកម្ពុជា ក្រុមប្រតិបត្តិស្ត្រីប្រឆាំងអំពើជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស និងការធ្វើអាជីវកម្មលើកម្លាំងពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទចំពោះស្ត្រី និង កុមារ សេចក្តីណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ លេខ ០០១ សណនបក្របផ ចុះថ្ងៃ ទី ២៨ ខែ តុលា ឆ្នាំ ២០០៨

19 សម្រង់ដកចេញពីសេចក្តីណែនាំដែលអង្គការ UNIAP បានបកប្រែក្រៅផ្លូវការ

ការលើកយកមកពិចារណានូវមាត្រានានានៃច្បាប់នេះជុំវិញសញ្ញាករកម្ម អំពើអូសទាញ និងការគ្រប់គ្រង ពេស្យាចារ របររកស៊ីផ្លូវភេទគ្មានពាក់ព័ន្ធជាមួយសកម្មភាពឧក្រិដ្ឋចំពោះនរណាម្នាក់ឡើយប្រសិនបើៈ

- បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ ផ្តល់សេវានៅផ្ទះសម្ញែងដែលជាកម្មសិទ្ធិរបស់ខ្លួនមុនពេលចាប់ផ្តើមប្រកបរបររកស៊ីផ្លូវភេទ
- គ្មាននរណាផ្សេងរស់នៅ ឬបម្រើការនៅទីនោះ រាប់ទាំងសមាជិកគ្រួសារផងដែរ
- អ្នករកស៊ីផ្លូវភេទមិនផ្សព្វផ្សាយ ឬមិនធ្វើការអូសទាញភ្ញៀវជាសាធារណៈហើយ
- អ្នករកស៊ីផ្លូវភេទមិនឧបត្ថម្ភគាំទ្រនរណាម្នាក់ផ្សេងចំពោះប្រាក់ចំណូលដែលខ្លួនរកបាន

អាចមានកាលៈទេសៈផ្សេងទៀតនៅពេលដែលបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ អាចប្រកបរបរដោយ មិនល្មើសច្បាប់ ។ ទោះជាយ៉ាងណាក៏ដោយម្ចាស់ផ្ទះ ឬអ្នកគ្រប់គ្រងគ្រឹះស្ថានដែលមានសេវាកម្ម បែបនេះកំពុងប្រព្រឹត្តបទឧក្រិដ្ឋ ហើយគ្រឹះស្ថានទាំងនោះត្រូវទទួលរងនូវការធ្វើការបង្ក្រាបពីសំណាក់ប៉ូលីស ហេតុនេះអ្នករកស៊ីផ្លូវភេទ មិនអាចប្រកបរបរនៅទីនោះបានឡើយ ។

សេចក្តីណែនាំសម្រាប់ប៉ូលីស ព្យាយាមផ្តល់សិទ្ធិមួយចំនួនចំពោះអ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ នៅតាមហាងម៉ាស្សា និងខារ៉ាអូខេ។ ទោះជាយ៉ាងណាក៏ដោយ ផ្នែកនេះនៃសេចក្តីណែនាំទំនងជាមានភាពផ្ទុយគ្នា ដោយផ្ទាល់ជាមួយច្បាប់នេះ ។

**អាស្រ័យហេតុនេះ ខណៈដែលច្បាប់ស្តីពីការជួញដូរមិនចាត់ជាចំហនូវរបររកស៊ីផ្លូវភេទ ថាជាឧក្រិដ្ឋកម្ម ច្បាប់នេះមានឥទ្ធិពល**ចំពោះអ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយភាគច្រើន ដែលមានជីវភាពក្រីក្រ និងមាន កម្រិតអប់រំទាប (ជាមធ្យមស្ត្រីទទួលបានការអប់រំត្រឹម ៣,៩ ឆ្នាំ) ។ ហេតុនេះ ច្បាប់នេះធ្វើឱ្យប៉ះពាល់ដល់ភាពថ្លៃថ្នូរ និងសិទ្ធិ របស់ក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះខ្លាំង ព្រោះច្បាប់នេះមិនទទួលស្គាល់សិទ្ធិរបស់ពួកគេក្នុងការប្រកបការងារ ដើម្បីទ្រទ្រង់ក្រុមគ្រួសាររបស់អ្នកទាំងនោះឡើយ (ជាមធ្យមស្ត្រីត្រូវរ៉ាប់រងសមាជិកគ្រួសារចំនួន ៣,៣ នាក់) ។


33 page.indd 21 7/14/2009 8:03:39 AM

### *សិទ្ធិប្រកបរបរនិងការអនុវត្តន៍ច្បាប់*

ទន្ទឹមគ្នានេះ ទំនងជាមានភាពមិនស៊ីសង្វាក់គ្នា និងការយល់ដឹងមិនត្រឹមត្រូវក្នុងចំណោមប៉ូលីស និងស្ថាប័ន មានសមត្ថកិច្ចដទៃទៀត នៅពេលអនុវត្តច្បាប់នេះ ឧទាហរណ៏

- ឃាត់ខ្លួនអ្នករកស៊ីផ្លូវភេទដោយសារពួកគេស្ថិតនៅផ្ទះបនក្នុងពេលបង្ក្រាប[២០] :
- អ្នករកស៊ីផ្លូវភេទមួយចំនួនបានរាយការណ៏ថានៅពេលដែលពួកគេត្រូវបានឃាត់ខ្លួន ប៉ូលីសបានសួរពួកគេថាតើពួកគេបម្រើការឱ្យម្ចាស់បន ឬមេបន ដែលអ្នកទាំងនេះអាចបង់ប្រាក់លោះពួកគេមកវិញ។

ទោះបីជាសេចក្តីណែនាំសម្រាប់ប៉ូលីសបញ្ជាក់ថាពេស្យាចារពុំមែនជាឧក្រិដ្ឋកម្មក្តី ចំណុចនេះមិនធានាបានចំពោះ សិទ្ធិប្រកបការងាររបស់អ្នករកស៊ីផ្លូវភេទឡើយ។ អ្នករកស៊ីផ្លូវភេទទាំងឡាយត្រូវបានចាត់ទុកដូចជា ជនរងគ្រោះ (សេចក្តីណែនាំលេខ ១(៤))។ យោងតាមសេចក្តីណែនាំលេខ ៤(២) ជនរងគ្រោះទាំងឡាយអាចត្រូវបាននាំខ្លួនដោយប៉ូលីសដើម្បីសាកសួរ បន្ទាប់មកនីតិជនមានជម្រើសពីរយ៉ាង ឬមួយពួកគេទៅមណ្ឌលស្តារនីតិសម្បទា ឬមួយវិលត្រឡប់ទៅកាន់ផ្ទះសម្បែងវិញ។ មានការរាយការណ៏ឱ្យដឹងថា ជួនកាលអ្នករកស៊ីផ្លូវភេទ មិនត្រូវបានអនុញ្ញាតឱ្យវិលត្រឡប់ទៅកាន់ផ្ទះសម្បែងឡើយ វៀរលែងតែពួកគេចុះហត្ថលេខាសន្យាថាពួកគេលះបង់របររកស៊ីផ្លូវភេទ។ អាស្រ័យហេតុនេះ ការអនុវត្តន៏សេចក្តីណែនាំនេះ ជួនកាលបំបិទសិទ្ធិមិនឱ្យអ្នករកស៊ីផ្លូវភេទដែលជានីតិជនប្រកបរបរដែលពួកគេបានព្រមព្រៀង។

### *អ្នករកស៊ីផ្លូវភេទភាគច្រើនដែលជានីតិជន មិនត្រូវបានគេជួញដូរឡើយ*

អ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយដែលបានផ្តល់កិច្ចសម្ភាសន៏ និងដែលបានចូលរួមអង្កេតនៅក្នុងការ ស្រាវជ្រាវនេះនិយាយថាពួកគេមានសិទ្ធិ ឬគប្បីមានសិទ្ធិលក់សេវាផ្លូវភេទលើមូលដ្ឋានស្ម័គ្រចិត្ត (៨៤%នៃស្ត្រីរកស៊ីផ្លូវភេទ និង៨៦%នៃក្រុមស្រលាញ់បុរស និងក្រុមស្រីស្រស់ )។ អង្កេតនេះបង្ហាញថា ដូចកន្លែងធ្វើការដទៃទៀតដែរអាចមានមូលហេតុផ្សេងៗដែលធ្វើឱ្យបុគ្គលណាម្នាក់លក់សេវាផ្លូវភេទ។ ស្ត្រីជាង ៥០% ដែលបានផ្តល់កិច្ចសម្ភាសន៏បាន និយាយថាពួកគេប្រកបរបរនេះដោយស្ម័គ្រចិត្ត។ ៤០,១៦ % ទៀត និយាយថាពួកគេជ្រើសយករបរនេះដោយសារបញ្ហាគ្រួសារ។ ការស្រាវជ្រាវផ្សេងទៀតបង្ហាញថាបញ្ហាគ្រួសារអាចជាកត្តាទាំងឡាយ ដូចជាភាពក្រីក្រ

[20] សូមអាន កាសែតកោះសន្តិភាព ថ្ងៃទី ១៩/០៣/០៩



33 page.indd 22 7/14/2009 8:03:39 AM

បំណងប្រាថ្នាចាកផុតពីស្ថានភាពរំលោភបំពានក្នុងគ្រួសារនិងបំណងប្រាថ្នាចង់បានសេរីភាពបុគ្គលឱ្យបានកាន់តែច្រើន[២១] ។ មូលហេតុដូចគ្នានេះមានឥទ្ធិពលចំពោះសេចក្តីសម្រេចចិត្តរបស់ស្ត្រីវ័យក្មេង ក្នុងការចាកចេញពីផ្ទះសម្បែង ទៅធ្វើការនៅក្នុងផ្នែកដទៃ ដូចជានៅតាមរោងចក្រជាដើម[២២] ។ ហេតុនេះ គេអាចសន្និដ្ឋានថាអ្នកទាំងឡាយណា ដែលសំដៅទៅដល់បញ្ហាគ្រួសារ យល់ថារបររកស៊ីផ្លូវភេទជាមធ្យោបាយមួយនៃការចាកផុតពីស្ថានភាពលំបាក និង/ឬ លើកកំពស់ជីវភាពរស់នៅរបស់ពួកគេ ។

បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងស្ត្រីរកស៊ីផ្លូវភេទតិចជាង ០,៨% ដែលបានចូលរួមអង្កេតនិយាយថាពួកគេត្រូវបានគេលក់ ឱ្យធ្វើស្ត្រីពេស្យា ហើយ ៦,២១% បាននិយាយថាពួកគេត្រូវបានលួងលោម ។ ចាំបាច់ត្រូវមានការស៊ើបអង្កេតបន្ថែម ដើម្បី កំណត់ថាតើពួកគេចង់និយាយយ៉ាងដូចម្តេចចំពោះពាក្យថាពួកគេត្រូវបានលួងលោម ។ ទោះជាយ៉ាងណាក៏ដោយ យោងតាមនិយមន័យនៃពិធីសារ Palermo ប្រសិនបើ អ្នកដែលត្រូវបានគេល្បួងលួងលោមទាំងឡាយត្រូវបានបោក បញ្ឆោត ឬចាប់បង្ខំឱ្យលក់សេវាផ្លូវភេទ ប្រការនេះនៅតែមានន័យថាអ្នកផ្តល់ចម្លើយចំនួន ៧,១% ប៉ុណ្ណោះដែលត្រូវបាន ជួញដូរ ។ ករណីសិក្សាពីការស្រាវជ្រាវនេះបង្ហាញថា ទោះបីជាមនុស្សមួយចំនួនដែលធ្លាប់ត្រូវបានជួញដូរក៏អាច ជ្រើសធ្វើជាអ្នករកស៊ីផ្លូវភេទជាបន្តដោយសេរីបានដែរ ។

អាស្រ័យហេតុនេះ ការស្រាវជ្រាវបង្ហាញថារបររកស៊ីផ្លូវភេទគឺជារបរប្រសើរបំផុត ហើយជាជម្រើសប្រចាំជីវិតយ៉ាងហោចណាស់ចំពោះអ្នកដែលបានចូលរួមក្នុងអង្កេតចំនួន ៩០% ។ ដោយសារអក្ខរភាពមានកម្រិតទាប និងដោយសារភាពក្រីក្រមានកម្រិតខ្ពស់ ការលក់សេវាផ្លូវភេទ អាចជាជម្រើសតែមួយគត់របស់ពួកគេ ។ ករណីសិក្សានានាបង្ហាញថាអ្នករកស៊ីផ្លូវភេទភាគច្រើនត្រូវបានជម្រុញទឹកចិត្តដោយសារតម្រូវការចិញ្ចឹមក្រុមគ្រួសាររបស់ខ្លួន ។ ជាមធ្យមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងស្ត្រីរកស៊ីផ្លូវភេទទ្រទ្រង់សមាជិកគ្រួសារពី ៣ ទៅ ៤ នាក់ ។ របររកស៊ីផ្លូវភេទជាជម្រើសប្រសើរ បំផុតសម្រាប់ពួកគេក្នុងការធ្វើបែបនេះ ។ នេះគឺជាមូលហេតុដូចគ្នា ដែលមនុស្សជាច្រើនសម្រេចចិត្តប្រកាន់យកទម្រង់ការងារមួយជាក់លាក់ ។ ការសិក្សាក៏បានរកឃើញផងដែរថាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទជាច្រើននាក់ចង់ ប្រកបរបរនេះជាងរបរដទៃ ប្រសិនបើមិនសូវមានគ្រោះថ្នាក់ ហើយបានទទួលប្រាក់ចំណូល

---

[21] ឧទាហរណ៍ សូមអាន Annuska Derks, ស្ត្រីខ្មែរលើការបោះជំហានទៅមុខ: ការស្វែងយល់ការងារ និងជីវិតនៅជនបទនៃប្រទេសកម្ពុជា សាកលវិទ្យាល័យ Hawaii Press ឆ្នាំ ២០០៨ ទំព័រ ៩៧ ជាដើម

[22] ដូចចំណុចខាងលើ



33 page.indd 23 7/14/2009 8:03:40 AM

ដែលអាចរស់នៅបាន។ **ទោះជាយ៉ាងណាក៏ដោយ នេះពុំមែនជាមូលហេតុមួយសម្រាប់ដកចេញ នូវអ្វីដែលជាឱកាសប្រសើរបំផុតចំពោះពួកគេ ក្នុងការចិញ្ចឹមជីវិតនោះទេ។**

### ខ) ផលប៉ះពាល់ផ្នែកសិទ្ធិមនុស្សមកលើអ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ

***ផលប៉ះពាល់អំពីការគ្មានសិទ្ធិប្រកបការងារ***

ផលប៉ះពាល់ផ្នែកសិទ្ធិមនុស្សអំពីការដកហូតសិទ្ធិប្រកបការងារយ៉ាងមានប្រសិទ្ធិភាពពីបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទមានទំហំធំគួរឱ្យកត់សម្គាល់។ ពួកគេមិនសូវមានលទ្ធភាពប្រកបការងារស្របច្បាប់ដើម្បីទ្រទ្រង់ក្រុមគ្រួសាររបស់ពួកគេឡើយ។

***កាន់តែមានភាពងាយរងគ្រោះចំពោះអំពើហឹង្សាធ្ងន់ធ្ងរ និងគ្មានសិទ្ធិទទួលសេវាសុខភាព***

ផលប៉ះពាល់មួយទៀតនៃច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្សគឺបង្កើនគ្រោះថ្នាក់នៃរបររកស៊ីផ្លូវភេទ។ ការបិទផ្ទះបនធ្វើឱ្យអ្នករកស៊ីផ្លូវភេទចេញទៅប្រកបរបរនៅក្នុងស្ថានភាពដែលកាន់តែមានគ្រោះថ្នាក់បន្ថែមទៀត។ លទ្ធភាពរបស់ពួកគេក្នុងការទទួលបានការបង្ការមេរោគអេដស៍ និងជម្ងឺអេដស៍ និងកម្មវិធីព្យាបាលត្រូវបានកាត់បន្ថយ។

***ការឃាត់ខ្លួនដោយខុសច្បាប់ និងការរំលោភសិទ្ធិមនុស្សនៅក្នុងមន្ទីរឃុំឃាំង***

ទិន្នន័យ និងព័ត៌មានពីប្រភពនានា រាប់ទាំងរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ របាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល ការអង្កេត និងបទសម្ភាសន៍នានាជាមួយអ្នករកស៊ីផ្លូវភេទ បានបង្ហាញថា នៅក្នុងឆមាសទីមួយនៃឆ្នាំ ២០០៨ អ្នករកស៊ីផ្លូវភេទជាច្រើននាក់រងគ្រោះពីការរំលោភបំពានលើសិទ្ធិមនុស្ស បណ្តាលមកពីយុទ្ធនាការបង្ក្រាប និងឃាត់ខ្លួន។

អំពើរំលោភបំពានទាំងនោះ រួមមានៈ

- ការឃុំខ្លួនដោយមិនបានដាក់បន្ទុក និងមិនត្រូវបានចោទប្រកាន់អំពីបទល្មើសណាមួយ និងឃុំខ្លួនដោយគ្មាន កំណត់ពេលវេលា
- ចាំបាច់ត្រូវបង់សំណូក ឬពុំនោះសោតត្រូវផ្តល់ការរួមភេទ ជាថ្នូរនឹងការដោះលែង
- អំពើរំលោភសេពសន្ថវៈ ការវាយដំ ការធ្វើទារុណកម្ម ការទះកំភ្លៀង ការមួលក្តិច ការបង្ខំឱ្យធ្វើការ និងរហូតមានដល់ការស្លាប់ក្នុងពេលឃុំខ្លួន
- បុរស ស្ត្រី និងកុមារត្រូវបានដាក់នៅក្នុងបន្ទប់ឃុំឃាំងតែមួយ

- ស្បៀងអាហារ អនាម័យ សម្លៀកបំពាក់ និងទឹកផឹកមានគុណភាពអន់ជាខ្លាំងក្នុងការទ្រទ្រង់ភាពថ្លៃថ្នូរ និងអាយុជីវិតរបស់មនុស្ស
- អ្នកជាប់ឃុំដែលមានផ្ទុកមេរោគអេដស៍មួយចំនួនមិនបានអនុញ្ញាតឱ្យទទួលឱសថប្រឆាំងនឹងមេរោគអេដស៍ឡើយ

***ការឃាត់ខ្លួននិងការបិទផ្ទះបននៅបន្តអនុវត្ត***

មណ្ឌលស្តារនីតិសម្បទាទាំងពីរនៅក្បែរក្រុងភ្នំពេញ មិនបានប្រើសម្រាប់ឃុំខ្លួនបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទទៀតហើយ។ ប្រព្រឹត្តិកម្មចំពោះបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទដែលត្រូវបានបង្ក្រាប និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទដទៃទៀត ដែលត្រូវបានឃាត់ខ្លួនដោយប៉ូលីសគឺមានភាពមិនជាប់លាប់ទេ។ មានអំណះអំណាងដែលឮតៗគ្នាថាអ្នករកស៊ីផ្លូវភេទមួយចំនួនត្រូវបានឃុំខ្លួនដោយ ប៉ូលីស ឬដោយមន្ត្រីក្រសួងសុខុមាលភាពសង្គមរយៈពេលប៉ុន្មានម៉ោងប៉ុណ្ណោះ ដើម្បី "ធ្វើការអប់រំសារជាថ្មី " រួចបន្ទាប់មកត្រូវបានដោះលែង។ ទោះជាយ៉ាងណាក៏ដោយ អ្នកដទៃទៀតនៅតែបានបន្តឃុំខ្លួនដោយប៉ូលីស ក្នុងរយៈពេលខុសៗគ្នា។ អ្នកខ្លះត្រូវបានបង្ខំឱ្យទៅកាន់មណ្ឌលនានាផ្សេងពីផ្ទះរបស់ពួកគេ ព្រោះថាប៉ូលីសមួយចំនួន មិនចាត់ទុកបន្ទប់ជួល ថាជាផ្ទះរបស់ពួកឡើយ។

## ៦. ផលប៉ះពាល់ដទៃនៃច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស

***ការបន្តមិនយកចិត្តទុកដាក់និងបន្តមាក់ងាយអ្នករកស៊ីផ្លូវភេទ***

ប្រព័ន្ធផ្សព្វផ្សាយបន្តមាក់ងាយអ្នករកស៊ីផ្លូវភេទ នៅពេលដែលរាយការណ៍អំពីការអនុវត្តច្បាប់នេះ ដូចជា នៅថ្ងៃ ទី ៩ ខែ មីនា ឆ្នាំ ២០០៩ កាសែត "កោះសន្តិភាព "បានពណ៌នាអំពីអ្នករកស៊ីផ្លូវភេទដែលត្រូវបានឃាត់ខ្លួនដោយប៉ូលីសប្រៀបបីដូចសត្វធាតុ។ គេត្រូវការជាបន្ទាន់នូវយុទ្ធនាការសកម្មមួយ ដើម្បីបង្កើនការយល់ដឹងអំពីមូលហេតុ នៃការចូលទៅធ្វើជាអ្នករកស៊ីផ្លូវភេទ និងប្រការដែលថាអ្នករកស៊ីផ្លូវភេទជាមនុស្ស ហើយមានសិទ្ធិទទួលស្គាល់ ដូចពលរដ្ឋដទៃទៀតដែរ។

***លើកទឹកចិត្តឱ្យមានការរើសអើងផ្នែកយេនឌ័រ***

ទោះបីជាច្បាប់មានគោលបំណងការពារភាពថ្លៃថ្នូរ និងការពារសិទ្ធិមនុស្សក្តី នៅកន្លែងមួយចំនួន ច្បាប់បានបង្កឱ្យមានការរើសអើងផ្នែកយេនឌ័រ។ ស្ត្រីមួយចំនួនដែលពុំមែនជាអ្នករកស៊ីផ្លូវភេទ ត្រូវបានឃាត់ខ្លួន ដោយសារ



33 page.indd 25 7/14/2009 8:03:40 AM

តែពួកគេមានវត្តមាននៅក្នុងតំបន់ដែលប៉ូលីសកំពុងបើកយុទ្ធនាការបង្ក្រាប[២៣] ។ មន្ត្រីប៉ូលីសជាន់ខ្ពស់នៅភ្នំពេញត្រូវបាន ដកស្រង់សំដីដែលនិយាយថាស្ត្រី "ធម្មតា "មិនគប្បីចេញក្រៅផ្ទះនៅពេលយប់តែម្នាក់ឯងនោះទេ[២៤] ។ ជាមួយគ្នានេះក៏ មានភស្តុតាងផងដែរថា ក្រុមបុរសស្រលាញ់បុរសសក់វែងដែលរកស៊ីផ្លូវភេទបានទទួលរងគ្រោះពីការរើសអើងបន្ថែម ទៀតដោយសារច្បាប់នេះ[២៥] ។

### ***មិនបន្ថយចំនួនអ្នករកស៊ីផ្លូវភេទឡើយ***

ការស្រាវជ្រាវបានបង្ហាញថាច្បាប់ដូចគ្នានេះនៅក្នុងបណ្តាប្រទេសដទៃរាប់ទាំងនៅតំបន់អាស៊ីមិនអាចកាត់បន្ថយចំនួនអ្នករកស៊ីផ្លូវភេទបានឡើយ ។ ជាទូទៅ ការបដិសេធសិទ្ធិក្នុងការប្រកបការងារបណ្តាលឱ្យការងារនេះទៅជាលាក់កំបាំងហើយ បង្កើនគ្រោះថ្នាក់នៃការធ្វើអាជីវកម្ម និងអំពើហឹង្សា ។

## ៧. ភាពស៊ីសង្វាក់ជាមួយច្បាប់អន្តរជាតិ

ទិដ្ឋភាពមួយចំនួននៃច្បាប់នេះមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយលិខិតូបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្សដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័ន និងស៊ីសង្វាក់គ្នាជាមួយសេចក្តីណែនាំអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងអំពើជួញដូរមនុស្ស ។ បញ្ហាជាគន្លឹះរួមមានៈ

### ***សិទ្ធិមានសេរីភាព និងមានសន្តិសុខបុគ្គល***

- មាត្រា ២៥ នៃច្បាប់ស្តីពីអំពើជួញដូរមនុស្សៈ

មាត្រា ២៥ បើកចំហចំពោះការបកស្រាយដែលមានលក្ខណៈទូទៅច្រើនហួស ហេតុនេះការអនុវត្តន៏មាត្រានេះនឹងជួបការលំបាកក្នុងការព្យាករណ៍ឱ្យមានភាពប្រាកដប្រជាហើយមាត្រានេះមុខជាបើកឱ្យមានការអនុវត្តន៏ដែលប្រែប្រួល មិនអាចប៉ាន់ប្រមាណជាមុនបាន ហើយនាំទៅដល់ការឃាត់ខ្លួន និងឃុំខ្លួនតាមទំនើងចិត្ត ។

---

[23] ប្រជាពលរដ្ឋភ័យខ្លាចចំពោះការល្បាតប្រឆាំងពេស្យាចារ ដោយ មុំ គន្ធា និងឆាយ ចាន់នីដា ភ្នំពេញប៉ុស្តិ៍ ថ្ងៃ សុក្រ ទី ៣ ខែ មេសា ឆ្នាំ ២០០៩ គេហទំព័រ E:\Trafficking law\report\summary report\ppp articles\The Phnom Penh Post - Residents fear vice patrols.mht

[24] "ប្រជាពលរដ្ឋភ័យខ្លាចចំពោះយុទ្ធនាការបង្ក្រាបពេស្យាចារ "យោងប្រភពទើបបានបញ្ជាក់ខាងលើ កំណត់សម្គាល់ទី ២៣

[25] Michael Hansen "លិខិតផ្ញើជូននិពន្ធនាយក " កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃ ទី ៩ ខែ មេសា ឆ្នាំ ២០០៩ ទំព័រ ៦



33 page.indd 26 7/14/2009 8:03:40 AM

- មាត្រា ២៤ ស្តីពីអំពើអូសទាញ នៃច្បាប់ស្តីពីអំពើជួញដូរមនុស្ស៖
  ការឃាត់ខ្លួនតាមអំពើចិត្តបានកើតឡើង ដោយសារកង្វះនិយមន័យអំពីអំពើអូសទាញជាសាធារណៈ

***អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី***

- **មាត្រា ៦ នៃអនុសញ្ញា CEDAW – និងមតិទូទៅលេខ ១៩**

*មាត្រា ៦ នៃអនុសញ្ញា CEDAW ចែងថា៖ ភាគីរដ្ឋត្រូវចាត់វិធានការសមស្រប រាប់ទាំងវិធានការផ្លូវច្បាប់ផងដែរ ដើម្បីបង្ក្រាបរាល់ទម្រង់នៃអំពើជួញដូរស្ត្រី និងការធ្វើអាជីវកម្មពេស្យាចារចំពោះស្ត្រី ។*[មានការបញ្ជាក់បន្ថែម]

មតិទូទៅលេខ ១៩ (១៥)៖ សំដៅដល់មាត្រា ៦ នៃអនុសញ្ញា CEDAW ៖ *ពេស្យាជនងាយរងគ្រោះជាពិសេសពីអំពើហិង្សា ដោយសារស្ថានភាពរបស់ពួកគេ ដែលអាចមានលក្ខណៈមិនស្របច្បាប់ ទំនងជាគ្មានការយកចិត្តទុកដាក់ចំពោះពួកគេ ។ ពួកគេត្រូវការឱ្យច្បាប់ការពារដូចគ្នាប្រឆាំងអំពើរំលោភសេពសន្ថវៈ និងប្រឆាំងនឹងទម្រង់ដទៃទៀតនៃអំពើហិង្សា ។*

ច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្សកំពុងរួមចំណែកដល់ការផ្លាស់ប្តូរសេវាផ្លូវភេទដែលមានមូលដ្ឋាននៅតាមផ្ទះបន ទៅកាន់សេវាផ្លូវភេទដែលមានលក្ខណៈឯករាជ្យម្ចាស់ការ លាក់លៀម និងការងារដែលកាន់តែមានគ្រោះថ្នាក់។ ហេតុនេះ គេអាចមើលឃើញថាច្បាប់នេះមិនអនុលោមទាំងស្រុងតាមស្មារតីនៃអនុសាសន៍ទូទៅលេខ ១៩ (១៥) នៃអនុសញ្ញា CEDAW ឡើយ ព្រោះថាការខ្វះចន្លោះនៃច្បាប់នេះជម្រុញឱ្យអ្នករកស៊ីផ្លូវភេទធ្លាក់ក្នុងស្ថានភាពផ្សេងៗ ដែលពួកគេ ងាយមានភាពរងគ្រោះជាខ្លាំងចំពោះអំពើហិង្សាលើមូលដ្ឋានយែនឌ័រ។ អាស្រ័យហេតុនេះ មានវិធីបកស្រាយមាត្រា ៦ មួយចំនួននៃអនុសញ្ញា CEDAW ដែលមិនតម្រូវឱ្យចាត់ទុកជាអំពើឧក្រិដ្ឋ (ឬការចាត់ ជាអំពើឧក្រិដ្ឋដែលមាន ប្រសិទ្ធភាព) ចំពោះរបររកស៊ីផ្លូវភេទទេ។

***ការិយាល័យអង្គការសហប្រជាជាតិនៃស្នងការជាន់ខ្ពស់សម្រាប់គោលការណ៍ស្តីពីសិទ្ធិមនុស្ស និងសេចក្តីណែនាំស្តីពីសិទ្ធិមនុស្ស និងអំពើជួញដូរមនុស្ស***

សេចក្តីណែនាំ និងគោលការណ៍នានាដែលចេញដោយការិយាល័យសហប្រជាជាតិនៃស្នងការជាន់ខ្ពស់ផ្នែកសិទ្ធិមនុស្សនៅឆ្នាំ ២០០២ បង្កើតបានជាការណែនាំដែលមានចរិតអាជ្ញាចំពោះអ្វីដែលពិធីសារ Palermo តម្រូវឱ្យការពារសិទ្ធិរបស់ជនរងគ្រោះពីអំពើជួញដូរ ( មាត្រា ២ នៃពិធីសារ Palermo ) ។



33 page.indd 27 7/14/2009 8:03:41 AM

**គោលការណ៍ទី ៣.** វិធានការប្រឆាំងអំពើជួញដូរមនុស្សមិនត្រូវធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានចំពោះសិទ្ធិមនុស្ស និងភាពថ្លៃថ្នូររបស់បុគ្គលឡើយ *ពិសេសសិទ្ធិរបស់អ្នកដែលត្រូវបានគេជួញដូរ និងសិទ្ធិរបស់ពលករចំណាកស្រុក ជនបម្លាស់ទី ក្នុងស្រុក ជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន ។*[មានការបញ្ជាក់បន្ថែម]

ដូចបានបង្ហាញពីខាងលើ តាមពិតទៅកង្វះចន្លោះនៃច្បាប់ស្តីពីអំពើជួញដូរបានប៉ះពាល់ទៅលើគោលការណ៍ ស្តីពីសិទ្ធិមនុស្ស ហើយបានធ្វើឱ្យមានអំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំពោះអ្នកព្រមព្រៀងរកស៊ីផ្លូវភេទដែលជានីតិជន និងរំលោភចំពោះសិទ្ធិដទៃទៀត របស់ជនរងគ្រោះពីអំពើជួញដូរ ប្រសិនបើត្រូវកំណត់សិទ្ធិទាំងនោះ ។

សេចក្តីណែនាំលេខ ៣ (១) របស់សហប្រជាជាតិតម្រូវឱ្យរដ្ឋនានាអនុមតិ និងអនុវត្តជាប្រចាំនូវ ” *និយមន័យដែលបានឯកភាពគ្នាអំពីអំពើជួញដូរមនុស្សដែលមានចែងនៅក្នុងពិធីសារ Palermo* ”។ ដូចបានពិភាក្សាខាងលើ ច្បាប់ស្តីពីអំពើជួញដូរមិនបានអនុមតិយក ឬអនុវត្តជាប្រចាំទៅតាមនិយមន័យរបស់វាទេ ។

សេចក្តីណែនាំលេខ ៥ របស់សហប្រជាជាតិឆ្លើយតបនឹងការធានាឱ្យមានការអនុវត្តន៍ច្បាប់ឱ្យបានគ្រប់គ្រាន់ ។ សេចក្តីណែនាំទី ៥(៥)ចែងថា វិធីមួយសម្រាប់បំពេញការងារនេះគឺតាមរយៈ ***ការធានាឱ្យអ្នកជួញដូរស្ថិតនៅ និងនៅតែជាចំណុចផ្តោតការយកចិត្តទុកដាក់ចំពោះយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស*** *ហើយកិច្ចប្រឹងប្រែងអនុវត្តច្បាប់ មិនធ្វើឱ្យអ្នកដែលដែលត្រូវបានគេជួញដូរស្ថិតក្នុងគ្រោះថ្នាក់នៃការរងទោសទណ្ឌចំពោះបទល្មើសដែលបានប្រព្រឹត្តបណ្តាលមកពីផលវិបាកនៃស្ថានភាពរបស់ពួកគេទាំងនោះឡើយ ។*[មានការបញ្ជាក់បន្ថែម]

បញ្ហាចំបងមួយនៃបញ្ហាចំបងនានាពីច្បាប់ស្តីពីអំពើជួញដូរមនុស្សគឺថាច្បាប់នេះមិនបែងចែកឱ្យដាច់ចេញពីគ្នារវាងការងាររកស៊ីផ្លូវភេទដែលជាការព្រមព្រៀងរបស់នីតិជន និងអំពើជួញដូរមនុស្ស ប៉ុន្តែមានប្រព្រឹត្តិកម្មចំពោះបាតុភូតទាំងពីរនេះហាក់បីដូចជាបាតុភូតដូចគ្នា ។ មាត្រា ២៤ ដាក់ទោសទណ្ឌអ្នករកស៊ីផ្លូវភេទ ប៉ុន្តែមិនបានដាក់ទោសទណ្ឌចំពោះអ្នកជួញដូរឡើយ ។ មាត្រា ២៥-២៧ ផ្តោតលើការដាក់ទោសទណ្ឌចំពោះសញ្ចារកម្មពេស្យាចារ ។ ហេតុនេះច្បាប់ស្តីពីអំពើជួញដូរមនុស្សមិនបានផ្តោតតែមួយមុខគត់ (ឬមិនផ្តោតជាសំខាន់) លើអ្នកជួញដូរមនុស្សឡើយ ។



33 page.indd 28 7/14/2009 8:03:41 AM

## ៨. អនុសាសន៍

ដូចបានបញ្ជាក់នៅក្នុងសេចក្តីផ្តើមនៃរបាយការណ៍នេះ ជំហានវិជ្ជមាននានាត្រូវបានប្រកាន់យករួចហើយ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមួយចំនួននៃច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស និងដើម្បីលើកកំពស់ បរិយាកាសអំណោយផលសំដៅឱ្យមានសិទ្ធិទទួលបានសេវាជាសកល។ អនុសាសន៍ខាងក្រោមនេះ បានរៀបចំដោយឈរលើមូលដ្ឋាននៃគំនិតផ្តួចផ្តើមទាំងនេះ។

ការស្រាវជ្រាវបង្ហាញថាវិធីដែលមានប្រសិទ្ធិភាពបំផុតដើម្បីបង្កើត និងអនុវត្តគោលនយោបាយស្តីពីក្រុម ដែលគេមិនបានយកចិត្តទុកដាក់ ដូចជាអ្នករកស៊ីផ្លូវភេទ និងអ្នកផ្ទុកមេរោគអេដស៍ គឺតាមរយៈ**វិធីសាស្រ្តដែលផ្អែកលើសិទ្ធិ**។ គេឃើញមានការបកស្រាយជាច្រើនអំពីវិធីសាស្រ្តដែលមានមូលដ្ឋានផ្អែកលើសិទ្ធិ ប៉ុន្តែវិធី នោះអាចសង្ខេបថា គ្រាន់តែជាវិធីសាស្រ្តដែល**ទទួលស្គាល់ក្រុមគោលដៅថាជាអ្នក ឬភ្នាក់ងារមានសិទ្ធិសកម្ម ជាជាងជាអ្នកទទួលជំនួយឧបត្ថម្ភដែលមានលក្ខណៈអកម្ម**។

បទពិសោធន៍នៃអ្នកដែលធ្វើការជាមួយក្រុមពលរដ្ឋងាយរងគ្រោះបង្ហាញថា ចាំបាច់ត្រូវមានវិធានការពិសេសដើម្បីពង្រឹងក្រុមដែលគេមិនបានយកចិត្តទុកដាក់ ហើយធ្វើយ៉ាងណាឱ្យពួកគេដើរតួសំខាន់ក្នុងការបង្កើត និងអនុវត្តគោលនយោបាយដែលពាក់ព័ន្ធដល់ពួកគេ[២៦]។ ដោយសារ ជាទូទៅពួកគេមិនសូវមានអំណាចដូចភាគីពាក់ព័ន្ធដទៃ ហើយរងការរើសអើង និងការមាក់ងាយ ចាំបាច់ត្រូវមានការបញ្ជាក់ច្បាស់លាស់អំពីការកសាងសម្លេងរួមគ្នា ក្នុងចំណោមក្រុមដែលគេមិនបានយកចិត្តទុកដាក់។

### ក) វិធីសាស្រ្តដែលមានមូលដ្ឋានផ្អែកលើសិទ្ធិទទួលកម្មវិធីប្រើស្រោមអនាម័យ ១០០%

នៅខែកក្កដា ឆ្នាំ ២០០៨ មណ្ឌលស្វែងរកការគាំទ្រឱ្យមានការកាត់បន្ថយការមាក់ងាយនិងការមិនយកយកចិត្តទុកដាក់ (CASAM) បានបោះផ្សាយនូវសេចក្តីណែនាំសម្រាប់ពង្រឹងសមត្ថភាពអ្នករកស៊ីផ្លូវភេទ និងជម្រើសដទៃចំពោះកម្មវិធីប្រើស្រោម អនាម័យ ១០០%។ សេចក្តីណែនាំទាំងនោះមានមូលដ្ឋានផ្អែកលើការស្រាវជ្រាវកម្មវិធីប្រើ

[26] Jennifer Chapman ក្នុងកិច្ចសហការ និងកិច្ចពិភាក្សាជាមួយ Valerie Miller, Adriano Campolina Soares និង Valerie Miller, Adriano Campolina Soares ក្នុងស្នាដៃស្តីពី “ការអភិវឌ្ឍលើមូលដ្ឋាននៃសិទ្ធិ បញ្ហាប្រឈមនៃការផ្លាស់ប្តូរ និងអំណាច,”ក្រុមស្រាវជ្រាវភាពក្រីក្រពិភពលោក ឆ្នាំ ២០០៥ គេហទំព័រ http://www.gprg.org/pubs/workingpapers/pdfs/gprg-wps-027.pdf ទំព័រ ៥

ស្រោមអនាម័យ ១០០% នៅតាមបណ្តាប្រទេសជាច្រើននៅតំបន់អាស៊ី រាប់ទាំងប្រទេសកម្ពុជា និងប្រទេសសៀម ផងដែរ។ សេចក្តីណែនាំទាំងនោះផ្តល់អនុសាសន៍ថាដើម្បីឱ្យមានប្រសិទ្ធភាពការពង្រឹងកម្មវិធីប្រើប្រាស់ស្រោមអនាម័យដែលផ្អែកលើ សិទ្ធិក្នុងចំណោមអ្នករកស៊ីផ្លូវភេទ ត្រូវមានមូលដ្ឋានជាគោលការណ៍បីយ៉ាង[២៧] :

*ក.១. ការចូលរួមរបស់អ្នករកស៊ីផ្លូវភេទ និងភាពជាអ្នកដឹកនាំនៅក្នុងរាល់ទិដ្ឋភាពជាទម្រង់ និងការអនុវត្តន៍កម្មវិធី*

*ក.២. ជម្រុញឱ្យមានសញ្ញាណសហគមន៍ក្នុងចំណោមអ្នករកស៊ីផ្លូវភេទ ដើម្បីសម្រួលសកម្មភាពដែលមានលក្ខណៈសហការ*

*ក.៣. លុបបំបាត់ការមាក់ងាយ និងការរើសអើងប្រឆាំងអ្នករកស៊ីផ្លូវភេទ*

កម្មវិធីប្រើស្រោមអនាម័យ ១០០%បង្ហាញនូវការប្តេជ្ញាចិត្តមោះមុតរបស់រាជរដ្ឋាភិបាលក្នុងការលុបបំបាត់ មេរោគអេដស៍ ក៏ដូចជាការប្តេជ្ញារបស់រាជរដ្ឋាភិបាលក្នុងការការពារអ្នករកស៊ីផ្លូវភេទប្រឆាំងនឹងមេរោគអេដស៍ផងដែរ។ ការស្រាវជ្រាវបង្ហាញថា រហូតមកដល់ពេលនេះកម្មវិធីនេះមានទិដ្ឋភាពវិជ្ជមានជាច្រើន។ ឧទាហរណ៍ អង្កេតនេះបាន រកឃើញថាស្ត្រីរកស៊ីផ្លូវភេទ និងស្ត្រីបម្រើសេវាកំសាន្តភាគច្រើនបាននិយាយថាបុគ្គលិមណ្ឌលថែទាំ និងព្យាបាលជម្ងឺកាមរោគ និងមណ្ឌលធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់មានលក្ខណៈស្និទ្ធស្នាល ទោះបីជាបទពិសោធន៍របស់អ្នករកស៊ីផ្លូវភេទជាក្រុមស្រីស្រស់ និងក្រុមបុរសស្រលាញ់បុរសថាពុំសូវល្អក្តី។ ប្រការនេះបង្ហាញឱ្យឃើញការកែលំអរយ៉ាងច្រើន ចាប់តាំងពីឆ្នាំ ២០០៣មក នៅពេលដែលគេបានរកឃើញថាអ្នករកស៊ីផ្លូវភេទជាច្រើនបានជួបប្រទះភាពទ្រគោះបោះបោក និងគ្រោតគ្រាតនៅតាមគ្លីនិកក្តី[២៨] ។

បញ្ហាមួយនៃកង្វល់របស់អ្នករកស៊ីផ្លូវភេទគឺការចូលរួមរបស់ប៉ូលីសក្នុងការតាមដាន និងអនុវត្តកម្មវិធីប្រើស្រោមអនាម័យ ១០០%។ លើមូលដ្ឋាននៃការដាក់កំហិតសិទ្ធិរបស់អ្នករកស៊ីផ្លូវភេទ នៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស និងមុខងាររបស់ប៉ូលីសក្នុងការអនុវត្តន៍ច្បាប់នោះ គេកាន់តែមានមូលហេតុដែលនាំដល់ការព្រួយបារម្ភបន្ថែមទៀត។ ផែនការយុទ្ធសាស្ត្រថ្មីរបស់ក្រសួងមហាផ្ទៃគួរបញ្ជាក់អំពីការតាមដានសហគមន៍។ សង្ឃឹមថាប្រការនេះ

---

27 គោលការណ៍ណែនាំដើម្បីពង្រឹងអ្នករកស៊ីផ្លូវភេទលើមូលដ្ឋាននៃសិទ្ធិ: វិធីសាស្ត្រអន្តរាគមន៍បែបផ្សេងចំពោះមេរោគអេដស៍/ជម្ងឺអេដស៍ចំពោះកម្មវិធីប្រើស្រោមអនាម័យ ១០០% CASAM ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៥

28 សូមអានរបាយការណ៍របស់ David Lowe "ទស្សនៈនៃកម្មវិធីប្រើស្រោមអនាម័យ ១០០%នៅកម្ពុជា: ការចងក្រងឯកសារស្តីពីបទពិសោធន៍របស់អ្នករកស៊ីផ្លូវភេទ" ចំពោះគម្រោង Policy Project ខែ មីនា ឆ្នាំ ២០០៣

នឹងជួយកាត់បន្ថយបញ្ហា តាមរយៈការលើកទឹកចិត្តចំពោះប៉ូលីសឱ្យដើរតួជាអ្នកបង្កលក្ខណៈងាយស្រួលដល់សហគមន៍។ យើងទទួលស្គាល់តម្រូវការឱ្យបន្តចាត់វិធានការហ្មត់ចត់ក្នុងការប្រយុទ្ធប្រឆាំងមេរោគអេដស៍។ ផ្អែកលើ របកគំហើញទាំងឡាយនៃការស្រាវជ្រាវនេះ រាប់ទាំងការពណ៌នាអំពីបទពិសោធន៍នៅបណ្តាប្រទេសនានាផងដែរ យើងសូមលើកសំណើដូចខាងក្រោម សម្រាប់ដំណាក់បន្ទាប់នៃកម្មវិធីប្រើប្រាស់ស្រោមអនាម័យរបស់រាជរដ្ឋាភិបាលៈ

- សម្រួលការចូលរួមរបស់អ្នករកស៊ីផ្លូវភេទទៅក្នុងក្រុមការងារបច្ចេកទេសរួមគ្នារវាងរដ្ឋាភិបាល និងម្ចាស់ជំនួយ ស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍
- តាមរយៈក្រសួងមហាផ្ទៃ ផ្តួចផ្តើមបង្កើតកម្មវិធីភាពជាដៃគូរវាងប៉ូលីសនិងសហគមន៍ និងកម្មវិធីទំនាក់ទំនង ដើម្បីធានាឱ្យមានបរិយាកាសប្រកបដោយសុវត្ថិភាព គ្មានការបៀតបៀនក្នុងការផ្តល់សេវាប្រឆាំងមេរោគអេដស៍ ចំពោះប្រជាជនប្រឈមមុខនឹងគ្រោះថ្នាក់ខ្លាំង រាប់ទាំងអ្នករកស៊ីផ្លូវភេទ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ព្រមទាំងធានាឱ្យមានការតាមដាន និងតាមពិនិត្យផងដែរ។ ការចូលរួមប្រកបដោយខ្លឹមសាររបស់អ្នករកស៊ីផ្លូវភេទនៅក្នុងកិច្ច ប្រឹងប្រែងថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក-ខ័ណ្ឌ និងថ្នាក់ឃុំ-សង្កាត់ក្នុងការបង្កើត និងអនុវត្តកម្មវិធីប្រឆាំងមេរោគអេដស៍ ក្នុងចំណោមអ្នករកស៊ីផ្លូវភេទ។
- គាំទ្រកិច្ចពិភាក្សារវាងអ្នករកស៊ីផ្លូវភេទ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយជាមួយសមាជិក សមាជិការដ្ឋសភាតាមរយៈគណៈកម្មការទី ៦ និងទី ៨។
- ការគាំទ្ររបស់អន្តរក្រសួងចំពោះអ្នកទាំងឡាយណាដែលមានបំណងយកស្រោមអនាម័យតាមខ្លួន ឱ្យពួកគេអាចធ្វើបែបនេះបានដោយគ្មានការគម្រាមកំហែងចំពោះការឃាត់ខ្លួន ការជម្រិត ឬការបៀតបៀនពីសំណាក់មន្ត្រីមានសមត្ថកិច្ចឡើយ
- ការគាំទ្ររបស់អន្តរក្រសួងចំពោះការជម្រុញ និងការលក់ស្រោមអនាម័យដោយតម្លៃថោក និងការផ្តល់ព័ត៌មានអំពីការបង្ការមេរោគអេដស៍នៅក្នុងគ្រឹះស្ថានផ្តល់សេវាកំសាន្តសប្បាយ (ដូចជាហាងខារ៉ាអូខេ បៀហ្គាដិន កន្លែងម៉ាស្សា ជាដើម) និងសណ្ឋាគារ ឬផ្ទះសំណាក់ ដោយគ្មានការគម្រាមកំហែងចំពោះការឃាត់ខ្លួន ការជម្រិត ឬការបៀតបៀនពីសំណាក់មន្ត្រីមានសមត្ថកិច្ចឡើយ។
- ធ្វើការជាមួយក្រុមអ្នករកស៊ីផ្លូវភេទ ដើម្បីពង្រឹងសមត្ថភាពពួកគេសំដៅលើកទឹកចិត្តឱ្យប្រើស្រោមអនាម័យ និងត្រួតពិនិត្យសុខភាព។ ធ្វើការដើម្បីធានាឱ្យមានការដាក់លក់ស្រោមអនាម័យដោយតម្លៃថោកដោយគ្មានការភ័យខ្លាចអំពីការដាក់ទោសទណ្ឌចំពោះការយកស្រោមអនាម័យតាមខ្លួន ឬចំពោះការទិញស្រោមអនាម័យ។

- ផ្តល់ ឬគាំទ្រការកសាងសមត្ថភាពចំពោះអាជ្ញាធរពាក់ព័ន្ធ និងចំពោះអ្នករកស៊ីផ្លូវភេទក្នុងការកសាងយុទ្ធសាស្រ្តថ្មីស្តីពីការប្រាស្រ័យទាក់ទងអំពីការផ្លាស់ប្តូរការប្រព្រឹត្តិ ដែលរួមបញ្ចូលវិធីសាស្រ្តដែលមានមូលដ្ឋានផ្អែកលើសិទ្ធិផងដែរ ។
- ជម្រុញវិធីសាស្រ្តតាមដានសហគមន៍ដែលចាត់ទុកអ្នករកស៊ីផ្លូវភេទថាជាដៃគូនៅសហគមន៍ ហើយមិនចាត់ទុកពួកគេថាជាឧក្រិដ្ឋជនឡើយ
- បណ្តុះបណ្តាលមន្រ្តីពាក់ព័ន្ធអំពីវិធីសាស្រ្តនានាដែលមានមូលដ្ឋានផ្អែកលើសិទ្ធិ រាប់ទាំងប៉ូលីសផងដែរដោយរួមបញ្ចូលនូវវិគ្គនានាដែលអ្នករកស៊ីផ្លូវភេទអាចមានលទ្ធភាពសម្តែងទស្សនៈរបស់ពួកគេផងដែរ
- ធ្វើការជាមួយអ្នករកស៊ីផ្លូវភេទដើម្បីបង្កើតវិធីសាស្រ្តនានាដែលមានតុល្យភាព ហើយពង្រឹងសមត្ថភាពអ្នករកស៊ីផ្លូវភេទក្នុងការធានាឱ្យភ្ញៀវ និងដៃគូរួមភេទដទៃទៀតប្រើស្រោមអនាម័យ ព្រមទាំងលើកទឹកចិត្តឱ្យដៃគូរួមភេទប្រើស្រោមអនាម័យ ។
- ជ្រើសរើសអ្នករកស៊ីផ្លូវភេទប្រយោល (បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ)ឱ្យធ្វើការផ្សព្វផ្សាយដល់មិត្តភក្តិរបស់ខ្លួន ព្រមទាំង ជម្រុញឱ្យមានសាមគ្គីភាពក្នុងចំណោមអ្នករកស៊ីផ្លូវភេទ តាមរយៈការកាត់បន្ថយនូវការមាក់ងាយ ។
- ធ្វើយុទ្ធនាការប្រឆាំងនឹងការរើសអើង និងការមាក់ងាយចំពោះអ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយទាំងឡាយ រាប់ទាំងក្រុមស្រីស្រស់ និងក្រុមបុរសស្រលាញ់បុរស ដែលជាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងជាអ្នករកស៊ីផ្លូវភេទ រួមទាំងប្រព័ន្ធផ្សព្វផ្សាយផងដែរ ។
- ប្រើប្រាស់យន្តការដែលមានស្រាប់ ដូចជាក្រុមការងារបច្ចេកទេសផ្សព្វផ្សាយ មិត្តអប់រំមិត្ត និងប្រើប្រាស់ស្រោមអនាម័យ ហើយក្រុមស្នូលនៃអ្នករកស៊ីផ្លូវភេទអាចបើកវេទិកាសម្រាប់ពិភាក្សាជាមួយរដ្ឋាភិបាល និងអង្គការមិនមែន រដ្ឋាភិបាល ដើម្បីរៀបចំចក្ខុវិស័យថ្មីមួយសម្រាប់ពង្រឹងសមត្ថភាពអ្នករកស៊ីផ្លូវភេទ ហើយបើអាចធ្វើបាន គប្បីជ្រើសរើសអ្នករកស៊ីផ្លូវភេទឱ្យធ្វើការជាបុគ្គលិកផ្សព្វផ្សាយ និងមិត្តអប់រំមិត្ត ។
- ក៏ដូចជាការកាត់បន្ថយអត្រាឆ្លង សូចនាករនៃភាពជោគជ័យនៃកម្មវិធីប្រើស្រោមអនាម័យ ១00% គប្បីរួមបញ្ចូលនូវការកាត់បន្ថយភាពរើសអើង និងអំពើហឹង្សាប្រឆាំងអ្នករកស៊ីផ្លូវភេទ អាកប្បកិរិយារបស់បុគ្គលិកសុខាភិបាល កម្រិតនៃការចូលរួមប្រកបដោយខ្លឹមសារនៃអ្នករកស៊ីផ្លូវភេទនៅគ្រប់កម្រិតនៃកម្មវិធី ការលើកកំពស់កិច្ចសហការ និងការយល់ដឹងរវាងប៉ូលីស និងអ្នករកស៊ីផ្លូវភេទ ។



33 page.indd 32 7/14/2009 8:03:42 AM

**ខ) វិធីសាស្ត្រដទៃចំពោះការប្រយុទ្ធនឹងអំពើជួញដូរ និងអំពើធ្វើអាជីវកម្មផ្លូវភេទ**

វិធីសាស្ត្រដែលផ្អែកលើសិទ្ធិក៏អាចជាវិធីមួយដែលមានប្រសិទ្ធិភាពក្នុងការប្រយុទ្ធនឹងអំពើជួញដូរមនុស្សផងដែរ។ ការស្រាវជ្រាវនៅប្រទេសឥណ្ឌា និងបទពិសោធន៍នានារបស់អ្នករកស៊ីផ្លូវភេទនៅកម្ពុជាបង្ហាញថាមូលហេតុនៃអំពើជួញដូរ និងអំពើធ្វើអាជីវកម្មគឺបណ្តាលមកពីវិសមភាព (វណ្ណៈ និងយែនឌ័រ លទ្ធភាពមិនដូចគ្នា ក្នុងការទទួលព័ត៌មាន និងលទ្ធភាពមិនដូចគ្នាអំពីជំនាញ) និងការបាត់សិទ្ធិ (គ្មានសិទ្ធិអំពីពលកម្មនៅក្នុងទម្រង់ការងារមួយចំនួន)[២៩]។

យើងសូមលើកសំណើដោយគោរពចំពោះអាជ្ញាធរជាតិប្រយុទ្ធនឹងអំពើជួញដូរមនុស្សនៅកម្ពុជា ក្នុងការពិចារណាលើការប្រកាន់យកនូវ**វិធីសាស្ត្រឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងការប្រយុទ្ធនឹងអំពើជួញដូរមនុស្ស** ដែលផ្តោតជាសំខាន់លើសិទ្ធិ និងការលើកកម្ពស់សិទ្ធិក្នុងក្រុមដែលមិនសូវបានយកចិត្តទុកដាក់ រាប់ទាំងអ្នកដែលត្រូវគេជួញដូរផងដែរ (ចំពោះរាល់ទម្រង់ទាំងអស់នៃពលកម្ម ស្ទុំកូន ជាដើម) និងនីតិជនដែលព្រមព្រៀងធ្វើជាអ្នករកស៊ីផ្លូវភេទ។

ឧទាហរណ៍ស្តីពី Durbar នៅទីក្រុងកាល់គុតតា (Calcutta) នៃប្រទេសឥណ្ឌា បានបង្ហាញថាអ្នករកស៊ីផ្លូវភេទដែលដឹកនាំ និងគ្រប់គ្រងកម្មវិធីអាចដើរតួកាន់តែមានប្រសិទ្ធភាពក្នុងការប្រយុទ្ធនឹងអំពើជួញដូរ និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទៅលើអនីតិជនបានកាន់តែប្រសើរជាងវិធីសាស្ត្រអនុវត្តច្បាប់។ នៅក្នុងកម្មវិធី Durbar អ្នករកស៊ីផ្លូវភេទបានបង្កើតអង្គភាព និយ័តកម្មដោយខ្លួនឯងនៅថ្នាក់ស្រុក ហើយក៏រួមបញ្ចូលតំណាងអាជ្ញាធរមូលដ្ឋានផងដែរ។ ពួកគេមានបំណងធ្វើឱ្យ គ្រឹះស្ថាននានាដែលលក់សេវាផ្លូវភេទ មិនអាចជ្រើសរើស ឬមិនអនុញ្ញាតឱ្យមានការជ្រើសរើសអនីតិជន ឬអ្នករកស៊ីផ្លូវភេទដែលមិន ស្ម័គ្រចិត្តឱ្យបម្រើការនៅទីនោះឡើយ។ ការងារនេះបានធ្វើឱ្យអត្រានៃអ្នករកស៊ីផ្លូវភេទដែលស្ថិតក្នុងអនីតិភាព នៅក្នុងតំបន់ គោលដៅនានាធ្លាក់ចុះពី ២៥,៣% មកត្រឹម ៣,១%[៣០]។ ល័ក្ខខ័ណ្ឌការងាររបស់អ្នករកស៊ីផ្លូវភេទក៏បានទទួលការគាំទ្រ ហើយអ្នករកស៊ីផ្លូវភេទក៏បានទទួលការជួយរំដោះចេញពីស្ថានភាពដែលពួកគេត្រូវបានម្ចាស់បន និងភ្នាក់ងារបនទុច្ចរិតធ្វើអាជីវកម្ម។

**បុរេល័ក្ខខ័ណ្ឌចំបងមួយសម្រាប់ប្រយុទ្ធនឹងអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទគឺការទទួលស្គាល់សិទ្ធិប្រកបការងាររបស់នីតិជនដែលព្រមព្រៀងធ្វើជាអ្នករកស៊ីផ្លូវភេទ។** តាមរយៈការអនុវត្តន៍វិធីសាស្ត្រដែលមានមូល

---

[29] ឯកសារដូចបានពណ៌នាខាងលើរបស់ Nandinee Bandyopadhyay កំណត់សម្គាល់លេខ ១ ទំព័រ ៦

[30] ឯកសារដូចបានពណ៌នាខាងលើរបស់ Nandinee Bandyopadhyay កំណត់សម្គាល់លេខ ១ ទំព័រ ១៦-១៧



33 page.indd 33 7/14/2009 8:03:42 AM

ដ្ឋានផ្អែកលើសិទ្ធិជាថ្មីម្តងទៀត ប្រទេសកម្ពុជានឹងក្លាយទៅជាប្រទេស ឈានមុខក្នុងតំបន់ ក្នុងការប្រយុទ្ធនឹងអំពើជួញដូរមនុស្ស។ វិធីសាស្ត្រនេះក៏ជួយជម្រុញភាពថ្លៃថ្នូរ សុខុមាលភាព និងសុខភាពរបស់អ្នករកស៊ីផ្លូវភេទផងដែរ។ ហេតុនេះ យើងសូមលើកសំណើដូចខាងក្រោមសម្រាប់ដាក់ជូនរាជរដ្ឋាភិបាល កម្ពុជាពិចារណា ដើម្បីប្រយុទ្ធនឹងអំពើជួញដូរនៅក្នុងឧស្សាហកម្មផ្លូវភេទ។

- ជម្រុញការពិគ្រោះយោបល់រវាងតំណាងអ្នករកស៊ីផ្លូវភេទ ជាមួយគណៈកម្មការធិការប្រឆាំងអំពើជួញដូរមនុស្សនៅគ្រប់កម្រិត។ ពិចារណាអំពីការបង្កើតគណៈកម្មាធិការជាតិដែលប្រមូលអ្នករកស៊ីផ្លូវភេទ ឬអ្នកតំណាងរបស់ពួកគេដែលត្រូវបានចាត់តាំង អ្នកដែលត្រូវបានជួញដូរ ឬអ្នកតំណាងរបស់ពួកគេដែលត្រូវបានចាត់តាំង។
- គាំទ្រកិច្ចពិភាក្សារវាងអ្នករកស៊ីផ្លូវភេទ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយជាមួយសមាជិក សមាជិការដ្ឋសភាតាមរយៈគណៈកម្មការទី ៦ និងទី ៨។
- ជម្រុញអនុវត្តវិធីសាស្ត្រតាមដាននៅសហគមន៍។ លើកទឹកចិត្តមន្ត្រីមានសមត្ថកិច្ចឱ្យផ្តោតការយកចិត្តទុកដាក់ លើអ្នកទាំងឡាយណាដែលប្រព្រឹត្តអំពើហឹង្សា និងប្រើកម្លាំងបាយចំពោះជនរងគ្រោះពុំមែនផ្តោតលើអ្នកដែលព្រមព្រៀងក្នុងទំនាក់ទំនងរកស៊ីជាមួយនីតិជនដែលព្រមព្រៀងធ្វើជាអ្នករកស៊ីផ្លូវភេទនោះទេ។
- កែសម្រួលសេចក្តីណែនាំសម្រាប់ប៉ូលីស ដើម្បីឱ្យប្រាកដថា មានតែជនរងគ្រោះពីអំពើជួញដូរមនុស្សតែប៉ុណ្ណោះពុំមែននីតិជនដែលព្រមព្រៀងធ្វើជាអ្នករកស៊ីផ្លូវភេទនោះទេ ដែលត្រូវនាំខ្លួនទៅស្នងការប៉ូលីសដើម្បីសាកសួរ។ កែសម្រួលសេចក្តីណែនាំ ដើម្បីឱ្យសេចក្តីណែនាំទាំងនោះអនុលោមតាមសេចក្តីណែនាំរបស់ ឧត្តមស្នងការជាន់ខ្ពស់សហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (NHCHR) ស្តីពីសិទ្ធិមនុស្ស និងអំពើជួញដូរ។
- បន្ទាប់ពីការពិគ្រោះយោបល់បន្ថែមជាមួយក្រុមអ្នករកស៊ីផ្លូវភេទ និងជាមួយភាគីពាក់ព័ន្ធដទៃ សូមចេញជាអនុក្រឹត្យ ថ្នាក់ក្រសួង ហើយកែតម្រូវសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ដើម្បីកំណត់ន័យអំពីអំពើអូសទាញជាសាធារណៈដោយបញ្ជាក់ថា:
  - ទទួលស្គាល់សិទ្ធិរបស់នីតិជនទាំងឡាយក្នុងការធ្វើដំណើរទៅកាន់ទីសាធារណៈ ដោយគ្មានការភ័យខ្លាចពីការឃាត់ខ្លួន និងឃុំខ្លួនឡើយ
  - មិនរាប់បញ្ចូលដូចជា:
    - ការយកស្រោមអនាម័យតាមខ្លួន
    - សារជាអក្សរ

- ការឆ្លើយតបតាមសំណើដែលភ្ញៀវជាអ្នកស្នើសុំ
- ការចរចាដោយសន្តិវិធីជាមួយភ្ញៀវ
- ចលនាដោយដៃដែលមិនមែនជាទង្វើខ្វះសុជីវធម៌ ឬមិនមែនជាការគម្រាមកំហែង
- ការអង្គុយនៅក្បែរបរិវេណផ្ទះឯកជន

- ធានាឱ្យបានថាសេចក្តីណែនាំនៃច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរ សម្រាប់ចៅក្រម និងព្រះរាជអាជ្ញាទទួលស្គាល់សិទ្ធិក្នុងការប្រកបការងាររបស់នីតិជនដែលព្រមព្រៀងធ្វើជាអ្នករកស៊ីផ្លូវភេទ និង**សិទ្ធិរបស់ពួកគេក្នុងការចូលរួមដោយសេរីក្នុងទំនាក់ទំនងរកស៊ីចំពោះការងារនោះ**។ (ដូចជាមិនដាក់ទោសទណ្ឌចំពោះអ្នកទាំងឡាយ ណាដែលជួលឬលក់ផ្ទះទៅឱ្យនីតិជនដែលព្រមព្រៀងធ្វើជាអ្នករកស៊ីផ្លូវភេទ) ។
- ធ្វើការជាមួយតំណាងរបស់អ្នករកស៊ីផ្លូវភេទ ដើម្បីរៀបចំអនុក្រឹត្យថ្នាក់ក្រសួង សំដៅបញ្ជាក់ និងបំភ្លឺពីចេតនាការបកស្រាយ និងការអនុវត្តន៍មាត្រានានាស្តីពីការធ្វើអាជីវកម្មផ្លូវភេទនៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដូចជាមាត្រា ២៤ ២៥ ៣០ ៣១ និង ៣២ ជាដើម ។
- ធានាឱ្យបានថាសេចក្តីណែនាំស្តីពីច្បាប់ប្រឆាំងអំពើជួញដូរសម្រាប់ឱ្យចៅក្រម និងព្រះរាជអាជ្ញាបានអនុលោមទៅតាមសេចក្តីណែនាំរបស់ឧត្តមស្នងការជាន់ខ្ពស់សហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ។
- គាំទ្រការបណ្តុះបណ្តាលប៉ូលីសនៅថ្នាក់ជាតិ ដែលមានវគ្គរួមគ្នាជាមួយអ្នករកស៊ីផ្លូវភេទ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានាឱ្យមានការយល់ដឹងទូទៅអំពីច្បាប់ និងសេចក្តីណែនាំអំពីការប្រឆាំងអំពើជួញដូរមនុស្ស និងដើម្បីជម្រុញសហប្រតិបត្តិការ និងការពិភាក្សា ។
- ដឹកនាំសមាជិកក្នុងរចនាសម្ព័ន្ធជាតិប្រឆាំងនឹងអំពើជួញដូរមនុស្ស ក្នុងការធ្វើទស្សនកិច្ចសិក្សា ជាមួយតំណាងរបស់អង្គការចាត់តាំងរបស់អ្នករកស៊ីផ្លូវភេទ ដើម្បីរៀនសូត្រអំពីកម្មវិធីពង្រឹងសមត្ថភាពលើមូលដ្ឋានសិទ្ធិ ដើម្បីប្រយុទ្ធនឹងអំពើជួញដូរមនុស្សក្នុងគោលបំណងនៃការធ្វើអាជីវកម្មផ្លូវភេទ (ដូចជា Durbar ជាដើម)
- ធានាឱ្យបានថាអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ការសង្គ្រោះ និងផ្តល់កន្លែងជ្រកកោនដល់អ្នកដែលត្រូវបានជួញដូរ មិនអាចថែរក្សាពួកគេបានដោយគ្មានការជូនដំណឹង និងការព្រមព្រៀងជាមុនពីពួកគេឡើយ (ហើយការព្រមព្រៀងនោះអាចលុបចោលនៅពេលណាក៏បាន) ។
- ធ្វើយ៉ាងណាឱ្យអនីតិជន និងកុមារនៅក្នុងមណ្ឌល មានលទ្ធភាពបានជួបឪពុក-ម្តាយរបស់ពួកគេ លើកលែងតែនៅក្នុងកាលៈទេសៈដែលមានដីកាបង្គាប់ចេញដោយតុលាការដែលកំហិតនូវលទ្ធភាពជួបគ្នានេះ

- ធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលទទួលស្គាល់ និងគាំទ្រសិទ្ធិរបស់នីតិជនដែលព្រមព្រៀងធ្វើជាអ្នករកស៊ីផ្លូវភេទ ឱ្យចាត់ទុកពួកគេថាជាអ្នកដែលមានសិទ្ធិ និងមានសមត្ថភាពក្នុងការប្រកបការងារនៅក្នុង មុខរបរផ្លូវភេទ។

### គ) ការកសាងសមត្ថភាពចំពោះបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ

អ្នករកស៊ីផ្លូវភេទ បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអង្គការចាត់តាំងរបស់ពួកគេមានមុខងារសំខាន់ក្នុងការជម្រុញ និងអនុវត្តវិធីសាស្ត្រផ្អែកលើមូលដ្ឋានសិទ្ធិក្នុងការបង្ការមេរោគអេដស៍ ការទទួលការប្រព្រឹត្តមកលើខ្លួន និងការបង្ការអំពើជួញដូរ។ សំខាន់បំផុត ពួកគេចាំបាច់ត្រូវរៀបចំ និងស្វែងរកការគាំទ្ររួមគ្នាដោយមានការជូនដំណឹង ប្រកបដោយប្រសិទ្ធភាពចំពោះសិទ្ធិ របស់ពួកគេក្នុងការប្រកបការងារ និងការទទួលស្គាល់សិទ្ធិមនុស្ស និងភាពថ្លៃថ្នូររបស់ពួកគេ។

ចាំបាច់ត្រូវមានការបន្តពិគ្រោះយោបល់ជាមួយអ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ដើម្បីឱ្យបានដឹងអំពីជំនាញ និងធនធាននានាដែលពួកគេត្រូវការ។ ទោះជាយ៉ាងណាក៏ដោយ សំណើជំហានដំបូង រួមមានៈ

- ការយល់ដឹងច្បាស់លាស់ និងយល់ដឹងជាទូទៅអំពីច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស សិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេ
- មានលទ្ធភាពបានទទួលការប្រឹក្សាច្បាប់ដែលអាចជឿទុកចិត្តបាន និងការប្រឹក្សាដែលពុំមែនជាសេចក្តីវិនិច្ឆ័យ និងភាពជាតំណាង និងការប្រឹក្សាជាមួយអ្នកជំនាញដទៃទៀត តាមការចាំបាច់
- ពង្រឹងធនធាន និងជំនាញកសាងបណ្តាញនៅថ្នាក់ជាតិ
- ប្រើបច្ចេកវិទ្យាសម្រាប់កសាងបណ្តាញ
- បង្កើនទំនុកចិត្ត និងបង្កើនសមត្ថភាពក្នុងការចរចាជាមួយមន្ត្រីរដ្ឋាភិបាលនៅគ្រប់កម្រិត
- ការយល់ដឹងអំពីវិធីសាស្ត្រនានាដែលមានមូលដ្ឋានផ្អែកលើសិទ្ធិ
- សកម្មភាពផ្សេងទៀត និងកម្មវិធីបណ្តុះបណ្តាលដោយអង្គការមិនមែនរដ្ឋាភិបាលដើម្បីជ្រើសរើស និងបណ្តុះបណ្តាលអ្នករកស៊ីផ្លូវភេទ និងបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយធ្វើជាបុគ្គលិកផ្សព្វផ្សាយ និងមិត្តអប់រំមិត្ត ដើម្បីមានលទ្ធភាពជម្រុញ វិធីសាស្ត្រនានាដែលមានមូលដ្ឋានផ្អែកលើសិទ្ធិ។
- លទ្ធភាពក្នុងការធ្វើជាតំណាងសមាជិក ជម្រុញការស្វែងរកការគាំទ្រ និងទំនាក់ទំនងជាមួយមន្ត្រីរដ្ឋាភិបាល និងមន្ត្រីដទៃទៀត

- លទ្ធភាពក្នុងការទាក់ទងជាមួយប្រព័ន្ធផ្សព្វផ្សាយ និងកសាងទំនាក់ទំនងជាមួយអ្នកតំណាង ប្រព័ន្ធផ្សព្វផ្សាយដែលមានសុទិដ្ឋិនិយម
- លទ្ធភាពទទួលបានកម្មវិធីអក្ខរភាពដែលមានប្រសិទ្ធភាពជាមួយនីតិជន
- គាំទ្រឱ្យមានកម្មវិធីអប់រំសមស្របចំពោះកូនចៅរបស់អ្នករកស៊ីផ្លូវភេទ

**ឧបសម្ព័ន្ធ**

1. ករណីសិក្សា និងកិច្ចសម្ភាសន៍ជាមួយអ្នករកស៊ីផ្លូវភេទ
2. របាយការណ៍អំពីការស្រាវជ្រាវដើម្បីធ្វើសកម្មភាពក្រោមប្រធានបទស្តីពី "បរិយាកាសគោលនយោបាយស្តីពីសិទ្ធិទទួលបានសេវាជាសកល និងសិទ្ធិក្នុងការប្រកបការងារជាបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និងអ្នករកស៊ីផ្លូវភេទ" រៀបរៀងឡើងដោយ ឯកឧត្តមវេជ្ជបណ្ឌិត. **ទា ផលា**
3. "ជីវិតដ៏លំបាកចំពោះការងារគតិយុត្តៈ ច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស និងការងាររកស៊ីផ្លូវភេទ " ដោយលោក **កែវ ចិន្តា**
4. ការវិភាគអំពីផលប៉ះពាល់មកលើសិទ្ធិមនុស្សនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការអនុវត្តសេចក្តីណែនាំសម្រាប់ប៉ូលីស ដោយ **Sally Low** និងដោយសាស្ត្រាចារ្យ Bebe Loff
5. ភារកិច្ច និងការទទួលខុសត្រូវសម្រាប់ការស្រាវជ្រាវនេះ